**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# អំពីការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក លាប ដា**

**លោក ស៊ុយ គឹមហុង**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ម៉ូលី បញ្ញា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **ស៊ុយ គឹមហុង** និង **លាប ដា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**សូមលើកអង្គអញ្ជលីលំឱនកាយវិចារចិត្តដើម្បីសម្តែងនូវការគោរព ការដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖**

**លោកឪពុក យិន សម្បត្តិ** **លោកឪពុក អាន់ សែត**

**អ្នកម្តាយ ស៊ុយ គឹមហៀង** **អ្នកម្តាយ ស៊ីវ សម្បត្តិ**

ដែលបានផ្តល់កំណើតចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីបាតជើងក្រហមននៀល រហូតដល់កូនចម្រើនធំពេញវ័យដោយបានផ្តល់នូវសេចក្តីស្រឡាញ់យ៉ាងធំធេង ដែលគ្មានអ្វីអាចប្រៀបផ្ទឹមបាន និងភាពកក់ក្តៅប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មានប្រៀនប្រដៅ និងបានទំនុកបម្រុងគ្រប់សព្វបែបយ៉ាងទាំងសម្ភារៈ ទាំងកម្លាំងចិត្ត លើកទឹកចិត្តកូនគ្រប់ពេលវេលា មិនតែប៉ុណ្ណោះលោកទាំងទ្វេរបានផ្គត់ផ្គង់ថវិការ ឱ្យកូនបានសិក្សារៀនសូត្រចាប់តាំងពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់មហាវិទ្យាល័យមិនដែលរុញរាឡើយ ក្នុងគោលបំណងដើម្បីឱ្យកូនបានសម្រេចនូវក្តីស្រមៃរបស់ខ្លួន ដើម្បីក្លាយខ្លួនជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ និងអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមជាតិថែមទៀតផង។

**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និង លោកគ្រូ អ្នកគ្រូ** ដែលជាសាស្រ្តាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានលះបង់នូវពេលវេលា ព្រមទាំងកម្លាំងកាយចិត្ត ខិតខំបណ្តុះបណ្តាលផ្តល់ចំណេះដល់យើងខ្ញុំ។

ជាពិសេសចំពោះ **លោកស្រីសាស្រ្តាចារ្យជំនួយ ម៉ូលី បញ្ញា** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃដើម្បីដឹកនាំក្នុងការសរសេរសារណាមួយនេះ ដោយអ្នកគ្រូបានលះបង់ទាំងកម្លាំងកាយចិត្ត និងពេលវេលាផ្ទាល់ខ្លួន ក្នុងការជួយណែនាំបង្ហាញផ្លូវ និងជួយពិនិត្យកែតម្រូវនូវរាល់ចំណុចខ្វះខាតនានាដែលយើងខ្ញុំមានថែមទៀតផង មិនតែប៉ុណ្ណោះអ្នកគ្រូបានផ្តល់នូវអនុសាសន៍ល្អៗដែលពោរពេញទៅដោយអត្ថន័យ ព្រមទាំងឯកសារពាក់ព័ន្ធនានាដល់យើងខ្ញុំក្នុងគោលបំណងធ្វើយ៉ាងណាជួយឱ្យសារណាមួយនេះមានភាពល្អប្រសើរ។

ជាទីបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គលជូនដល់ អ្នកមានគុណទាំងទ្វេរ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី អ្នកនាងកញ្ញា សាស្រ្តាចារ្យ មិត្តនិស្សិត និងមិត្តរួមជំនាន់ទាំងអស់អោយជួបតែពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាជំនាញនីតិសាស្ត្រអស់រយៈពេលបួនឆ្នាំ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ យើងខ្ញុំទទួលបាននូវចំណេះដឹងយ៉ាងច្រើនឥតគណនា ដោយបានយល់ដឹងយ៉ាងស៊ីជម្រៅទៅលើចំណេះដឹងផ្នែកច្បាប់។ ហើយតាមរយៈការសិក្សានៅក្នុងឆ្នាំទីបួន ឆមាសទីមួយ យើងខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះមុខវិជ្ជានីតិនគរូបនីយកម្ម និងសំណង់ ជាពិសេសគឺមេរៀនពាក់ព័ន្ធជាមួយដីធ្លី ដូច្នេះហើយទើបបានជាយើងខ្ញុំជ្រើសរើសយកប្រធានបទស្តីអំពី **"អំពីការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា"** យកមកធ្វើការស្រាវជ្រាវដើម្បីបានឈ្វេងយល់ឱ្យកាន់តែច្បាស់ពីដំណើរការ និងការទទួលបាននូវប័ណ្ណកម្មសិទ្ធិលើដីធ្លីនៅក្នុងប្រទេស។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលទើបតែមានស្ថានភាពល្អប្រសើរឡើងវិញ ក្រោយពីឆ្លងកាត់សង្គ្រាមផ្ទៃក្នុងអស់កាលជាច្រើនទសវត្សមក និងទទួលបាននូវឯកភាពជាតិពេញលេញនាឆ្នាំ១៩៩៨ បានន័យថាប្រទេសកម្ពុជាបានបង្រួបបង្រួមជាតិ ហើយក្លាយជាប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ។ ជាងនេះទៅទៀតយើងមើលឃើញថាពីឆ្នាំ១៩៩៨ មកទល់បច្ចុប្បន្ន ប្រទេសកម្ពុជាមានសន្ទុស្សន៍នៃការអភិវឌ្ឍយ៉ាងខ្លាំងលើគ្រប់វិស័យ។ បន្ថែមពីនេះ ក្នុងដំណើរការនៃការអភិវឌ្ឍប្រទេសជាតិ រាជរដ្ឋាភិបាលក៏បានផ្តោតសំខាន់ទៅលើការផ្តល់សិទ្ធិកម្មសិទ្ធិដល់ប្រជាពលរដ្ឋផងដែរ ដោយបានបង្កើតនូវគោលនយោបាយដីធ្លីជាច្រើនឡើងមក។

តាមរយៈប្រធានបទសារណាមួយនេះយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា នឹងផ្តល់នូវពុទ្ធិ ក៏ដូចជាចំណេះដឹងជាពិសេសនោះគឺបានយល់ដឹងច្បាស់ពីបែបបទនិងនីតិវិធីយ៉ាងលម្អិតចំពោះការស្នើសុំចុះបញ្ជីដីធ្លី ហើយអាចយកទៅអនុវត្តបានចំពោះប្រជាពលរដ្ឋទូទៅ សិស្ស និស្សិត និងមិត្តអ្នកសិក្សាទាំងឡាយដែលមានគោលបំណងចង់ក្លាយជាម្ចាស់កម្មសិទ្ធិដែលច្បាប់ទទួលស្គាល់ (កម្មសិទ្ធិករស្របច្បាប់) នៅលើដីរបស់ខ្លួនដែលកំពុងកាន់កាប់ក្នុងបច្ចុប្បន្នកាល។

ជាទីអវសាននៃអារម្ភកថា យើងខ្ញុំសូមស្វាគមន៍នូវរាល់មតិរិះគន់ពីគ្រប់មជ្ឈដ្ឋានក្នុងន័យស្ថាបនាចំពោះកំហុសទាំងអស់ដែលកើតឡើងដោយអចេតនាដូចជាពាក្យពេចន៍ ឃ្លាឃ្លោង ពុម្ពអក្សរ ឬ បញ្ហាបច្ចេកទេសណាមួយក៏ដូចជាអក្ខរាវិរុទ្ធ ឬ រចនាបទផ្សេងៗដែលមាននៅក្នុងសៀវភៅមួយនេះ។ ហើយសូមជូនពរដល់មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តៗនិស្សិតទាំងអស់ ទទួលបាននូវពុទ្ធពរទាំងឡាយបួនប្រការ សម្បត្តិបី អរិយទ្រព្យទាំងប្រាំពីរ មានសេចក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងសម្រេចនូវគោលបំណងដែលប៉ងចង់បានគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិកា

ទំព័រ


**សេចក្ដីផ្ដើម** ..... ១

## ជំពូកទី១

## សញ្ញាណទូទៅនៃការចុះបញ្ជីដីនៅកម្ពុជា

**ផ្នែកទី១៖ ប្រវត្តិសង្ខេបអំពីការគ្រប់គ្រងដីធ្លី** ..... ៤

កថាខណ្ឌទី១៖ ការគ្រប់គ្រងដីធ្លីមុនឆ្នាំ១៩៧៥ ..... ៤

កថាខណ្ឌទី២៖ ការគ្រប់គ្រងដីធ្លីនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ..... ៧

កថាខណ្ឌទី៣៖ ការគ្រប់គ្រងដីធ្លីនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៣ ..... ៧

**ផ្នែកទី២៖ ការវិវត្តនៃស្ថាប័នទទួលបន្ទុកចុះបញ្ជីដី** ..... ១៣

កថាខណ្ឌទី១៖ នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម (ពីឆ្នាំ១៩៧៩ ដល់ ១៩៨៩) .. ១៤

កថាខណ្ឌទី២៖ នាយកដ្ឋានសុរិយោដី (ចាប់ពីឆ្នាំ ១៩៨៩ ដល់ ១៩៩៩) ..... ១៥

កថាខណ្ឌទី៣៖ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ (ចាប់ពីឆ្នាំ ១៩៩៩ មកទល់បច្ចុប្បន្ន) ..... ១៦

## ជំពូកទី២

## អំពីរបបនៃការចុះបញ្ជីដីនៅកម្ពុជា (ចាប់ពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្ន)

**ផ្នែកទី១៖ ការចុះបញ្ជីដីរដ្ឋ** ..... ២១

**កថាខណ្ឌទី១៖ ការកំណត់លក្ខណៈនៃដីរដ្ឋ** ..... ២១

**កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការចុះបញ្ជីដីរដ្ឋ** ..... ២៣

វាក្យខណ្ឌទី១៖ ការធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋ ..... ២៣

វាក្យខណ្ឌទី២៖ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ..... ២៥

**កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីដីរដ្ឋ** ..... ២៦

វាក្យខណ្ឌទី១៖ នីតិវិធីនៃការចុះបញ្ជីដីរដ្ឋតាមលក្ខណៈទូទៅ ..... ២៧

ក. នីតិវិធីចុះបញ្ជីដីរដ្ឋតាមលក្ខណៈជាប្រព័ន្ធ ..... ២៧

ខ. ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ..... ៣១

វាក្យខណ្ឌទី២៖ នីតិវិធីពិសេសនៃការចុះបញ្ជីដីរដ្ឋ ..... ៣៥

**ផ្នែកទី២៖ ការចុះបញ្ជីដីឯកជន** ..... ៣៧

**កថាខណ្ឌទី១៖ ការកំណត់លក្ខណៈនៃដីឯកជន ..... ៣៧**

**កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការចុះបញ្ជីដីឯកជន ..... ៣៨**

វាក្យខណ្ឌទី១៖ ត្រូវមានសញ្ជាតិខ្មែរ ..... ៣៨

ក. រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ ..... ៣៨

ខ. នីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ..... ៣៩

វាក្យខណ្ឌទី២៖ ជាភោគៈស្របច្បាប់ ..... ៤០

វាក្យខណ្ឌទី៣៖ ការកាន់កាប់លើដីចាប់ពី ៥ឆ្នាំឡើងទៅ ..... ៤៣

វាក្យខណ្ឌទី៤៖ ការកាន់កាប់លើដីឯកជនរបស់រដ្ឋ ..... ៤៥

វាក្យខណ្ឌទី៥៖ តាមរយៈសម្បទានដីសង្គមកិច្ច ..... ៤៥

**កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីដីឯកជន ..... ៤៦**

វាក្យខណ្ឌទី១៖ នីតិវិធីចុះបញ្ជីដីឯកជនតាមលក្ខណៈជាប្រព័ន្ធ ..... ៤៦

វាក្យខណ្ឌទី២៖ នីតិវិធីចុះបញ្ជីដីឯកជនតាមលក្ខណៈដាច់ដោយដុំ ..... ៥៣

**ផ្នែកទី៣៖ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ..... ៦២**

**កថាខណ្ឌទី១៖ ការកំណត់លក្ខណៈនៃដីសហគមន៍ជនជាតិដើមភាគតិច ..... ៦៤**

**កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច ..... ៦៦**

វាក្យខណ្ឌទី១៖ ការកំណត់អត្តសញ្ញាណពីក្រសួងអភិវឌ្ឍន៍ជនបទ ..... ៦៦

វាក្យខណ្ឌទី២៖ ការចុះបញ្ជីទទួលស្គាល់ជាផ្លូវការ ដើម្បីទទួលបាននូវសិទ្ធិជានីតិបុគ្គល ..... ៦៧

វាក្យខណ្ឌទី៣៖ ការដាក់ពាក្យសុំចុះបញ្ជីដីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..... ៦៩

**កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ..... ៧១**

## ជំពូកទី៣

## អត្ថប្រយោជន៍នៃការចុះបញ្ជីដី

**ផ្នែកទី១៖ អត្ថប្រយោជន៍ចំពោះអាជ្ញាធរមានសមត្ថកិច្ច ..... ៧៦**

**កថាខណ្ឌទី១៖ អាជ្ញាធរថ្នាក់ជាតិ ..... ៧៧**

វាក្យខណ្ឌទី១៖ ចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..... ៧៧

វាក្យខណ្ឌទី២៖ ចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ..... ៧៨

វាក្យខណ្ឌទី៣៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ..... ៧៩

**កថាខណ្ឌទី២៖ អាជ្ញាធរថ្នាក់ក្រោមជាតិ ..... ៨០**

វាក្យខណ្ឌទី១៖ រដ្ឋបាលដែនដីថ្នាក់រាជធានី ខេត្ត ....................................................................................៨០
វាក្យខណ្ឌទី២៖ រដ្ឋបាលដែនដីថ្នាក់ក្រុង ស្រុក ខណ្ឌ ..............................................................................៨១
**ផ្នែកទី២៖ អត្ថប្រយោជន៍ចំពោះប្រជាពលរដ្ឋ** ..................................................................................៨១
**កថាខណ្ឌទី១៖ ការកាត់បន្ថយទំនាស់នៅក្នុងការរស់នៅ** ....................................................................៨១
**កថាខណ្ឌទី២៖ ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី**..........................................................................**៨២**
ក. ការការពារតាមផ្លូវច្បាប់ ..........................................................................................................៨២
ខ. សុវត្ថិភាពនៃការកាន់កាប់ .......................................................................................................៨៣
គ. ការលក់-ទិញ...........................................................................................................................៨៣
ឃ. ការផ្ទេរកម្មសិទ្ធិលើដីធ្លី..............................................................................................................៨៤
ង. ឥណទាន ................................................................................................................................៨៥
**សេចក្តីសន្និដ្ឋាន**.........................................................................................................................**៨៦**
**អនុសាសន៍**.................................................................................................................................**៨៧**
**ឯកសារយោង**.................................................................................................................................
**ឧបសម្ព័ន្ធ**.....................................................................................................................................

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

ដីធ្លី គឺជាធនធានដ៏កម្រមួយដែលមិនអាចខ្វះបានក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដោយប្រជាពលរដ្ឋមានតម្រូវការដីធ្លីជាចាំបាច់ដើម្បីធ្វើជាទីស្នាក់អាស្រ័យ និងប្រកបរបរចិញ្ចឹមជីវិត។ ម្យ៉ាងវិញទៀត ដីធ្លី ក៏ជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការទ្រទ្រង់ សង្គម សេដ្ឋកិច្ច និងនយោបាយ ហើយក៏ជាកម្លាំងចលករមួយប្រកបដោយសក្ដានុពល ដែលមិនអាចខ្វះបានសម្រាប់ប្រទេស ជាពិសេសនោះគឺប្រទេសដែលកំពុងអភិវឌ្ឍក្នុងការកសាងប្រទេសជាតិឱ្យមានភាពរីកចម្រើនជាលំដាប់ទាំងបច្ចុប្បន្ន និងនាថ្ងៃអនាគត។

ជាក់ស្ដែងប្រទេសកម្ពុជា ជាប្រទេសមួយដែលស្ថានភាពដីធ្លីមានភាពល្អប្រសើរក្នុងអតីតកាល ប៉ុន្តែជាអកុសលរបបដីធ្លីត្រូវបានផ្លាស់ប្ដូរជាខ្លាំងដោយសារសង្គ្រាមផ្ទៃក្នុងរ៉ាំរ៉ៃ ជាពិសេសគឺនាសម័យខ្មែរក្រហម ហើយរបបដ៏ខ្មៅងងឹតនេះ ត្រូវបានដួលរលំនៅដើមឆ្នាំ១៩៧៩។ ក្រោយពីទទួលបានជ័យជម្នះ ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានខឿនសេដ្ឋកិច្ចជាតិពឹងផ្អែកទាំងស្រុងទៅលើ ផ្ទៃដីកសិកម្មដើម្បីដាំដុះ ដោយប្រជាពលរដ្ឋប្រមាណ ៨០ភាគរយ[1] រស់នៅជនបទ ក្នុងនោះភាគច្រើនប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ នេះសបញ្ជាក់ឱ្យឃើញថា ដីធ្លី គឺពិតជាមានសារៈសំខាន់ណាស់នៅក្នុងប្រទេស ដោយមើលឃើញសភាពបែបនេះ រដ្ឋាភិបាលបានចាប់ផ្តើមបង្កើតឱ្យមានប្រព័ន្ធនៃការគ្រប់គ្រងដីធ្លី របបកម្មសិទ្ធិ និងសិទ្ធិផ្សេងទៀតដែលមានលើដីរួមមានការបែងចែកប្រភេទដីជា ដីរដ្ឋ ដីឯកជន និងដីសមូហភាព ក្នុងគោលបំណងលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងការប្រកបរបរកសិកម្ម និងដាំដុះ ព្រមទាំងបានបង្កើត និងដាក់ចេញនូវគោលនយោបាយជាច្រើនដែលមានភាពពាក់ព័ន្ធឡើងមក ដើម្បីគាំទ្រដល់ដំណើរការផ្ដល់កម្មសិទ្ធិដីធ្លី។ យ៉ាងណាមិញប្រព័ន្ធនៃការគ្រប់គ្រងដីធ្លីទាំងអស់តម្រូវឱ្យធ្វើការចុះបញ្ជី និងកំណត់នូវអត្តសញ្ញាណក្បាលដី កម្មសិទ្ធិករលើដី សិទ្ធិកាន់កាប់លើដីចូលក្នុងសៀវភៅគោលបញ្ជីដីធ្លីជាមុនសិនទើបអាចធានាបាននូវសុវត្ថិភាពនៃសិទ្ធិកម្មសិទ្ធិ កិច្ចប្រតិបត្តិការនៃការជួញដូរប្រកបដោយសុវត្ថិភាពពេញលេញបាន។

ដើម្បីជួយសម្រួលដល់ដំណើរការនេះច្បាប់ភូមិបាល២០០១ ត្រូវបានបង្កើតឡើង ហើយក្រោយមកមានការដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី២០០២ ដែលតាមរយៈគោលនយោបាយនេះបានបង្កើតឱ្យមាននូវអនុក្រឹត្យធំៗចំនួនពីរដើម្បីអនុវត្តដំណើរការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា ដែលមានដូចជាអនុក្រឹត្យលេខ៤៦ ស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី និងអនុក្រឹត្យលេខ៤៨ ស្ដីពីនីតិវិធីនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ។ បន្ថែមពីលើនេះ រដ្ឋាភិបាលក៏បានចេញនូវសេចក្ដីថ្លែងការណ៍ស្ដីពីគោលនយោបាយដីធ្លីឆ្នាំ២០០៩ និងគោលនយោបាយដីធ្លី(សៀវភៅសដីធ្លី)ឆ្នាំ២០១៥ បន្ថែមទៀតដើម្បីគាំទ្រក្នុងការអនុវត្តនីតិវិធីទាំងពីរនេះទៅលើក្បាលដីទាំងអស់ក្នុងប្រទេសកម្ពុជា។ ប៉ុន្តែទោះបីជាយ៉ាង

[1] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤ ដល់២០១៨*, ខែមិថុនា ២០១៥, ទំព័រ៥។

ណាក៏ដោយឃើញថា មកទល់ពេលបច្ចុប្បន្នដំណើរការនៃការចុះបញ្ជីដីមិនទាន់បានបញ្ចប់ជាស្ថាពរនោះទេ ដោយបច្ចុប្បន្នក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងអនុវត្តនូវការចុះបញ្ជីដីបង្ហើយនៅទូទាំងប្រទេស។ ហេតុនេះហើយទើបក្រុមរបស់យើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ “**អំពីការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជា**” យកមកធ្វើការបកស្រាយនៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ។ ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះមាននូវចំណោទគតិយុត្តជាច្រើនបានលេចឡើងមកដែលមានដូចជា ដូចម្តេចដែលហៅថាការចុះបញ្ជីដី ? តើការចុះបញ្ជីដីមានអ្វីខ្លះ ? តើការចុះបញ្ជីដីត្រូវបានបែងចែកជាប៉ុន្មានប្រភេទ ? និងការចុះបញ្ជីត្រូវបានធ្វើឡើងតាមនីតិវិធីណាខ្លះ ? ហើយតាមរយៈការចុះបញ្ជីដីធ្លីនេះបានផ្តល់គុណប្រយោជន៍អ្វីខ្លះ ?

ជាការពិតណាស់ចំពោះគោលបំណងនៃសារណាមួយនេះគឺដោយសារ យើងខ្ញុំបានមើលឃើញថានៅក្នុងដំណើរការចុះបញ្ជីដីធ្លីនៅក្នុងប្រទេសកម្ពុជានៅតែជាចម្ងល់សម្រាប់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ សិស្សនិស្សិត និងប្រជាពលរដ្ឋខ្មែរមួយភាគធំមិនទាន់បានយល់ច្បាស់លាស់នៅឡើយទាក់ទងនឹងដំណើរការចុះបញ្ជីជាពិសេសនោះគឺប្រជាពលរដ្ឋដែលគាត់រស់នៅតាមជនបទ។ ដោយឡែកការបកស្រាយនៅក្នុងសារណាមួយនេះ យើងខ្ញុំសូមលើកយកតែនីតិវិធីនៅក្នុងការចុះបញ្ជីដីធ្លីលើកដំបូងដែលអនុវត្តនៅក្នុងប្រទេសកម្ពុជាមកធ្វើការបង្ហាញតែប៉ុណ្ណោះ ដោយមិនបានលើកយកអំពីការចុះបញ្ជីដីធ្លីបន្ត ការចុះបញ្ជីដីធ្លីបំពេញបន្ថែមមកពិភាក្សានោះឡើយ។ ជារួមមកការពិភាក្សាគឺផ្តោតសំខាន់តែទៅលើប្រភេទដីដែលអាចចុះបញ្ជីបាន លក្ខខណ្ឌ និងនីតិវិធីនៅក្នុងការចុះបញ្ជីដីតែប៉ុណ្ណោះ។

នៅក្នុងប្រធានបទសារណាមួយនេះត្រូវបានចែកជាបីជំពូក។ ដែលជំពូកទី១ នឹងធ្វើការបរិយាយទៅលើសញ្ញាណទូទៅនៃការចុះបញ្ជីដីនៅក្នុងប្រទេសកម្ពុជា ដោយក្នុងនោះចែកជាពីរផ្នែក។ ផ្នែកទី១ និយាយពីប្រវត្តិសង្ខេបអំពីការគ្រប់គ្រងដីធ្លី និងផ្នែកទី២ បង្ហាញពីការវិវត្តនៃស្ថាប័នទទួលបន្ទុកចុះបញ្ជីដី។ ចំណែកឯជំពូកទី២ នឹងពិភាក្សាទៅលើរបបនៃការចុះបញ្ជីដីនៅកម្ពុជា ដែលត្រូវបែងចែកជាបីផ្នែកទៀត។ ផ្នែកទី១ បង្ហាញអំពីការចុះបញ្ជីដីរដ្ឋ បន្ទាប់មកផ្នែកទី២ បង្ហាញអំពីការចុះបញ្ជីដីឯកជន និងផ្នែកទី៣ បង្ហាញអំពីការចុះបញ្ជីដីសមូហភាព ដោយក្នុងនោះយើងខ្ញុំសូមធ្វើការបកស្រាយផ្តោតទៅលើតែដីសហគមន៍ជនជាតិដើមភាគតិចតែប៉ុណ្ណោះ។ ដោយមើលឃើញថានៅក្រោយការចុះបញ្ជីបានផ្តល់ចំណុចវិជ្ជមានជាច្រើនដល់សង្គមជាតិ ដូច្នេះទើបនៅក្នុងជំពូកទី៣ បរិយាយអំពីអត្ថប្រយោជន៍នៃការចុះបញ្ជីដី ដែលក្នុងនោះមានពីរផ្នែកទៀត។ ផ្នែកទី១ បកស្រាយពីអត្ថប្រយោជន៍ចំពោះអាជ្ញាធរមានសមត្ថកិច្ច និងផ្នែកទី២ បកស្រាយពីអត្ថប្រយោជន៍ចំពោះប្រជាពលរដ្ឋ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការចុះបញ្ជីដីនៅកម្ពុជា

# ជំពូកទី១

## សញ្ញាណទូទៅនៃការចុះបញ្ជីដីនៅកម្ពុជា

នៅក្នុងបច្ចុប្បន្នកាលដែលពិភពលោកកំពុងស្ថិតនៅក្នុងសម័យឯកជនភាវូបនីយកម្ម ប្រទេសទាំងអស់នៅលើពិភពលោកបានចាប់ផ្តើមបង្កើតឱ្យមានកម្មសិទ្ធិឯកជនឡើងមក ដោយរដ្ឋមួយចំនួនចាប់ផ្តើមបង្កើតនូវគោលនយោបាយនានាពាក់ព័ន្ធនឹងដីធ្លី ដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋរបស់ខ្លួននូវសិទ្ធិកម្មសិទ្ធិមួយយ៉ាងពេញលេញចំពោះអចលនវត្ថុដែលជាទ្រព្យរបស់ខ្លួន។ នៅពេលដែលទទួលបានកម្មសិទ្ធិនោះកម្មសិទ្ធិករនឹងទទួលបានការគាំពារពីសំណាក់រដ្ឋថែមទៀតផង នៅក្នុងករណីដែលមានការរំលោភបំពានពីបុគ្គលណាមួយ។ ទោះបីជាកម្មសិទ្ធិឯកជននេះមានការការពារពីរដ្ឋក៏ពិតមែន ប៉ុន្តែមិនមានស្ថេរភាពនោះឡើយ ពោលគឺមានការប្រែប្រួលទៅតាមបរិបទនយោបាយរបស់ប្រទេសនីមួយៗផងដែរ។ ជាក់ស្តែងនៅពេលដែលប្រទេសមួយកំពុងញាំញីដោយភ្លើងសង្គ្រាម ប្រាកដណាស់កម្មសិទ្ធិឯកជនក៏អាចមានការផ្លាស់ប្តូរទៅតាមនោះដែរ។ ដោយឡែកបើយើងក្រឡេកមកមើលនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាវិញ ឃើញថានៅមុនសម័យអាណានិគមបារាំងព្រះមហាក្សត្រគឺជាម្ចាស់នៃទឹកដីទាំងអស់នៅក្នុងដែនដី ព្រោះថានៅពេលនោះព្រះមហាក្សត្រត្រូវបានគេចាត់ទុកជានិមិត្តរូបនៃទេវរាជ[2] ដូច្នេះក្រៅពីព្រះមហាក្សត្រគ្មានបុគ្គលណាមួយអាចធ្វើការទាមទារកម្មសិទ្ធិលើដីធ្លីជារបស់ខ្លួនបានឡើយពោលគឺប្រជាពលរដ្ឋមានត្រឹមតែសិទ្ធិភោគៈតែប៉ុណ្ណោះ។[3] ប៉ុន្តែក្រោយមកដោយសាររបត់នយោបាយនៅក្នុងប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរទើបកម្មសិទ្ធិឯកជនចាប់ផ្តើមកើតមានឡើងក្នុងសតវត្សទី១៩ ពោលគឺនៅក្នុងសម័យអាណានិគមរបស់បារាំង( ១៨៦៣-១៩៥៣ ) ដោយបារាំងបាននាំមកនូវសញ្ញាណនៃកម្មសិទ្ធិឯកជនលើធ្លីជាលើកដំបូងមកក្នុងប្រទេសកម្ពុជា ហើយក្រោយមករបបនៃកម្មសិទ្ធិឯកជននេះគឺនៅតែត្រូវបានបន្តអនុវត្តនៅក្នុងសម័យកាលបន្តបន្ទាប់ទៀត ពោលគឺនៅក្នុងសម័យសង្គមរាស្ត្រនិយម( ១៩៥៣-១៩៧០ ) និងសម័យសារធារណៈរដ្ឋកម្ពុជា( ១៩៧០-១៩៧៥ )។[4] ទោះបីជាប្រទេសកម្ពុជាបានបន្តអនុវត្តនូវរបបកម្មសិទ្ធិឯកជនក៏ពិតមែន ប៉ុន្តែមិនមានភាពស្ថិតស្ថេរយូរអង្វែងនោះទេ ដោយហេតុថានៅសម័យកម្ពុជាប្រជាធិបតេយ្យកម្មសិទ្ធិឯកជនទាំងអស់ត្រូវបានលុបបំបាត់ចោលទាំងស្រុង។[5] លុះក្រោយមកនៅក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលស្ទើរតែពេញមួយសម័យកាល( ១៩៧៩-១៩៨៩ ) ក៏គេនៅតែមិនទាន់ឃើញមានកម្មសិទ្ធិឯកជនកើតមានឡើងវិញនោះឡើយ។ ទើបតែមកដល់សម័យរដ្ឋកម្ពុជា( ១៩៨៩-១៩៩២ ) ទើបរបបឯកជនភាវូបនីយកម្មត្រូវបានបង្កើតឡើងវិញ ប៉ុន្តែមិនទាន់មានភាពទូលំទូលាយនៅឡើយ ពោលគឺរដ្ឋ

---

[2] ត្រឹង ងា, *ប្រវត្តិសាស្ត្រខ្មែរ ភាគ១-២( សំរាប់មធ្យម និង ឧត្តមសិក្សា )*, ភ្នំពេញ គ.ស១៩៧៣, ទំព័រ១៣៥។

[3] East-West Management Institute. Inc, *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ*, ( កែសម្រួលនៅឆ្នាំ២០០៥ ), ទំព័រ២២។ ( តទៅហៅថា *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥*)

[4] អង្គការទិន្នន័យអំពីការអភិវឌ្ឍ. *ដីធ្លី*. ដកស្រង់ចេញពីគេហទំព័រ ដីធ្លី | Open Development Cambodia ( ODC )( បានចូលទស្សនាថ្ងៃទី១៦ មិថុនា ២០២៤ )។

[5] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥*, ទំព័រ២៦។

បានផ្តល់ត្រឹមតែកម្មសិទ្ធិឯកជនតែលើដីលំនៅឋានតែប៉ុណ្ណោះ ហើយតម្រូវឱ្យទៅដាក់ពាក្យស្នើសុំចុះបញ្ជីនៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីដី។ ដូច្នេះដើម្បីឈ្វេងយល់ពីការកកើតនូវកម្មសិទ្ធិឯកជនឡើងវិញយើងនឹងសិក្សា ប្រវត្តិសង្ខេបអំពីការគ្រប់គ្រងដីធ្លី(**ផ្នែកទី១**) និងការវិវត្តស្ថាប័នទទួលបន្ទុកចុះបញ្ជីដីធ្លី(**ផ្នែកទី២**)។

## ផ្នែកទី១៖ ប្រវត្តិសង្ខេបអំពីការគ្រប់គ្រងដីធ្លី

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលបានឆ្លងកាត់នូវសម័យកាលជាច្រើន ជាហេតុធ្វើឱ្យការគ្រប់គ្រង និងដឹកនាំប្រទេសក៏មានការផ្លាស់ប្តូរទៅតាមបរិបទនយោបាយនាម័យកាលនីមួយៗផងដែរ ជាពិសេសនោះគឺពាក់ព័ន្ធនឹងរបបកម្មសិទ្ធិឯកជន។ កម្មសិទ្ធិឯកជនត្រូវបានលេចរូបរាងឡើងដំបូងនៅក្នុងសម័យអាណានិគមបារាំង ហើយបានបន្តអនុវត្តរហូតមកទល់សម័យសាធារណរដ្ឋខ្មែរ ប៉ុន្តែត្រូវបានលុបបំបាត់ទាំងស្រុងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ លុះក្រោយមកទើបលេចរូបរាងម្តងទៀតនៅក្នុងសម័យរដ្ឋកម្ពុជា ហើយត្រូវបានទទួលស្គាល់និងអនុវត្តជាផ្លូវការនៅក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២។ តាមការរៀបរាប់ខាងលើយើងឃើញថាការគ្រប់គ្រងកម្មសិទ្ធិលើដីមានការវិវត្តយ៉ាងខ្លាំងគួរឱ្យកត់សម្គាល់។ ដូចនេះដើម្បីយល់ដឹងឱ្យច្បាស់ថារបបកម្មសិទ្ធិឯកជនមានការវិវត្តយ៉ាងណានោះ យើងនឹងធ្វើការពិភាក្សាទៅលើ ការគ្រប់គ្រងដីធ្លីមុនឆ្នាំ១៩៧៥ (**កថាខណ្ឌទី១**) នឹងដើម្បីដឹងពីការលុបបំបាត់នូវកម្មសិទ្ធិឯកជនទៅវិញបែបណានោះ យើងនឹងពិភាក្សាទៅលើការគ្រប់គ្រងដីធ្លីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ (**កថាខណ្ឌទី២**) ហើយដើម្បីដឹងថាតើកម្មសិទ្ធិឯកជនមានការកកើតឡើងជាថ្មីម្តងទៀតយ៉ាងដូចម្តេចនោះយើងនឹងសិក្សាទៅលើ ការគ្រប់គ្រងដីធ្លីនៅក្រោយឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ (**កថាខណ្ឌទី៣**)។

### កថាខណ្ឌទី១៖ ការគ្រប់គ្រងដីធ្លីមុនឆ្នាំ១៩៧៥

អនុលោមទៅតាមច្បាប់របស់ខ្មែរនាសម័យមុន គឺព្រះមហាក្សត្រជាម្ចាស់លើទឹកដីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[6] ចំណែកឯប្រជាពលរដ្ឋមានសិទ្ធិត្រឹមតែប្រើប្រាស់ និងអាស្រ័យផលលើដីតែប៉ុណ្ណោះ ដោយមិនអាចក្លាយជាម្ចាស់កម្មសិទ្ធិបានឡើយ(ទទួលស្គាល់ត្រឹមតែភោគៈ)។ ប៉ុន្តែសម្រាប់ប្រជាជនដែលបានអាស្រ័យផលលើសិទ្ធិភោគៈ សិទ្ធិនោះត្រូវបានទទួលស្គាល់នៅពេលដែលដីនោះត្រូវបានបង្កបង្កើនផល(រួមមានការរុករាន សង់ផ្ទះ ឬធ្វើរបងជាដើម) ដោយគ្មានការអាក់ខាន និងមានការដឹងឮជាសាធារណៈ ហើយនៅពេលដែលទទួលបានសិទ្ធិជាភោគៈនៅលើដីហើយ សិទ្ធិភោគៈនោះអាចផ្ទេរបានតាមរយៈសន្តតិកម្ម ឬមតកសាសន៍ ហើយក៏អាចជាកម្មវត្ថុនៃកិច្ចសន្យាទិញ លក់ ខ្ចី និងជួលផងដែរ ក្រៅពីករណីលើកលែងមួយចំនួន សិទ្ធិនេះក៏អាចបាត់បង់ទៅវិញ នៅពេលដីនោះត្រូវបានបោះបង់ចោលក្នុងរយៈពេល ៣ឆ្នាំ ក្នុងករណីនេះសិទ្ធិរបស់អ្នកកាន់កាប់ថ្មីនឹងត្រូវបានទទួលស្គាល់ហើយភោគីដើមមិនមានសិទ្ធិទាមទារយកដីនោះមកវិញបានទេ។[7] តាមន័យនេះ អ្នកកាន់កាប់ភោគៈមានកាតព្វកិច្ចត្រូវកាន់កាប់ដោយជាប់លាប់ និងត្រូវបន្តរហូតបើពុំនោះទេនឹងបាត់បង់សិទ្ធិធ្វើ

[6] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥*, ទំព័រ២២។

[7] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥*, ទំព័រ២៣។

ជាម្ចាស់លើដីជាក់ជាមិនខាន។ លុះក្រោយមក នៅថ្ងៃទី១៧ មិថុនា ១៨៨៤ ព្រះបាទនរោត្តមបានចុះហត្ថលេខាលើសន្ធិសញ្ញា ជាមួយនឹងសាធារណរដ្ឋបារាំង តាមរយៈសន្ធិសញ្ញានេះបានដកហូតសិទ្ធិអំណាចរបស់ស្តេច ដើម្បីឱ្យបារាំងធ្វើជាអាណាព្យាបាលលើប្រទេសខ្មែរទាំងមូល ពោលគឺសិទ្ធិអំណាចផ្នែករដ្ឋបាលត្រូវបានប្រគល់ជូនបារាំង។[8]

នៅក្នុងសម័យអាណាព្យាបាលបារាំង ដីធ្លី ទាំងអស់ជាសម្បត្តិរបស់ព្រះមហាក្សត្រ "**ព្រះរាជទ្រព្យ**" ក្រោយមកនៅក្នុងរជ្ជកាលនោះព្រះបាទនរោត្តម ព្រះអង្គបានប្រកាសរំសាយដីធ្លីដែលជាព្រះរាជទ្រព្យ ចែកជូនប្រជាពលរដ្ឋដូចមានបញ្ជាក់ក្នុងមាត្រា៩ នៃសេចក្ដីសម្រេចចុះថ្ងៃទី២៨ តុលា ១៨៨៤ "ដីធ្លីនៃព្រះរាជាណាចក្រដែលមកទល់ថ្ងៃនេះកម្មសិទ្ធិផ្ដាច់មុខរបស់ព្រះរាជទ្រព្យនឹងឈប់ជារបស់ដែលលក់ដូរមិនបានទៀតហើយ"។[9] ចំណេរក្រោយមកនាថ្ងៃអភិសេកព្រះមហាក្សត្រស៊ីសុវត្ថិ នៅថ្ងៃទី៧ មេសា ១៩០៦ ព្រះរាជាបានប្រកាសចំពោះប្រជាពលរដ្ឋថា "ឥឡូវនេះ យើងចង់ឱ្យមានសក្ខីភាពមួយដ៏ត្រចះត្រចង់ ពីការខ្វល់ខ្វាយយ៉ាងខ្លាំងលើផលប្រយោជន៍រាជាណាចក្រ និងប្រជាពលរដ្ឋយើង។ យើងបានសម្រេចផ្ដល់ដីគាស់រាន និងដីកំពុងដាំដុះជូនជាកម្មសិទ្ធិឯកជនដល់ប្រជាពលរដ្ឋដែលបានស្នើសុំ..."។[10] បន្ទាប់ពីការឡើងគ្រងរាជរបស់ព្រះអង្គបានមួយរយៈ នៅឆ្នាំ១៩២០ បារាំងបានបង្កើតច្បាប់មួយឡើងដែលមានឈ្មោះថា ក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលការអនុម័តក្រមនេះគឺមានគោលបំណងបង្កើតនូវប្រព័ន្ធអភិរក្សសុរិយោដីមជ្ឈការមួយទូទាំងប្រទេស ដែលការចុះបញ្ជីជាលាយលក្ខណ៍អក្សរនឹងក្លាយទៅជាភស្តុតាងនៃសិទ្ធិផ្សេងៗ ដូចជាកម្មសិទ្ធិ ភោគៈ ហ៊ីប៉ូតែក ប៉ុន្តែគោលបំណងនេះមិនដែលបានសម្រេច ឬទទួលបានជោគជ័យទាល់តែសោះ ដោយសារតែប្រព័ន្ធនេះមិនត្រូវបានអនុវត្តទូទាំងប្រទេស។[11] មូលហេតុដែលការចុះបញ្ជីនេះមិនអាចអនុវត្តទូទាំងប្រទេសបាន អាចដោយសារតែនៅសម័យនោះប្រជាពលរដ្ឋខ្មែរមិនទាន់យល់ដឹងពីការចុះបញ្ជី ដូចនេះវាគឺថ្មីសម្រាប់ពួកគាត់ ណាមួយការិយាល័យអភិរក្សសុរិយោដីមិនទាន់មាននៅគ្រប់ខេត្ត ក្រុង នៅក្នុងប្រទេសឡើយ ដូច្នេះហើយទើបការចុះបញ្ជីមិនអាចដំណើរការទៅបាន។ ក្រោយមកនៅក្នុងឆ្នាំ១៩២៥ រដ្ឋបានបង្កើតក្រុមអភិរក្សភូមិបាល "Service de la Conversation Foncière" ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងហិរញ្ញវត្ថុ ប៉ុន្តែក្រោយមកបញ្ចូលមកនាយកដ្ឋានសុរិយោដី និងការិយាល័យភូមិបាល តាមស្មារតីព្រះរាជក្រមលេខ ១០១-នស ខាងលើ នាយកដ្ឋានភូមិសាស្ត្រក៏បានបង្កើតឡើង ដោយផ្ដាច់ចេញពីនាយកដ្ឋានសុរិយោដី និងឋានលេខា ដែលមានតួនាទីក្នុងការធ្វើប្រថពីវិភាគ "Géodésie" ឋានលេខា "Topographie" និងការកសាងផែនទី ដោយកំណត់ព្រំប្រទល់រដ្ឋបាល ប្រទេស ខេត្ត ស្រុក និងឃុំ។ លើសពីនេះរដ្ឋបានប្រកាសបើកសម័យទទួលចុះបណ្ដឹងអចលនវត្ថុឡើងមក ដើម្បីកសាងសៀវភៅដីដែលត្រូវបានគេស្គាល់ថា "**សៀវភៅចុះបណ្ដឹងអចលនវត្ថុ**" ដោយបណ្ដឹងអចលនវត្ថុទាំងឡាយនឹង

---

[8] ឥន្ទ ឱមសាម៉េង, *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា*, ២០០៩, ទំព័រ២៣២។

[9] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ២។

[10] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ២។

[11] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥*, ទំព័រ២៥។

ត្រូវបានទទួលក្នុងរយៈពេលច្បាស់លាស់ កំណត់ដោយអភិបាលខេត្ត គឺថ្ងៃបើកសម័យទទួលចុះបណ្តឹងនិងថ្ងៃបិទសម័យទទួលចុះបណ្តឹងអចលនវត្ថុ ហើយមុននឹងចាប់ផ្តើមបើកសម័យទទួលចុះបណ្តឹងអចលនវត្ថុ អភិបាលស្រុក ត្រូវប្រជុំណែនាំដល់មេឃុំ និងប្រជាពលរដ្ឋទាំងអស់នៅឃុំនីមួយៗ ដើម្បីពន្យល់ពីគោលបំណង និងការចាំបាច់របស់រដ្ឋាភិបាលក្នុងការចុះបណ្តឹងអចលនវត្ថុ ដែលសម័យទទួលចុះបណ្តឹងនេះនឹងនាំទៅដល់៖

- ការទទួលស្គាល់ជាផ្លូវការពីរដ្ឋ ក្នុងការកាន់កាប់ **ភោគៈ** និងធានាតាមផ្លូវច្បាប់ជាភស្តុតាងដែលតតិយជនមិនអាចរំលោភបាន។
- ការផ្លាស់ប្តូរសិទ្ធិទៅជា **កម្មសិទ្ធិ** នាអនាគត នៅពេលកសាងបានផែនទីសុរិយោដី។
- ការកសាងសៀវភៅដី **សៀវភៅចុះបណ្តឹងអចលនវត្ថុ** ងាយស្រួលនៅក្នុងការគ្រប់គ្រងនិងការធ្វើផែនការអភិវឌ្ឍន៍ផ្សេងៗ។
- ការកសាងបញ្ជីពន្ធដី ប្រកបដោយភាពត្រឹមត្រូវ និងសមធម៌។

❖ **ដោយឡែក មេឃុំទាំងអស់ ត្រូវបានណែនាំបំពាក់បំប៉នបន្ថែមយ៉ាងស៊ីជម្រៅអំពី៖**

- របៀបរបបបំពេញបណ្តឹងអចលនវត្ថុ ដែលប្រជាពលរដ្ឋបានប្រកាសជំពោះមុខ (នាសម័យនោះប្រជាពលរដ្ឋភាគច្រើនមិនចេះអក្សរ)។
- ការទទួលខុសត្រូវរបស់មេឃុំ ក្នុងប្រតិបត្តិការសម័យទទួលចុះបណ្តឹងអចនវត្ថុ។
- របៀបរបបចុះបញ្ជី នៅពេលចប់សម័យទទួលចុះបណ្តឹងអចនវត្ថុ។

ការទទួលចុះបណ្តឹងអចលនវត្ថុ ធ្វើឡើងជាសាធារណៈ នៅសាលាឃុំ សង្កាត់ ដែលអចលនវត្ថុតាំងនៅ បន្ទាប់ពីបានបំពេញបែបបទរួច ម្ចាស់ដីទទួលបាន "**ចុងសន្លឹក**" ហៅថា "**ពាក្យបណ្តឹងសម្គាល់អចលនវត្ថុ**" ហែកចេញពីគោលបញ្ជីដែលចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ហើយមានតម្លៃជា **ភោគៈ។**[12] នៅពេលចប់សម័យទទួលចុះបណ្តឹងមេឃុំ ចៅសង្កាត់ ធ្វើការបញ្ឈប់គោលបញ្ជីដោយចុះថ្ងៃ ខែ ឆ្នាំ ហត្ថលេខា និងត្រា រួចផ្ញើគោលបញ្ជីនោះមកសាលាស្រុក ខណ្ឌ "**ការិយាល័យភូមិបាល**" ដើម្បីស្រង់ចូលក្នុងសៀវភៅដីនោះគឺការកសាងសៀវភៅចុះបណ្តឹងអចលនវត្ថុ ដែលសៀវភៅនេះត្រូវបានកសាងដោយប្រុងប្រយ័ត្នបំផុត ហើយត្រូវបានកាន់កាប់យ៉ាងយកចិត្តទុកដាក់នៅថ្នាក់ស្រុក ខណ្ឌ និងនៅថ្នាក់ខេត្ត ក្រុង។[13]

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ក្រោមព្រះរាជបូនីយកិច្ចរបស់ព្រះបាទនរោត្តមសីហនុ ប្រទេសកម្ពុជាបានទទួលឯករាជ្យពេញលេញពី**សាធារណរដ្ឋបារាំង** ហើយប្តូរមកជា**សម័យសង្គមរាស្ត្រនិយម** ដែលក្នុងការដឹកនាំ និងគ្រប់គ្រងនៅក្នុងសម័យនោះ របបគ្រប់គ្រងដីធ្លីមិនមានការធ្វើកំណែទម្រង់នោះឡើយហើយបន្តអនុវត្តដូចក្នុងសម័យអាណានិគមនិយមបារាំងដែរ ពោលគឺបទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលពាក់ព័ន្ធនឹង

[12] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៤ និង៥។
[13] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៥។

ទ្រព្យសម្បត្តិនៅតែបន្តអនុវត្តក្នុងរយៈពេលនេះ។[14] បន្ទាប់ពីបានដឹកនាំប្រទេស អស់រយៈពេល១៥ឆ្នាំ របបសង្គមរាស្ត្រនិយមត្រូវបានបិទបញ្ចប់ ដោយសារព្រឹត្តិការណ៍នៅថ្ងៃទី១៨ មីនា ១៩៧០ ដែលដឹកនាំដោយសេនាប្រមុខ លន់ នល់ ហើយរដ្ឋាភិបាលថ្មីក៏ត្រូវបានចាប់បដិសន្ធិឡើង ដោយបានប្តូរឈ្មោះប្រទេសកម្ពុជាពី **សង្គមរាស្ត្រនិយម** មកជា **សាធារណរដ្ឋខ្មែរ** នៅថ្ងៃទី៩ តុលា ១៩៧០ ដែលនៅក្នុងសម័យនេះរបបកម្មសិទ្ធិនៅតែបន្តអនុវត្តរហូតដល់ឆ្នាំ១៩៧៥។[15]

### កថាខណ្ឌទី២៖ ការគ្រប់គ្រងដីធ្លីនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

បន្ទាប់ពីមានភាពវង្វេងរង្គើផ្នែកនយោបាយ និងសេដ្ឋកិច្ច ក៏ដូចជារបបសង្គមនាសម័យសាធារណរដ្ឋ-ខ្មែរអស់រយៈពេល៥ឆ្នាំ ប្រទេសកម្ពុជាបានធ្លាក់ក្នុងសង្គ្រាមស៊ីវិលយ៉ាងក្តៅគគុកនៅឆ្នាំ១៩៧០ដល់១៩៧៥ ពោលគឺពេញមួយសម័យកាល។[16] ក្រោយមកនៅថ្ងៃ១៧ មេសា ១៩៧៥ កងទ័ពខ្មែរក្រហមបានទទួលជោគជ័យទាំងស្រុងលើរបបសាធារណរដ្ឋខ្មែរ ហើយក៏បានផ្លាស់ប្តូរឈ្មោះពី**សាធារណរដ្ឋខ្មែរ** មកជា **កម្ពុជា-ប្រជាធិបតេយ្យ**។[17] ដែលនៅក្នុងសម័យកាលនេះ របបដីធ្លីត្រូវបានផ្លាស់ប្តូរយ៉ាងគំហុក[18] ផ្អែកតាមមាត្រា២ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ទទួលស្គាល់តែកម្មសិទ្ធិរួមរបស់សមូហភាព។ មានន័យថា រដ្ឋាភិបាលខ្មែរក្រហមបានសម្រេចចិត្តមិនទទួលស្គាល់កម្មសិទ្ធិឯកជនទៀតទេ មិនតែប៉ុណ្ណោះថែមទាំងមិនអនុញ្ញាតឱ្យជនណាម្នាក់ធ្វើការទាមទារកម្មសិទ្ធិរបស់ខ្លួន ពោលគឺដីធ្លីទាំងអស់នោះជាទ្រព្យសម្បត្តិរួម។ ជាងនេះទៅទៀតរចនាសម្ព័ន្ធរដ្ឋបាលសុរិយោដី ត្រូវបានកម្ទេចចោលទាំងស្រុង ហើយបណ្តាឯកសារសំខាន់ៗដូចជាច្បាប់ ប្លង់សុរិយោដី សៀវភៅដី ឧបករណ៍បច្ចេកទេសត្រូវខូចខាតអស់ លើសពីនេះមន្ត្រីបច្ចេកទេសសុរិយោដីដែលនៅមុនឆ្នាំ១៩៧៥ មានចំនួនប្រហែល ១០០០នាក់ ត្រូវនៅសល់មិនដល់ ៥០នាក់ នាក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩។[19]

### កថាខណ្ឌទី៣៖ ការគ្រប់គ្រងដីធ្លីនៅចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣

នៅថ្ងៃទី៧ មេសា ១៩៧៩ ក្រោមការដឹកនាំរបស់កងទ័ពរណសិរ្សរំដោះជាតិកម្ពុជា បានរំដោះប្រទេសកម្ពុជាឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានដឹកនាំប្រទេសអស់រយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។[20] តាមរយៈជ័យជម្នះនេះមានការផ្លាស់ប្តូររបបនយោបាយពី**សម័យកម្ពុជាប្រជាធិបតេយ្យ** មកជានាមផ្លូវការថា **សាធារណរដ្ឋប្រជាមានិតកម្ពុជា**[21] ហើយរដ្ឋាភិបាលនាសម័យនោះបានចាប់ផ្តើមស្តារប្រទេសដែលក្រុមខ្មែរ

---

[14] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៥។

[15] ឥន្ទ ឱមសាម៉េង, *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា,* ២០០៩, ទំព័រ៣២១ និង៣២២។

[16] ពៅ សាវឿន, *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា,* ២០១០, ទំព័រ១៩៨។

[17] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ១៤ ធ្នូ ១៩៧៥, ប្រកាសប្រើជាផ្លូវការ នៅថ្ងៃ៥ មករា ១៩៧៦, មាត្រា១។

[18] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៦។

[19] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៧។

[20] ឥន្ទ ឱមសាម៉េង, *ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា,* ២០០៩, ទំព័រ៣៣៨។

[21] រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១, មាត្រា១ កថាខណ្ឌ១។(តទៅហៅថារដ្ឋធម្មនុញ្ញឆ្នាំ១៩៨១)

ក្រហមបានបំផ្លិចបំផ្លាញពីចំណុចសូន្យមកវិញ ដោយចាប់ផ្តើមដាក់ចេញនូវគោលនយោបាយជាច្រើន ដើម្បីរៀបចំប្រទេសជាបន្តបន្ទាប់ ជាពិសេសនោះគឺរដ្ឋាភិបាលបានយកចិត្តទុកជាខ្លាំងពាក់ព័ន្ធនឹងវិស័យដីធ្លី។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាឆ្នាំ១៩៨១ នៅតែបន្តមិនទទួលស្គាល់កម្មសិទ្ធិឯកជនដដែល "ដីធ្លីនៅតែជាសម្បត្តិរដ្ឋ ពុំទាន់ត្រូវបានប្រគល់សិទ្ធិជាឯកជនណាមួយនៅឡើយទេគឺនៅប្រើប្រាស់គ្រប់គ្រងជាសមូហភាព"[22] តាមស្មារតីនៃរដ្ឋធម្មនុញ្ញនេះ រដ្ឋនៅតែបន្តគ្រប់គ្រងទៅលើដីធ្លីតាមបែបសមូហភាពដដែល "ពេលនោះបញ្ហាចោទខ្លាំងគឺបាក់កម្លាំង គ្មានឧបករណ៍ផលិតកម្ម បាត់បង់សមាជិកគ្រួសារនៅសេសសល់ស្ត្រីមេម៉ាយ ចាស់ជរា ក្មេងកំព្រា និងជម្ងឺរ៉ាំរ៉ៃ..."[23] ទាំងនេះក៏ព្រោះតែនាសម័យខ្មែរក្រហមពួកគាត់ត្រូវបានគេបង្ខំឱ្យធ្វើការរហូតដល់បាក់កម្លាំង និងមិនមានអាហារហូបគ្រប់គ្រាន់នោះឡើយ បែបនេះហើយដែលបញ្ជាក់ឱ្យឃើញថាស្ទើរតែគ្រប់គ្រួសារទាំងអស់មានការខ្វះខាតកម្លាំងពលកម្ម មនុស្ស និងកម្លាំងអូសទាញ ក្នុងការងារកសិកម្ម ហើយប្រសិនបើរដ្ឋផ្តល់ជាកម្មសិទ្ធិឯកជនដល់ពួកគាត់ នោះច្បាស់ណាស់ចំពោះគ្រួសារដែលមានភាពខ្វះខាតសម្ភារៈ និងកម្លាំងពលកម្មនោះនឹងមិនអាចប្រកបរបរចញ្ចឹមជីវិតបានទេ ហើយភាពអត់ឃ្លាន នឹងកើតឡើងម្តងទៀតជាក់ជាមិនខាន។ ម្យ៉ាងវិញទៀតប្រសិនបើបង្កើតឱ្យមានកម្មសិទ្ធិដីធ្លីនឹងមានការលំបាកក្នុងការឱ្យពួកគាត់គ្រប់គ្រងដោយខ្លួនឯង ដោយសារតែរូបភាពនៃការទន្ទ្រានចូលចាប់យកដីបែបអាណាធិបតេយ្យនឹងកើតមានឡើងហើយធ្វើឱ្យសង្គមមានភាពចលាចលពិបាកក្នុងការគ្រប់គ្រង ហេតុនេះហើយទើបរដ្ឋជ្រើសរើសយកការគ្រប់គ្រងដីធ្លីតាមបែបសមូហភាពដើម្បីឱ្យពួកគាត់បានជួយគ្នាទៅវិញទៅមកក្នុងការប្រើប្រាស់រួមទៅលើដីធ្លី កម្លាំងពលកម្ម និងឧបករណ៍ផលិតកម្ម។ តាមរយៈការអនុវត្តការគ្រប់គ្រងដីធ្លីតាមបែបសមូហភាពនេះរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតឱ្យមាននូវ "**នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម**" ដែលស្ថិតនៅចំណុះឱ្យក្រសួងកសិកម្ម ហើយមានតួនាទីរៀបចំបង្កើត និងគ្រប់គ្រងក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃ ដែលក្រុមសាមគ្គីបង្កបង្កើនផលត្រូវបានចែកចេញជាបីដំណាក់កាលរួមមាន៖[24]

- ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី១
  - ដីស្រែ ចម្ការ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមផ្ទាល់
  - គោ ក្របី រទេះ និងឧបករណ៍ផលិតកម្ម ប្រើប្រាស់រួមក្រុម
  - ប្រធានក្រុមចាត់ចែងបង្កបង្កើនផល និងបែងចែកភោគផលដល់សមាជិកក្រុម
- ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី២
  - ដីស្រែ ចម្ការ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមផ្ទាល់

[22] លឹម វ៉ាន់, "ការគ្រប់គ្រងដីធ្លីនៅកម្ពុជា", (២៤ ឧសភា ២០០៧), ទំព័រ១ និង២។

[23] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៧។

[24] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៨។

- ក្រុម ចែកជាពួកតូចៗ ពី ៣ ទៅ ៥ គ្រួសារក្នុងមួយក្រុម
- ពួកតូចៗ ចាត់ចែងបង្កបង្កើនផល និងបែងចែកភោគផលដល់សមាជិកពួក

• ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី៣

- ក្រុម ផ្ដើរួមនូវផ្ទៃដីមួយចំនួនតូច
- ផ្ទៃដីមួយចំនួនធំ ចែកឱ្យគ្រួសារក្នុងក្រុមបង្កបង្កើនផល និងទទួលផលជាឯកជន។

ក្រោយពីបានអនុវត្តមួយរយៈពេលមកឃើញថាការអនុវត្តរបស់ក្រុមសាមគ្គីបង្កបង្កើនផលបានចាប់ផ្ដើមអន់ថយចុះជាលំដាប់ ជាក់ស្ដែងចំនួនក្រុមសាមគ្គីប្រភេទទី១ ចេះតែថយចុះ ហើយក្រុមសាមគ្គីប្រភេទទី៣ ចេះតែកើនឡើង[25] ការថយចុះបែបនេះក៏ព្រោះតែប្រជាជនចាប់ផ្ដើមចង់បាននូវកម្មសិទ្ធិដីធ្លីធ្វើជារបស់ខ្លួនឡើងវិញ ដោយមើលឃើញបែបនេះរដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចាប់ផ្ដើមដាក់ចេញនូវគោលនយោបាយជាបន្តបន្ទាប់ ដើម្បីឱ្យសមស្របតាមគោលបំណងរបស់ប្រជាពលរដ្ឋ ហេតុនេះហើយដើម្បីលើកទឹកចិត្តដល់ប្រជាជន តាមរយៈគោលនយោបាយរបស់រណសិរ្សក្រុមសាមគ្គីបង្កបង្កើនផលនៃប្រជាជនកម្ពុជាបានផ្លាស់ប្ដូរពីក្រុមសាមគ្គីប្រវាស់ដៃទៅម្ចាស់ការទាំងស្រុងក្នុងការរៀបចំទំនាក់ទំនងផ្នែកផលិតកម្ម និងជីវភាពរស់នៅ ដោយឈានទៅរករបបកម្មសិទ្ធិឯកជនលើដីធ្លីឡើងវិញ។[26]

ជាក់ស្ដែងនៅក្នុងការបរាជ័យរបស់ក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃមក សញ្ញាណនៃការចាប់ផ្ដើមផ្ដល់កម្មសិទ្ធិលើដីធ្លីពីរដ្ឋដល់ប្រជាជន ឬអាចហៅម្យ៉ាងទៀតថា "ឯកជនភាវូបនីយកម្មដីធ្លីត្រូវបានចាប់ផ្ដើមឡើងនៅឆ្នាំ១៩៨៩"[27] ដែលនៅក្នុងខែមេសា ឆ្នាំ១៩៨៩ សន្និបាតតំណាងកម្មាភិបាលទូទាំងប្រទេសលើកទី២ បានប្រារព្ធធ្វើឡើងហើយបានដាក់ចេញនូវសេចក្ដីសម្រេចចិត្តចំនួន៥ ដែលនៅក្នុងនោះគេសង្កេតឃើញថា "សេចក្ដីសម្រេចចិត្តស្ដីពីគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី គឺជាសេចក្ដីសម្រេចចិត្តដែលលេចធ្លោជាងគេក្នុងចំណោមសេចក្ដីសម្រេចចិត្តចំនួន៥"។[28] ក្រោយមកមានការអនុម័ត អនុក្រឹត្យលេខ២៥ ចុះថ្ងៃទី២២ មេសា ១៩៨៩ ស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះសម្បែងជូនពលរដ្ឋ (តទៅហៅថា អនុក្រឹត្យស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះសម្បែងជូនពលរដ្ឋឆ្នាំ១៩៨៩) តាមរយៈខ្លឹមសារមាត្រា១ នៃអនុក្រឹត្យនេះបានចែងថា៖[29]

*ដីសង់លំនៅឋាន និងអាគារធំ តូច ផ្ទះជាភូមិគ្រឹះ ផ្ទះដាច់ដោយឡែកឯទៀត ឬផ្ទះល្វែងទាំងអស់ក្នុងទូទាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាទ្រព្យសម្បត្តិរបស់ប្រជាជនដែលរដ្ឋគ្រប់គ្រងតាមច្បាប់ជាធរមាន។*

*គ្មានជនណាមួយអាចទាមទារសិទ្ធិលើកម្មសិទ្ធិចាស់មុនឆ្នាំ១៩៧៩ លើដីសង់លំនៅឋាន ឬផ្ទះប្រភេទណាមួយបានឡើយ។*

[25] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៨។
[26] ក្រសួងអប់រំ យុវជន និងកីឡា, *ប្រវត្តិវិទ្យាថ្នាក់ទី១២* (ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ២០១១), ទំព័រ១៦០។
[27] ហាប់ ផល្លី, *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា* (ភ្នំពេញ៖ Premium Advertising, ២០២១), ទំព័រ៥។
[28] ហាប់ ផល្លី, *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា* (ភ្នំពេញ៖ Premium Advertising, ២០២១), ទំព័រ៥។
[29] អនុក្រឹត្យ ស្ដីពីការផ្ដល់កម្មសិទ្ធិលើផ្ទះសម្បែងជូនពលរដ្ឋកម្ពុជា, លេខ២៥ អនក្រ, ២២ មេសា ១៩៨៩, មាត្រា១។

❖ **ចំណែកឯមាត្រា២ នៃអនុក្រឹត្យនេះបានបន្ថែមថា៖**

*ចាប់ពីថ្ងៃនេះតទៅ រដ្ឋបែងចែកកម្មសិទ្ធិដាច់ឱ្យគ្រួសារជាពលរដ្ឋកម្ពុជា លើលំនៅឋានដែលគ្រួសាររបស់ខ្លួនកំពុងរស់នៅក្នុងឃុំ សង្កាត់ទូទាំងប្រទេស ហើយដែលរដ្ឋអំណាចឃុំ សង្កាត់នោះទទួលស្គាល់។ គ្រួសារពលរដ្ឋកម្ពុជាដែលរស់នៅលើលំនៅឋានដែលជាផ្ទះភូមិគ្រឹះ ផ្ទះដាច់ដោយឡែកឯទៀត ឬផ្ទះល្វែងត្រូវបានទទួលកម្មសិទ្ធិកាន់កាប់ ប្រើប្រាស់លំនៅឋាននោះ ដែលសន្មតហៅថាផ្ទះសម្រាប់រស់នៅតរៀងទៅ។*

*កម្មសិទ្ធិលើផ្ទះនេះ អាចបន្តមត៌កទៅកូន ចៅកាន់កាប់ ប្រើប្រាស់ដោយគ្មានកំណត់ពេល ឬប្រគល់ជាអំណោយឱ្យទៅបងប្អូនញាតិមិត្ត ឬលក់ឱ្យទៅអ្នកដទៃណាមួយទៀតកាន់កាប់ ប្រើប្រាស់បាន លើកលែងតែការប្រើប្រាស់ដោយអ្នកទាំងនោះបម្រើគោលដៅ និងផលប្រយោជន៍ដែលផ្ទុយនឹងច្បាប់កំណត់។ រដ្ឋហាមឃាត់ការលក់ផ្ទះ និងដីសង់លំនៅឋានឱ្យទៅជនបរទេស។*

តាមស្មារតីមាត្រា១ នៃអនុក្រឹត្យនេះ បានចែងអំពីប្រភេទនៃកម្មសិទ្ធិសមូហភាពនៃដីលំនៅឋាន ឯមាត្រា២ នៃអនុក្រឹត្យដដែល បានធ្វើការកែប្រែយ៉ាងច្រើនដោយចែងថា ប័ណ្ណលើផ្ទះសម្បែងអាចចេញជូនបុគ្គលម្នាក់ៗ ហើយប័ណ្ណលើផ្ទះសម្បែងនេះអាចធ្វើការផ្ទេរតាមរយៈមរតកសាសន៍[30] ឬការលក់។[31] ប៉ុន្តែអ្វីដែលគួរកត់សម្គាល់នោះគឺថា អនុក្រឹត្យនេះកម្មសិទ្ធិដីធ្លីមុនឆ្នាំ១៩៧៩ មិនត្រូវបានទទួលស្គាល់នោះទេ ដូចនេះប្រជាជនមិនអាចធ្វើការទាមទារកម្មសិទ្ធិចាស់របស់ខ្លួនបានឡើយ។ បន្ទាប់ពីបានផ្តល់កម្មសិទ្ធិលើផ្ទះដល់ពលរដ្ឋកម្ពុជាបានមួយរយៈមក បន្ថែមពីលើអនុក្រឹត្យដែលមានស្រាប់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានចេញនូវសេចក្តីណែនាំមួយទៀត ដែលស្តីពីការអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លី លេខ ០៣ សណន ៣ មិថុនា ១៩៨៩ ដែលក្នុងនោះមានចែងអំពីការកំណត់បែងចែក និងរូបភាពនៃការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីឱ្យកាន់តែមានភាពច្បាស់លាស់ ដែលបានកំណត់ដូចតទៅ៖[32]

- **ចំពោះដីលំនៅឋាន៖** តាមរយៈសេចក្តីសម្រេចនេះ រដ្ឋបានសម្រេចផ្តល់ដីសម្រាប់លំនៅឋានជូនពលរដ្ឋកម្ពុជា កំណត់មិនឱ្យលើសពី២០០០ម$^{២}$ សម្រាប់មួយគ្រួសារ ប៉ុន្តែក្នុងករណីបើគ្រួសារប្រជាជនណាមួយ ដែលពីមុនមានដីសម្រាប់សង់លំនៅឋានលើសពី២០០០ម$^{២}$ នោះចំណែកដែលលើសត្រូវចាត់ចូលជាដីភោគៈវិញ។ តាមន័យនេះ ទោះបីជាមានការផ្តល់នូវកម្មសិទ្ធិឯកជនលើដីលំនៅឋានក៏ពិតមែន ប៉ុន្តែការផ្តល់ឱ្យនេះនៅតែមានការរឹតត្បិតលើទំហំដីពីរដ្ឋនៅឡើយ ពោលគឺមិនទាន់មានភាពទូលំទូលាយ ហើយការផ្តល់កម្មសិទ្ធិឯកជនលើដីលំនៅឋាននឹងត្រូវសម្រេចដោយអភិបាលក្រុងជាអ្នកមានសមត្ថកិច្ច។

---

[30] សន្ធានុក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, *"មរតកសាសន៍ ឬ មតកសាសន៍"* សំដៅទៅលើលិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ដែលកំណត់ដោយច្បាប់ ដើម្បីសំដែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍បន្ទាប់ពីទទួលមរណភាព។

[31] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៦។

[32] លឹម វ៉ាន់, "ការគ្រប់គ្រងដីធ្លីនៅកម្ពុជា", ២៤ ឧសភា ២០០៧, ទំព័រ៣។

- **ចំពោះដីស្រែចម្ការសម្រាប់ផលិតកម្មអាជីវកម្ម៖** តាមរយៈសេចក្តីសម្រេចនេះបានផ្តល់ជូនជាភោគៈនៅលើផ្ទៃដីស្រែ ឬចម្ការ បានន័យថាដីភោគៈគឺជាដីដែលរដ្ឋប្រគល់សិទ្ធិផ្តាច់មុខជូនដល់គ្រួសារកសិករកាន់កាប់ ប្រើប្រាស់ក្នុងពេលធ្វើផលិតកម្ម អាជីវកម្ម និងបន្តមត៌ក។ តាមន័យនេះ កម្មសិទ្ធិលើដីស្រែចម្ការ មិនត្រូវបានផ្តល់ជូនពលរដ្ឋឡើយ ពោលគឺរដ្ឋបានផ្តល់ត្រឹមតែសិទ្ធិបណ្តោះអាសន្នលើដីកសិកម្មប៉ុណ្ណោះ។ ចំពោះដីភោគៈត្រូវបានរដ្ឋកំណត់មិនឱ្យលើសពី ៥ហិកតា យោងទៅតាមលទ្ធភាពដីរបស់មូលដ្ឋាន និងលទ្ធភាពរបស់គ្រួសារនីមួយៗ បន្ថែមពីលើនេះដីភោគៈត្រូវបានផ្តល់ជូនចំពោះតែគ្រួសារណាដែលបានតស៊ូធ្វើស្រែចម្ការយ៉ាងតិចមួយឆ្នាំមុនថ្ងៃកំណត់។ ហើយដើម្បីទទួលបានសិទ្ធិភោគៈ គឺទាមទារឱ្យមានការចុះបញ្ជី[33] ហើយចំណែកឯការសម្រេចលើសិទ្ធិជាភោគៈលើដីស្រែចម្ការនឹងត្រូវសម្រេចដោយអភិបាលស្រុក ខណ្ឌ។
- **ចំពោះដីដាំដំណាំ៖** យោងតាមសេចក្តីណែនាំដដែលខាងលើនេះ ចំពោះដីដាំដំណាំដែលមានទំហំធំជាង ៥ហិកតា ត្រូវបានផ្តល់ក្នុងទម្រង់ជាសម្បទាន[34] ហើយការសម្រេចសិទ្ធិជាសម្បទានលើដីនឹងត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម។

__**កំណត់សម្គាល់៖**__ ចំពោះដីភោគៈខុសគ្នា និងកម្មសិទ្ធិត្រង់ថា ដីភោគៈអាចមានអថេរភាពក្នុងដំណាក់កាលដែលកំពុងប្រើប្រាស់ពេលឈប់ប្រើគឺលែងជាភោគៈ។ ចំណែកឯកម្មសិទ្ធិគឺគ្មានកំណត់ពេល ទោះបីមិនប្រើប្រាស់ ឬមិនធ្វើអាជីវកម្មក៏ដោយ ក៏នៅតែជាកម្មសិទ្ធិដដែល លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ។

បន្តមកនៅថ្ងៃទី៣០ មេសា ១៩៨៩ មានកិច្ចប្រជុំវិសាមញ្ញមួយនៅទីក្រុងភ្នំពេញ តាមរយៈកិច្ចប្រជុំនេះសភាជាតិនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ ហើយបានផ្លាស់ប្តូរឈ្មោះប្រទេសពី **សាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅ រដ្ឋកម្ពុជា**។[35] ក្រោយពីបានផ្លាស់ប្តូររបបរួចមកឃើញថារដ្ឋាភិបាលចាប់ផ្តើមយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការផ្តល់កម្មសិទ្ធិឯកជន និងព្យាយាមបន្តបង្កើតនូវបទដ្ឋានគតិយុត្តជាច្រើនឡើងមកថែមទៀតពាក់ព័ន្ធនឹងដីធ្លី។ ជាក់ស្តែងគេឃើញមានការបង្កើតច្បាប់ដ៏សំខាន់មួយ ហើយត្រូវបានប្រកាសឱ្យប្រើតាម ក្រឹត្យរបស់ក្រុមប្រឹក្សានៃរដ្ឋធម្មនុញ្ញ លេខ១០០ក្រ ដែល "បានប្រកាសឱ្យប្រើច្បាប់ភូមិបាលដែលរដ្ឋសភានៃរដ្ឋកម្ពុជា បានអនុម័តនៅថ្ងៃទី១០ សីហា ១៩៩២ នាសម័យប្រជុំលើកទី២៣ នីតិកាលទី១"។[36] ច្បាប់នេះគឺជាច្បាប់មួយដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតឱ្យមាននូវកម្ម

---

[33] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៧។

[34] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៦។ សន្ទានុក្រមច្បាប់ភូមិបាល២០០១, "***សម្បទាន***" សំដៅដល់អចលនវត្ថុ (ដីធ្លី) ដែលរដ្ឋផ្តល់ឱ្យរូបវ័ន្តបុគ្គល ឬនីតិបុគ្គល សម្រាប់សង់លំនៅឋាន ឬ/និងបង្កបង្កើនផល ដោះស្រាយជីវភាពរស់នៅក្នុងទំហំដីតូច ពិសេសសម្រាប់ប្រជាពលរដ្ឋក្រីក្រ (សម្បទានឆ្លើយតបទៅនឹងផលប្រយោជន៍សង្គម) ឬសម្រាប់ធ្វើការដាំដុះធ្វើអាជីវកម្ម កសិឧស្សាហកម្ម ក្នុងទំហំដីធំទូលាយពិសេសសម្រាប់វិនិយោគទុន(សម្បទានឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច)តាមរយៈកិច្ចសន្យាសម្បទានដោយត្រូវបង់ប្រាក់ជូនរដ្ឋ។

[35] រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ៣០ មេសា ១៩៨៩, មាត្រា១។

[36] ច្បាប់ភូមិបាល, លេខ១០០ក្រ, ១៣ តុលា ១៩៩២ (តទៅហៅថាច្បាប់ភូមិបាល១៩៩២)។

សិទ្ធិឯកជនក្នុងប្រទេសកម្ពុជា ដោយច្បាប់ភូមិបាលឆ្នាំ១៩៩២ បានចែងឡើងវិញពីគោលការណ៍ច្បាប់នានាដែលមានចែងក្នុងក្រមរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជា ហើយច្បាប់នេះក៏បានទទួលស្គាល់ការទទួលបានកម្មសិទ្ធិតាមរយៈ សន្តតិកម្ម មរតកសាសន៍ កិច្ចសន្យា ប្រទានកម្ម និងតាមរយៈភោគៈផងដែរ ជាក់ស្តែងគេឃើញថាមាននិយមន័យនៃពាក្យកម្មសិទ្ធិ ដែលតាមរយៈមាត្រា១៩ បានឱ្យនិយមន័យថា ជាសិទ្ធិអាស្រ័យផល និងសិទ្ធិលក់ទ្រព្យសម្បត្តិ ហើយសិទ្ធិនោះជាសិទ្ធិដាច់ខាត និងផ្តាច់មុខ ប៉ុន្តែត្រូវអនុវត្តក្នុងព្រំដែនច្បាប់កំណត់។[37] គួរបញ្ជាក់ផងដែរមាត្រា១៩ នៃច្បាប់ដដែលនេះ សិទ្ធិជាកម្មសិទ្ធិលើដីធ្លីគឺមានតែដីលំនៅឋានតែមួយគត់ដែលអាចជាកម្មវត្ថុនៃកម្មសិទ្ធិឯកជន និងដីសម្រាប់សង់លំនៅឋានដែលស្ថិតក្នុងទីប្រជុំជន និងទីក្រុងត្រូវកំណត់នៅក្នុងច្បាប់មួយដោយឡែក។ ហើយច្បាប់ដដែលនេះ បានអនុញ្ញាតឱ្យមានកម្មសិទ្ធិតាមរយៈភោគៈ ដើម្បីក្លាយជាកម្មសិទ្ធិករលើដីធ្លី ភោគីត្រូវបង្ហាញថាភោគៈរបស់ខ្លួន គឺបានមកដោយឥតប្រើហិង្សា ដោយសុចរិត ដោយមានការដឹងឮជាសាធារណៈ ដោយមិនមានការអាក់ខាន ដោយគ្មានបន្លំ។[38] ក្រៅពីលក្ខខណ្ឌដែលមាននៅខាងលើមានបន្ថែមលក្ខខណ្ឌមួយទៀតដែលជារយៈពេលតម្រូវឱ្យភោគីត្រូវកាន់កាប់ភោគៈយ៉ាងហោចណាស់បានរយៈពេល ៥ឆ្នាំ ទើបអាចក្លាយជាកម្មសិទ្ធិករបាន។[39] លើសពីនេះទៀតច្បាប់ភូមិបាលឆ្នាំ១៩៩២ បានចែងពីលក្ខខណ្ឌពីរតម្រូវផ្សេងទៀតគឺ៖[40]

- ភោគីបានប្តឹងសុំកាន់កាប់ដល់ប្រធានឃុំ សង្កាត់ ជាចៅនាទីនៃអចលនវត្ថុនោះ
- ភោគីបានបង់ពន្ធដីជាទៀងទាត់។

ដូចដែលបានរៀបរាប់ខាងលើ ដើម្បីក្លាយជាកម្មសិទ្ធិករ ភោគីដែលជាអ្នកកាន់កាប់ភោគៈ ត្រូវតែគោរពគ្រប់លក្ខខណ្ឌទាំងអស់នេះ ដូច្នេះប្រសិនបើភោគីមានការខ្វះខាតចំណុចណាមួយនោះគាត់មិនអាចដាក់ពាក្យសុំដើម្បីក្លាយជាកម្មសិទ្ធិករបានទេ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តច្បាប់ភូមិបាលឆ្នាំ១៩៩២ មិនមានភាពរលូននោះទេ ព្រោះតែបញ្ហាធំៗចំនួនពីរត្រូវបានលេចឡើងក្នុងការអនុវត្តដែលមានដូចជា៖[41]

- **បញ្ហាទី១**៖ កម្រមានការចេញប័ណ្ណកម្មសិទ្ធិជូនដល់ប្រជាជនណាស់ ដូច្នេះប្រជាជនគ្រាន់តែបានចូលកាន់កាប់ដីតែប៉ុណ្ណោះ។ លើសពីនេះទៀត ការផ្លាស់ប្តូរទីកន្លែងច្រើនដងរបស់ប្រជាជន និងការពិបាកក្នុងការចូលទៅដល់តំបន់មួយចំនួនបង្កឱ្យមានការប៉ះពាល់ដល់លទ្ធភាពអនុវត្តច្បាប់ភូមិបាលឆ្នាំ១៩៩២ នេះ។
- **បញ្ហាទី២**៖ មានការពិបាកក្នុងការផ្តល់ព័ត៌មានជូនប្រជាជនគ្រប់រូបអំពីកាតព្វកិច្ចតាមផ្លូវច្បាប់ថ្មីស្តីពីការប្រកាសជូនដំណឹងពីភោគៈរបស់ខ្លួន និងការបង់ពន្ធទៀងទាត់។ ហើយប្រសិនបើប្រជាជនមិនបាន

[37] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៧។
[38] ច្បាប់ភូមិបាល១៩៩២, មាត្រា៦២។
[39] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៨។
[40] ច្បាប់ភូមិបាល១៩៩២, មាត្រា៦៦។
[41] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២៨។

ទទួលព័ត៌មាន ពួកគាត់មិនអាចអនុវត្តតាមកាតព្វកិច្ចថ្មីទាំងនេះបានឡើយ ដូច្នេះតាមច្បាប់ ពួកគាត់មិនអាចទាមទារកម្មសិទ្ធិលើដីដោយផ្អែកលើភោគៈរបស់ពួកគាត់បានទេ។

ជារួមមក បញ្ហាទាំងអស់នេះធ្វើឱ្យច្បាប់ភូមិបាលឆ្នាំ១៩៩២ មិនអាចអនុវត្តទៅបានល្អ ជាពិសេស គឺដំណើរការនៃការផ្តល់កម្មសិទ្ធិដល់ប្រជាពលរដ្ឋមិនទាន់មានភាពរលូននោះទេ ហេតុនេះហើយទើបបញ្ហាទាំងអស់នេះត្រូវបានដោះស្រាយដោយច្បាប់ភូមិបាលថ្មីមួយទៀត ដែលគេស្គាល់ថាជាច្បាប់ភូមិបាល២០០១ ហើយច្បាប់នេះយើងនឹងពិភាក្សាលម្អិតក្នុងជំពូកទី២។

ក្រោយមកនៅថ្ងៃ២៤ កញ្ញា ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមដែលមានឈ្មោះថា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។ តាមរយៈរដ្ឋធម្មនុញ្ញនេះបានផ្លាស់ប្តូរឈ្មោះប្រទេស ពី **រដ្ឋកម្ពុជា** មកជា **ព្រះរាជាណាចក្រកម្ពុជា**។[42] លើសពីនេះរដ្ឋធម្មនុញ្ញដដែលបានបញ្ជាក់សារជាថ្មីចំពោះកម្មសិទ្ធិឯកជន ជាក់ស្តែងមាត្រា៤៤ បានចែងថា៖

*ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី។*

*កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់។*

*ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យនិងយុត្តិធម៌។*

អនុលោមតាមខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ១៩៩៣ ដែលជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា គេអាចសង្កេតឃើញថា កម្មសិទ្ធិឯកជនចាប់ផ្តើមមានភាពទូលំទូលាយជាងមុនគួរឱ្យកត់សម្គាល់ ដោយរដ្ឋបើកឱ្យប្រជាពលរដ្ឋមានសិទ្ធិជាកម្មសិទ្ធិករលើទ្រព្យសម្បត្តិរបស់ខ្លួន ហើយសិទ្ធិកម្មសិទ្ធិនោះនឹងត្រូវបានការពារដោយច្បាប់ ប៉ុន្តែសម្រាប់តែប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត មាត្រា៥៦ នៃរដ្ឋធម្មនុញ្ញដដែល បានធ្វើការផ្លាស់ប្តូរប្រទេសកម្ពុជាពីសេដ្ឋកិច្ចផែនការ មកជារបបសេដ្ឋកិច្ចទីផ្សារសេរីផងដែរ ហើយតាមរយៈការផ្លាស់ប្តូរនេះក៏ជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់នៃរបបកម្មសិទ្ធិឯកជន ព្រោះតែនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី អនុញ្ញាតឱ្យមនុស្សគ្រប់គ្នាអាចចូលរួមសកម្មភាពនៃការជួញដូរបានដោយសេរីទៅលើទ្រព្យដែលជារបស់ខ្លួន ជាពិសេសនោះគឺដីធ្លីជាដើម។

## ផ្នែកទី២៖ ការវិវត្តនៃស្ថាប័នទទួលបន្ទុកចុះបញ្ជីដី

នៅក្នុងដំណើរការនៃការចុះបញ្ជីដីនៅក្នុងប្រទេសកម្ពុជាគឺមានស្ថាប័នមួយដែលទទួលបន្ទុកក្នុងការគ្រប់គ្រង ចុះបញ្ជី និងចេញប័ណ្ណកម្មសិទ្ធិលើដីធ្លី ហើយស្ថាប័ននេះមានឈ្មោះថា "**អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ**" ដែលជាសេនាធិការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[43] ប៉ុន្តែបើក្រឡេក

[42] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ២៤ កញ្ញា ១៩៩៣(តទៅហៅថា រដ្ឋធម្មនុញ្ញ១៩៩៣)។

[43] អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២អនក្រ/បក, ២០កក្កដា១៩៩៩។

មើលមកក្រោយបន្តិច យើងនឹងឃើញថា ចាប់តាំងមានឯកជនភាវូបនីយកម្មដីធ្លីមកទល់បច្ចុប្បន្ន ស្ថាប័ននេះមានការវិវត្តជាលំដាប់គួរឱ្យកត់សម្គាល់ ហើយការវិត្តនេះគឺជាការផ្លាស់ប្តូរទៅលើចំណុចសំខាន់ៗដូចជា ការប្តូរឈ្មោះ សមត្ថកិច្ចក្នុងការចេញប័ណ្ណដី ការផ្លាស់ប្តូរក្រសួងសាមីដែលមានសមត្ថកិច្ចគ្រប់គ្រងទៅលើស្ថាប័ន ពីក្រសួងមួយទៅក្រសួងមួយទៀត ដើម្បីស្របតាមភាពចាំបាច់ បរិបទសង្គម និងកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងការដឹកនាំប្រទេសជាអាទិ៍។ ជាក់ស្តែងតាំងពីមានឯកជនភាវូបនីយកម្មមក ស្ថាប័នដែលទទួលបន្ទុកក្នុងការចុះបញ្ជីដី នៅក្នុងប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរចំនួនបីដងរួចមកហើយ។ ដូច្នេះដើម្បីឱ្យដឹងកាន់តែច្បាស់ទៅលើការផ្លាស់ប្តូរនៃស្ថាប័នទាំងនេះ យើងនឹងធ្វើការសិក្សាលម្អិតទៅលើការបង្កើតស្ថាប័នទទួលបន្ទុកដែលមានដូចជា នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម ចាប់ពីឆ្នាំ១៩៧៩ ដល់ ១៩៨៩ (**កថាខណ្ឌទី១**) បន្ទាប់មកក៏មានការផ្លាស់ប្តូរបន្តមកជា នាយកដ្ឋានសុរិយោដី ចាប់ពីឆ្នាំ១៩៨៩ ដល់ ១៩៩៩(**កថាខណ្ឌទី២**) និងការផ្លាស់ប្តូរចុងក្រោយបំផុតមកជា អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ចាប់ពី១៩៩៩ មកដល់បច្ចុប្បន្ន(**កថាខណ្ឌទី៣**)។

### កថាខណ្ឌទី១៖ នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម (ពីឆ្នាំ១៩៧៩ ដល់ ១៩៨៩)

ក្រោយពីទទួលបានជ័យជម្នះលើពួកខ្មែរក្រហមមក នាថ្ងៃ ៧ មេសា ១៩៧៩ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតនូវនាយកដ្ឋានមួយដែលមានឈ្មោះថា នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម មានទីតាំងស្ថិតនៅក្រោមក្រសួងកសិកម្មដែលមានតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំចងក្រងនិងដឹកនាំក្រុមសាមគ្គីបង្កបង្កើនផលក្នុងន័យជួយគ្នាទៅមក ហើយនៅក្នុងការអនុវត្តតួនាទីរបស់នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម បានបង្កើតឱ្យមាននូវក្រុមសាមគ្គីបង្កបង្កើនផលបីប្រភេទ ដែលមានដូចជា៖[44]

- ក្រុមសាមគ្គីបង្កបង្កើនផលប្រភេទទី១
  - ដីស្រែ ចម្ការ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមផ្ទាល់
  - គោ ក្របី រទេះ និងឧបករណ៍ផលិតកម្ម ប្រើប្រាស់រួមក្នុងក្រុម
  - ប្រធានក្រុមចាត់ចែងការបង្កបង្កើនផល និងបែងចែកភោគផលដល់សមាជិកក្រុម។
- ក្រុមសាមគ្គីប្រភេទទី២
  - ដីស្រែ ចម្ការ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមផ្ទាល់
  - ក្រុម ចែកជាពួកតូចៗពីបី ទៅ ប្រាំគ្រួសារក្នុងមួយក្រុម
  - ពួកតូចៗ ចាត់ចែងបង្កបង្កើនផល និងបែងចែកភោគផលដល់សមាជិកពួក។
- ក្រុមសាមគ្គីប្រភេទទី៣

[44] លឹម វ៉ាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៧ និង៨។

- ក្រុម ផ្ញើរមនូវផ្ទៃដីមួយចំនួនតូច
- ផ្ទៃដីមួយចំនួនធំ ចែកឱ្យគ្រួសារក្នុងក្រុមបង្កបង្កើនផល និងទទួលផលជាឯកជន។

ដោយសារតែនៅក្នុងចន្លោះឆ្នាំ១៩៧៩ ដល់ ១៩៨៩ ប្រទេសកម្ពុជាមិនទាន់មានឯកជនភាវូបនីយកម្មនៅឡើយ ពោលគឺនៅតែបន្តដឹកនាំតាមបែបសមូហភាព ដូច្នេះដីធ្លីទាំងអស់នៅតែជារបស់រដ្ឋ មិនទាន់មានការបើកឱ្យធ្វើការចុះបញ្ជីដី អាស្រ័យហេតុនេះហើយទើបនាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្មមិនបានធ្វើសកម្មភាពណាមួយពាក់ព័ន្ធនឹងការចុះបញ្ជីដីធ្លីទេ ហើយភារកិច្ចដែលសំខាន់របស់នាយកដ្ឋាននៅពេលនោះគឺ បង្កើត គ្រប់គ្រង និងសម្របសម្រួលក្រុមសាមគ្គីបង្កបង្កើនផល ធ្វើយ៉ាងណាធានានូវការអនុវត្តរបស់ក្រុមឱ្យមានភាពរលូន។

ក្រោយពីការអនុវត្តអស់រយៈ ១០ឆ្នាំមក គេសង្កេតឃើញថានាយកដ្ឋាននេះហាក់មិនសូវទទួលបានជោគជ័យដូចការរំពឹងទុកនោះទេ ព្រោះថាប្រជាជនមានគំនិតចង់បានដីធ្លីមកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលជាហេតុធ្វើឱ្យការគ្រប់គ្រងដីធ្លីតាមបែបសមូហភាពមិនអាចអនុវត្តទៅតមុខទៀតបាន។ លុះក្រោយមកទើប របបឯកជនភាវូបនីយកម្ម ត្រូវបានបង្កើតឡើងឱ្យស្របតាមបរិបទសង្គម និងបើកឱ្យធ្វើការចុះបញ្ជីដែលការចុះបញ្ជីធ្វើបានតែចំពោះតែដីលំនៅឋានប៉ុណ្ណោះ ដោយមាននាយកដ្ឋានសុរិយោដីជាអ្នកទទួលបន្ទុក។

### កថាខណ្ឌទី២៖ នាយកដ្ឋានសុរិយោដី (ចាប់ពីឆ្នាំ ១៩៨៩ ដល់ ១៩៩៩)

នៅក្នុងឆ្នាំ១៩៨៩ ឯកជនភាវូបនីយកម្មដីធ្លីត្រូវបានចាប់ផ្តើមឡើងនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីបរាជ័យនៃក្រុមសាមគ្គីបង្កបង្កើនផលដែលបានអុវត្តអស់រយៈពេល១០ឆ្នាំកន្លងមក ហើយកម្មសិទ្ធិឯកជនលើដីត្រូវបានកើតមានឡើង ដោយរដ្ឋបានផ្តល់តែចំពោះដីលំនៅឋានប៉ុណ្ណោះ ហើយតម្រូវឱ្យដាក់ពាក្យស្នើសុំចុះបញ្ជីនៅនាយកដ្ឋានសុរិយោដី។[45] នៅក្នុងដំណើរការនៃការចុះបញ្ជីដីធ្លី ផ្អែកតាមខ្លឹមសារនៃអនុក្រឹត្យលេខ៣១ អនក្រចុះថ្ងៃទី១៤ មិថុនា ១៩៨៩ បានធ្វើការផ្ទេរនូវ**នាយកដ្ឋានគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចកសិកម្ម** មកជា**នាយកដ្ឋានសុរិយោដី**។[46] ក្រោយមានការដាក់ចេញនូវប្រកាសលេខ១១១ ប្រក/កសក ចុះថ្ងៃទី ៣១ តុលា ១៩៨៩ ស្តីពីការតែងតាំង និងនាយកដ្ឋានសុរិយោដី តាមរយៈមាត្រា១ នៃប្រកាសនេះ នាយកដ្ឋានសុរិយោដី គឺជាអង្គភាពសេនាធិការមួយដែលមានតួនាទីជំនួយឱ្យក្រសួងកសិកម្ម លើការងារគ្រប់គ្រង និងប្រើប្រាស់ដីធ្លីនៅទូទាំងប្រទេស។[47] លើសពីនេះយោងតាមមាត្រា៣ នៃប្រកាសដដែល នាយកដ្ឋានសុរិយោដី គឺជាអ្នកពិនិត្យ និងសម្រេចលើរាល់ឯកសារស្នើសុំកាន់កាប់ដីធ្លីនៅក្នុងក្របខណ្ឌ និងសិទ្ធិអំណាចរបស់ខ្លួន។ មានន័យថា នាយកដ្ឋានសុរិយោដីគឺជាអង្គភាពតែមួយគត់ដែលក្រសួងកសិកម្មបានផ្តល់ភារកិច្ចឱ្យក្នុងការគ្រប់គ្រង តាមដាន និង

---

[45] ហាប់ ផល្លី, *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា* (ភ្នំពេញ៖ Premium Advertising, ២០២១), ទំព័រ៥។

[46] លឹម វាន់, "របបដីធ្លីនៅកម្ពុជា", (កក្កដា ២០០៦), ទំព័រ៩។

[47] ប្រកាសស្តីពីការតែងតាំង និងសកម្មភាពនាយកដ្ឋានសុរិយោដី, លេខ១១១ ប្រក/កសក, ៣១ តុលា ១៩៨៩, នៅក្នុង ហាប់ ផល្លី, វាយឡើងវិញ, *កម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្មឆ្នាំ១៩៨៥-២០១៥, បោះពុម្ពលើកទី៤* (ភ្នំពេញ៖ ជោគជ័យ, ២០១៨), ទំព័រ៤៥ (តទៅហៅថា ហាប់ ផល្លី, កម្រងច្បាប់ដីធ្លីឆ្នាំ១៩៨៥-២០១៥)។

ការកំណត់ទម្រង់ ដើម្បីបំពេញបែបបទផ្សេងៗដែលជាប់ទាក់ទងនឹងដំណើរការនៃការចុះបញ្ជីដីធ្លីនៅកម្ពុជានាសម័យនោះ។

ក្រោយពីបានអនុវត្តនូវភារកិច្ចរបស់ខ្លួនបានមួយរយៈមក នាយកដ្ឋានសុរិយោដីត្រូវបានផ្ទេរមកស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈអនុក្រឹត្យលេខ៥៨ អនក្រ ចុះថ្ងៃទី៣ តុលា ១៩៩៤។[48] តាមរយៈការផ្លាស់ប្តូរនេះ គឺមិនមានផ្លាស់ប្តូរសមត្ថកិច្ច ឬតួនាទីរបស់នាយកដ្ឋានសុរិយោដីនោះទេ ពោលគឺគ្រាន់តែផ្លាស់ប្តូរក្រសួងអាណាព្យាបាលប៉ុណ្ណោះ មានន័យថានាយកដ្ឋានសុរិយោដីនៅតែបន្តការងារជាធម្មតា។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៩៥ តួនាទីរបស់នាយកដ្ឋានសុរិយោដីមានការប្រែប្រួល ដោយរាល់ការស្នើសុំត្រូវឆ្លងកាត់ទីស្តីការគណៈរដ្ឋមន្ត្រី តាមរយៈនាយកដ្ឋានសុរិយោដី ដើម្បីពិនិត្យ និងសម្រេចដោយពុំមែនត្រូវបញ្ចប់ត្រឹមនាយកដ្ឋានសុរិយោដីដូចដែលបានអនុវត្តកន្លងមកឡើយ។[49] ដូច្នេះនាយកដ្ឋានសុរិយោដីលែងមានអំណាចសម្រេចដូចមុនទៀតហើយ ដោយការសម្រេចត្រូវផ្ទេរឱ្យស្ថិតនៅក្រោមសមត្ថកិច្ចទីស្តីការគណៈរដ្ឋមន្ត្រីដែលជាស្ថាប័ននយោបាយជំនួសវិញ ដើម្បីកាត់បន្ថយវិវាទដីធ្លីនាសម័យកាលនោះ។

**កថាខណ្ឌទី៣៖ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ (ចាប់ពីឆ្នាំ ១៩៩៩ មកទល់បច្ចុប្បន្ន)**

ក្រោយពីនាយកដ្ឋានសុរិយោដីបានអនុវត្តតួនាទី និងភារកិច្ច ក្នុងការចុះបញ្ជីដីធ្លីអស់រយៈពេល១០ឆ្នាំកន្លងមក ទើបនៅឆ្នាំ១៩៩៩ នាយកដ្ឋានសុរិយោដីត្រូវបានប្តូរឈ្មោះមកជាអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រវិញ ហើយមានទីតាំងស្ថិតនៅចំណុះឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[50] លើសពីនេះ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រមានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារ៖[51]

- ជាសេនាធិការរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ លើកិច្ចការសុរិយោដី និងភូមិសាស្ត្រ
- សិក្សាស្រាវជ្រាវ កសាងគម្រោងលិខិតបទដ្ឋានទាំងឡាយដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រង និងប្រើប្រាស់ដីធ្លី
- កសាងទិសដៅ និងផែនការ ដើម្បីបម្រើការងារលើវិស័យសុរិយោដី និងភូមិសាស្ត្រ
- ធ្វើការវាស់វែង និងគូរផែនទីសុរិយោដី

[48] អនុក្រឹត្យ ស្តីពីការផ្ទេរនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈ-រដ្ឋមន្ត្រី, លេខ៥៨ អនក្រ, ៣០ តុលា ១៩៩៤, នៅក្នុង ហាប់ ផល្លី, កម្រងច្បាប់ដីធ្លីឆ្នាំ១៩៨៥-២០១៥ ទំព័រ១៨៨។

[49] លិខិតរបស់គណៈរដ្ឋមន្ត្រីស្តីពីករណីបញ្ហាទំនាស់កម្មសិទ្ធិដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ, លេខ១០៥២ សជណ/សរ, ៥ កក្កដា ១៩៩៥, នៅក្នុង ហាប់ ផល្លី, កម្រងច្បាប់ដីធ្លីឆ្នាំ១៩៨៥-២០១៥, ទំព័រ២១២។

[50] ច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, នស/រកម/០៦៩៩/០៩, ២៣ មិថុនា ១៩៩៩, មាត្រា៤។

[51] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២ អនក្រ/បក, ២០ កក្កដា ១៩៩៩, មាត្រា២១។

- ចេញប័ណ្ណសម្គាល់ដីធ្លីទូទាំងព្រះរាជាណាចក្រកម្ពុជា
- ធ្វើការអភិរក្សសុរិយោដី និងធ្វើអធិការកិច្ចក្នុងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- កំណត់ព្រំប្រទល់ក្បាលដី
- អភិរក្សទ្រព្យសម្បត្តិរដ្ឋ
- សហការជាមួយនាយកដ្ឋានបុគ្គលិក និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងមុខជំនាញដល់មន្ត្រីរាជការក្រោមឱវាទ
- ធ្វើជាសេនាធិការឱ្យក្រសួង ក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិ និងបណ្តាប្រទេសនានាលើផ្នែកបច្ចេកទេស វិទ្យាសាស្ត្របម្រើឱ្យវិស័យសុរិយោដី និងភូមិសាស្ត្រ
- សហការជាមួយក្រសួង និងស្ថាប័ននានា ក្នុងការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី។

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងជាជំនួយការជាការចាំបាច់។

ក្រោយមកនៅពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវបានចូលជាធរមាន តាមរយៈមាត្រា២២៦ ដល់ ២២៨ នៃច្បាប់នេះ សិទ្ធិអំណាចក្នុងការអនុវត្តដំណើរការចុះបញ្ជីដីធ្លីនៅទូទាំងប្រទេសកម្ពុជា ត្រូវបានប្រគល់ឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយតម្រូវឱ្យក្រសួងនេះបង្កើតរដ្ឋបាលសុរិយោដី[52]ដើម្បីគ្រប់គ្រង និងអនុវត្តដំណើរការចុះបញ្ជីដីធ្លីថ្នាក់ជាតិ។[53] បន្ថែមពីលើនេះផ្អែកតាមច្បាប់ភូមិបាល២០០១ រដ្ឋបាលសុរិយោដីមានរចនាសម្ព័ន្ធដូចតទៅៈ

- **រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល៖** ជាអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដែលមានទីតាំងស្ថិតនៅក្នុងក្រសួងរៀបចំដែនដី នគរូបនីយកម្ម ដែលទទួលបន្ទុករៀបចំ សម្របសម្រួល និងត្រួតពិនិត្យប្រតិបត្តិការទាំងឡាយនៃការវាស់វែងសុរិយោដីដែលធ្វើឡើងលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងរាល់ប្រតិបត្តិការកសាងប្លង់សុរិយោដី កសាងបញ្ជីឈ្មោះកម្មសិទ្ធិករ កសាងសៀវភៅគោលបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ម្ចាស់អចលនវត្ថុ។ ក្រៅពីនេះ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវកំណត់វិធី និងស្តង់ដារទាក់ទងទៅនឹងឯកសារ។[54]

---

[52] ច្បាប់ភូមិបាល២០០១, មាត្រា២២៦, "**រដ្ឋបាលសុរិយោដី**" ត្រូវបានចាត់ទុកថាជាភ្នាក់ងារចំណុះឱ្យក្រសួងរៀបចំដែនដី នគរូបនីយ-កម្ម និងសំណង់ មានសមត្ថកិច្ចធ្វើអត្តសញ្ញាណកម្មទ្រព្យ កសាងប្លង់សុរិយោដី ចេញប័ណ្ណកម្មសិទ្ធិ ចុះបញ្ជីដី និងផ្តល់ព័ត៌មានដល់ជនទាំងឡាយអំពីស្ថានភាពក្បាលដីទាក់ទងទៅនឹងប្រភេទ ទំហំ កម្មសិទ្ធិករ និងបន្ទុកផ្សេងដែលអាចមានលើក្បាលដី។

[53] *សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សា និងស្រាវជ្រាវ ២០០៥,* ទំព័រ២២៤ និង២២៥។

[54] ច្បាប់ភូមិបាល២០០១, មាត្រា២៣១។

- **រដ្ឋបាលសុរិយោដីខេត្ត ក្រុង៖** មានទីតាំងស្ថិតនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដែលត្រូវប្រតិបត្តិរាល់ការណែនាំពីសុរិយោដីថ្នាក់កណ្ដាល។ រដ្ឋបាលសុរិយោដីថ្នាក់ខេត្ត ក្រុង ទទួលធ្វើសម្រង់សុរិយោដី ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដទៃទៀត កាន់កាប់សៀវភៅគោលបញ្ជីដី ធ្វើចរន្តការជាប្រចាំ ក្រោមការត្រួតពិនិត្យពីរដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល រក្សាទុកឯកសារ និងផ្ដល់ព័ត៌មានដល់អ្នកស្នើសុំ។[55]
- **រដ្ឋបាលសុរិយោដីថ្នាក់ស្រុក ខណ្ឌ៖** មានទីតាំងស្ថិតក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដែលត្រូវប្រតិបត្តិរាល់ការណែនាំពីរដ្ឋបាលសុរិយោដីថ្នាក់ខេត្ត ក្រុង និងរដ្ឋបាលសុរិយោដីថ្នាក់កណ្ដាល និងត្រូវផ្ញើច្បាប់ចម្លងនៃសម្រង់ឯកសារសុរិយោដីដល់ឃុំ ឬសង្កាត់ដែលពាក់ព័ន្ធ។ មេឃុំ ឬចៅសង្កាត់ ត្រូវអនុញ្ញាតឱ្យជនគ្រប់រូបពិគ្រោះយោបល់ ហើយត្រូវរាយការណ៍ទៅរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ នូវរាល់ការផ្លាស់ប្ដូរដែលទាក់ទងនឹងស្ថានភាពនៃកម្មសិទ្ធិ និងកម្មសិទ្ធិករក្នុងមូលដ្ឋានរបស់ខ្លួន។[56]

❖ **យោងតាមមាត្រា២២៩ នៃច្បាប់ភូមិបាល២០០១ រដ្ឋបាលសុរិយោដីមានភារកិច្ចដូចតទៅ៖**[57]

- ធ្វើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធតាមបញ្ញត្តិនៃអនុក្រឹត្យស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- ធ្វើការពង្រឹងការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ តាមនីតិវិធីដែលនឹងបញ្ញត្តិដោយអនុក្រឹត្យ
- អនុវត្តការអង្កេតវាស់វែងសុរិយោដីនៃក្បាលដីរួមមានការកំណត់ព្រំដី ការបំបែកក្បាលដី ការបង្រួមក្បាលដី និងការកែតម្រូវព្រំប្រទល់នៃក្បាលដី និងជាទូទៅរាល់ការប្រែប្រួលអំពីទំហំដែលបណ្ដាលមកពីធម្មជាតិ ឬដោយស្ម័គ្រចិត្ត
- កសាងសៀវភៅគោលបញ្ជីដី ហើយធ្វើលេខាចារឹកឈ្មោះកម្មសិទ្ធិករ និងរាល់ទិន្នន័យដែលប្រមូលបានទាក់ទងទៅនឹងលក្ខណៈរូប ទំហំ និងអត្តសញ្ញាណនៃអចលនវត្ថុទាំងនោះ
- ធ្វើចរន្តការនូវរាល់ការផ្លាស់ប្ដូរ ប្រែប្រួល ទាក់ទងទៅនឹងសិទ្ធិដែលកើតឡើងដោយកិច្ចសន្យាផ្ទេរ ដូចជាការលក់ ការឱ្យ ការដូរ សន្តតិកម្ម ឬពាក់ព័ន្ធនឹងការដូរប្រភេទ ឬស្ថានភាពនៃដី ដូចជាការសាងសង់ ការចាក់បំពេញដី ការជីកកកាយយកដីជាដើម

[55] ច្បាប់ភូមិបាល២០០១, មាត្រា២៣២។
[56] ច្បាប់ភូមិបាល២០០១, មាត្រា២៣៣។
[57] ច្បាប់ភូមិបាល២០០១, មាត្រា២២៩។

- អភិរក្សនូវរាល់ឯកសារសុរិយោដីដែលមានប្លង់សុរិយោដី បញ្ជីឈ្មោះកម្មសិទ្ធិករ សៀវភៅគោលបញ្ជីដី និងរាល់ឯកសារគតិយុត្តទាក់ទងទៅនឹងក្បាលដីនីមួយៗ
- ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនកម្មសិទ្ធិករ និងលិខិតបញ្ជាក់ផ្សេងៗទៀតទាក់ទងនឹងក្បាលដី
- មានកាតព្វកិច្ចប្រគល់ជូនជនដែលបានដាក់ពាក្យស្នើសុំ ថតប្លង់ និងឯកសារ ព័ត៌មាន ទាក់ទងទៅនឹងទីតាំង អត្តសញ្ញាណ ព្រំដី និងសិទ្ធិដែលទាក់ទងនឹងក្បាលដី
- ធ្វើលេខាចារឹកនូវរាល់ហ៊ីប៉ូតែក ការបញ្ចាំ ការជួលរយៈពេលវែង ឬសេវភាពដែលបង្កើតឡើងលើទ្រព្យដែលជាអចលនវត្ថុ ហើយផ្តល់ព័ត៌មានទៅគ្រប់ជនដែលសាកសួរមករដ្ឋបាលសុរិយោដីអំពីស្ថានភាពនៃកម្មសិទ្ធិដែលជាកម្មវត្ថុនៃការដាក់ហ៊ីប៉ូតែក ការបញ្ចាំ ដាក់ធានា ការជួលរយៈពេលវែង ឬសេវភាព។

ជារួមមក អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រគឺជាស្ថាប័នមួយដែលទទួលបាននូវការអនុញ្ញាតពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការអនុវត្តដំណើរការចុះបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន។

# ជំពូកទី២
# អំពីរបបនៃការចុះបញ្ជីដីនៅកម្ពុជា

# ជំពូកទី២
# អំពីរបបនៃការចុះបញ្ជីដីនៅកម្ពុជា

បន្ទាប់ពីបានឆ្លងកាត់ជាច្រើនសម័យកាលមក នៅថ្ងៃទី២៤ កញ្ញា ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានប្រកាសឱ្យប្រើ អនុលោមតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញនេះ គេសង្កេតឃើញថាមានការផ្លាស់ប្តូរជាច្រើនទាំងរបបនយោបាយ និងរបបសេដ្ឋកិច្ច នៅក្នុងការគ្រប់គ្រងប្រទេស ជាពិសេសនោះគឺបានបង្កើតឱ្យមាននូវរបបកម្មសិទ្ធិលើដីធ្លីឡើងមក។ តាមរយៈនេះយើងមើលឃើញថា រដ្ឋធម្មនុញ្ញបានចាប់បដិសន្ធិមក សិទ្ធិកាន់កាប់ គ្រប់គ្រង និងចាត់ចែងចំពោះដីធ្លីត្រូវបានគេទទួលស្គាល់យ៉ាងពេញលេញនៅក្នុងប្រទេស ពោលគឺរដ្ឋបានលុបបំបាត់ចោលទាំងស្រុងនូវការគ្រប់គ្រងតាមបែបសមូហភាព ហើយងាកមកចាប់ផ្តើមបង្កើត នូវរបបនៃការគ្រប់គ្រងដីធ្លីថ្មីមួយតាមបែបទីផ្សារសេរី ដើម្បីឱ្យស្របតាមបរិបទនៃឯកជនភាវូបនីយកម្មផងដែរ។ ទោះបីជាតាមរយៈស្មារតីរដ្ឋធម្មនុញ្ញដដែលបានទទួលស្គាល់កម្មសិទ្ធិលើដីធ្លីក៏ពិតមែន ប៉ុន្តែការអនុវត្តនៅពេលនោះមិនទាន់អាចធ្វើការអនុវត្តបាននៅឡើយទេ ដោយសារតែរដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូលមួយដែលបង្កើតមកសម្រាប់គ្រប់គ្រងប្រទេសទាំងមូល ដូចនេះទើបមិនមានចែងលម្អិតអំពីនីតិវិធីដើម្បីអាចទទួលបានកម្មសិទ្ធិឯកជននៅលើដីធ្លីនៅឡើយទេ។ ហេតុនេះហើយទើបរដ្ឋាភិបាលបានបង្កើតនូវលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនឹងដីធ្លី ដើម្បីគាំទ្រលើខ្លឹមសារដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដើម្បីអាចយកទៅអនុវត្តបាននៅក្នុងការផ្តល់នូវកម្មសិទ្ធិលើដីធ្លីឱ្យមានប្រសិទ្ធិភាពខ្ពស់។ ក្រោយមកថ្ងៃទី៣០ សីហា ២០០១ មានការប្រកាសឱ្យប្រើច្បាប់ភូមិបាលថ្មីមួយ( តទៅហៅថាច្បាប់ភូមិបាល២០០១ ) ដែលច្បាប់នេះបង្កើតឡើងស្របតាមគោលការណ៍ និងបទបញ្ញត្តិដែលមាននៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ក្នុងការផ្តល់កម្មសិទ្ធិលើដីធ្លីនៅក្នុងប្រទេសកម្ពុជា។ ជាពិសេស ច្បាប់នេះក៏បានបង្កើតនូវរបបកម្មសិទ្ធិជាក់លាក់ រួមមានដូចជា កម្មសិទ្ធិសាធារណៈ កម្មសិទ្ធិឯកជន កម្មសិទ្ធិសមូហភាព ហើយរបបកម្មសិទ្ធិទាំងអស់គឺតម្រូវឱ្យធ្វើការចុះបញ្ជីនៅរដ្ឋបាលសុរិយោដីជាមុនសិនទើបទទួលបានប័ណ្ណកម្មសិទ្ធិ។ ប៉ុន្តែចំពោះដំណើរការនៃការចុះបញ្ជីដីទាំងនេះគឺមានភាពខុសប្លែកគ្នាត្រង់ លក្ខខណ្ឌ និងតួអង្គដែលដើរតួនាទីនៅក្នុងការចុះបញ្ជី ដោយដីឯកជន គឺជាប្រជាពលរដ្ឋដែលជាម្ចាស់ដីជាអ្នកដាក់ពាក្យចុះបញ្ជី ចំណែកឯដីសមូហ-ភាពរបស់បងប្អូនជនជាតិដើមភាគតិច គឺប្រធានគណៈកម្មាធិការសហគមន៍ជាអ្នកតំណាងនៅក្នុងការចុះបញ្ជី។ ដោយឡែកចំពោះដីរដ្ឋគឺតម្រូវឱ្យមានតំណាងមកពីក្រសួង ស្ថាប័នទទួលបន្ទុកគ្រប់គ្រង និងកាន់កាប់ទ្រព្យសម្បត្តិរដ្ឋដែលមានដូចជារាជរដ្ឋាភិបាល ក្រសួង ស្ថាប័នសាមីដែលពាក់ព័ន្ធ អាជ្ញាធរគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសាធារណៈជាដើម ត្រូវដើរតួនាទីក្នុងនាមជារដ្ឋនៅក្នុងដំណើរការចុះបញ្ជី។ ដូច្នេះដើម្បីយល់ច្បាស់ពីដំណើរការនៃការចុះបញ្ជីនូវប្រភេទដីនីមួយៗ យើងនឹងសិក្សាអំពី

ការចុះបញ្ជីដីរដ្ឋ(**ផ្នែកទី១**) ហើយបន្ទាប់មកការចុះបញ្ជីដីឯកជន(**ផ្នែកទី២**) និងចុងក្រោយនោះគឺការចុះបញ្ជីដីសមូហភាព(**ផ្នែកទី៣**)។

## ផ្នែកទី១៖ ការចុះបញ្ជីដីរដ្ឋ

នៅក្នុងការដំណើរការនៃការចុះបញ្ជីដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីដីឯកជន ដីដែលជាទ្រព្យសម្បត្តិរដ្ឋក៏ជាផ្នែកមួយដែលជាកម្មវត្ថុនៃការចុះបញ្ជីបានផងដែរ។ ជាក់ស្តែងនៅពេលដែលច្បាប់ភូមិបាល ២០០១ បានចូលជាធរមាន ច្បាប់នេះតម្រូវឱ្យធ្វើការចុះបញ្ជីរាល់ក្បាលដីទាំងអស់ក្នុងប្រទេសកម្ពុជា ដើម្បីបញ្ជាក់ពីសិទ្ធិកម្មសិទ្ធិនៅលើក្បាលដី។ ចំពោះការចុះបញ្ជីដីរដ្ឋ គឺជាការចុះបញ្ជីដើម្បីកំណត់នូវសិទ្ធិរបស់រដ្ឋក្នុងការគ្រប់គ្រងទ្រព្យសាធារណៈឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីបញ្ជាក់ពីសិទ្ធិកម្មសិទ្ធិលើដី ការកំណត់ព្រំប្រទល់ច្បាស់លាស់លើដី ការដោះស្រាយទំនាស់ដោយអាជ្ញាធរមានសមត្ថកិច្ចចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។[58] ដូច្នេះដើម្បីឈ្វេងយល់លម្អិតពីបែបបទនៃការចុះបញ្ជីដីរដ្ឋ យើងនឹងពិភាក្សាទៅលើ ការកំណត់លក្ខណៈដីរដ្ឋ(**កថាខណ្ឌទី១**) និងសិក្សាបន្តទៅលើលក្ខខណ្ឌនៃការចុះបញ្ជីដីរដ្ឋ(**កថាខណ្ឌទី២**) ហើយបន្ទាប់មកយើងនឹងឈ្វេងយល់បន្ត អំពីនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ(**កថាខណ្ឌទី៣**)។

### កថាខណ្ឌទី១៖ ការកំណត់លក្ខណៈនៃដីរដ្ឋ

ដីរដ្ឋ ជាធនធានដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម[59] ដែលសំដៅទៅដល់ដីសាធារណៈរបស់រដ្ឋ ឬ របស់នីតិបុគ្គលសាធារណៈព្រមទាំងដីឯកជនរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដទៃទៀត។[60] ដីរដ្ឋត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រង់មាត្រា៥៨ កថាខណ្ឌទី១ បានចែងថា ទ្រព្យរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។ ក្រោយមកតាមរយៈច្បាប់ភូមិបាល២០០១ ក៏បានធ្វើការចែងលម្អិតទៅលើរដ្ឋធម្មនុញ្ញបន្ថែមទៀត ដោយបានចែងថា ទ្រព្យមួយចំនួនជារបស់រដ្ឋ ឬរបស់សមូហភាពដែនដីសាធារណៈដែលត្រូវបានដាក់នៅក្រោមរបបគតិយុត្តពិសេស គឺជាទ្រព្យសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ហើយទ្រព្យមួយចំនួនទៀតត្រូវគ្រប់គ្រងដូចកម្មសិទ្ធិឯកជន និងអាចជាកម្មវត្ថុនៃកិច្ចការជំនួញ គឺជាទ្រព្យសម្បត្តិឯកជន

---

[58] បណ្ឌិត អ៊ិន សកក្កដា, *នីតិទ្រព្យសម្បត្តិសាធារណៈ៖ សំរាប់បរិញ្ញាបត្រជាន់ខ្ពស់ រដ្ឋបាលសាធារណៈ*, ឆ្នាំសិក្សា២០១៥-២០១៦, ទំព័រ ២៥។

[59] រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយដីធ្លី, "សៀវភៅសដីធ្លី", ២៨ សីហា ២០១៥, (តទៅហៅថា សៀវភៅសដីធ្លី), ទំព័រ៣០។

[60] អនុក្រឹត្យ ស្តីពីការកំណត់លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ, លេខ៣២១ អនក្រ.បក, ២ វិច្ឆកា ២០២៣, មាត្រា៣(តទៅហៅថា អនុក្រឹត្យ៣២១ ឆ្នាំ២០២៣)។

របស់នីតិបុគ្គលសាធារណៈ។[61] ដូច្នេះច្បាប់ភូមិបាលបានបែងចែកប្រភេទដីរដ្ឋជាពីរប្រភេទគឺ ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។

**ដីសាធារណៈរបស់រដ្ឋ** សំដៅដល់ដីដែលដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំរួច ឬដីដែលមានជាប់ផលប្រយោជន៍សាធារណៈ ឬជាដីដែលមានការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈទូទៅ។[62] ហើយតាមរយៈមាត្រា១៥ នៃច្បាប់ភូមិបាល២០០១ ដែលបានកំណត់លក្ខណៈនៃដី ដែលអាចចាត់ចូលជាដីសាធារណៈរបស់រដ្ឋមានប្រាំពីរប្រភេទរួមមាន៖[63]

- ទ្រព្យទាំងឡាយណាដែលបានបង្ហាញនូវការកកើតឡើងពីធម្មជាតិ ដូចជាព្រៃឈើ ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្ដែតបាន បឹងធម្មជាតិ ច្រាំងទន្លេ ដែលនាវា ឬក្បូនចេញចូលបានបណ្ដែតបាន និងត្រើយសមុទ្រ។
- ទ្រព្យទាំងឡាយណាដែលជាកម្មវត្ថុនៃការរៀបចំពិសេសសំរាប់ប្រយោជន៍ទូទៅដូចជា តំបន់ កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ។
- ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈ និងដីចំណីផ្លូវ។
- ទ្រព្យទាំងឡាយណាដែលត្រូវបានដាក់ដំណើរការសំរាប់សេវាសាធារណៈ អាគាររដ្ឋបាល និងមន្ទីរពេទ្យសាធារណៈទាំងឡាយ។
- ទ្រព្យទាំងឡាយដែលបង្កើតជាដែនបម្រុងការពារធម្មជាតិការពារដោយច្បាប់។
- បេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ និងប្រវត្តិសាស្ត្រ។
- អចលនវត្ថុជាព្រះរាជទ្រព្យដែលមិនមែនជាទ្រព្យសម្បត្តិឯកជនរបស់ព្រះរាជវង្សានុវង្ស អចលនវត្ថុជាព្រះរាជទ្រព្យត្រូវបានចាត់ចែងដោយព្រះមហាក្សត្រកំពុងគ្រងរាជ្យ។

<u>**កំណត់សម្គាល់**</u>៖ ក្រៅពីទ្រព្យដែលបានរៀបរាប់ដូចខាងលើ ចំពោះទ្រព្យទាំងឡាយណាដែលមានចរិតបម្រើដល់ផលប្រយោជន៍សាធារណៈក៏អាចចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈបានផងដែរ។

**រីឯដីឯកជនរបស់រដ្ឋ** សំដៅដល់ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ និងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬមិនមែនជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាម

---

[61] ច្បាប់ភូមិបាល២០០១, មាត្រា១៤។

[62] សន្ធានុក្រម, ច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, លេខនស/រកម/១១២០/០៣០, ១៤ ខែវិច្ឆកា ២០២០(តទៅហៅថា សន្ធានុក្រមច្បាប់ស្ដីពីការគ្រប់គ្រង និងប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ២០២០)។

[63] ច្បាប់ភូមិបាល២០០១,មាត្រា១៥។

ច្បាប់ភូមិបាល២០០១។[64] តាមរយៈនិយមន័យនេះបានបង្ហាញឱ្យឃើញថា ដីឯកជនរបស់រដ្ឋជាទ្រព្យសម្បត្តិមួយប្រភេទ ដែលរដ្ឋអាចធ្វើការចាត់ចែងនៅក្នុងកម្មវត្ថុនៃការ លក់ដូរ ឬជួលបាន ដែលវាផ្ទុយពីដីសាធារណៈរបស់រដ្ឋ។ ដូច្នេះយើងអាចមើលឃើញថា ដីឯកជនរបស់រដ្ឋ ត្រូវបានកើតឡើងមកតាមរយៈសេចក្តីសម្រេចរបស់តុលាការ ទ្រព្យនិទាយាទ[65] ដីដែលកម្មសិទ្ធិករបានប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ដីដែលគេមិនអាចកំណត់បាននូវអត្តសញ្ញាណរបស់ភោគី និងដី ដែលរដ្ឋបានធ្វើអនុប្បយោគ[66] ពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋជាដើម។

ជារួមមកទាំងដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋគឺសុទ្ធសឹងតែជាកម្មវត្ថុដែលអាចចុះបញ្ជីជាកម្មសិទ្ធិរបស់រដ្ឋ។ កថាខណ្ឌនេះគ្រាន់តែជាដំណាក់កាលដំបូងនៅក្នុងដំណើរការនៃការចុះបញ្ជីដីរដ្ឋប៉ុណ្ណោះ។

### កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការចុះបញ្ជីដីរដ្ឋ

ផ្អែកតាមជំពូកទី២ នៃច្បាប់ភូមិបាល២០០១ បានកំណត់ដីរដ្ឋជាពីរគឺមានដូចជា ដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ ក្នុងគោលបំណងធានាដល់ការគ្រប់គ្រង និងចាត់ចែងដីរដ្ឋឱ្យស្របតាមកាលៈទេសៈ និងការអភិវឌ្ឍ តាមតម្រូវការជាក់ស្តែង។ ហើយដើម្បីគ្រប់គ្រងដីទាំងនេះបាន រដ្ឋត្រូវមានផែនទីនិងប្រព័ន្ធទិន្នន័យក្នុងការកំណត់ទីតាំង ធ្វើអត្តសញ្ញាណកម្ម និងធ្វើចំណាត់ថ្នាក់ដីទាំងនោះ ជាដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ។ ម្យ៉ាងវិញទៀត ដីទាំងពីរប្រភេទនេះតម្រូវឱ្យធ្វើការចុះបញ្ជីផងដែរ ដែលដំណើរការនៃការចុះបញ្ជីអាចធ្វើឡើងតាមរយៈការចុះបញ្ជីដីដែលមានលក្ខណៈជាប្រព័ន្ធ ឬការចុះបញ្ជីដីដែលមានលក្ខណៈដាច់ដោយដុំដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។[67] តែមុននឹងឈានដល់ដំណើរការនៃការចុះបញ្ជីដីរដ្ឋបាន យើងនឹងសិក្សាទៅលើលក្ខខណ្ឌនៃការចុះបញ្ជីដីរដ្ឋ តាមរយៈការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ[68] ជាមុនសិន។

#### ខណ្ឌទី១៖ ការធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋ

ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ គឺជាដំណើរការដែលមានតម្លាភាព ដោយតម្រូវឱ្យមានការសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការកំណត់ទីតាំងព្រំប្រទល់ដីរដ្ឋ និងកត់ត្រានូវរាល់ការតវ៉ាផ្សេងៗ

[64] សន្ធានុក្រមច្បាប់ស្តីពីការគ្រប់គ្រង និងប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ២០២០។

[65] សន្ធានុក្រមច្បាប់ស្តីពីការគ្រប់គ្រងប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ២០២០, **ទ្រព្យនិទាយាទ** សំដៅដល់ទ្រព្យដែលគ្មានទាយាទស្នងមត៌ក។

[66] សន្ធានុក្រមច្បាប់ស្តីពីការគ្រប់គ្រងប្រើប្រាស់ និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ២០២០, **អនុប្បយោគ** សំដៅទៅដល់ការផ្លាស់ប្តូរប្រភេទទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

[67] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១៤។

[68] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១។

របស់សាធារណៈជន និងអាជ្ញាធរដែលមានអាណត្តិកាន់កាប់ដីរដ្ឋ។[69] តាមរយៈនេះមានន័យថា ត្រូវធ្វើការសម្របសម្រួលជាមួយប្រជាពលរដ្ឋ អាជ្ញាធរកាន់កាប់ដីរដ្ឋ និងរកការឯកភាពពីភាគីពាក់ព័ន្ធជាមុនសិនទើបអាចឈានដល់ការកំណត់ និងបែងចែកដីរដ្ឋដែលស្ថិតក្រោមការកាន់កាប់របស់អាជ្ញាធរមានសមត្ថកិច្ចណាមួយបាន។ ហើយអ្នកដែលប្រតិបត្តិការនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋនោះ គឺក្រុមការងារគ្រប់គ្រងដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងត្រូវធ្វើកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយត្រូវប្រមូលរាល់ការអះអាងទាំងអស់ដែលទាក់ទងនឹងទីតាំង និងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋ ព័ត៌មានដែលបញ្ជាក់អំពីប្រភេទនៃដីរដ្ឋ ព័ត៌មានអំពីប្រភេទប្រើប្រាស់ដីនិងតំបន់ប្រើប្រាស់ដី និងអាណត្តិកាន់កាប់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយកិច្ចប្រតិបត្តិការនេះស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។[70] ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ នឹងអនុវត្តតាមនីតិវិធីដូចខាងក្រោម៖[71]

- ប្រមូលព័ត៌មានទាក់ទងនិងដីរដ្ឋនៅក្នុងឃុំ សង្កាត់ ពីសមាជិកក្រុមការងាររបស់ខ្លួន និងពីតំណាងក្រសួង ស្ថាប័ន មេភូមិ និងមេឃុំ ចៅសង្កាត់ដែលពាក់ព័ន្ធនៅក្នុងក្រុង ស្រុក ខណ្ឌ។
- ស្វែងរកការឯកភាពមតិគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ដែលមានការពាក់ព័ន្ធ។ ករណីមិនអាចសម្រេចបានការឯកភាព ត្រូវបញ្ជាក់អំពីការអះអាងដែលមិនស្របទាំងឡាយនៅក្នុងរបាយការណ៍ការងារដែលត្រូវដាក់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។
- ធ្វើការបិទផ្សាយជាសាធារណៈរយៈពេល១៥ថ្ងៃ នូវសេចក្តីសង្ខេបអំពីការអះអាងអំពីផែនទីបង្ហាញពីការអះអាង និងសេចក្តីពន្យល់ច្បាស់លាស់អំពីគោលបំណងនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋសម្រាប់ឱ្យសាធារណៈជនអាចចូលរួមផ្តល់មតិយោបល់ និងធ្វើការសង្ខេប និងបញ្ចូលមតិយោបល់សាធារណៈដែលទទួលបានទៅក្នុងរបាយការណ៍ការងាររបស់ខ្លួន ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានីខេត្ត។
- រៀបចំរបាយការណ៍ការងារជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដោយមានបញ្ចូលព័ត៌មានដូចជា ទីតាំងនិងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋ ព័ត៌មានដែលបញ្ជាក់អំពីប្រភេទដីរដ្ឋ និងព័ត៌មានអំពីប្រភេទប្រើប្រាស់ដីនិងតំបន់ប្រើប្រាស់ដីប្រសិនបើមាន និងផែនទីបង្ហាញពីការអះអាងរបស់តំណាងក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ព្រមទាំងសេចក្តីសង្ខេបអំពីមតិសាធារណៈ។

---

[69] សៀវភៅសដីធ្លី, ទំព័រ៣០។

[70] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១១។

[71] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១២។

នៅពេលដែលទទួលបានរបាយការណ៍ពីក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ រួចមក គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត នឹងធ្វើការពិនិត្យ ហើយបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋរួមមាន៖[72]

- **ក្នុងករណីមានការឯកភាពមតិគ្នា**លើលទ្ធផលនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ រវាងក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានីខេត្ត ត្រូវបញ្ចូលព័ត៌មានអំពីការឯកភាពនេះទៅក្នុងប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋ។
- **ក្នុងករណីមានការអះអាងមិនស្របគ្នា**រវាងក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងធ្វើការស៊ើបអង្កេតលើការអះអាងទាំងនោះ និងត្រូវពិចារណាលើយោបល់សាធារណៈដែលបានសង្ខេបបញ្ចូលនៅក្នុងរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងត្រូវស្វែងរកការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ដែលមានការពាក់ព័ន្ធ។ ហើយបើក្នុងករណីគណៈកម្មាធិការគ្រប់គ្រងការងារដីរដ្ឋថ្នាក់រាជធានីខេត្ត នៅតែមិនអាចស្វែងរកការឯកភាពគ្នាលើការអះអាងដែលមិនស្រប លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ រួមទាំងព័ត៌មានអំពីការអះអាងដែលមិនស្របគ្នានោះ ត្រូវបញ្ចូលទៅក្នុងទិន្នន័យនិងផែនទីដីរដ្ឋដោយបញ្ជាក់ថាមិនទាន់មានការឯកភាពគ្នា។ ក្នុងករណីនេះ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលអះអាងថាក្បាលដីណាមួយស្ថិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួន មានកាតព្វកិច្ចប្រគល់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវរាល់ព័ត៌មាន និងឯកសារចាំបាច់ដើម្បីគាំទ្រនូវអំណះអំណាងរបស់ខ្លួន។[73]

### ខ. វាក្យខណ្ឌទី២៖ ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

តាមរយៈច្បាប់ភូមិបាល២០០១ដីរដ្ឋមានពីរប្រភេទគឺដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។ ប៉ុន្តែដើម្បីអាចចាត់ថ្នាក់ថាចូលប្រភេទណាមួយបាននោះគេត្រូវធ្វើចំណាត់ថ្នាក់លើដីនោះជាមុនសិន។ ដែលការធ្វើចំណាត់ថ្នាក់ដីរដ្ឋ សំដៅដល់ការកំណត់នូវលក្ខណៈដីរបស់រដ្ឋទៅតាមចំណាត់ថ្នាក់នៃដីដោយផ្អែកលើគោលដៅនៃការប្រើប្រាស់ដី។ ចំពោះដីដែលមិនបម្រើគោលដៅសាធារណៈជាក់លាក់ទេ នឹងត្រូវបានធ្វើចំណាត់ថ្នាក់ជាដីឯកជនរបស់រដ្ឋ ប៉ុន្តែដីឯកជនរបស់រដ្ឋ ក៏អាចធ្វើចំណាត់ថ្នាក់ឡើងវិញ មកជាដីសាធារណៈរបស់រដ្ឋនៅពេលដែលដីនោះមានតម្រូវការនៃការបម្រើផលប្រយោជន៍សាធារណៈ ឬការផ្តល់សេវាសាធារណៈ ដោយផ្អែកតាមអនុក្រឹត្យស្តីពីអធិប្បាយោគផងដែរ។[74] ដោយឡែកចំពោះដីសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផល

---

[72] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១៣។

[73] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា២៣។

[74] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ២០២០, មាត្រា២៩។

ប្រយោជន៍សាធារណៈ អាចត្រូវចាត់ថ្នាក់បញ្ចូលជាដីឯកជនរបស់រដ្ឋ តាមរយៈអនុក្រឹត្យស្ដីពីអនុប្បយោគបានវិញផងដែរ។[75] ម្យ៉ាងវិញទៀត ចំពោះការធ្វើចំណាត់ថ្នាក់ដីរដ្ឋ គឺដើម្បីធ្វើការបែងចែកដីរដ្ឋឱ្យបានច្បាស់លាស់រវាងដីសាធារណៈរបស់រដ្ឋ ឬដីសាធារណៈរបស់នីតិបុគ្គលសាធារណៈ ឬដីឯកជនរបស់រដ្ឋ ដើម្បីឱ្យអាជ្ញាធរកាន់កាប់ដីរដ្ឋដែលនៅមានអាណត្តិកាន់កាប់ អាចកំណត់ដីនោះជាទ្រព្យសម្បត្តិរដ្ឋ និង ត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋបាន និងងាយស្រួលក្នុងការយកដីនោះ មកធ្វើការអភិវឌ្ឍឱ្យស្របតាមតម្រូវការចាំបាច់នៃសង្គម។[76] លើសពីនេះអ្នកដែលមានសមត្ថកិច្ចក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ គឺជាគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដែលនឹងត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖[77]

- ពិនិត្យរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានរួមបញ្ចូលទាំងមតិយោបល់សាធារណៈ ក្នុងករណីបានធ្វើអត្តសញ្ញាណកម្មនិងបានធ្វើផែនទីដីរដ្ឋរួចហើយ ឬធ្វើការស៊ើបអង្កេតរាល់ការអះអាងដែលមិនស្របគ្នារបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់ឱកាសដល់សាធារណៈជនចូលរួមមតិលើការធ្វើចំណាត់ថ្នាក់នេះ ក្នុងករណីមិនទាន់បានធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋ។
- លើកយោបល់សុំការសម្រេចពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីប្រភេទដីនោះដោយបង្ហាញអំពីមូលដ្ឋានគតិយុត្តនៃការធ្វើចំណាត់ថ្នាក់នោះ។

<u>**កំណត់សម្គាល់៖**</u> ក្នុងករណីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនអាចសម្រេចអំពីលទ្ធផលនៃការធ្វើចំណាត់ថ្នាក់ថាដីរដ្ឋនៅក្នុងទីតាំងនោះចូលក្នុងប្រភេទណាមួយបាន ក្រសួងអាចស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

### កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីដីរដ្ឋ

ក្រោយពីបានសិក្សាអំពីសញ្ញាណខ្លះៗ អំពីលក្ខខណ្ឌនៃការចុះបញ្ជីដីរដ្ឋរួចមក យើងនឹងធ្វើការសិក្សាបន្ថែមទាក់ទងទៅនឹងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋវិញម្តង ដែលដំណើរការនៃការចុះបញ្ជីដីរដ្ឋចែកជាពីរធំៗគឺ នីតិវិធីនៃការចុះបញ្ជីដីរដ្ឋតាមលក្ខណៈទូទៅ(**វាក្យខណ្ឌទី១**) និង នីតិវិធីនៃការចុះបញ្ជីដីរដ្ឋតាមលក្ខណៈពិសេស (**វាក្យខណ្ឌទី២**)។

---

[75] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ២០២០, មាត្រា២៧។

[76] ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ២០២០, មាត្រា១៧។

[77] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១៩។

**ខាក្យខណ្ឌទី១៖ នីតិវិធីនៃការចុះបញ្ជីដីរដ្ឋតាមលក្ខណៈទូទៅ**

នៅក្នុងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋតាមលក្ខណៈទូទៅចែកចេញជាពីរទៀតរួមមាន ការចុះបញ្ជីដីរដ្ឋតាមលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីរដ្ឋតាមលក្ខណៈដាច់ដោយដុំ។[78]

**ក. នីតិវិធីចុះបញ្ជីដីរដ្ឋតាមលក្ខណៈជាប្រព័ន្ធ**

នៅក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដីរដ្ឋនៅក្នុងតំបន់វិនិច្ឆ័យត្រូវបានកំណត់ព្រំប្រទល់ ហើយដីនោះត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីថាជាដីរដ្ឋ នឹងត្រូវអនុវត្តតាម ៥ដំណាក់កាលរួមមាន ដំណាក់កាលត្រៀមរៀបចំ ដំណាក់កាលប្រតិបត្តិការបច្ចេកទេស ដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដំណាក់កាលសម្រេចលើឯកសារនៃការវិនិច្ឆ័យ និងដំណាក់កាលចេញប័ណ្ណ។

**១. ដំណាក់កាលត្រៀមរៀបចំ**

ក្នុងដំណាក់កាលនេះ នៅពេលដែលអភិបាលខេត្ត ទទួលបានការឯកភាពគ្នាជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីទីតាំងនិងព្រំប្រទល់នៃតំបន់វិនិច្ឆ័យដើម្បីធ្វើការចុះបញ្ជីរួចហើយ អភិបាលខេត្ត នឹងចេញសេចក្តីប្រកាសអំពីតំបន់វិនិច្ឆ័យ ដែលប្រកាសនេះធ្វើឡើងតាមរបៀបបង្ហាញផែនទី ឬអាចតាមការពិពណ៌នា ឬតាមរបៀបទាំងពីរ ដើម្បីឱ្យអ្នកមានក្បាលដីនៅក្នុងតំបន់វិនិច្ឆ័យទាំងអស់ ត្រៀមខ្លួនចូលរួមសហការជាមួយមន្ត្រីជំនាញសុរិយោដីក្នុងដំណើរការចុះបញ្ជីដីបានរលូន។[79] ក្រោយពេលដែលតំបន់វិនិច្ឆ័យត្រូវបានប្រកាសរួចហើយ គណៈកម្មការរដ្ឋបាលនឹងត្រូវបានតែងតាំង ដោយអភិបាលខេត្តនៃតំបន់វិនិច្ឆ័យ ដើម្បីមកធ្វើការគ្រប់គ្រងតំបន់វិនិច្ឆ័យ និងដឹកនាំមន្ត្រីជំនាញដើម្បីធ្វើការចុះបញ្ជីដីនៅក្នុងតំបន់វិនិច្ឆ័យ។[80] លុះដល់ថ្ងៃកំណត់ដូចដែលបានប្រកាស កិច្ចប្រជុំផ្សព្វផ្សាយនៅក្នុងតំបន់វិនិច្ឆ័យ នឹងត្រូវបានប្រព្រឹត្តឡើងនៅទីកន្លែងណាមួយក្នុងតំបន់វិនិច្ឆ័យ ដើម្បីធ្វើការផ្សព្វផ្សាយនិងណែនាំដល់អ្នកកាន់កាប់ដីនិងជនដែលមានការពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់វិនិច្ឆ័យ ដែលរួមមានដូចជា ប្រជាពលរដ្ឋដែលមានក្បាលដីដែលមិនទាន់ចុះបញ្ជី ឬបានចុះបញ្ជីហើយតែចង់ផ្ទៀងផ្ទាត់ទិន្នន័យក្បាលដី និងតំណាងអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋជាដើម[81] ដែលបានកាន់កាប់និងប្រើប្រាស់លើដីរដ្ឋដែលមិនទាន់បានចុះបញ្ជី ឱ្យបានដឹងនឹងត្រៀមខ្លួនជាមុន ទាំងការរៀបចំឯកសារ និងធ្វើការបោះបង្គោលព្រំដីឱ្យបានច្បាស់លាស់ ដែលវានឹងផ្តល់ភាពងាយស្រួលដល់មន្ត្រីជំនាញ

---

[78] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១៤។

[79] សារាចរណែនាំ អនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ០០១ ដនស/សដ, ១៩ សីហា ២០០២, ដំណាក់កាលទី១ ចំណុច១, ទំព័រ១(តទៅហៅថា សារាចរណែនាំលេខ០០១ ឆ្នាំ២០០២)។

[80] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី១ ចំណុច២, ទំព័រ១។

[81] អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិនិងនីតិបុគ្គលសាធារណៈដទៃទៀត ដែលកាន់កាប់និងប្រើប្រាស់ដីរដ្ឋ, សន្ធានុក្រម ច្បាប់ស្តីពីការគ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ២០២០។

ក្នុងការប្រតិបត្តិការបច្ចេកទេស។[82] ហើយចំពោះឯកសារដែលអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវត្រៀម មានដូចខាងក្រោម៖[83]

- សេចក្តីសម្រេចតែងតាំងតំណាងនីតិបុគ្គល ថតចម្លងតាមច្បាប់ដើម (៣ច្បាប់)
- លិខិតប្រគល់សិទ្ធិតំណាងនីតិបុគ្គលឈរឈ្មោះក្នុងការចុះបញ្ជីដីរដ្ឋ (៣ច្បាប់)
- អត្តសញ្ញាណសញ្ជាតិខ្មែរត្រូវបញ្ជាក់ថតចម្លងតាមច្បាប់ដើម (៣ច្បាប់)
- លិខិតបញ្ជាក់ពីសាវតាដី (៣ច្បាប់)
- បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ឯកសារពាក់ព័ន្ធផ្សេងៗ។

ដោយឡែកឯកសារដែលប្រជាពលរដ្ឋត្រូវត្រៀមក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ សូមមើលក្នុងផ្នែកទី២ កថាខណ្ឌទី២ ចំណុច ១. ដំណាក់កាល ត្រៀមរៀបចំ។

### ២. ដំណាក់កាលប្រតិបត្តិការបច្ចេកទេស

- **ការងារវាល**

ការងារវាលនេះត្រូវបានអនុវត្តនៅក្នុងតំបន់វិនិច្ឆ័យដោយមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យ ហើយមន្ត្រីជំនាញទាំងបីផ្នែកនេះត្រូវស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់មន្ត្រីគ្រប់គ្រងតំបន់វិនិច្ឆ័យ ដើម្បីធ្វើការចុះទៅកំណត់ព្រំ និងវាស់វែងផ្ទាល់ជូនក្បាលដីរបស់ប្រជាពលរដ្ឋ និងក្បាលដីរបស់អាជ្ញាធរកាន់កាប់ទ្រព្យរដ្ឋ ដែលមានអាណត្តិកាន់កាប់និងប្រើប្រាស់ដីរដ្ឋ ស្របពេលជាមួយគ្នា។[84] នៅពេលកំណត់ព្រំនិងវាស់វែង បើក្នុងករណីដីរដ្ឋណាដែលបានធ្វើចំណាត់ថ្នាក់ថាជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ហើយនឹងបានកំណត់អត្តសញ្ញាណកម្មនិងផែនទៅដីរដ្ឋរួចដោយគ្មានការអះអាងផ្ទុយណាមួយរបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនស្របគ្នាទេ នោះមន្ត្រីកំណត់ព្រំ និងមន្ត្រីវាស់វែង ធ្វើការកំណត់ព្រំនិងវាស់វែងយោងតាមអត្តសញ្ញាណនិងផែនទីដីរដ្ឋដែលមានស្រាប់។ ដោយឡែកចំពោះករណីដីនោះមិនទាន់មានការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ ប៉ុន្តែមានព័ត៌មានដែលអាចឱ្យធ្វើការសន្និដ្ឋានបានអំពីប្រភេទដី និងប្រភេទប្រើប្រាស់ដីបច្ចុប្បន្ននោះ ហើយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងឡាយក៏មានការឯកភាពមតិគ្នាលើប្រភេទដីនោះជាដីសាធារណៈ ឬជាដីឯកជនរបស់រដ្ឋឬរបស់

[82] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី១ ចំណុច៦, ទំព័រ២។

[83] លិខិតរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ, ស្តីពីការគ្រប់គ្រងដីរដ្ឋក្នុងអាណត្តិដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវចុះបញ្ជីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ(កម្មសិទ្ធិលើដីរដ្ឋ) ក្នុងខេត្តបន្ទាយមានជ័យ,លេខ ៤៨៩៩/២២ដនសស-បជ/សដក, ១៥ កក្កដា ២០២២។

[84] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី២ ចំណុច១, ទំព័រ៣។

នីតិបុគ្គលសាធារណៈដទៃទៀត នោះមន្ត្រីជំនាញទាំងបីផ្នែកនិងធ្វើការកំណត់ វាស់វែង និងវិនិច្ឆ័យក្បាលដីនោះដោយយោងតាមការឯកភាពគ្នា និងការបញ្ជាក់អំពីព្រំប្រទល់ដីជាមួយម្ចាស់ដែលមានក្បាលដីនៅជាប់គ្នា។[85] បន្ទាប់មកទៀតមន្ត្រីវិនិច្ឆ័យនិងធ្វើការប្រមូលឯកសារ ភស្តុតាង និងព័ត៌មានទាក់ទងនឹងសិទ្ធិលើក្បាលដីនីមួយៗក្នុងតំបន់វិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកកាន់កាប់ដីឬអ្នកតំណាងក្បាលដីរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋផ្តិតមេដៃ ហើយមន្ត្រីវិនិច្ឆ័យត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ ហើយប្រសិនបើករណីមានវិវាទកើតឡើង ទាក់ទងនឹងព្រំប្រទល់ក្តី ទាក់ទងនឹងសិទ្ធិលើក្បាលដីក្តី មន្ត្រីវិនិច្ឆ័យត្រូវកត់ត្រាក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីថា ដីមានទំនាស់។[86]

- **ការងារការិយាល័យ**

ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីដែលប្រមូលបានពីការងារវាល នឹងត្រូវបញ្ចូលក្នុងកុំព្យូទ័រដើម្បីកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី។[87]

### ៣. ដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ

ក្រោយពីដំណើរការនៃការបញ្ចូលទិន្នន័យនៃការវិនិច្ឆ័យចូលក្នុងកុំព្យូទ័រ ដើម្បីរៀបចំឯកសាររួចរាល់ហើយ គណៈកម្មការរដ្ឋបាលនឹងលើកសំណើទៅអភិបាលខេត្ត ក្រុង ដើម្បីបិទផ្សាយជាសាធារណៈនូវឯកសារវិនិច្ឆ័យនោះដែលរួមមានប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី បញ្ជីឈ្មោះក្បាលដីរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងរយៈពេល ១៥ថ្ងៃ នៅកន្លែងដែលងាយមើលឃើញសម្រាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់វិនិច្ឆ័យ។[88] លើសពីនេះនៅក្នុងរយៈពេលបិទផ្សាយ ភាគីទាំងអស់ដែលពាក់ព័ន្ធ អាចធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលបានបិទផ្សាយដើម្បីឱ្យប្រាកដថាមានភាពត្រឹមត្រូវ ប៉ុន្តែក្នុងករណីទិន្នន័យនោះមិនត្រឹមត្រូវ ឬមានអ្នកជំទាស់តវ៉ាទិន្នន័យដែលបានបិទផ្សាយ នោះគាត់អាចដាក់ពាក្យបណ្តឹងធ្វើការតវ៉ាទៅគណៈកម្មការរដ្ឋបាលបាន ដើម្បីធ្វើការព្យាយាមដោះស្រាយដោយការផ្សះផ្សាវិវាទនោះ បើនៅតែមិនមានការព្រមព្រៀងគ្នាទេ ត្រូវបញ្ជូនសំណុំរឿងវិវាទនោះទៅគណៈកម្មការសុរិយោដីដើម្បីដោះស្រាយបន្ត។[89] ផុតរយៈពេលដែលបានបិទផ្សាយជាសាធារណៈ ក្នុងករណីមិនមានការជំទាស់ ឬតវ៉ា ទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះ

[85] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១៦។

[86] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី២ ចំណុច១.១.៣, ទំព័រ៤ និង៥។

[87] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី២ ចំណុច ២, ទំព័រ៥។

[88] អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦អនក្រ.បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២អនក្រ.បក, ០៩ មិថុនា ២០១៦, មាត្រា១១។

[89] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី៣ កថាខណ្ឌទី៤, ទំព័រ៦។

ត្រូវបានចាត់ទុកថាជាទិន្នន័យសុក្រឹត ដែលអាចយកជាផ្លូវការតាមផ្លូវច្បាប់បាន លើកលែងតែចំពោះករណី ដែលសាមីអ្នកកាន់កាប់ដីឬអចលនវត្ថុមានឯកសារសំអាងច្បាស់លាស់ ហើយបានបង្ហាញអំពីមូលហេតុដែល មិនបានមកធ្វើការជំទាស់ ឬតវ៉ាក្នុងរយៈពេលបិទផ្សាយនោះ សាមីជនអាចដាក់ពាក្យបណ្តឹងទៅគណៈកម្មការ សុរិយោដី ដើម្បីធ្វើការដោះស្រាយតាមនីតិវិធីដែលបានកំណត់។[90] ជាឧទាហរណ៍ គឺអ្នកកាន់កាប់ដីខកខាន ដោយសារតែកំពុងឈឺធ្ងន់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬ ជាប់បំពេញបេសកកម្មនៅក្រៅប្រទេសជា ដើម ដែលហេតុផលទាំងនេះច្បាប់អាចទទួលស្គាល់បាន។

### ៤. ដំណាក់កាលសម្រេចលើឯកសារនៃការវិនិច្ឆ័យ

ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ គណៈកម្មការរដ្ឋបាល ត្រូវចុះហត្ថលេខាយល់ព្រមលើឯកសារនៃការវិនិច្ឆ័យចំពោះក្បាលដីទាំងអស់ និងក្បាលដីក្នុងតំបន់វិនិច្ឆ័យដែល មានទំនាស់តែត្រូវបានសម្រុះសម្រួលរួចមុនរយៈពេលបិទផ្សាយជាសាធារណៈ លើកលែងតែក្បាលដីដែលមាន ទំនាស់និងមិនទាន់ដោះស្រាយដោយការសម្រុះសម្រួលរួច។ បន្ទាប់មកគណៈកម្មការរដ្ឋបាលត្រូវបញ្ជូនឯកសារ នៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខា ហើយបញ្ជូនបន្តទៅអភិបាលខេត្តក្រុងដើម្បីចុះហត្ថលេខា។[91] ក្រោយពីអភិបាលខេត្ត ក្រុង និងរដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានចុះហត្ថលេខាសម្រេចយល់ព្រមរួចរាល់ហើយ នោះ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរនិងត្រូវចាត់ទុកជាឯកសារតាមផ្លូវច្បាប់ ចំពោះតែក្បាលដីដែលមិន ទាក់ទងនិងវិវាទ ហើយឯកសារនោះនឹងត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដីដើម្បីធ្វើការចុះបញ្ជី រីឯចំពោះក្បាលដី ដែលមានវិវាទ ហើយមិនទាន់ដោះស្រាយចប់ជាស្ថាពរ នឹងត្រូវបានបន្តការដោះស្រាយនៅគណៈកម្មការ សុរិយោដី ឬនៅតុលាការ។[92]

### ៥. ដំណាក់កាលចេញប័ណ្ណ

នៅពេលដែលនីតិវិធីនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរ ឯកសារនៃការវិនិច្ឆ័យ និង ឯកសារណាប ពាក់ព័ន្ធទាំងអស់ត្រូវបានបញ្ជូនទៅរដ្ឋបាលសុរិយោដីដើម្បីបញ្ចូលទៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។ ក្រោយពី ក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យត្រូវបានចុះបញ្ជីរួចហើយនោះ វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុនឹងត្រូវធ្វើនៅក្នុងពិធីប្រគល់ជាសាធារណៈ ជូនដល់ម្ចាស់អចលនវត្ថុ ដែលជាអាជ្ញាធរមានអាណត្តិកាន់កាប់ដីរដ្ឋនិងជាអ្នកតំណាងឱ្យរដ្ឋក្នុងការចុះបញ្ជី។

---

[90] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី៣ កថាខណ្ឌទី៥, ទំព័រ៧។

[91] អនុក្រឹត្យ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦ អនក្រ.បក, ៣១ ឧសភា២០០២, មាត្រា១៣ (តទៅហៅថា អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២)។

[92] អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា១៤។

### ខ. ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ

នៅក្នុងដំណើរការនៃការចុះបញ្ជី ដីរដ្ឋក៏អាចក្លាយជាកម្មវត្ថុនៃការចុះបញ្ជីដីតាមលក្ខណៈដាច់ដោយដុំផងដែរ ផ្អែកតាមអនុក្រឹត្យលេខ៤៨អនក្រ.បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំមាន ៥ ដំណាក់កាលត្រូវអនុវត្តដែលមានដូចជា ដំណាក់កាលដាក់ពាក្យសុំ ដំណាក់កាលកិច្ចការបច្ចេកទេស ដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដំណាក់កាលការសម្រេចលើឯកសារ និងដំណាក់កាលចេញប័ណ្ណ។

#### ១. ដំណាក់កាលដាក់ពាក្យស្នើសុំចុះបញ្ជី

នៅក្នុងដំណាក់កាលនេះអាជ្ញាធរដែលទទួលបានអាណត្តិកាន់កាប់ដីរដ្ឋដែលមានបំណងស្នើសុំចុះបញ្ជីក្បាលដីរបស់រដ្ឋនៅក្នុងតំបន់របស់ខ្លួន ត្រូវបំពេញពាក្យសុំតាមគម្រូដែលបានរៀបចំ និងដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង តាមរយៈមេឃុំ ចៅសង្កាត់ ដែលក្បាលដីរបស់រដ្ឋនោះស្ថិតនៅ។ ពាក្យស្នើសុំសម្រាប់ការចុះបញ្ជីដីរដ្ឋតាមលក្ខណៈដាចដោយដុំមានដូចជា៖[93]

- សេចក្តីសម្រេចតែងតាំងតំណាងនីតិបុគ្គល ថតចម្លងតាមច្បាប់ដើម (៣ច្បាប់)
- លិខិតប្រគល់សិទ្ធិតំណាងនីតិបុគ្គលឈរឈ្មោះក្នុងការចុះបញ្ជីដីរដ្ឋ (៣ច្បាប់)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរត្រូវបញ្ជាក់ថតចម្លងតាមច្បាប់ដើម (៣ច្បាប់)
- លិខិតបញ្ជាក់ពីសាវតាដី (៣ច្បាប់)
- ឯកសារពាក់ព័ន្ធផ្សេងៗ។

បន្ទាប់ពីបានបំពេញឯកសារគ្រប់គ្រាន់ហើយ នៅពេលទទួលពាក្យស្នើសុំរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យមើលលើពាក្យសុំនោះដោយផ្អែកទៅលើគោលការណ៍ជំនាញ និងច្បាប់។[94] នៅក្នុងករណីដែលពិនិត្យទៅឃើញថាពាក្យសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវកត់ត្រាពាក្យស្នើសុំទាំងនោះចូលក្នុងសៀវភៅទទួលពាក្យចុះលេខ រួចចារលើពាក្យស្នើសុំនោះ កំណត់កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវចុះអនុវត្ត កំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ហើយត្រូវប្រគល់ពាក្យមួយច្បាប់ជូនតំណាងអាជ្ញាធរកាន់កាប់ដីរដ្ឋដែលបានដាក់ពាក្យស្នើសុំវិញ។[95] បន្ទាប់មករដ្ឋបាលសុរិយោដីត្រូវចេញសេចក្តីជូនដំណឹងអំពីកាលបរិច្ឆេទនៃការចុះកំណត់ព្រំដី ដល់អ្នកដាក់ពាក្យសុំ និងត្រូវបិទផ្សាយជាសាធារណៈឱ្យបាន

---

[93] អនុក្រឹត្យ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨ អនក្រ.បក, ៣១ ឧសភា ២០០២, មាត្រា៧ (តទៅហៅថា អនុក្រឹត្យលេខ៤៨ ឆ្នាំ២០០២)។

[94] សារាចរណែនាំ ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ១៤ ដនស/សរណន, ៣០ កញ្ញា ២០០៩ ដំណាក់កាលទី១, (តទៅហៅថា សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩)។

[95] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី១។

យ៉ាងតិចរយៈពេល ៧ថ្ងៃ[96] នៅក្នុងសាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់ និងនៅកន្លែងដែលងាយមើលឃើញក្នុងទីតាំងដែលក្បាលដីរដ្ឋនោះស្ថិតនៅ។

### ២. ដំណាក់កាលកិច្ចការបច្ចេកទេស

នៅក្នុងដំណាក់កាលកិច្ចការបច្ចេកទេសត្រូវបានបែងចែកជាពីរផ្សេងទៀត ការងារវាល និងការងារនៅការិយាល័យខាងក្រោមនេះគឺជាការបកស្រាយលម្អិតលើចំណុចទាំងពីរនេះ។

- **ការងារវាល**

នៅក្នុងការងារវាលមន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងវាស់វែងត្រូវកំណត់ព្រំក្បាលដីដែលស្នើសុំចុះបញ្ជីតាមពេលវេលាដែលបានជូនដំណឹង ស្របតាមសេចក្តីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំរបស់រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ។ ការងារវាលត្រូវអនុវត្តដោយមន្ត្រីជំនាញដោយមានការសហការ និងជ្រោមជ្រែងពីអាជ្ញាធរនៅមូលដ្ឋាន។ មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវចុះប្រតិបត្តិការទៅតាមពេលវេលាកំណត់ និងត្រូវតែគោរពតាមគោលការណ៍ច្បាប់។[97] ហើយនៅក្នុងការអនុវត្តនូវការងារវាលនេះផងដែរមន្ត្រីសុរិយោដីមានសិទ្ធិចេញចូលបរិវេណដីដោយសេរីដើម្បីកំណត់ និងវាស់វែងហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬបង្ហាញឯកសារភស្តុតាងជាអាទិ៍ដែលទាក់ទងនឹងព្រំដី ហើយអ្នកកាន់កាប់ដីត្រូវមានកាតព្វកិច្ចចូលរួមនៅក្នុងនីតិវិធីនេះផងដែរ។

បន្ទាប់មកមន្ត្រីដែលបានចាត់តាំងឱ្យទទួលបន្ទុកការងារវាល មានភារកិច្ចទទួលខុសត្រូវលើការងារបំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យដើម្បីធ្វើការវិនិច្ឆ័យឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងគោលការណ៍ច្បាប់ ដែលឯកសារនៃការវិនិច្ឆ័យរួមមាន៖

- ទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវតែបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី កម្មសិទ្ធិករ ឬភោគី កាលបរិច្ឆេទនៃការកាន់កាប់ដី កាលបរិច្ឆេទនៃការកំណត់ព្រំដីការវាស់វែង និងការវិនិច្ឆ័យ រាល់សិទ្ធិ និងបន្ទុកដែលមានលើក្បាលដីដូចមានចែងក្នុងច្បាប់ភូមិបាល។
- ផែនទីក្បាលដី និងគំនូសបង្ហាញទីតាំងដី ត្រូវបង្ហាញអំពីអត្តសញ្ញាណនៃក្បាលដី រួមមាន លេខក្បាលដី រូបរាងក្បាលដី លេខក្បាលដី ឬ/និងឈ្មោះម្ចាស់ក្បាលដីជាប់ព្រំ។
- បញ្ជីឈ្មោះម្ចាស់ក្បាលដីដែលស្នើសុំចុះបញ្ជី បង្ហាញអំពីឈ្មោះសារពើ ប្រភេទទ្រព្យរបស់កម្មសិទ្ធិករ ឬភាគីនៃក្បាលដី ប្រភព និងកាលបរិច្ឆេទនៃការកាន់កាប់ ទំហំ និងរូបភាពប្រើប្រាស់ដី។

[96] អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ៣១ ឧសភា ២០០២, ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា៩ថ្មី។
[97]សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី២ ចំណុច១, កថាខណ្ឌទី១។

- **ការងារការិយាល័យ**

បន្ទាប់ពីការងារវាលត្រូវបានបញ្ចប់ ចំពោះទិន្នន័យដែលប្រមូលបានមកពីការងារវាលរដ្ឋបាលសុរិយោដី ត្រូវកសាងផែនទីក្បាលដី ផែនទីបង្ហាញទីតាំងដី ស្នើសុំផែនទីមានលក្ខណៈដាច់ដោយដុំ កសាងបញ្ជីឈ្មោះម្ចាស់ដីហើយបញ្ចូលទិន្នន័យទាំងអស់នោះទៅក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ។[98] ការបញ្ចូលទិន្នន័យអាចធ្វើបានតាមវិធីពីរគឺ ការបញ្ចូលក្នុងកុំព្យូទ័រចំពោះក្បាលដីទាំងឡាយណាដែលបានធ្វើឡើងដោយឧបករណ៍ទំនើប (រាល់ចំណុចជ្រុងនៃក្បាលដីនីមួយៗត្រូវកំណត់ដោយនិយាមកា)។ ហើយមួយវិញទៀតអាចគូរផែនទីក្បាលដី គូរគំនូរបង្ហាញទីតាំងដីស្នើសុំ ចំពោះក្បាលដីទាំងឡាយណាដែលធ្វើឡើងដោយឧបករណ៍សាមញ្ញ (មិនអាចបង្កើតនិយាមកា តាមចំណុចជ្រុងនៃក្បាលដីនីមួយៗបាន)។[99]

### ៣. ដំណាក់កាលបិទផ្សាយជាសាធារណៈនៅឯកសារនៃការវិនិច្ឆ័យ

ក្រោយពីបានពិនិត្យភាពច្បាស់លាស់ខាងបច្ចេកទេសរួចមក រដ្ឋបាលសុរិយោដី ក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។ បន្ទាប់មកអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងដល់សាធារណៈជនអ្នកកាន់កាប់ដីព្រមទាំងតំណាងគ្រប់ក្រសួងស្ថាប័ន មន្ទីរ អង្គភាព គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានការពាក់ព័ន្ធនឹងក្បាលដីក្នុងរយៈពេល ៣ថ្ងៃ[100] ដើម្បីចូលរួមពិនិត្យទិន្នន័យក្នុងឯកសារដែលនឹងបិទផ្សាយដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬខុសឆ្គង ដែលត្រូវកែតម្រូវ ឬជំទាស់តវ៉ា ក្នុងរយៈពេល១៥ថ្ងៃ។[101] ចំពោះឯកសារដែលត្រូវបិទផ្សាយរួមមានដូចជា ផែនទីក្បាលដី គំនូសបង្ហាញក្បាលដី និងឈ្មោះម្ចាស់ដី ដែលត្រូវធ្វើឡើងនៅកន្លែងដែលងាយមើលឃើញ នៅក្នុងភូមិ សាលាឃុំ សាលាស្រុក ខណ្ឌ ក្រុងដែលក្បាលដីរបស់រដ្ឋនោះស្ថិតនៅ។

នៅក្នុងរយៈពេលនៃការបិទផ្សាយ តំណាងអាជ្ញាធរកាន់កាប់ដីរដ្ឋដែលទទួលបានអាណត្តិកាន់កាប់ដីរដ្ឋត្រូវចូលរួមពិនិត្យលើឯកសារនៃការផ្សាយជាសាធារណៈ ក្នុងពេលនេះប្រជាពលរដ្ឋក៏អាចចូលរួមពិនិត្យបានផងដែរ។ ក្នុងករណីទិន្និន័យនោះមិនត្រឹមត្រូវ ឬមានអ្នកជំទាស់តវ៉ានឹងទិន្នន័យដែលបានបិទផ្សាយ នោះគាត់អាចដាក់ពាក្យបណ្ដឹងតវ៉ាទៅអ្នកប្រចាំការនៅទីកន្លែងបិទផ្សាយ រដ្ឋបាលសុរិយោដីត្រូវបើកការស៊ើបអង្កេតលើការតវ៉ានោះហើយត្រូវធ្វើការសម្របសម្រួល ប៉ុន្តែបើមិនអាចធ្វើការសម្របសម្រួលបានទេនោះត្រូវបញ្ជូនសំណុំ

---

[98] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី២, ចំណុច២។

[99] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី២, ចំណុច២។

[100] អនុក្រឹត្យ ស្ដីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ៣១ ឧសភា ២០០២, ស្ដីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា១៣ថ្មី។

[101] អនុក្រឹត្យ ស្ដីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ៣១ ឧសភា ២០០២, ស្ដីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា១៣ថ្មី។

រឿងនោះទៅគណៈកម្មការសុរិយោដីដើម្បីដោះស្រាយបន្ត។[102] ប្រសិនបើក្នុងករណីមិនមានការជំទាស់ ឬការតវ៉ាក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹតដែលអាចកំណត់យកជាផ្លូវការតាមច្បាប់។ ហើយក្រោយផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវបញ្ចូលក្បាលដីរដ្ឋនោះទៅក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ[103]

**៤. ដំណាក់កាលការសម្រេចលើឯកសារ**

បន្ទាប់ពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យត្រូវវាយតម្លៃ ត្រូវលើកសំណើផ្តល់សិទ្ធិលើដី ឬអចលនវត្ថុ ជូនអ្នកកាន់កាប់ដែលបានស្នើសុំ ឬអាជ្ញាធរដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតាមប្រភេទ កម្មសិទ្ធិ ភោគៈ សម្បទាន មិនត្រូវធ្វើការផ្តល់ប័ណ្ណជាលក្ខណៈឯកជន ឬរក្សាទុកជាទ្រព្យរដ្ឋ ដោយយោងតាមច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងឯកសារភស្តុតាងដែលប្រមូលបាន។ ហើយបន្តមកទៀតមន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានទំនាស់ ចូលក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ។

បន្ទាប់មកមន្ត្រីដែលទទួលបន្ទុកការងារវិនិច្ឆ័យក្បាលដីតាមពាក្យស្នើសុំត្រូវរៀបចំសំណុំឯកសារដូចខាងក្រោម ដើម្បីដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ពិនិត្យ និងចុះហត្ថលេខាបញ្ជូនសំណុំរឿងទាំងមូលទៅលោកអភិបាលស្រុក ខណ្ឌ ក្រុង និងពិនិត្យ និងបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត។ ឯកសារដែលត្រូវបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីរាជធានីខេត្តមានដូចជា៖[104]

- ពាក្យស្នើសុំ
- ឯកសារនៃការវិនិច្ឆ័យ (ឯកសារទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែង ទំរង់បែបបទនៃការប្រមូលទិន្នន័យ ផែនទីក្បាលដី)
- សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី
- ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ ឬគំនូសបង្ហាញទីតាំងក្បាលដី
- សេចក្តីជូនដំណឹងពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
- របាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យ
- ពាក្យបណ្តឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន

[102] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី៣, កថាខណ្ឌទី៦។

[103] អនុក្រឹត្យលេខ៤៨ ឆ្នាំ២០០២, មាត្រា១៥។

[104] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី៤, ចំណុច២។

- លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន
- កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន។

**៥. ដំណាក់កាលការចេញប័ណ្ណ**

បន្ទាប់ពីទទួលបានសំណុំរឿងពីរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ត្រូវពិនិត្យ និងផ្តល់យោបល់ជូនអភិបាលរាជធានី ខេត្ត ដើម្បីសំរេចយល់ព្រមឱ្យចេញប័ណ្ណ។[105] រដ្ឋបាលសុរិយោដីរាជធានីខេត្តដែលបានទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាលអាចចេញប័ណ្ណជូនដល់អាជ្ញាធរកាន់កាប់ដីរដ្ឋដែលបានស្នើសុំតែម្តង ប៉ុន្តែសម្រាប់រដ្ឋបាលសុរិយោដីរាជធានីខេត្តណាដែលមិនទាន់បានទទួលប្រតិភូកម្មពីក្រសួងអាណាព្យាបាល ត្រូវបញ្ជូនសំណុំរឿងបន្តមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីពិនិត្យបន្ថែមតាមគោលការណ៍ជំនាញបើឃើញថាត្រឹមត្រូវ នឹងធ្វើការចេញប័ណ្ណជូនអ្នកស្នើសុំ។

**វាក្យខណ្ឌទី២៖ នីតិវិធីពិសេសនៃការចុះបញ្ជីដីរដ្ឋ**

នីតិវិធីពិសេសនៃការចុះបញ្ជីដីរដ្ឋត្រូវបានបង្កើតឡើង ដោយយោងតាមជំពូកទី៧ នៃអនុក្រឹត្យលេខ ៣២១ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ដែលត្រូវបានអនុម័តនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣[106] ដើម្បីបន្ថែមទៅលើការអនុវត្តនៃការចុះបញ្ជីដីរដ្ឋកន្លងមក ដែលធ្វើឡើងតាមរយៈការចុះបញ្ជីដីដែលមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីដែលមានលក្ខណៈដាច់ដោយដុំ។[107] ផ្អែកតាមអនុក្រឹត្យដដែលនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចចាត់ចែងធ្វើការចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស ក្នុងលក្ខខណ្ឌដែលដីរដ្ឋនោះត្រូវបានកំណត់ទំហំ ប្រភេទ ប្រភេទប្រើប្រាស់ដី និងមានព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការចុះបញ្ជីត្រឹមត្រូវរួចហើយ និងតាមរយៈអាជ្ញាធរកាន់កាប់ដីរដ្ឋបានស្នើសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស។[108] តាមរយៈការស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេសនេះ អាជ្ញាធរកាន់កាប់ដីរដ្ឋ ត្រូវផ្តល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវឯកសារដូចខាងក្រោម៖[109]

- លិខិតបទដ្ឋានគតិយុត្តដែលបានកំណត់អាណត្តិកាន់កាប់ដីរដ្ឋ ទំហំដី ប្រភេទដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងព័ត៌មានចាំបាច់ដទៃទៀតសម្រាប់ការចុះបញ្ជីដីរដ្ឋ។
- ផែនទីដីរដ្ឋដែលមានភ្ជាប់តារាងនិយាមកា ទាំងទម្រង់រឹង ទាំងទម្រង់ឌីជីថល។
- របាយការណ៍ស្តីពីការវាស់វែងដោយមន្ត្រីជំនាញនៃអាជ្ញាធរកាន់កាប់ដីរដ្ឋសាមី។

---

[105] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី៥។

[106] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, ជំពូកទី៧។

[107] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា១៤។

[108] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា២៤។

[109] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា២៥។

- របាយការណ៍ស្ដីពីការបោះបង្គោលព្រំដីរដ្ឋ។
- ឯកសារ និងព័ត៌មានចាំបាច់ផ្សេងទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។

បន្ទាប់ពីបានទទួលសំណើពីអាជ្ញាធរកាន់កាប់ដីរដ្ឋស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចអនុវត្តជម្រើសណាមួយដូចខាងក្រោម៖[110]

❖ **ក្នុងករណីព័ត៌មាននិងឯកសារពាក់ព័ន្ធមានលក្ខណៈគ្រប់គ្រាន់**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចាត់តាំងរដ្ឋបាលសុរិយោដីឱ្យធ្វើការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសម្រាប់ដីរដ្ឋនោះ ដោយពុំចាំបាច់អនុវត្តនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំឡើយ។ ក្នុងករណីចាំបាច់ដើម្បីធានាឱ្យមានតម្លាភាពនៃការចុះបញ្ជីដីរដ្ឋ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់អាចសម្រេចឱ្យធ្វើការបិទផ្សាយជាសាធារណៈក្នុងរយៈពេល១៥ថ្ងៃ នូវព័ត៌មាននិងឯកសារទាំងឡាយដែលទទួលបានពីអាជ្ញាធរកាន់កាប់ដីរដ្ឋនោះនៅតាមទីតាំងពាក់ព័ន្ធ មុននឹងការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសម្រាប់ដីរដ្ឋនោះ។ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលបានស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេសមានភារកិច្ចចូលរួមឱ្យបានពេញលេញក្នុងដំណើរការចុះបញ្ជីដីរដ្ឋ ដោយត្រូវផ្ដល់ព័ត៌មាននិងឯកសារជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[111]

❖ **ក្នុងករណីព័ត៌មាននិងឯកសារមិនមានលក្ខណៈគ្រប់គ្រាន់**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចតម្រូវឱ្យអាជ្ញាធរកាន់កាប់ដីរដ្ឋដែលជាម្ចាស់សំណើកំណត់អត្តសញ្ញាណក្បាលដី កសាងផែនទី និងកំណត់និយាមកាដីរដ្ឋនោះឱ្យបានចប់សព្វគ្រប់ រួចផ្ដល់លទ្ធផលត្រឡប់មកវិញមុននឹងការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់អចលនវត្ថុសម្រាប់ដីរដ្ឋនោះតាមនីតិវិធីដូចបានកំណត់ក្នុងចំណុចទីមួយខាងលើ។ បន្ថែមពីនេះ ក្នុងពេលធ្វើការកំណត់អត្តសញ្ញាណ ការកសាងផែនទី ការកសាងប្លង់សុរិយោដីនិង/ឬការកំណត់និយាមកាដីរដ្ឋ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលបានស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធិពិសេសមានភារកិច្ចសម្របសម្រួលស្វែងរកការឯកភាពគ្នាពីគ្រប់ភាគីពាក់ព័ន្ធយ៉ាងច្រើន២លើក ក្នុងរយៈពេលសរុបមិនលើសពី ១៤ថ្ងៃ ករណីផុតរយៈពេលកំណត់នេះ ប្រសិនបើនៅតែមិនអាចស្វែងរកការឯកភាព

[110] អនុក្រឹត្យ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា២៦។

[111] អនុក្រឹត្យ ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា២៧ កថាខណ្ឌទី១។

គ្នាជាស្ថាពរ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលជាម្ចាស់សំណើ ត្រូវបញ្ជូនឯកសំណុំឯកសារទាំងនោះមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យសម្រេច។[112]

## ផ្នែកទី២៖ ការចុះបញ្ជីដីឯកជន

ចាប់តាំងពីមាននូវឯកជនភាវូបនីយកម្មដីធ្លីមក សញ្ញាណនៃកម្មសិទ្ធិឯកជនត្រូវបានកើតមាននៅក្នុងប្រទេសកម្ពុជា ជាពិសេសនោះគឺបន្ទាប់ពីមានការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ១៩៩៣ ដោយរដ្ឋាភិបាលចាប់ផ្តើមដាក់ចេញនូវគោលនយោបាយពាក់ព័ន្ធទៅនឹងដីធ្លីមួយចំនួនដើម្បីអាចឱ្យប្រជាជនអាចទទួលបានកម្មសិទ្ធិលើទ្រព្យតាមរយៈការចុះបញ្ជី។ ហើយតាមរយៈការផ្តល់កម្មសិទ្ធិនេះរដ្ឋបានដាក់ចេញនូវអនុក្រឹត្យចំនួនពីរសម្រាប់បម្រើឱ្យការចុះបញ្ជីដីធ្លីជាកម្មសិទ្ធិឯកជន ដែលមានដូចជាការចុះបញ្ជីជាមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ហើយក៏បានដាក់ឱ្យអនុវត្តនូវទូទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មុននឹងអាចអនុវត្តការចុះបញ្ជីបានលុះត្រាតែកម្មសិទ្ធិករបានបំពេញតាមបែបបទ និងលក្ខខណ្ឌដែលកំណត់ដោយច្បាប់ជាមុនសិនទើបអាចចាប់ផ្តើមនីតិវិធីនៃការចុះបញ្ជីដីរបស់ខ្លួនបាន។ ដូចនេះយើងនឹងធ្វើការសិក្សាទៅលើ ការកំណត់លក្ខណៈនៃដីឯកជន(**កថាខណ្ឌទី១**) បន្ទាប់មកទៀតយើងនឹងពិភាក្សាទៅលើ លក្ខខណ្ឌនៃការចុះបញ្ជីដីឯកជន(**កថាខណ្ឌទី២**) ជាចុងក្រោយយើងនឹងសិក្សាអំពី នីតិវិធីនៃការចុះបញ្ជីដីឯកជន(**កថាខណ្ឌទី៣**)។

### កថាខណ្ឌទី១៖ ការកំណត់លក្ខណៈនៃដីឯកជន

ដីឯកជន សំដៅទៅដល់ដីទាំងឡាយណាដែលកាន់កាប់ដោយបុគ្គលឯកជន ហើយដីទាំងអស់នោះមិនស្ថិតនៅក្នុងប្រភេទណាមួយនៃដីសាធារណៈរបស់រដ្ឋ ឬដីឯកជនរបស់រដ្ឋ ឬរបស់សមូហភាពដទៃទៀត ដែលដីឯកជនមានដូចជា ដីលំនៅឋាន ឬដីសម្រាប់សាងសង់ ដីឡូត៍ ដីស្រែ-ចម្ការ ដីសម្រាប់ដាំដុះ ដីសម្រាប់ប្រកបរបរកសិកកម្ម ដីចញ្ចឹមសត្វ ដីសម្រាប់ធ្វើពាណិជ្ជកម្ម ឬឧស្សាហកម្មជាលក្ខណៈឯកជន និងដីដែលទទួលបានពីរដ្ឋជាអាទិ៍។ តាមរយៈអត្ថន័យខាងលើនេះអាចសង្កេតឃើញថា ដីឯកជនមានភាពខុសគ្នាយ៉ាងខ្លាំងទៅនឹងដីរដ្ឋ និងដីរបស់សមូហភាព ព្រោះថាដីឯកជនជាដីដែលបម្រើផលប្រយោជន៍របស់បុគ្គលឯកជនដែលជាអ្នកមានសិទ្ធិលើដី ហើយមានលក្ខណៈពិសេសត្រង់ថា ពេលដែលដីទាំងនោះបានចុះបញ្ជីរួចរាល់នោះបុគ្គលឯកជននឹងក្លាយទៅជាកម្មសិទ្ធិករស្របតាមច្បាប់។ មិនតែប៉ុណ្ណោះក្នុងនាមជាកម្មសិទ្ធិករច្បាប់បានផ្តល់សិទ្ធផ្តាច់មុខនៅក្នុង ការប្រើប្រាស់ អាស្រ័យផល និងចាត់ចែងលើទ្រព្យរបស់ខ្លួនថែមទៀតផងដែលសិទ្ធិទាំងនេះត្រូវបានទទួលស្គាល់ដោយមាត្រា៤៤ នៃរដ្ឋធម្មនុញ្ញ១៩៩៣ និងមាត្រា៨៥ នៃច្បាប់ភូមិបាល២០០១។ ប៉ុន្តែ

---

[112] អនុក្រឹត្យ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ ២០២៣, មាត្រា២៧ កថាខណ្ឌ២។

ទោះបីជាយ៉ាងណាក៏ដោយមុននឹងអាចក្លាយជាកម្មសិទ្ធិករបានបុគ្គលដែលបានកាន់កាប់ដីត្រូវតែដាក់ពាក្យសុំចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ហើយត្រូវគោរពលក្ខខណ្ឌដូចដែលមាននៅក្នុងកថាខណ្ឌទី២ជាមុនសិនទើបអាចចុះបញ្ជីបាន។

**កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការចុះបញ្ជីដីឯកជន**

នៅក្នុងប្រទេសកម្ពុជា របបកម្មសិទ្ធិឯកជនលើដីធ្លីនឹងត្រូវបានផ្តល់ឱ្យប្រជាពលរដ្ឋយ៉ាងពេញលេញតាមរយៈការចុះបញ្ជីដី ទន្ទឹមនឹងនេះមិនមែនចេះតែផ្តល់ជូននោះទេ គឺទាមទារឱ្យប្រជាពលរដ្ឋដែលអះអាងថាខ្លួនជាម្ចាស់ដី និងបានបំពេញនូវលក្ខខណ្ឌដែលច្បាប់ភូមិបាល២០០១ តម្រូវមួយចំនួនឱ្យបានត្រឹមត្រូវជាមុនសិនទើបអាចធ្វើការដាក់ពាក្យសុំចុះបញ្ជីដីបាន។ ដូចនេះនៅក្នុងការចុះបញ្ជីដីឯកជនតើច្បាប់តម្រូវឱ្យបំពេញនូវលក្ខខណ្ឌអ្វីខ្លះ? តាមរយៈច្បាប់ភូមិបាល២០០១ លក្ខខណ្ឌនៃការចុះបញ្ជីដីឯកជនមានដូចតទៅ ត្រូវមានសញ្ជាតិខ្មែរ (**វាក្យខណ្ឌទី១**) ជាភោគៈស្របច្បាប់(**វាក្យខណ្ឌទី២**) ការកាន់កាប់លើដីចាប់ពី ៥ឆ្នាំឡើងទៅ(**វាក្យខណ្ឌទី៣**) ការកាន់កាប់លើដីឯកជនរបស់រដ្ឋ(**វាក្យខណ្ឌទី៤**) និងចុងក្រោយដីដែល ទទួលតាមរយៈសម្បទានដីសង្គមកិច្ច(**វាក្យខណ្ឌទី៥**)។

**វាក្យខណ្ឌទី១៖ ត្រូវមានសញ្ជាតិខ្មែរ**

យោងតាមរដ្ឋធម្មនុញ្ញ១៩៩៣ មាត្រា៤៤ បានចែងថា *"មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេទើបមានសិទ្ធិជាម្ចាស់ កម្មសិទ្ធិលើដីធ្លី"*[113] រីឯច្បាប់ភូមិបាល២០០១ ក៏បានចែងបន្ថែមត្រង់មាត្រា៨ មានខ្លឹមសារថា *"មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ដែលមានសិទ្ធិជាម្ចាស់លើដីនៃព្រះរាជាណាចក្រកម្ពុជា"។*[114] ជារួមមក ក្រៅពីរូបវ័ន្តបុគ្គល និងនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ មិនអាចទទួលបានកម្មសិទ្ធិលើដីធ្លីនៅក្នុងប្រទេសកម្ពុជានោះទេ។

**ក. រូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ**

រូបវន្តបុគ្គល សំដៅដល់បុគ្គលដែលមានរូបមែនៗ គឺមនុស្សមែនៗ ផ្ទុយនឹងនីតិបុគ្គល ដែលជាមនុស្សដោយសន្មតតាមរបៀបច្បាប់។[115] បន្ថែមពីនេះ យោងតាមមាត្រា៦ កថាខណ្ឌទី១ នៃច្បាប់ស្តីពីសញ្ជាតិបានកំណត់ថា "**ជនណាដែលមានសញ្ជាតិជាខ្មែរ គឺជាប្រជាពលរដ្ឋខ្មែរ**" ។[116] ដូចនេះយើងអាចសំយោគន័យបានថាមានតែប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះ ក្រៅពីនេះជនដែលមិនមានសញ្ជាតិជាខ្មែរ(**សំដៅទៅលើជនបរទេស**) គឺ

[113] រដ្ឋធម្មនុញ្ញ ១៩៩៣, មាត្រា៤៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[114] ច្បាប់ភូមិបាល២០០១, មាត្រា៨ កថាខណ្ឌទី១។

[115] សន្ទានុក្រមច្បាប់ភូមិបាល២០០១។

[116] ច្បាប់ស្តីពីសញ្ជាតិ, លេខនស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨, មាត្រា៦ កថាខណ្ឌ១(តទៅហៅថាច្បាប់ស្តីពីសញ្ជាតិឆ្នាំ២០១៨)។

ពុំអាចទទួលបានកម្មសិទ្ធិលើដីធ្លីក្នុងប្រទេសកម្ពុជាទេ តែបើជននោះទទួលបានសញ្ជាតិខ្មែរតាមនីតិវិធីច្បាប់ស្តីពីសញ្ជាតិ នោះបានន័យថាសិទ្ធិលើដីធ្លីរបស់គាត់នឹងត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ភូមិបាល ២០០១។ លើសពីនេះយោងតាមច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨ ជនម្នាក់ៗអាចទទួលសញ្ជាតិខ្មែរ ប្រសិនបើឪពុក ឬម្តាយរបស់ខ្លួនជាជនជាតិខ្មែរ ឬប្រសិនបើជននេះបានកើតនៅប្រទេសកម្ពុជាស្របតាមលក្ខខណ្ឌជាក់លាក់[117] ឬបន្ទាប់ពីបានរៀបអាពាហ៍ពិពាហ៍ជាមួយជនដែលមានសញ្ជាតិខ្មែរ[118] ឬដោយការសុំកូនពេញលេញ[119] ឬដោយសញ្ជាតូបនីយកម្ម[120] ស្របតាមលក្ខខណ្ឌជាក់លាក់នៃច្បាប់នេះ។ ជារួមមក យើងអាចកំណត់បានថាឱ្យតែជនដែលទទួលបានសញ្ជាតិខ្មែរស្របច្បាប់ ផ្អែកតាមច្បាប់ស្តីពីសញ្ជាតិ២០១៨ នោះលក្ខខណ្ឌត្រូវមានសញ្ជាតិជាខ្មែរនៃការចុះបញ្ជីដីឯកជននឹងត្រូវបានបំពេញ ដែលនាំឱ្យជនដែលមានសញ្ជាតិខ្មែរនេះអាចមានសិទ្ធិកម្មសិទ្ធិលើដីធ្លីបាន។

**ខ. នីតិបុគ្គលដែលមានសញ្ជាតិខ្មែរ**

នីតិបុគ្គល សំដៅដល់ក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរ តែដទៃពីសមាជិកនៃខ្លួន។[121] តាមរយៈពាក្យថាក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ ក្នុងន័យនេះ គឺចង់សំដៅលើក្រុមហ៊ុនដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ បន្ថែមពីនេះមាត្រា៩ នៃច្បាប់ច្បាប់ភូមិបាល២០០១ បានចែងថា៖[122]

*ក្រុមហ៊ុនដែលបានចុះបញ្ជីនៅកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី ៥១% ឡើងទៅ កាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជាអាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន។ មានតែចំនួនភាគរយនៃប្រាក់ហ៊ុនដែលមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុនតែប៉ុណ្ណោះទេដែលទទួលយកជាការបាន។ រាល់ការព្រមព្រៀងដែលចុះហត្ថលេខាជាលក្ខណៈឯកជនរវាងអ្នកចូលភាគហ៊ុនទាំងឡាយដែលមានន័យផ្ទុយពីនេះត្រូវទុកជាមោឃៈ និងគ្មានអានុភាព។*

*ប្រសិនបើចំនួនភាគរយដែលមានចែងក្នុងលក្ខន្តិកៈបានប្រែប្រួលបណ្តាលឱ្យក្រុមហ៊ុនលែងមានសញ្ជាតិជាខ្មែរ ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើការផ្លាស់ប្តូរលក្ខន្តិកៈឱ្យបានសមស្របតាមស្ថានភាពជាក់ស្តែង ហើយត្រូវផ្តល់ព័ត៌មានទៅស្ថាប័នមានសមត្ថកិច្ចអំពីការប្រែប្រួលនេះដោយអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន។*

[117] ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨, មាត្រា៥។
[118] ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨, មាត្រា១១ ដល់ មាត្រា១៧។
[119] ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨, មាត្រា១០។
[120] ច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ២០១៨, មាត្រា១៨ ដល់ ២៧។
[121] សន្ទានុក្រមច្បាប់ភូមិបាល២០០១។
[122] ច្បាប់ភូមិបាល២០០១, មាត្រា៩។

តាមរយៈស្មារតីនៃមាត្រា៩ នៃច្បាប់នេះបានកំណត់យ៉ាងជាក់លាក់ចំពោះក្រុមហ៊ុនដែលមានសញ្ជាតិខ្មែរ គឺសំដៅទៅលើក្រុមហ៊ុនណាដែលបង្កើតឡើងហើយមានពលរដ្ឋខ្មែរមួយឬច្រើនរូបមានភាគហ៊ុនសរុបចាប់ពី ៥១% ឡើងទៅ ហើយបានសហការជាមួយជនបរទេសដែលមានភាគហ៊ុនសរុបមិនលើសពី ៤៩% នៃក្រុមហ៊ុនទាំងមូល ដែលចំនួនភាគរយនេះយកតាមចំនួនប្រាក់ហ៊ុនដែលមានចែងយ៉ាងពិតប្រាកដនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ទើបអាចចុះបញ្ជីជាក្រុមហ៊ុនដែលមានសញ្ជាតិខ្មែរបាន ដូចនេះប្រសិនបើក្រុមហ៊ុននោះបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់នៃប្រទេសកម្ពុជា ទើបអាចដាក់ពាក្យស្នើសុំចុះបញ្ជីដី ដើម្បីក្លាយជាម្ចាស់កម្មសិទ្ធិករលើដីធ្លីបាន។

**ខ-ភាគខណ្ឌទី២៖ ជាភោគៈស្របច្បាប់**

តាមន័យទូទៅ ភោគៈ គឺសំដៅចំពោះអំពើរបស់ប្រជាពលរដ្ឋ ក្នុងការចូលកាន់កាប់លើដីឯកជនរបស់រដ្ឋដើម្បីយកមកធ្វើជាកម្មសិទ្ធិពិតប្រាកដរបស់ខ្លួន ទាំងនេះគឺជាសភាពការណ៍មួយដែលមានន័យថា កិរិយាកាន់កាប់នូវវត្ថុអ្វីមួយយ៉ាងផ្តាច់មុខតែឯង និងបំពេញចំពោះវត្ថុនោះនូវកិច្ចការទាំងឡាយដូចដែលកម្មសិទ្ធិករបានបំពេញដែរ។[123] រីឯតាមច្បាប់ភូមិបាល២០០១ ភោគៈ គឺសំដៅដល់សិទ្ធិដែលជនម្នាក់ៗមានលើទ្រព្យណាមួយជាបណ្តោះអាសន្ន មិនទាន់ស៊ប់ជារបស់ខ្លួនមែនទែនទេ ហើយភោគៈនេះជាពាក្យផ្ទុយនឹងកម្មសិទ្ធិដែលជាសិទ្ធិពេញបរិបូរណ៍របស់ជនម្នាក់ៗលើទ្រព្យណាមួយ ដែលជាឧទាហរណ៍ ដីមានប្លង់សុរិយោដី ជាដីកម្មសិទ្ធិ ឯដីមិនទាន់មានប្លង់សុរិយោដី គឺជាដីភោគៈ។[124]តាមរយៈនិយមន័យខាងលើ ភោគៈ សំដៅដល់សិទ្ធិបណ្តោះអាសន្នដែលភោគីមាននៅពេលបានចូលទៅកាន់កាប់លើដីឯកជនរបស់រដ្ឋមុនច្បាប់ភូមិបាល២០០១។

ដោយឡែកភោគី គឺជាអ្នកដែលទទួលភោគៈផ្អែកតាមសន្ទានុក្រមច្បាប់ភូមិបាល២០០១ ហើយដើម្បីទទួលបាននូវភោគៈស្របច្បាប់នោះ តម្រូវឱ្យភោគីត្រូវបំពេញលក្ខខណ្ឌទាំងឡាយនៃភោគៈ ក្នុងការកាន់កាប់ដីជាទ្រព្យឯកជនរបស់រដ្ឋដើម្បីឈានដល់ការទទួលបានជាកម្មសិទ្ធិផ្ទាល់ខ្លួន។ យោងតាមមាត្រា ៣៨ នៃច្បាប់ភូមិបាល២០០១ ភោគីត្រូវតែកាន់កាប់ដីធ្លីនោះដោយ ពិតប្រាកដ គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានការអាក់ខាន សុចរិត ទើបក្លាយជាជាភោគៈស្របច្បាប់។[125]

**ភោគីត្រូវកាន់កាប់ដីធ្លីដោយពិតប្រាកដ** គឺថាភោគី ទោះកាន់កាប់ដោយខ្លួនឯងក្តី ឱ្យអ្នកដទៃធ្វើឱ្យក្តីត្រូវកាន់កាប់ឱ្យឃើញថាការនោះប្រាកដជាធ្វើដើម្បីខ្លួន ក្នុងគោលដៅជាភោគីយ៉ាងផ្តាច់មុខ កុំឱ្យឃើញថាការ

[123] មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងសមាគមន៍អាដហុក, *គំរោងសាកល្បងស្តីពី ការអប់រំច្បាប់ភូមិបាល៖ ឯកសារសម្រាប់ការអប់រំប្រជាពលរដ្ឋ*, ឆ្នាំ២០០២, ទំព័រ១៤។

[124] សន្ទានុក្រមច្បាប់ភូមិបាល២០០១។

[125] ច្បាប់ភូមិបាល២០០១, មាត្រា៣៨។

ដែលធ្វើនោះ គឺធ្វើដោយសារសិទ្ធិណាមួយផ្សេងទៅវិញ។ ប្រសិនបើភោគីពិតប្រាកដមិនចេញមុខ នៅពីក្រោយភោគីមិនពិតប្រាកដ ភោគីនោះមិនអាចទាមទារប័ណ្ណភោគៈ ដើម្បីធ្វើលទ្ធកម្មទៅជាកម្មសិទ្ធិបានឡើយ ហើយភោគៈនោះត្រូវចាត់ទុកជាមោឃៈ។ តាមរយៈនេះមានន័យថា ភោគីត្រូវតែបង្ហាញឱ្យគេដឹងថាខ្លួនពិតជាបាននិងកំពុងកាន់កាប់លើដីហ្នឹងពិតប្រាកដមែន ហើយការចូលកាន់កាប់នេះ គឺធ្វើឡើងក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិជាស្ថាពរទៀតផង។

**ឧទាហរណ៍១៖** លោក **ក** បានចូលកាន់កាប់លើដីភូមិមួយកន្លែងដែលជាដីឯកជនរបស់រដ្ឋក្នុងឆ្នាំ ១៩៩៤ ពេលនោះគាត់ក៏បានសាងសង់ផ្ទះឈើមួយដើម្បីរស់នៅហើយថែមទាំងបានធ្វើរបងព័ទ្ធជុំវិញផ្ទះទៀតផង ហើយក៏បានចិញ្ចឹមមាន់ ទាជាច្រើនក្បាលដើម្បីទុកហូបនិងទុកលក់ខ្លះដើម្បីទទួលបានចំណូលសម្រាប់ការចំណាយផ្សេងៗក្នុងជីវភាពរស់នៅរបស់គាត់ បន្ទាប់មកទៀតលោក **ក** ក៏បានបន្តសកម្មភាពដដែលនេះរហូតមកដល់បច្ចុប្បន្ន(២០២៤)។ ផ្អែកតាមឧទាហរណ៍នេះបញ្ជាក់ឱ្យឃើញថាលោក **ក** គឺពិតជាមានគោលបំណងយ៉ាងផ្តាច់មុខក្នុងការចូលទៅកាន់កាប់ដីភូមិមួយកន្លែងនោះយកមកធ្វើជាកម្មសិទ្ធិពិតប្រាកដមែន ព្រោះថាលោក **ក** មិនត្រឹមតែបានសាងសង់ផ្ទះលើដីភូមិដើម្បីរស់នៅទេ ពោលគឺគាត់បានសាងសង់របងបន្ថែមដើម្បីការពារផ្ទះនិងដីនោះជៀសវៀងកុំឱ្យមានបុគ្គលណាផ្សេងចូលមកកាន់កាប់ដីរបស់គាត់។ ដូចនេះសកម្មភាពដែលលោក **ក** បានធ្វើនេះគឺជាភោគីដែលបានការកាន់កាប់លើដីក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិជាស្ថាពរយ៉ាងពិតប្រាកដមែន។

**ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានហិង្សា** គឺថាភោគៈដែលបានមកដោយហិង្សា មិនទុកជាភោគៈត្រឹមត្រូវតាមច្បាប់ឡើយ។ ក៏ប៉ុន្តែ បើកាលណាគេប្រើហិង្សាក្នុងពេលមានតតិយជន ឥតសិទ្ធិសោះមកដណ្តើមនោះហិង្សានេះគ្មានឥទ្ធិពលអ្វីទៅលើភោគៈដែលគេបានមកដោយសន្តិភាព តាំងពីដើមមកនោះទេ។ តាមរយៈនេះបានន័យថា អ្នកកាន់កាប់ត្រូវតែបានចូលកាន់កាប់ដីនោះដោយមិនប្រើហិង្សាទៅលើបុគ្គលណាមួយដើម្បីទទួលបានដីមួយកន្លែងនោះទេ ក៏ប៉ុន្តែច្បាប់បានអនុញ្ញាតឱ្យប្រើហិង្សាដើម្បីទទួលបានភោគៈស្របច្បាប់បានក្នុងករណីដែលការប្រើអំពើហិង្សានោះ ក្នុងគោលបំណងការពារដីរបស់ខ្លួន។

**ឧទាហរណ៍២៖** ក្នុងឆ្នាំ១៩៩៤ លោក **ខ** បានចូលកាន់កាប់លើដីមួយកន្លែងក្នុងភូមិចាបមាសដែលជាដីឯកជនរបស់រដ្ឋ ហើយដីនោះទំនេរគ្មានអ្នករស់នៅលើទេ ហើយគាត់ក៏បានសង់ផ្ទះឈើនិងមានរបងព័ទ្ធជុំវិញផ្ទះរបស់គាត់បានយ៉ាងល្អ ក្រោយមកនៅឆ្នាំបន្ទាប់ក៏មានជនខិលខូចប៉ុន្មាននាក់បានមកព្រួតគ្នាប្រើអំពើហិង្សាមកលើលោក **ខ** ក្នុងគោលបំណងបណ្តេញគាត់ចេញដើម្បីយកដីនោះមកកាន់កាប់បន្ត ក្នុងករណីនេះគឺលោក **ខ** អាចប្រើអំពើហិង្សាដើម្បីតបតទៅជនខិលខូចទាំងនោះវិញបាន ហើយគាត់ក៏នៅតែអាចទទួលបានភោគៈស្របច្បាប់ដដែល ព្រោះទង្វើដែលគាត់បានធ្វើគឺក្នុងគោលបំណងរារាំងមិនឱ្យតតិយជនយកដីរបស់គាត់ដែលបានចូលកាន់កាប់យ៉ាងត្រឹមត្រូវនោះទេ។ ដូចនេះសកម្មភាពដែលលោក **ខ** បានប្រព្រឹត្តដើម្បីការពារដីរបស់ខ្លួនមិនមែនជាការកាន់កាប់ដោយប្រើហិង្សានោះឡើយ។

**ភោគីត្រូវកាន់កាប់អចលនវត្ថុដោយដឹងឮជាសាធារណៈ** គឺថាភោគីត្រូវកាន់កាប់ដោយឥតលាក់បិទបាំង អ្នកទាំងពួងដែលចង់តវ៉ាអំពីសិទ្ធិរបស់ខ្លួនលើវត្ថុនោះនឹងបានដឹងឮឃើញមិនខាន។

**ឧទាហរណ៍៣៖** បន្ថែមទៅលើឧទាហរណ៍២ខាងលើ មានន័យថានៅពេលដែលលោក **ខ** កំពុងសាងសង់របងព័ទ្ធជុំវិញផ្ទះរបស់គាត់ក្នុងគោលបំណងយ៉ាងផ្តាច់មុខយកមកធ្វើជាកម្មសិទ្ធិ ហើយមានប្រជាពលរដ្ឋក្នុងភូមិចាបមាសបានឃើញគាត់សាងសង់របងនោះ មិនតែប៉ុណ្ណោះថែមទាំងបានជួយលោក **ខ** ដើម្បីសាងសង់របងទៀតផង ដោយផ្អែកតាមឧទាហរណ៍នេះគឺបានបញ្ជាក់យ៉ាងច្បាស់ថាលោក **ខ** គឺបានចូលទៅកាន់កាប់លើដីនោះជាសាធារណៈដោយឥតលាក់បាំងឡើយ ព្រោះប្រជាពលរដ្ឋអាចមើលឃើញលោក **ខ** កំពុងរស់នៅក្នុងផ្ទះដែលមានរបងព័ទ្ធជុំវិញបានគ្រប់ពេល។ ដូចនេះការកាន់កាប់របស់លោក **ខ** ជាការកាន់កាប់ដោយមានការដឹងឮជាសាធារណៈ។

**ភោគីត្រូវកាន់កាប់អចលនវត្ថុដោយគ្មានអាក់ខាន** គឺថាភោគីត្រូវធ្វើនូវកិច្ចការផង ទាំងពួងតាមធម្មតាជាប្រក្រតី ក្នុងរយៈពេលចាំបាច់នៃការទាមទារលទ្ធកម្មកម្មសិទ្ធិ។ ការអាក់ខាន ក្នុងរយៈពេលខ្លី ឬបានបង់ទុកឱ្យនៅទំនេរ ដើម្បីឱ្យមានជីជាតិឡើងវិញ មិនមែនជាឧបសគ្គដល់ លទ្ធកម្មកម្មសិទ្ធិនោះទេ។ មានន័យថាអ្នកកាន់កាប់មិនអាចបញ្ឈប់ការកាន់កាប់និងទុកដីនោះចោល ហើយថ្ងៃក្រោយត្រឡប់មកចូលកាន់កាប់លើដីនោះវិញបានទេ ក៏ប៉ុន្តែចំពោះករណីដែលភោគីណាដែលបានទុកដីឱ្យទំនេរចោលមួយរយៈពេលខ្លី ក្នុងមូលហេតុទុកឱ្យដីនោះមានជីជាតិឡើងវិញ ឬ ទៅលេងផ្ទះបងប្អូន ឬ ទៅបំពេញបេសកកម្មជាដើម ក្នុងមួយរយៈពេលខ្លីមួយ ហើយក្រោយពីចប់កិច្ចការគឺគាត់ត្រឡប់មកកាន់កាប់លើដីនោះបន្តបានដែលការកាន់កាប់នោះនឹងត្រូវចាត់ទុកថាគ្មានការអាក់ខានដដែល។

**ឧទាហរណ៍៤៖** បន្តមកពីករណីខាងលើដដែលនៅឆ្នាំ១៩៩៦ លោក **ខ** បានរកឃើញសាច់ញាតិរបស់គាត់ដែលបានឃ្លាតឆ្ងាយពីគ្នាដោយសាររបបខ្មែរក្រហម ដោយសារចិត្តនឹកនានិងបងប្អូនដែលខានជួបមុខគ្នាអស់រយៈពេលយូរឆ្នាំមកហើយ គាត់ក៏បានទៅជួបជុំបងប្អូនរបស់គាត់នៅភូមិផ្សេងរយៈពេល២ខែ ក្រោយពីនោះគាត់ក៏បានត្រឡប់មកកាន់កាប់លើដីរបស់គាត់ដូចពេលធម្មតាវិញ។ ដូចនេះការដែលលោក **ខ** ទៅលេងបងប្អូនរបស់គាត់មួយរយៈពេលខ្លីនេះ ច្បាប់នៅតែចាត់ទុកគាត់ថាបានកាន់កាប់ដោយគ្មានអាក់ខានដដែល(ផ្អែកតាមលក្ខខណ្ឌភោគៈស្របច្បាប់ មាត្រា៣៨ នៃច្បាប់ភូមិបាល២០០១)។ តែប្រសិនបើករណី លោក **ខ** បានជួបជុំបងប្អូន ហើយគាត់ក៏បានសាងសង់ផ្ទះថ្មីមួយនៅជិតផ្ទះរបស់បងប្អូនរបស់គាត់ដើម្បីបានរស់នៅជុំគ្នាតាំងពីឆ្នាំ១៩៩៦ រហូតមក ២០០៣ គាត់ក៏នឹកឃើញផ្ទះរបស់គាត់ដែលបានសាងសង់នៅភូមិចាបមាសពីមុនមក ហើយគាត់ក៏បានវិលត្រឡប់ទៅផ្ទះនោះវិញ ករណីនេះគឺចាត់ទុកថាគាត់បានកាន់កាប់ដោយអាក់ខាន ព្រោះមានរយៈពេលវែង ដូចនេះគាត់មិនអាចក្លាយជាភោគីស្របតាមច្បាប់ទេ។

**ភោគីត្រូវបានកាន់កាប់ដោយសុចរិត** គឺថាភោគីមិនដឹងពីសិទ្ធិដាយថាហេតុរបស់តតិយជន លើវត្ថុដែលខ្លួនកំពុងកាន់កាប់នោះសោះ។ មានន័យថាអ្នកកាន់កាប់ពិតជាមិនបានដឹងថាមានបុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍នៅលើដីនោះឡើយនៅពេលដែលខ្លួនចូលកាន់កាប់។

**ឧទាហរណ៍៖** នៅឆ្នាំ២០០០ លោក **ណ** បានឃើញផ្ទះឈើមួយមានសភាពបែកបាក់ខ្លាំងនិងមានរបងឈើព័ទ្ធជុំវិញដែលរបងនោះបាក់រលំសឹងតែទាំងអស់ទៅហើយ ដោយឃើញសភាពថាជាភូមិដែលត្រូវគេបោះបង់ចោលហើយផ្ទះទាំងអស់នៅក្នុងភូមិគ្មានមនុស្សរស់នៅបែបនេះលោក **ណ** គិតថាភូមិនេះត្រូវបានគេបោះបង់ចោលតាំងពីសម័យខ្មែរក្រហម ក៏បានចូលរស់នៅក្នុងផ្ទះដែលបាក់បែកមួយកន្លែងក្នុងភូមិ ដោយបានរុះផ្ទះចាស់នឹងសាងសង់ផ្ទះថ្មីនិងរបងថ្មីលើដីនោះ ហើយរស់នៅលើដីនោះរហូតដល់ឆ្នាំ២០០៨ ទើបឃើញលោក **ឃ** មកទាមទារវិញថាដីនោះជាដីរបស់គាត់ ក្នុងករណីនេះលោក **ណ** អាចអះអាងថាដីដែលគាត់ចូលកាន់កាប់នេះត្រឹមត្រូវតាមច្បាប់ ហើយលោក **ឃ** គ្មានសិទ្ធិជាភោគៈលើដីនោះបន្តទៀតទេ។ ដោយហេតុថា នៅពេលដែលលោក **ណ** ចូលកាន់កាប់លើដីនោះ គាត់មិនបានដឹងថាដីនោះជាដីរបស់លោក **ឃ** ឡើយ ព្រោះផ្ទះមានសភាពបាក់បែងខ្លាំង ហើយទាំងផ្ទះ ទាំងភូមិគ្មានមនុស្សរស់នៅសូម្បីម្នាក់។

## ខណ្ឌទី៣៖ ការកាន់កាប់លើដីចាប់ពី ៥ឆ្នាំឡើងទៅ

ជាការពិតណាស់ក្រោយពីភោគីបានបំពេញលក្ខខណ្ឌ៥យ៉ាងនៃភោគៈស្របច្បាប់ខាងលើ គឺភោគីគ្រាន់តែមានសិទ្ធិជាបណ្ដោះអាសន្នតែប៉ុណ្ណោះ ដែលសិទ្ធិនោះមិនទាន់ស៊ប់ជារបស់ខ្លួនមែនទែននោះទេ។[126] ដែលតាមរយៈសិទ្ធិនេះ បើភោគីចង់ប្រែក្លាយពីសិទ្ធិបណ្ដោះអាសន្នទៅជាសិទ្ធិពេញលេញ គឺតម្រូវឱ្យភោគី ត្រូវបំពេញនូវលក្ខខណ្ឌពេលវេលាក្នុងការចូលកាន់កាប់ភោគៈស្របច្បាប់នោះ ពោលគឺត្រូវកាន់កាប់ឱ្យបានយ៉ាងតិច៥ឆ្នាំមុនច្បាប់ភូមិបាល២០០១ចូលជាធរមាន ព្រោះដោយសារមាត្រា២៩ កថាខណ្ឌ២ នៃច្បាប់ភូមិបាល២០០១នេះបានចែងហាមឃាត់ថា“**ការចូលកាន់កាប់គោគៈត្រូវបញ្ចប់ នៅពេលដែលច្បាប់នេះចូលជាធរមាន**” ទើបភោគីនោះមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរបាន។ ប៉ុន្តែដោយសារមានករណីខ្លះ ភោគីបានកាន់កាប់ភោគៈស្របច្បាប់តែមិនទាន់បានគ្រប់ ៥ឆ្នាំ ពោលគឺកាន់កាប់បានតិចជាង ៥ឆ្នាំមុនច្បាប់ភូមិបាល២០០១ ចូលជាធរមាន ដូចនេះតើភោគីនោះមិនអាចស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរឬក៏យ៉ាងណា? ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះយើងនឹងពិភាក្សាទៅលើការកាន់កាប់ដីបានយ៉ាងតិច៥ឆ្នាំមុនច្បាប់ភូមិបាល និងការកាន់កាប់ដីបានតិចជាង៥ឆ្នាំមុនច្បាប់ភូមិបាលដូចតទៅ៖

- **ក្នុងករណីការកាន់កាប់លើដីបានយ៉ាងតិច ៥ឆ្នាំ មុនច្បាប់ភូមិបាល២០០១**

  យោងតាមមាត្រា៣០ កថាខណ្ឌទី១ នៃច្បាប់ភូមិបាល២០០១ បានចែងថា៖[127]

  *“បុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ (ប្រាំ)ឆ្នាំយ៉ាងតិច គិតមកដល់ថ្ងៃប្រកាសឱ្យប្រើច្បាប់នេះ លើអចលនវត្ថុដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។”*

ផ្អែកតាមស្មារតីនៃមាត្រាខាងលើនេះ បានសំដៅលើការការពារសិទ្ធិរបស់ភោគីស្របច្បាប់ដែលបានកាន់កាប់លើដីឯកជនរបស់រដ្ឋយ៉ាងផ្ដាច់មុខ នឹងបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ ពោលគឺបានបំពេញលក្ខខណ្ឌនៃភោគៈស្របច្បាប់ទាំងប្រាំដែលមានដូចជាកាន់កាប់ដោយពិតប្រាកដ

[126] សន្ទានុក្រមច្បាប់ភូមិបាល២០០១។

[127] ច្បាប់ភូមិបាល២០០១, មាត្រា៣០ កថាខណ្ឌទី១។

គ្មានហិង្សា ដឹងឮជាសាធារណៈ គ្មានការអាក់ខាន និងដោយសុចរិត ហើយដែលការកាន់កាប់នោះបានគ្រប់រយៈពេល ៥(ប្រាំ)ឆ្នាំ នោះភោគីនឹងអាចធ្វើការដាក់ពាក្យសុំចុះបញ្ជីលើដីនោះ ដើម្បីទទួលប័ណ្ណកម្មសិទ្ធិជាស្ថាពរ (វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ) រីឯនីតិវិធីលម្អិតក្នុងការទទួលបានប័ណ្ណកម្មសិទ្ធិស្ថាពរយ៉ាងណានោះ យើងនឹងពិភាក្សានៅក្នុង(កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីដីឯកជន)។

❖ **ក្នុងករណីការកាន់កាប់លើដីបានតិចជាង៥ឆ្នាំ មុនច្បាប់ភូមិបាល២០០១**

យោងតាមមាត្រា៣១ កថាខណ្ឌទី១ នៃច្បាប់ភូមិបាល២០០១បានចែងថា៖

*បុគ្គលដែលបានអាស្រ័យផលនៃភោគៈកន្លងមក គិតមកដល់កាលបរិច្ឆេទនៃច្បាប់នេះចូលជាធរមាន ប្រសិនបើបានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌទាំងឡាយ ក្នុងការក្លាយទៅជាកម្មសិទ្ធិករអាចត្រូវបានអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ច ឱ្យបន្ថែមរយៈពេលកាន់កាប់ភោគៈរបស់ខ្លួនរហូតគ្រប់រយៈពេលស្របច្បាប់ ៥ឆ្នាំ និងបានកម្មសិទ្ធិជាស្ថាពរ។ ការអនុញ្ញាតឱ្យបន្តរយៈពេល មិនអាចត្រូវបានបដិសេធដោយអាជ្ញាធរមានសមត្ថកិច្ចឡើយ ប្រសិនបើភោគៈបានមកដោយសន្តិវិធី និងមិនមានការជំទាស់។*

ផ្អែកតាមស្មារតីនៃមាត្រាខាងលើនេះ បានសំដៅលើការការពារសិទ្ធិរបស់ប្រជាពលរដ្ឋដែលបានកាន់កាប់ដីឯកជនរបស់រដ្ឋយ៉ាងផ្ដាច់មុខ នឹងបានអាស្រ័យផលនៃភោគៈដោយសន្តិវិធីនិងមិនមានការជំទាស់ ពោលគឺបានបំពេញលក្ខខណ្ឌនៃភោគៈស្របច្បាប់ទាំងប្រាំដែលមានដូចជាកាន់កាប់ដោយពិតប្រាកដ គ្មានហឹង្សា ដឹងឮជាសាធារណៈ គ្មានការអាក់ខាន និងដោយសុចរិត តែការកាន់កាប់លើដីរបស់គាត់ពុំទាន់គ្រប់៥ឆ្នាំនៅឡើយ គិតមកដល់ថ្ងៃ៣០ សីហា ២០០១ ដែលច្បាប់ភូមិបាលបានចូលជាធរមាន ក៏ប៉ុន្តែដោយសារតែគាត់បានចូលកាន់កាប់លើដីនោះមុនច្បាប់ភូមិបាល២០០១ ដូច្នេះតាមស្មារតីនៃមាត្រាដដែលនេះគឺអនុញ្ញាតឱ្យប្រជាពលរដ្ឋកាន់កាប់លើដីនោះដោយស្របច្បាប់ហើយអាចបន្តរហូតបានគ្រប់រយៈពេល៥ឆ្នាំ ដើម្បីមានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរបាន។ ដើម្បីឱ្យងាយស្រួលយល់ យើងនឹងធ្វើការលើកឧទាហរណ៍ដូចខាងក្រោម៖

**ឧទាហរណ៍៖** លោក **ស** ជាជនជាតិខ្មែរ បានចូលទៅកាន់កាប់លើដីឯកជនរបស់រដ្ឋមួយកន្លែងដែលទំនេរនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៨ ហើយការកាន់កាប់របស់គាត់បានបំពេញលក្ខខណ្ឌស្របច្បាប់ទាំងប្រាំនៃភោគៈ រហូតមកដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ច្បាប់ភូមិបាលត្រូវបានបង្កើតឡើងដោយបានផ្ដល់សិទ្ធិឱ្យប្រជាពលរដ្ឋទទួលបានប័ណ្ណកម្មសិទ្ធិស្ថាពរលើដីធ្លី ដោយឃើញឱកាសបែបនេះ លោក **ស** ក៏មកធ្វើការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ តែដោយសារលោក **ស** កាន់កាប់លើដីនោះពុំទាន់គ្រប់៥ឆ្នាំនៅឡើយ។ ដូចនេះអាជ្ញាធរមានសមត្ថកិច្ចក៏បានណែនាំឱ្យលោក **ស** បន្តកាន់កាប់លើដីនោះ២ឆ្នាំបន្ថែមទៀតពោលគឺនៅថ្ងៃ១៥ ខែមិថុនា ឆ្នាំ២០០៣ ទើបគាត់អាចទទួលបានប័ណ្ណកម្មសិទ្ធិស្ថាពរលើដីធ្លីបាន។

**វាក្យខណ្ឌទី៤៖ ការកាន់កាប់លើដីឯកជនរបស់រដ្ឋ**

នៅក្នុងផ្នែកនេះជាផ្នែកដែលសំខាន់ជាងគេ ព្រោះថាបើប្រជាពលរដ្ឋខ្មែរដែលបានចូលទៅកាន់កាប់លើដីសាធារណៈរបស់រដ្ឋ ទោះបីជាការកាន់កាប់នោះមុនច្បាប់ភូមិបាល២០០១ ហើយបានបំពេញតាមលក្ខខណ្ឌទាំងប្រាំនៃភោគៈស្របច្បាប់និងបានលើសឬស្មើនឹង ៥ឆ្នាំ ក៏ពិតមែន ក៏គាត់មិនអាចក្លាយជាម្ចាស់កម្មសិទ្ធិទៅលើដីនោះបានឡើយ។[128] បានន័យថារាល់ដីសាធារណៈរបស់រដ្ឋដែលបានកំណត់ក្នុងមាត្រា១៥ នៃច្បាប់ភូមិបាល២០០១ គឺមិនអាចក្លាយជាកម្មវត្ថុនៃការយកមកធ្វើជាកម្មសិទ្ធិឯកជនរបស់បុគ្គលណាមួយបានទេ។ តាមរយៈន័យនេះគឺមានន័យថា ក្រៅពីដីសាធារណៈរបស់រដ្ឋដែលមានចែងនៅក្នុងច្បាប់ភូមិបាល២០០១ អាចក្លាយមកជាកម្មសិទ្ធិឯកជនបាន ពោលគឺមានតែដីឯកជនរបស់រដ្ឋ ទើបប្រជាពលរដ្ឋអាចមានលទ្ធភាពកាន់កាប់ដើម្បីទទួលបានកម្មសិទ្ធិស្ថាពរបាន។ គួរបញ្ជាក់ផងដែរថារាល់ការចូលកាន់កាប់ដីជាភោគៈនៅក្រោយថ្ងៃទី៣០ សីហា ២០០១ ទោះបីជាការកាន់កាប់លើដីឯកជនរបស់រដ្ឋក៏ដោយ ក៏មិនអាចក្លាយមកជាកម្មសិទ្ធិស្ថាពរបាននោះឡើយ ហើយថែមទាំងត្រូវចាត់ទុកជាមោឃៈភាព និងគ្មានអានុភាពថែមទៀតផង។[129]

**វាក្យខណ្ឌទី៥៖ តាមរយៈសម្បទានដីសង្គមកិច្ច**

សម្បទានដីសង្គមកិច្ច គឺជាយន្តការនៃការផ្ទេរដីឯកជនរបស់រដ្ឋតាមផ្លូវច្បាប់សម្រាប់គោលបំណងសង្គមកិច្ច ដល់ជនក្រីក្រដែលខ្វះខាតដីសម្រាប់លំនៅឋាន ឬ/និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។[130] តាមន័យនេះសម្បទានដីសង្គមកិច្ចត្រូវបានធ្វើឡើងក្នុងគោលបំណងបំរើផលប្រយោជន៍សង្គម ដែលរដ្ឋបានធ្វើការផ្តល់ដីដល់ប្រជាពលរដ្ឋដែលអត់មានដី ដើម្បីយកដីនោះទៅប្រើប្រាស់ក្នុងការសាងសង់លំនៅឋានសម្រាប់ស្នាក់នៅ និងប្រកបរបរដើម្បីចញ្ចឹមជីវិតលើដីនោះ។ ដោយឡែកសម្បទានដីសង្គមកិច្ចក៏អាចក្លាយទៅជាកម្មសិទ្ធិពេញលេញ ប្រសិនបើសម្បទានិកបានកាន់កាប់បន្តលើដីនោះជាប់ៗគ្នារហូតរយៈពេល ៥ឆ្នាំ ជាប់ៗគ្នា ដោយគ្មានការអាក់ខាន។ ជារួមមកមានន័យថា ដីសម្បទានសង្គមកិច្ចក៏អាចក្លាយជាកម្មវត្ថុនៃការចុះបញ្ជី ដោយសម្បទានិកអាចដាក់ពាក្យសុំចុះបញ្ជីលើក្បាលដីរបស់ខ្លួនបានផងដែរ ប្រសិនបើសម្បទានិកបានបំពេញបានត្រឹមត្រូវស្របតាមលក្ខខណ្ឌរបស់សម្បទានសង្គមកិច្ច។

[128] ច្បាប់ភូមិបាល២០០១, មាត្រា៤៣ កថាខណ្ឌទី១។

[129] ច្បាប់ភូមិបាល២០០១, មាត្រា២៩ កថាខណ្ឌទី២ និងមាត្រា១៨។

[130] អនុក្រឹត្យ ស្តីពីសម្បទានដីសង្គមកិច្ច, លេខ ១៩ អនក្រ, ១៩ មីនា ២០០៣, មាត្រា២។

### កថាខណ្ឌទី៣៖ នីតិវិធីការចុះបញ្ជីដីឯកជន

នៅក្នុងដំណើរការនៃការផ្តល់កម្មសិទ្ធិឯកជននៅក្នុងប្រទេសកម្ពុជា ត្រូវបានកំពុងដំណើរការដោយនីតិវិធីពីរធំៗ ដែលមានដូចជានីតិវិធីចុះបញ្ជីដីឯកជនតាមលក្ខណៈជាប្រព័ន្ធ (**វាក្យខណ្ឌទី១**) និងនីតិវិធីចុះបញ្ជីដីឯកជនតាមលក្ខណៈដាច់ដោយដុំ(**វាក្យខណ្ឌទី២**) ដែលបាននឹងកំពុងផ្តល់នូវកម្មសិទ្ធិជូនប្រជាពលរដ្ឋ។

#### វាក្យខណ្ឌទី១៖ នីតិវិធីចុះបញ្ជីដីឯកជនតាមលក្ខណៈជាប្រព័ន្ធ

ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ សំដៅទៅដល់ការចុះបញ្ជីដីធ្លី ដែលកើតចេញពីគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដោយមិនចាំបាច់មានការស្នើសុំពីម្ចាស់ដីឡើយ ហើយរដ្ឋាភិបាលជាអ្នកកំណត់ជ្រើសរើសភូមិ ឬឃុំណាមួយ ដែលត្រូវធ្វើការចុះបញ្ជីដីធ្លី។[131] តាមរយៈការចុះបញ្ជីនេះ នៅពេលដែលរដ្ឋាភិបាលបានជ្រើសរើសតំបន់វិនិច្ឆ័យប៉ះចំភូមិឬឃុំណាមួយដែលអាចដំណើរការចុះបញ្ជីដីបានហើយនោះ ប្រជាពលរដ្ឋគ្រាន់តែចូលរួមសហការជាមួយមន្ត្រីសុរិយោដីក្នុងការផ្តល់ភស្តុតាង និងចូលរួមក្នុងសកម្មភាព ដែលពាក់ព័ន្ធនិងនីតិវិធីនៃការចុះបញ្ជីដីទៅលើដីដែលប្រជាពលរដ្ឋបានអះអាងថាបានកាន់កាប់លើដីនោះពិតប្រាកដមែន។ ផ្អែកតាមអនុក្រឹត្យលេខ ៤៦ អនក្រ. បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី បានចែងលម្អិតអំពីដំណើរការនៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ដែលមានប្រាំដំណាក់កាលសំខាន់ៗដូចខាងក្រោម៖

**១. ដំណាក់កាល ត្រៀមរៀបចំ**

**ការចេញសេចក្តីប្រកាសអំពីតំបន់និងទីតាំងវិនិច្ឆ័យ៖** សេចក្តីប្រកាសនេះគឺជាផ្សព្វផ្សាយព័ត៌មានអំពីតំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ ដែលបានកំណត់ច្បាស់លាស់ក្រោយពីអភិបាលខេត្តទទួលបានការឯកភាពពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលការប្រកាសនេះអាចត្រូវបានធ្វើឡើងតាមរៀបបង្ហាញផែនទី ឬ តាមការពិពណ៌នា ឬ តាមរៀបទាំងពីរតែម្តងក៏បាន។[132] ការប្រកាសនេះមានគោលបំណងឱ្យប្រជាពលរដ្ឋនិងអាជ្ញាធរមូលដ្ឋានបានដឹងថាភូមិ ឃុំ ស្រុក ណាខ្លះដែលត្រូវបានជ្រើសរើសមកធ្វើការវិនិច្ឆ័យក្នុងកិច្ចដំណើរការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធនាពេលខាងមុខ អាចត្រៀមខ្លួនទុកជាមុនចំពោះប្រជាពលរដ្ឋដែលមានដីស្រែ ដីចម្ការ ដីលំនៅដ្ឋាន និងផ្ទៃដីសាងសង់ទាំងអស់ ដែលមានក្បាលដីស្ថិតនៅក្នុងតំបន់វិនិច្ឆ័យចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ ត្រូវចូលរួមសហការជាមួយមន្ត្រីជំនាញសុរិយោដីនៃក្រុមការងារដីធ្លី នៅលើ

---

[131] វិទ្យុបារាំងអន្តរជាតិ RFI, នាទីយល់ដឹងច្បាប់ នឹងជំនួញ៖ *នីតិវិធីចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ,* https://www.rfi.fr/km/procedure-collective-registration-land-property (បានទស្សនាថ្ងៃទី១ មិថុនា ២០២៤)។

[132] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី១ ចំណុច១, ទំព័រ១។

ក្បាលដីរបស់ខ្លួន។[133] នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យត្រូវបានប្រកាសហើយ អភិបាលខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យ ត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យ ហើយសមាសភាពរបស់គណៈកម្មការរដ្ឋបាលរួមមាន៖[134]

- តំណាងអភិបាលខេត្ត ក្រុង ជាប្រធាន
- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក
- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក
- អភិបាលស្រុក ខណ្ឌ ឬតំណាង ជាសមាជិក
- មេឃុំចៅសង្កាត់ ឬតំណាង ជាសមាជិក
- មេភូមិ ឬតំណាង ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប ជាសមាជិក

ជាងនេះទៅទៀត បើផ្អែកតាមមាត្រា៣ នៃអនុក្រឹត្យលេខ ៤៦ បានចែងអំពីភារកិច្ចរបស់គណៈកម្មការរដ្ឋបាលរួមមាន បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី មានជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី និងទទួលរាល់បណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង ព្រមទាំងធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃវិនិច្ឆ័យ និងលើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ។ បន្ថែមពីនេះ ក្រោយពីគណៈកម្មការរដ្ឋបាលត្រូវបានតែងតាំងរួចរាល់ហើយ គណៈកម្មការរដ្ឋបាលត្រូវរៀបចំប្រជុំណែនាំសមាជិករបស់ខ្លួន ដើម្បីឱ្យយល់អំពីកិច្ចដំណើរការ នៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ និងធ្វើការកំណត់បែងចែកភារកិច្ចដល់សមាជិកម្នាក់ៗ រៀបចំផែនការសម្រាប់អនុវត្ត និងលើកសំណើទៅអភិបាលខេត្ត ក្រុង អំពីកាលបរិច្ឆេទនិងទីកន្លែង ដែលត្រូវបើកកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសតំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ និងការចុះបំពេញការងារវាលរបស់មន្ត្រីជំនាញ។[135]

**ការប្រជុំផ្សព្វផ្សាយនៅក្នុងតំបន់និងទីតាំងនៃការវិនិច្ឆ័យ៖** អភិបាលខេត្ត ក្រុង ត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតនីតិវិធីនៃការវិនិច្ឆ័យមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងហោចណាស់ ៧ថ្ងៃ ជូនសាធារណៈជនជ្រាបជាដំណឹង មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់

---

[133] រដ្ឋបាលខេត្តមណ្ឌលគិរី, *ពិធីប្រកាសផ្សព្វផ្សាយតំបន់វិនិច្ឆ័យនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅភូមិជ្រៃសែន សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី,* https://www.mondulkiri.gov.kh/detail/4318 (បានទស្សនាថ្ងៃទី៥ កក្កដា២០២៤)។

[134] អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា៣។

[135] អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦អនក្រ ៣១ ឧសភា ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា៦ថ្មី។

តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យ។[136] ដែលសេចក្តីជូនដំណឹងនេះ មានគោលបំណងឱ្យកម្មសិទ្ធិករ ឬអ្នកកាន់កាប់ដី ព្រមទាំងជនដែលមានការពាក់ព័ន្ធនឹងក្បាលដីក្នុងតំបន់វិនិច្ឆ័យ បានយល់ជ្រួតជ្រាបពីសារៈសំខាន់នៃកិច្ចប្រតិបត្តិការរបស់មន្ត្រីជំនាញ ដើម្បីមកចូលរួមផ្តល់ព័ត៌មាន ឯកសារ និងភស្តុតាងសំខាន់ៗទាក់ទងនឹងអត្តសញ្ញាណនៃក្បាលដី អត្តសញ្ញាណនៃម្ចាស់ដី ធ្វើឱ្យទិន្នន័យដែលប្រមូលបានមានភាពពិតប្រាកដ និងសុក្រឹត។ នៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសតំបន់ធ្វើការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់ដំណើរការនៃការវិនិច្ឆ័យ ភាពចាំបាច់ និងឱកាសដែលត្រូវចូលរួមរបស់ប្រជាពលរដ្ឋជាម្ចាស់សិទ្ធិ បំភ្លឺអំពីសិទ្ធិស្របច្បាប់លើអចលនវត្ថុ និងកាតព្វកិច្ចដែលត្រូវបំពេញ ព្រមទាំងឆ្លើយរាល់សំណួរ ឬចម្ងល់ ដែលបានលើកឡើងក្នុងកិច្ចប្រជុំ។[137] ហើយការធ្វើកិច្ចប្រជុំនេះ គឺដើម្បីផ្សព្វផ្សាយជាសាធារណៈ នូវដំណើរការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធរួមមានការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ដែលនឹងត្រូវអនុវត្តផ្ទាល់ដោយមន្ត្រីជំនាញ នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដោយសហការជាមួយអាជ្ញាធរដែនដី និងមន្ទីរ អង្គភាពគ្រប់គ្រងដីរដ្ឋដែលពាក់ព័ន្ធ ដើម្បីឱ្យប្រជាពលរដ្ឋដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យត្រៀមបោះបង្គោលព្រំដីឱ្យបានច្បាស់លាស់ និងត្រៀមឯកសារពាក់ព័ន្ធរួមមាន សំបុត្រកំណើត អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងឯកសារពាក់ព័ន្ធផ្សេងៗដើម្បីងាយស្រួលដល់ក្រុមការងារចុះវាស់វែងបានឆាប់រហ័សក្នុងការចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ។[138]

### ២. ដំណាក់កាលប្រតិបត្តិការបច្ចេកទេស

ក្រោយពីបានបញ្ចប់កិច្ចប្រជុំផ្សព្វផ្សាយនៅក្នុងតំបន់និងទីតាំងវិនិច្ឆ័យ ហើយឈានមកដល់កាលបរិច្ឆេទនៃការចុះកំណត់ព្រំ វាស់វែង និងវិនិច្ឆ័យ របស់មន្ត្រីជំនាញទៅលើទីតាំងដីដែលស្ថិតនៅក្នុងតំបន់វិនិច្ឆ័យផ្ទាល់តែម្តង ដើម្បីដឹងពីដំណើរការរបស់មន្ត្រីជំនាញអនុវត្តបែបណា យើងនិងសិក្សាទៅលើ ការងារវាល និងការងារនៅការិយាល័យ។

- **ការងារវាល**

ការងារវាលនេះត្រូវបានអនុវត្តនៅក្នុងតំបន់វិនិច្ឆ័យដោយមន្ត្រីកំណត់ព្រំដី មន្ត្រីវាស់វែង និងមន្ត្រីវិនិច្ឆ័យដោយមានការសហការនិងការជួយជ្រោមជ្រែងពីមន្ត្រីនៅមូលដ្ឋាន ( មេភូមិ មេឃុំ ឬចៅសង្កាត់ ) ហើយមន្ត្រីជំនាញទាំងបីផ្នែកនេះត្រូវស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរបស់សមាជិកនៃគណៈកម្មការរដ្ឋបាលពោលគឺ

---

[136] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី១ ចំណុច៥ និង៦, ទំព័រ២។

[137] ទីកន្លែងនៃកិច្ចប្រជុំ អាចប្រព្រឹត្តនៅកន្លែងណាមួយ ក្នុងតំបន់វិនិច្ឆ័យ ដែលមានជាអាទិ៍ ទីវត្តអារាម ទីសាធារណៈ សាលារៀន សាលាឃុំ សង្កាត់ សាលាស្រុក ខណ្ឌ ដោយយោងតាមស្ថានភាពជាក់ស្តែងនៃទីតាំងវិនិច្ឆ័យនីមួយៗ។

[138] រដ្ឋបាលខេត្តកណ្តាល, *ពិធីផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់វិនិច្ឆ័យ សម្រាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ចំនួន៣ឃុំ ក្នុងស្រុកលើកដែក,* https://www.kandal.gov.kh/detail/24736 ( ចូលមើលថ្ងៃទី៦ កក្កដា ២០២៤ )។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យដែលត្រូវបានចាត់តាំងដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ។[139] លើសពីនេះ មន្ត្រីកំណត់ព្រំ(ទទួលខុសត្រូវការកំណត់ព្រំ) មន្ត្រីវាស់វែង(ទទួលខុសត្រូវការវាស់វែង) និងមន្ត្រីវិនិច្ឆ័យ(ទទួលខុសត្រូវការវិនិច្ឆ័យ) មន្ត្រីទាំងបីផ្នែកត្រូវចុះទៅតាមផ្ទះនីមួយៗ នៅក្នុងតំបន់វិនិច្ឆ័យ ដើម្បីពិនិត្យ និងស្រង់ អំណះអំណាងកម្មសិទ្ធិ ឯកសារនានា កំណត់ព្រំ និងអង្កេតវាស់វែងក្បាលដី និងបញ្ជាក់អំពីព្រំប្រទល់ដីជាមួយម្ចាស់ដីឡូត៍នៅជាប់គ្នា។[140] ប្រជាពលរដ្ឋគ្រប់រូបដែលមានពាក់ព័ន្ធនឹងក្បាលដីនៅក្នុងតំបន់វិនិច្ឆ័យ ត្រូវមានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី និងក្នុងកិច្ចដំណើរការវិនិច្ឆ័យ ដោយត្រូវផ្តល់នូវចម្លើយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ឯកសារ ឬភស្តុតាងផ្សេងៗទៀតដល់មន្ត្រីជំនាញ ដើម្បីអនុវត្តការកំណត់ព្រំ ការវាស់វែង និងការវិនិច្ឆ័យ។[141]

**ការកំណត់ព្រំ និងការវាស់វែង៖** មន្ត្រីកំណត់ព្រំ ត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការឱ្យបានមុន ៣ថ្ងៃ យ៉ាងតិច ដើម្បីឱ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីជូនដំណឹង។[142] បន្ទាប់មកមន្ត្រីកំណត់ព្រំ ធ្វើការកំណត់ព្រំប្រទល់ក្បាលដី ហើយមន្ត្រីវាស់វែងត្រូវវាស់វែងក្បាលដីនោះ។ លើសពីនេះមន្ត្រីកំណត់ព្រំ និងមន្ត្រីវាស់វែងមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយនៅក្នុងតំបន់វិនិច្ឆ័យដើម្បីកំណត់ព្រំនិងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់ចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗទាក់ទងនិងព្រំនៃក្បាលដីណាមួយ។[143] ក្រោយពីបានកំណត់ព្រំ និងវាស់វែងដីចប់សព្វគ្រប់នឹងបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី ដោយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖[144]

- ក្នុងករណី ម្ចាស់ក្បាលដី និងម្ចាស់ក្បាលដីដែលជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងគ្នាលើព្រំប្រទល់នោះព្រំប្រទល់នឹងត្រូវកំណត់យោងតាមការព្រមព្រៀង។ ប៉ុន្តែម្ចាស់ក្បាលដីដែលមានព្រំជាប់គ្នាមិនព្រមព្រៀងគ្នាលើព្រំដី នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ ទាក់ទងនឹងព្រំដី។

---

139 សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី២ ចំណុច១ ទំព័រ៣។

140 វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia), *ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា,* ភ្នំពេញ៖ វិច្ឆិកា ២០១២, ទំព័រ៤០។

141 អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា៥។

142 អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦អនក្រ ៣១ ឧសភា ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា៧ថ្មី កថាខណ្ឌទី១។

143 អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា៤ កថាខណ្ឌទី៣។

144 អនុក្រឹត្យ ស្តីពីការកែសម្រួល មាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ ៤៦ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២ អនក្រ.បក, ៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា៧ ថ្មី។

- ក្នុងករណី ក្បាលដីមានព្រំប្រទល់ជាប់នឹងដីសាធារណៈឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់ដោយយោងតាមតាមឯកសារដែលមាន និងភស្តុតាងជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ ទាក់ទងនឹងព្រំដី។
- ក្នុងករណីមានវិវាទអំពីព្រំប្រទល់មិនអាចដោះស្រាយបាន ក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅគណៈកម្មការរដ្ឋបាលដើម្បីធ្វើការសម្រុះសម្រួល និងដោះស្រាយ បើនៅតែមិនអាចដោះស្រាយបានទៀតត្រូវបញ្ជូនបន្តទៅគណៈកម្មការសុរិយោដីដើម្បីដោះស្រាយតាមនីតិវិធីច្បាប់។

**ការវិនិច្ឆ័យ៖** ជាដំណើរការមួយ ដែលកំណត់សិទ្ធិជាធរមានលើក្បាលដីជាស្ថាពរ និងមានលក្ខណៈជាផ្លូវការ ដែលដំណើរការវិនិច្ឆ័យមិនមានការកែប្រែសិទ្ធិជាធរមានលើក្បាលដី ឬបង្កើតសិទ្ធិថ្មីឡើយ ហើយបន្ថែមពីលើការកំណត់សិទ្ធិជាធរមាន ដំណើរការវិនិច្ឆ័យក៏កំណត់ផងដែរនូវបុគ្គលដែលជាម្ចាស់សិទ្ធិនោះ ព្រមទាំងលក្ខខណ្ឌនានា ដែលមានចំពោះសិទ្ធិទាំងនោះ( ដូចជាប្រភេទទ្រព្យ ៖ ទ្រព្យរួមប្តីប្រពន្ធ, ទ្រព្យផ្ទាល់ខ្លួនខាងប្តី, ទ្រព្យផ្ទាល់ខ្លួនខាងប្រពន្ធ, សហកម្មសិទ្ធិ, ទ្រព្យក្រុមហ៊ុន, ទ្រព្យសហគមន៍ ឬសមាគម...) ហើយលទ្ធផលនៃការវិនិច្ឆ័យគឺការទទួលបាននូវបញ្ជីដីធ្លីមួយ ដែលមានលក្ខណៈពេញលេញច្បាស់លាស់ និងស្ថាពរ។”[145] អាស្រ័យហេតុនេះហើយទើបច្បាប់បានផ្តល់សិទ្ធិឱ្យមន្ត្រីវិនិច្ឆ័យមានសិទ្ធិសាកសួរយកព័ត៌មានចាំបាច់សម្រាប់អនុវត្តការងារវិនិច្ឆ័យ ព្រមទាំងអាចអញ្ជើញជនដែលពាក់ព័ន្ធ ឱ្យមកផ្តល់ចម្លើយដោយផ្ទាល់មាត់ ឬជាឯកសារ ឬភស្តុតាងផ្សេងៗ ដែលទាក់ទងនិងការវិនិច្ឆ័យ។[146] បន្ទាប់ពីសាកសួររួចហើយមន្ត្រីវិនិច្ឆ័យត្រូវប្រមូលឯកសារ ភស្តុតាង និងព័ត៌មានទាក់ទងនឹងសិទ្ធិលើក្បាលដីនីមួយៗក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនោះចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកកាន់កាប់ដីផ្តិតមេដៃ ហើយមន្ត្រីវិនិច្ឆ័យត្រូវចុះហត្ថលេខា និងឈ្មោះទទួលខុសត្រូវលើឯកសារនោះផងដែរ ហើយប្រសិនបើករណីមានវិវាទកើតឡើង ទាក់ទងនឹងព្រំប្រទល់ក្តី ទាក់ទងនឹងសិទ្ធិលើក្បាលដីក្តី មន្ត្រីវិនិច្ឆ័យត្រូវកត់ត្រាក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីថា ដីមានទំនាស់។[147]

- **ការងារការិយាល័យ**

ទិន្នន័យដែលប្រមូលបានពីការងារវាល ត្រូវបញ្ចូលក្នុងកុំព្យូទ័រ ដើម្បីកសាងប្លង់សុរិយោដី បញ្ជីឈ្មោះម្ចាស់ដី និងសៀវភៅគោលបញ្ជីដីធ្លី។[148]

---

[145] វេទិកាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (The NGO Forum on Cambodia), *ព្រឹត្តិប័ត្រប្រចាំត្រីមាស៖ ដីនិងជីវិត,* ឆ្នាំទី៣ លេខ៩, ខែមករា-មីនា ឆ្នាំ២០០៨, ទំព័រ៣។

[146] អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា៤ កថាខណ្ឌទី៤។

[147] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ចំណុច ១.១.៣, ទំព័រ៤ និង៥។

[148] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ចំណុច ២, ទំព័រ៥។

**៣. ដំណាក់កាលបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

ក្រោយពីបានបញ្ចូលទិន្នន័យនៃការវិនិច្ឆ័យចូលក្នុងកុំព្យូទ័រ ដើម្បីរៀបជាឯកសារនៃការវិនិច្ឆ័យរួចរាល់ហើយ គណៈកម្មការរដ្ឋបាលត្រូវលើកសំណើទៅអភិបាលខេត្ត ក្រុង ដើម្បីបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដែលក្នុងនោះមានបញ្ជាក់អំពីទីកន្លែង និងកាលបរិច្ឆេទនៃការបិទផ្សាយ បន្ទាប់មកអាជ្ញាធរ ខេត្ត ក្រុង នឹងធ្វើការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីក្នុងរយៈពេល ១៥ថ្ងៃ នៅកន្លែងដែលងាយមើលឃើញសម្រាប់ការអង្កេតជាសាធារណៈ ស្ថិតក្នុងតំបន់វិនិច្ឆ័យ។[149] ការបិទផ្សាយនេះធ្វើឡើងក្នុងគោលបំណងឱ្យមានភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការចូលរួមពិនិត្យទិន្នន័យ ដែលបានបិទផ្សាយជាសាធារណៈ នៅកន្លែងទាំងអស់នោះជាឧទាហរណ៍រួមមាន ទីវត្តអារាម កន្លែងសាធារណៈ សាលារៀន សាលាឃុំ/សង្កាត់ សាលាស្រុក/ខណ្ឌ ជាដើម។ គួរបញ្ជាក់ផងដែរថា មន្ត្រីគ្រប់គ្រងការងារវិនិច្ឆ័យ មានសិទ្ធិកែតម្រូវចំពោះតែការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ប្រយោជន៍ស្របច្បាប់នៃជនណាមួយ រីឯការកែតម្រូវណាដែលនាំឱ្យប៉ះពាល់ដល់ប្រយោជន៍ជនណាមួយ លុះត្រាតែមានការយល់ព្រមពីជនដែលមានផលប្រយោជន៍នោះទើបអាចកែតម្រូវបាន។ ទន្ទឹមនិងរយៈពេលនេះដែរ គណៈកម្មការរដ្ឋបាលត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ និងមន្ត្រីនៅមូលដ្ឋានមានជាអាទិ៍ មេឃុំ ចៅសង្កាត់ឱ្យមកប្រចាំការរង់ចាំពន្យល់ បំភ្លឺ ឬបកស្រាយនូវខ្លឹមសារនៃការវិនិច្ឆ័យ ឬរង់ចាំទទួលបណ្តឹងជំទាស់ ឬបណ្តឹងតវ៉ា នៅទីកន្លែងបិទផ្សាយជារៀងរាល់ថ្ងៃគិតទាំងថ្ងៃបុណ្យផងដែរ។[150] លើសពីនេះនៅក្នុងរយៈពេលបិទផ្សាយភាគីទាំងអស់ដែលពាក់ព័ន្ធ អាចធ្វើការផ្ទៀងផ្ទាត់ទិន្នន័យដែលបានបិទផ្សាយដើម្បីឱ្យប្រាកដថាមានភាពត្រឹមត្រូវ ប៉ុន្តែក្នុងករណីទិន្នន័យនោះមិនត្រឹមត្រូវគាត់អាចដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មការរដ្ឋបាលបាន ដើម្បីធ្វើការព្យាយាមដោះស្រាយដោយការផ្សះផ្សាវិវាទនោះ បើនៅតែមិនមានការព្រមព្រៀងគ្នាទេ ត្រូវបញ្ជូនសំណុំរឿងវិវាទនោះទៅគណៈកម្មការសុរិយោដីដើម្បីដោះស្រាយបន្ត។[151]

**៤. ដំណាក់កាលសម្រេចលើឯកសារនៃការវិនិច្ឆ័យ**

ក្រោយពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ គណៈកម្មការរដ្ឋបាលត្រូវចុះហត្ថលេខាយល់ព្រមលើឯកសារនៃការវិនិច្ឆ័យចំពោះក្បាលដីទាំងអស់ និងក្បាលដីដែលមានទំនាស់តែត្រូវបានសម្រុះសម្រួលរួចមុនរយៈពេលបិទផ្សាយជាសាធារណៈក្នុងតំបន់វិនិច្ឆ័យ លើកលែងតែក្បាលដីដែលមានទំនាស់និងមិនទាន់ដោះស្រាយរួច។ បន្ទាប់មកគណៈកម្មការរដ្ឋបាលត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅ

[149] អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ ៤៦ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២ អនក្រ.បក, ៩ ខែមិថុនា ឆ្នាំ២០១៦, មាត្រា១១ ថ្មី កថាខណ្ឌទី១ និង២។

[150] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី៣ កថាខណ្ឌទី៣, ទំព័រ៦។

[151] អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា១២។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខា ហើយបញ្ជូនបន្តទៅអភិបាលខេត្ត ក្រុងដើម្បីចុះហត្ថលេខា។[152] ក្រោយពីអភិបាលខេត្ត ក្រុង និងរដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បានចុះហត្ថលេខាសម្រេចយល់ព្រមរួចរាល់ហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរនិងត្រូវចាត់ទុកជាឯកសារត្រឹមត្រូវតាមផ្លូវច្បាប់ ចំពោះតែក្បាលដីដែលមិនទាក់ទងនិងវិវាទ ហើយត្រូវបញ្ជូនឯកសារនោះទៅរដ្ឋបាលសុរិយោដីដើម្បីធ្វើការចុះបញ្ជី រីឯក្បាលដីដែលមានវិវាទ ហើយមិនទាន់ដោះស្រាយចប់ជាស្ថាពរ អាចត្រូវបានបន្តការដោះស្រាយនៅគណៈកម្មការសុរិយោដី ឬនៅតុលាការ។[153]

**៥. ដំណាក់កាលចេញប័ណ្ណ**

នៅពេលដែលនីតិវិធីនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរ ឯកសារនៃការវិនិច្ឆ័យ និង ឯកសារណេបពាក់ព័ន្ធទាំងអស់ត្រូវបានបញ្ជូលទៅរដ្ឋបាលសុរិយោដីដើម្បីចុះបញ្ជី ចេញប័ណ្ណ និងគ្រប់គ្រង៖[154]

- ថ្នាក់កណ្តាល (អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ចំពោះឯកសារទាក់ទងនឹងខេត្ត ក្រុងណាដែលមិនទាន់ទទួលបានប្រតិភូកម្ម។
- ថ្នាក់ខេត្ត ក្រុង (មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី) ចំពោះឯកសារដែលទាក់ទងនឹងខេត្ត ក្រុងណាដែលបានទទួលប្រតិភូកម្មរួចហើយ។

**បន្ថែមពីនេះដើម្បីអាចចេញប័ណ្ណបានត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖**[155]

១- ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលបានកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់ភូមិបាល (មាត្រា៣០ វាក្យខណ្ឌទី១នៃច្បាប់ភូមិបាល)។

២- ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ(ប័ណ្ណភោគៈ) ចំពោះក្បាលដី ឬអចលនវត្ថុណាដែលកាន់កាប់ដោយសន្តិវិធី និងមិនមានការជំទាស់ និងមានរយៈពេលតិចជាង៥ឆ្នាំ មុនច្បាប់ភូមិបាលចូលជាធរមាន។ ប័ណ្ណប្រភេទនេះអាចប្តូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ នៅពេលដែលរយៈពេលនៃការកាន់កាប់ដី ឬអចលនវត្ថុនោះបានគ្រប់ ៥ឆ្នាំ ឬលើស។

៣- អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដី ឬអចលនវត្ថុណាដែលគ្មានពាក់ព័ន្ធនឹងវិវាទ។

៤- ការប្រគល់ប័ណ្ណត្រូវមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីអ្នកប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃអ្នកទទួលទុកជាភស្តុតាង។ ការប្រគល់ប័ណ្ណត្រូវប្រព្រឹត្តនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច។ មន្ត្រីសុរិយោដីមិនត្រូវបានអនុញ្ញាតឱ្យប្រគល់ប័ណ្ណជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែងតែ៖

[152] អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា១៣។

[153] អនុក្រឹត្យលេខ៤៦ ឆ្នាំ២០០២, មាត្រា១៤។

[154] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី៥, ទំព័រ៩។

[155] សារាចរណែនាំលេខ០០១ ឆ្នាំ២០០២, ដំណាក់កាលទី៥, ទំព័រ៩ និង១០។

- ករណីម្ចាស់សិទ្ធិទទួលមរណៈភាព ឬអវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាពដែលច្បាប់ទទួលស្គាល់ ពេលនោះអ្នកតំណាងស្របច្បាប់មានសិទ្ធិទទួលជំនួស
- ករណីពិសេស និងចាំបាច់ ម្ចាស់សិទ្ធិអាចដាក់ពាក្យសុំប័ណ្ណបាន តែត្រូវបញ្ជាក់ច្បាស់ពីហេតុដែលមិនអាចមកទទួលប័ណ្ណនៅការិយាល័យ ទើបអនុញ្ញាតឱ្យធ្វើការប្រគល់ប័ណ្ណនៅគេហដ្ឋានរបស់កម្មសិទ្ធិករ ឬភោគី ដោយមន្ត្រីសុរិយោដីយ៉ាងតិច ២នាក់។

៥- នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដី ឬអចលនវត្ថុត្រូវប្រគល់ប័ណ្ណចាស់ទាក់ទងនឹងសិទ្ធិលើដី ឬអចលនវត្ថុនោះជូនមន្ត្រីសុរិយោដី ប្រសិនបើមាន។

៦- ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព( នីតិបុគ្គលសាធារណៈ មានជាអាទិ៍ សាលារៀន សាលាឃុំ . . . នីតិបុគ្គលឯកជន មានជាអាទិ៍ សមាគម ក្រុមហ៊ុន ) មិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាដាច់ខាត។ ចំពោះដី ឬអចលនវត្ថុរបស់សមូហភាព ដូចជាវត្ត ឬសហគមន៍ជនជាតិដើមភាគតិចនៅក្នុងប័ណ្ណក៏ត្រូវចុះឈ្មោះ វត្ត ឬសហគមន៍...ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ។

ទាក់ទងដល់ការប្រើសិទ្ធិ និងការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យ នីតិបុគ្គលនានា ក៏ដូចជាសមូហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងៗខ្លួន តាមវិធីផ្សេងៗគ្នា ដូចជានីតិបុគ្គលសាធារណៈមានលិខិតតែងតាំង នីតិបុគ្គលឯកជនមានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬប្រធានសមាគម វត្តមានប្រធានគណៈកម្មការវត្ត សហគមន៍ ជនជាតិដើមភាគតិច មានប្រធានសហគមន៍ . . .។ល។ តំណាងស្របច្បាប់ទាំងនេះមានសិទ្ធិ និងកាតព្វកិច្ចទាក់ទងនឹងអចលនវត្ថុ ដូចម្ចាស់សិទ្ធិជារូបវន្តបុគ្គលដែរ។

ឯប័ណ្ណដី ឬអចលនវត្ថុរបស់នីតិបុគ្គលសាធារណៈ និងឯកជន ត្រូវប្រគល់ឱ្យតំណាងស្របច្បាប់នៃនីតិបុគ្គលនីមួយៗជាអ្នកទទួលយក និងរក្សាទុក។ ចំពោះប័ណ្ណដី ឬអចលនវត្ថុរបស់សមូហភាពត្រូវប្រគល់ជូនតំណាងស្របច្បាប់ ឬប្រធានសហគមន៍ទទួលយក និងរក្សាទុក។

### វាក្យខណ្ឌទី២៖ នីតិវិធីចុះបញ្ជីដីឯកជនតាមលក្ខណៈដាច់ដោយដុំ

សញ្ញាណនៃនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំត្រូវបានលេចរូបរាងឡើងដំបូងនៅពេលដែលឯកជនភាវូបនីយកម្មដីធ្លីបានកើតឡើងនៅខែមិថុនាឆ្នាំ១៩៨៩ដោយសារតែនៅពេលនោះប្រជាពលរដ្ឋជាអ្នកដើរតួនាទីយ៉ាងសំខាន់ក្នុងការដាក់ពាក្យសុំកាន់កាប់ដីធ្លី ចំណែកឯអាជ្ញាធរមានសមត្ថកិច្ចគឺមានលក្ខណៈអកម្ម។[156] ទោះបីជារូបភាពនៃការដាក់ពាក្យសុំចុះបញ្ជីដីនៅពេលនោះមានរូបភាពលក្ខណៈដាច់ដោយដុំក៏ពិតមែន ប៉ុន្តែអ្វីគួរឱ្យកត់សម្គាល់នោះគឺគេមិនទាន់មានឃើញមានអនុក្រឹត្យ ឬច្បាប់ណាមួយមានចែងច្បាស់ពីនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំនៅឡើយ ពោលគឺទាល់តែមកទល់កំឡុងឆ្នាំ២០០២ទេទើបគេឃើញមានអនុក្រឹត្យលេខ៤៨អនក្រ/បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ និងសារាចរណែនាំអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំលេខ១៤ ដនស/សរណន ចុះថ្ងៃទី៣០ កញ្ញា ២០០៩ បានបញ្ជាក់បន្ថែមពីនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ដែលត្រូវបានអនុម័ត

[156] ហាប់ ផល្លី, *នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា* (ភ្នំពេញ៖ Premium Advertising, ២០២១ ), ទំព័រ៥២។

ដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកតាមរយៈមាត្រា១នៃអនុក្រឹត្យបានកំណត់ថាការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសំដៅដល់ការចុះបញ្ជីនូវអចលនវត្ថុទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុងតំបន់ដែលមិនទាន់បានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ។ បានសេចក្តីថាប្រសិនបើប្រជាពលរដ្ឋណាដែលចង់ចុះបញ្ជីដី ក្នុងតំបន់មិនទាន់មានដំណើរការនៃការចុះបញ្ជីដីជាប្រព័ន្ធមិនទាន់ទៅដល់ នោះគាត់អាចដាក់ពាក្យសុំចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំបាន ពោលគឺអនុវត្តចំពោះក្បាលដីណាដែលនៅក្រៅតំបន់វិនិច្ឆ័យ។ លើសពីនេះទៅទៀតអនុក្រឹត្យនេះក៏បានចែងផងដែរអំពីនីតិវិធីនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំដែលគេអាចមើលឃើញថាមាន ៥ដំណាក់កាលធំៗដែលមានដូចជា ដំណាក់កាលដាក់ពាក្យស្នើសុំចុះបញ្ជី ដំណាក់កាលប្រតិបត្តិការបច្ចេកទេស  ដំណាក់កាលការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដំណាក់កាលសម្រេចលើឯកសារ និងដំណាក់កាលចេញប័ណ្ណ។  ដូច្នេះដើម្បីឱ្យកាន់តែយល់ច្បាស់អំពីនីតិវិធីយើងនឹងធ្វើការបកស្រាយលម្អិតទៅតាមដំណាក់កាលនីមួយៗដែលមានចែងក្នុងអនុក្រឹត្យ។

**១. ដំណាក់កាលដាក់ពាក្យស្នើសុំចុះបញ្ជី**

នៅក្នុងដំណាក់កាលនេះអ្នកកាន់កាប់ដីដែលមានបំណងស្នើសុំចុះបញ្ជីក្បាលដីរបស់ខ្លួន ត្រូវបំពេញពាក្យសុំតាមគម្រូដែលបានរៀបចំ ដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង តាមរយៈមេឃុំ ចៅសង្កាត់ ដែលក្បាលដីនោះស្ថិតនៅ។ ពាក្យស្នើសុំត្រូវមានដូចជា៖[157]

- ឈ្មោះ និងស្នាមមេដៃរបស់អ្នកដាក់ពាក្យសុំ
- ការពិពណ៌នាលំអិតពីក្បាលដីដែលស្នើសុំចុះបញ្ជី និងទីតាំងរបស់ក្បាលដីនោះ
- ការពិពណ៌នាអំពីសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី
- ឯកសារ ឬ/និងភស្តុតាងផ្សេងៗទាក់ទងនឹងក្បាលដីដែលស្នើសុំចុះបញ្ជី។

បន្ទាប់មកមេឃុំចៅសង្កាត់ត្រូវពិនិត្យមើលលើពាក្យសុំថាបានបំពេញគ្រប់គ្រាន់ឬអត់ ប្រសិនបើពាក្យសុំបានបំពេញគ្រប់គ្រាន់ហើយមេឃុំចៅសង្កាត់ត្រូវចារលើពាក្យស្នើសុំ រួចធ្វើបែបបទបញ្ជូនពាក្យសុំនោះមកកាន់រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ។ នៅពេលទទួលបានពាក្យស្នើសុំរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យមើលលើពាក្យសុំនោះដោយផ្អែកទៅលើគោលការណ៍ជំនាញ និងច្បាប់។ នៅក្នុងករណីដែលពិនិត្យទៅឃើញថាពាក្យសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុងត្រូវកត់ត្រាពាក្យស្នើសុំទាំងនោះចូលក្នុងសៀវភៅទទួលពាក្យចុះលេខ រួចចារលើពាក្យស្នើសុំនោះ កំណត់កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវចុះអនុវត្ត កំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ហើយប្រគល់ពាក្យមួយច្បាប់ជូនអ្នកដាក់ពាក្យវិញ។[158] ប៉ុន្តែ

[157] អនុក្រឹត្យលេខ៤៨ ឆ្នាំ២០០២, មាត្រា៧។

[158] សារាចរណែនាំលេខ០១៤ ឆ្នាំ២០០៩, ដំណាក់កាលទី១។

ប្រសិនបើក្នុងករណីដែលពិនិត្យទៅឃើញថាពាក្យសុំមិនទាន់ត្រឹមត្រូវ ឬមានលក្ខណៈមិនទាន់គ្រប់គ្រាន់ ដោយសារតែការចូលកាន់កាប់ដីក្រោយថ្ងៃទី៣០ សីហា ២០០១ ឬការកាន់កាប់ដីមានលក្ខណៈមិនសមស្រប (ទុច្ចរិត) ឬការចូលកាន់កាប់លើដីសាធារណៈរបស់រដ្ឋជាដើម រដ្ឋបាលសុរិយោដីត្រូវចារលើពាក្យស្នើសុំ ព្រមទាំងមានបញ្ជាក់ផងដែរចំពោះមូលហេតុដែលមាននៅលើដី ជាហេតុមិនអាចឈានទៅដល់ការអនុវត្តនីតិវិធីបាន និងត្រូវមានភស្តុតាងបញ្ជាក់ភ្ជាប់ជាមួយពាក្យស្នើសុំ នោះរួចបញ្ជូនពាក្យសុំនោះទៅកាន់អ្នកដាក់ពាក្យស្នើសុំវិញ ប៉ុន្តែប្រសិនបើពាក្យដែលស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់ហើយតែរដ្ឋបាលសុរិយោដីបដិសេធមិនព្រមអនុវត្តនីតិវិធីតាមការស្នើសុំនោះ សាមីអ្នកស្នើសុំ ឬអ្នកតំណាងស្របច្បាប់របស់ជននោះអាចដាក់ពាក្យបណ្ដឹងទៅកាន់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសុរិយោដីរាជធានី ខេត្ត ឬដាក់ទៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បាន។ ចំណែកឯក្នុងករណីដែលពិនិត្យឃើញថាមានវិវាទពាក់ព័ន្ធនឹងក្បាលដីដែលស្នើសុំចុះបញ្ជីនោះរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនសំណុំវិវាទនោះទៅគណៈកម្មការសុរិយោដីដោះស្រាយតាមនីតិវិធីច្បាប់។[159]

ផ្ទុយទៅវិញ ប្រសិនបើពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ មិនមានវិវាទ ឬមានវិវាទប៉ុន្តែបានដោះស្រាយរួច រដ្ឋបាលសុរិយោដីត្រូវចេញសេចក្ដីជូនដំណឹងអំពីកាលបរិច្ឆេទនៃការចុះកំណត់ព្រំដីរួចត្រូវប្រគល់ឱ្យអ្នកដាក់ពាក្យសុំ និងបិទផ្សាយជាសាធារណៈឱ្យបានយ៉ាងតិចរយៈពេល ៧ថ្ងៃ នៅក្នុងសាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ និងនៅកន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដីរបស់អ្នកស្នើសុំចុះបញ្ជីនោះស្ថិតនៅ។[160]

**២. ដំណាក់កាលកិច្ចការបច្ចេកទេស**

នៅក្នុងដំណាក់កាលទីពីរនេះកិច្ចការបច្ចេកទេសនៅក្នុងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំត្រូវបានបែងចែកជាពីរទៀតគឺអំពី ការងារវាល និងការងារនៅការិយាល័យខាងក្រោមនេះគឺជាការបកស្រាយលម្អិតលើចំណុចទាំងពីរនេះ។

- **ការងារវាល**

មន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងវាស់វែងត្រូវកំណត់ព្រំក្បាលដីដែលស្នើសុំចុះបញ្ជីតាមពេលវេលាដែលបានជូនដំណឹងដោយយោងតាមសេចក្ដីណែនាំរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការណែនាំរបស់រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ។ ការងារវាលត្រូវអនុវត្តដោយមន្ត្រីជំនាញដោយមានការសហការ និង

[159] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី១។

[160] អនុក្រឹត្យ ស្ដីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ៣១ ឧសភា ២០០២ ស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា៩ ថ្មី។

ជ្រោមជ្រែងពីអាជ្ញាធរនៅមូលដ្ឋាន។ មន្ត្រីទទួលបន្ទុកកំណត់ព្រំដីត្រូវចុះប្រតិបត្តិការតាមពេលវេលាកំណត់ ហើយត្រូវតែគោរពនូវគោលការណ៍ដែលមានដូចខាងក្រោម[161]៖

- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ និងម្ចាស់ដីព្រំជាប់គ្នាមានវត្តមានហើយព្រមព្រៀងគ្នាអំពីព្រំប្រទល់ និងគ្មានភស្តុតាងផ្ទុយ ការកំណត់ត្រូវយកតាមការព្រមព្រៀង។
- ក្នុងករណី ម្ចាស់ដីជាប់ព្រំមិនមានវត្តមាន ការកំណត់ត្រូវធ្វើទៅតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ទាក់ទងនឹងព្រំដីនោះ។
- ក្នុងករណីដីដែលស្នើសុំចុះបញ្ជីនោះនៅជាប់នឹងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ នោះការកំណត់ព្រំត្រូវធ្វើទៅតាមចំណុចទាំងពីរខាងលើ។
- ក្នុងករណីដែលក្បាលដីមានវិវាទមិនអាចដោះស្រាយបាននោះត្រូវបញ្ជូនទៅសម្រុះសម្រួលនៅថ្នាក់ស្រុក ខណ្ឌ ស្របតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី។

បន្ទាប់មកមន្ត្រីសុរិយោដីដែលទទួលបន្ទុកវាស់វែងត្រូវធ្វើការវាស់វែង។ ការវាស់វែងអាចធ្វើតាមមធ្យោបាយពីរដែលអាស្រ័យទៅលើលក្ខណៈនៃភូមិសាស្ត្រ និងឧបករណ៍វាស់វែង ដើម្បីបំពេញទៅតាមតម្រូវការនៃការកសាងផែនទីក្បាលដី (Parcel Map) គំនូសបង្ហាញទីតាំងក្បាលដី និងផែនទីមានលក្ខណៈដាច់ដោយដុំ (Sporadic Index Map) ក្នុងតំបន់នីមួយៗ។

បន្ទាប់មកមន្ត្រីដែលទទួលបន្ទុកការងារវិនិច្ឆ័យ មានភារកិច្ច អង្កេតលើឯកសារដែលមាន ភស្តុតាង និងព័ត៌មានជាលាយលក្ខណ៍អក្សរ និងព័ត៌មានផ្ទាល់មាត់ទាក់ទងនឹងសិទ្ធិលើក្បាលដី[162] ចូលក្នុងទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី រួចឱ្យអ្នកដែលជាប់ពាក់ព័ន្ធទាំងអស់ផ្តិតមេដៃ ហើយមន្ត្រីសុរិយោដីនោះក៏ត្រូវចុះហត្ថលេខា និងឈ្មោះលើឯកសារនោះផងដែរ។[163]

**<u>កំណត់សម្គាល់</u>**៖ ក្នុងការអនុវត្តនូវការងារវាលនេះផងដែរមន្ត្រីសុរិយោដីមានសិទ្ធិចេញចូលបរិវេណដីដោយសេរី ដើម្បីកំណត់ និងវាស់វែងនឹងអាចអញ្ជើញជនពាក់ព័ន្ធឱ្យមកផ្តល់ព័ត៌មានដោយផ្ទាល់មាត់ ឬ ឯកសារភស្តុតាងជាអាទិ៍ដែលទាក់ទងនឹងព្រំដី ហើយអ្នកកាន់កាប់ដីត្រូវមានកាតព្វកិច្ចចូលរួមនៅក្នុងនីតិវិធីនេះផងដែរ។

- **ការងារការិយាល័យ**

បន្ទាប់ពីការងារវាលត្រូវបានបញ្ចប់ ទិន្នន័យទាំងអស់ដែលប្រមូលបានពីការងារវាល រដ្ឋបាលសុរិយោដីត្រូវកសាងផែនទីក្បាលដី ផែនទីបង្ហាញទីតាំងដីស្នើសុំផែនទីមានលក្ខណៈដាច់ដោយដុំកសាងបញ្ជីឈ្មោះម្ចាស់

[161] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី២ ចំណុចទី១.១។

[162] អនុក្រឹត្យលេខ៤៨ ឆ្នាំ២០០២, មាត្រា១១។

[163] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាកកាលទី២ ចំណុច១.១។

ដី ហើយបញ្ចូលទិន្នន័យទាំងអស់នោះទៅក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ។[164] ការបញ្ចូលទិន្នន័យអាចធ្វើបាន តាមវិធីពីរគឺ ការបញ្ចូលក្នុងកុំព្យូទ័រចំពោះក្បាលដីទាំងឡាយណាដែលបានធ្វើឡើងដោយឧបករណ៍ទំនើប[165] ហើយមួយវិញទៀតអាចគូរផែនទីក្បាលដី គូរគំនូរបង្ហាញទីតាំងដីស្នើសុំ ចំពោះក្បាលដីទាំងឡាយណាដែលធ្វើ ឡើងដោយឧបករណ៍សាមញ្ញ។[166]

**៣. ដំណាក់កាលបិទផ្សាយជាសាធារណៈនៅឯកសារនៃការវិនិច្ឆ័យ**

ក្រោយពីបានពិនិត្យអំពីភាពច្បាស់លាស់ខាងបច្ចេកទេសរួចមក រដ្ឋបាលសុរិយោដីស្រុកខណ្ឌ ត្រូវចុះហត្ថលេខាលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី។[167] បន្ទាប់មកអភិបាលក្រុង ស្រុក ត្រូវជូនដំណឹងដល់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីដីអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យយ៉ាងតិច ៣ថ្ងៃ មុនការបិទផ្សាយ។[168] ចំពោះឯកសារដែលត្រូវបិទផ្សាយរួមមានដូចជាផែនទីក្បាលដី គំនូសបង្ហាញក្បាលដី និងឈ្មោះម្ចាស់ដី ដែលនឹងត្រូវធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ នៅទីកន្លែងដែលងាយមើលឃើញ នៅក្នុងភូមិ សាលាឃុំ សាលាស្រុក ខណ្ឌ ក្រុងដែលក្បាលដីនោះស្ថិតនៅ។[169]

នៅក្នុងរយៈពេលនៃការបិទផ្សាយ សាមីអ្នកកាន់កាប់ដី ឬអ្នកតំណាងស្របច្បាប់ និងជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងក្បាលដីស្នើសុំចុះបញ្ជី អាចជូនដំណឹងពីការជំទាស់របស់ខ្លួន ឬធ្វើបណ្តឹងតវ៉ា ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ដល់អ្នកប្រចាំការកន្លែងបិទផ្សាយនៅសាលាក្រុង ស្រុក ខណ្ឌ អំពីភាពខ្វះចន្លោះ ឬភាពខុសឆ្គងនៃឯកសារដែលបានបិទផ្សាយ។ រដ្ឋបាលសុរិយោដីត្រូវបើកការស៊ើបអង្កេតទៅលើបណ្តឹងនោះប្រសិនបើបណ្តឹងនោះមានភាពសមហេតុផលដែលបណ្តាលមកពីកំហុសរបស់មន្ត្រីសុរិយោដីក្នុងការបញ្ចូលឯកសារ ហើយមិនប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ជនណាមួយនោះរដ្ឋបាលសុរិយោដីអាចធ្វើការកែតម្រូវបាន ហើយចំពោះការតវ៉ាផ្សេងៗទៀតអាចធ្វើបានដរាបណាមានការយល់ព្រមពីជនដែលពាក់ព័ន្ធដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។ ផ្ទុយទៅវិញប្រសិនបើ ការជំទាស់នោះមានលក្ខណៈមិនសមហេតុផល ឬមិនអាចធ្វើការសម្រុះសម្រួលបាននោះត្រូវបញ្ជូនទៅធ្វើការដោះស្រាយនៅគណៈកម្មការសុរិយោដី។[170] ម៉្យាង

[164] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី២ ចំណុចទី២។

[165] ឧបករណ៍ទំនើប មានដូចជា Theodolitte Total Station EDM GPS Orthophoto។

[166] ឧបករណ៍សាមញ្ញ មានដូចជា ឧបករណ៍ខ្សែម៉ែត្រ ឬខ្សែ ម៉ែត្រនិងព្រីស( Prism )។

[167] អនុក្រឹត្យលេខ៤៨ ឆ្នាំ២០០២, មាត្រា១៣។

[168] អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ៣១ ឧសភា ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា១៣ ថ្មី។

[169] អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ៣១ ឧសភា ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ, លេខ១២១ អនក្រ.បក, ៩ មិថុនា ២០១៦, មាត្រា១៣ ថ្មី។

[170] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី៣។

ទៀតប្រសិនបើក្នុងករណីមិនមានការជំទាស់ ឬការតវ៉ាក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈទិន្នន័យដែលបានកត់ត្រាក្នុងឯកសារបិទផ្សាយនោះត្រូវបានចាត់ទុកជាទិន្នន័យសុក្រឹតដែលអាចកំណត់យកជាផ្លូវការតាមច្បាប់។ ហើយក្រោយផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងការបញ្ចប់ការដោះស្រាយទំនាស់ រដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ត្រូវបញ្ចូលក្បាលដីទៅក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ[171]

**៤. ដំណាក់កាលសម្រេចលើឯកសារ**

បន្ទាប់ពីផុតរយៈពេលនៃការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យមន្ត្រីជំនាញទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការវិនិច្ឆ័យតាមខ្លឹមសារដូចខាងក្រោម[172]៖

- **លទ្ធផលសម្រេចបាន**

- ចំនួនក្បាលដីសរុបដែលបានធ្វើការវិនិច្ឆ័យ
- ចំនួនក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានវិវាទ ហើយគួរផ្តល់ប័ណ្ណ
- ចំនួនក្បាលដីដែលមិនគួរផ្តល់ប័ណ្ណជូនមានជាអាទិ៍៖

+ ក្បាលដីដែលស្នើសុំត្រូវបានកាន់កាប់ក្រោយច្បាប់ភូមិបាលចូលជាធរមាន

+ ក្បាលដីកំពុងមានវិវាទ ដែលបានបញ្ជូនទៅគណៈកម្មការសុរិយោដី ឬកំពុងមានបណ្តឹង និងកំពុងដំណើរការនីតិវិធីនៅតុលាការ។

- **ដំណើរការនៃការវិនិច្ឆ័យ**

មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យត្រូវវាយតម្លៃ លើកសំណើផ្តល់សិទ្ធិលើដី ឬអចលនវត្ថុ ជូនអ្នកកាន់កាប់ដែលបានស្នើសុំ ឬអាជ្ញាធរដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងតាមប្រភេទ កម្មសិទ្ធិ ភោគៈសម្បទាន មិនត្រូវផ្តល់ប័ណ្ណជាលក្ខណៈឯកជន ឬរក្សាទុកជាទ្រព្យរដ្ឋ ដោយយោងតាមច្បាប់បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងឯកសារភស្តុតាងដែលប្រមូលបាន។

មន្ត្រីជំនាញដែលទទួលបន្ទុកការងារវិនិច្ឆ័យ ត្រូវគូសក្បាលដីដែលមានលក្ខណៈត្រឹមត្រូវ និងគ្មានទំនាស់ ចូលក្នុងផែនទីមានលក្ខណៈដាច់ដោយដុំ។

ក្រោយពីផែនទីក្បាលដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី បានកែតម្រូវរួចហើយមន្ត្រីជំនាញ ដែលទទួលបន្ទុកការងារវិនិច្ឆ័យក្បាលដីតាមពាក្យស្នើសុំត្រូវរៀបចំសំណុំឯកសារដូចខាងក្រោម ដើម្បីដាក់ជូនរដ្ឋបាលសុរិយោដីក្រុង ស្រុក ខណ្ឌ ពិនិត្យ និងចុះហត្ថលេខាបញ្ជូនសំណុំរឿងទាំងមូលទៅលោកអភិបាល ក្រុង ស្រុក

---

[171] អនុក្រឹត្យលេខ៤៨ ឆ្នាំ២០០២, មាត្រា១៥។

[172] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី៤។

ខណ្ឌ និងពិនិត្យ និងបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីរាជធានី ខេត្ត។ ឯកសារដែលត្រូវបញ្ជូនបន្តទៅរដ្ឋបាលសុរិយោដីរាជធានីខេត្តមានដូចជា៖

- ពាក្យស្នើសុំ
- ឯកសារនៃការវិនិច្ឆ័យ (ឯកសារទាក់ទងនឹងការកំណត់ព្រំដី ការវាស់វែង ទំរង់បែបបទនៃការប្រមូលទិន្នន័យ ផែនទីក្បាលដី)
- សេចក្ដីជូនដំណឹងស្ដីពីកាលបរិច្ឆេទនៃការកំណត់ព្រំដី
- ការដកស្រង់ផែនទីមានលក្ខណៈដាច់ដោយដុំ ឬគំនូសបង្ហាញទីតាំងក្បាលដី
- សេចក្ដីជូនដំណឹងពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ
- របាយការណ៍ស្ដីពីលទ្ធផលនៃការវិនិច្ឆ័យ
- ពាក្យបណ្ដឹងជំទាស់តវ៉ាដែលពុំអាចដោះស្រាយបាន ប្រសិនបើមាន
- លិខិតស្នើសុំកែតម្រូវ ប្រសិនបើមាន
- កំណត់ហេតុសម្រុះសម្រួលវិវាទដែលបានដោះស្រាយរួច ប្រសិនបើមាន។

<u>**កំណត់សម្គាល់**</u>៖ នៅក្នុងដំណាក់កាលនេះគឺជាភារកិច្ចរបស់ក្រុមការងាររដ្ឋបាលសុរិយោដីសុទ្ធសាធដែលមិនតម្រូវឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ដីចូលរួមនោះឡើយ។

**៥. ដំណាក់កាលចេញប័ណ្ណ**

បន្ទាប់ពីទទួលបានសំណុំរឿងពីរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ក្រុង រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ត្រូវ៖[173]

- ពិនិត្យ និងផ្ដល់យោបល់ជូនអភិបាលរាជធានី ខេត្ត សំរេចយល់ព្រមឱ្យចេញប័ណ្ណ ឬជំទាស់ត្រង់ចំណុចណា ឬច្រានចោលទាំងស្រុងតែម្ដង។
- ករណីអភិបាលរាជធានី ខេត្ត សំរេចយល់ព្រមឱ្យចេញប័ណ្ណ រដ្ឋបាលសុរិយោដីរាជធានី ខេត្ត ដែលទទួលប្រតិភូកម្មហត្ថលេខាពីក្រសួងអាណាព្យាបាលអាចចេញប័ណ្ណជូនសាមីអ្នកស្នើសុំតែម្ដង។
- ករណីអភិបាលរាជធានី ខេត្ត ជំទាស់ត្រង់ចំណុចណាមួយ ឬច្រានចោល អភិបាលរាជធានី ខេត្ត នោះត្រូវបញ្ជាក់ឱ្យបានច្បាស់ពីមូលហេតុនៃការជំទាស់ ឬការច្រានចោលនោះដើម្បីរដ្ឋបាលសុរិយោដីជម្រាបទៅអ្នកស្នើសុំឱ្យបានជ្រាប។

[173] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី៥។

- ពិនិត្យ និងផ្តល់យោបល់ជូនដល់អភិបាលរាជធានី ខេត្ត សំរេចយល់ព្រម ឬជំទាស់ត្រង់ចំណុចណាមួយ ឬប្រានចោលមិនផ្តល់ប័ណ្ណជូនអ្នកស្នើសុំឱ្យបានជ្រាប។

- ករណីអភិបាលរាជធានីខេត្តសំរេចយល់ព្រម រដ្ឋបាលសុរិយោដីរាជធានីខេត្តណាដែលមិនទាន់បានទទួលប្រតិភូកម្មពីក្រសួងអាណាព្យាបាល ត្រូវបញ្ជូនសំណុំរឿងបន្តមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដើម្បីពិនិត្យបន្ថែមតាមគោលការណ៍ជំនាញបើឃើញថាត្រឹមត្រូវ ត្រូវធ្វើការចុះបញ្ជី ហើយចេញប័ណ្ណជូនអ្នកស្នើសុំ។ ប្រសិនបើមានចំណុចណាមួយមិនទាន់ត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវណែនាំរដ្ឋបាលសុរិយោដីរាជធានី ខេត្តកែតម្រូវ ឬបំពេញឡើងវិញដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់ជាមូលដ្ឋាន។
- ករណីដែលអភិបាលរាជធានី ខេត្ត ជំទាស់ត្រង់ចំណុចណាមួយ ឬធ្វើការប្រានចោលទាំងស្រុងតែម្តង រដ្ឋបាលសុរិយោដី រាជធានី ខេត្ត ត្រូវពិនិត្យមើលចំណុចនោះឡើងវិញ ហើយរាយការណ៍សុំយោបល់អភិបាលរាជធានី ខេត្ត នោះជាលើកទី២ ប្រសិនបើពិនិត្យឃើញថាមូលហេតុនៃការជំទាស់ ឬប្រានចោលនោះ មិនសមស្របនឹងសភាពការណ៍ពិតដូចដែលគាត់បានដឹង។
- ករណីដែលអភិបាលរាជធានី ខេត្តនៅតែរក្សាការសម្រេចលើកទីមួយរដ្ឋបាលសុរិយោដីរាជធានីខេត្ត ត្រូវបញ្ជូន សំណុំរឿងនោះមកអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដោយភ្ជាប់យោបល់ជំទាស់ ឬប្រានចោល និងរបាយការណ៍ពិនិត្យឡើងវិញមកជាមួយ ដើម្បីឱ្យអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រពិនិត្យ និងសម្រេច។

**បន្តមកទៀតនឹងឈានចូលដល់ការចេញប័ណ្ណ ដែលនៅក្នុងការចេញប័ណ្ណរដ្ឋបាលសុរិយោដីត្រូវគោរពនូវគោលការណ៍ ដែលមានដូចខាងក្រោម៖**[174]

១- សមត្ថកិច្ចក្នុងការសម្រេចលើទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី និងការចេញប័ណ្ណដីត្រូវបានប្រគល់ សិទ្ធិជូនរដ្ឋបាលសុរិយោដីខេត្ត ក្រុង លើកលែងតែដីដែលមានទំហំលើសពី ២០ហិកតាឡើងទៅ ដែលត្រូវសម្រេចដោយ រដ្ឋបាលសុរិយោដីថ្នាក់កណ្តាល។ ចំណែកឯសមត្ថកិច្ចក្នុងការវាស់វែងគឺអាស្រ័យទៅលើសមត្ថភាពបច្ចេកទេសរបស់មន្ត្រីមូលដ្ឋាន និងឧបករណ៍ប្រើប្រាស់ដែលមាន។ ករណីមិនអាចធ្វើបាន ឬមានទំហំលើសពី ២០ហិកតា រដ្ឋបាលសុរិយោដីខេត្ត ក្រុង ត្រូវលើកសំណើមករដ្ឋបាលសុរិយោដីថ្នាក់កណ្តាលដើម្បីឧបត្ថម្ភ។

២- ចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប័ណ្ណកម្មសិទ្ធិ) ជូនចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុនថ្ងៃទី៣០ សីហា ២០០១ ឬបានកាន់កាប់បន្តពីភោគីដើម មានលក្ខណៈត្រឹមត្រូវតាមច្បាប់

[174] សារាចរណែនាំលេខ១៤ ឆ្នាំ២០០៩, ដំណាក់កាលទី៥។

មិន មានការជំទាស់ មានរយៈពេល ៥ឆ្នាំយ៉ាងតិច គិតពីថ្ងៃចូលកាន់កាប់ដីមកដល់ថ្ងៃចេញប័ណ្ណ ហើយក្បាលដីនោះត្រូវ បានកសាងផែនទីក្បាលដីដែលមាននិយាមកាច្បាស់លាស់រួច។

៣- ចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ (ប័ណ្ណភោគៈ) ជូនចំពោះក្បាលដីណាដែលម្ចាស់សិទ្ធិបានចូលកាន់កាប់ដីមុនថ្ងៃទី៣០ សីហា ២០០១ ឬកាន់កាប់បន្តពីភោគីដើមមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហើយមានរយៈពេលតិចជាង ៥ឆ្នាំ ឬក្នុងករណីដែលបានកាន់កាប់លើសពី ៥ឆ្នាំ តែមិនទាន់បានកសាងផែនទីក្បាលដីដែល មាននិយាមកាច្បាស់លាស់រួច។ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុដែលបានផ្តល់ឱ្យតាមនីតិវិធីចុះបញ្ជីថ្មីនេះ អាចដូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបាន នៅពេលដែលរយៈពេលនៃការកាន់កាប់ដីបានគ្រប់ ៥ឆ្នាំ ឬលើស ហើយប្លង់សុរិយោដីត្រូវបានកសាងរួច។

៤- អាចចេញប័ណ្ណជូនបានចំពោះតែក្បាលដីណាដែលគ្មានទាក់ទិននឹងវិវាទ ឬមានវិវាទតែត្រូវបានដោះស្រាយចប់ជាស្ថាពរ។

៥- មិនអាចចេញប័ណ្ណជូនបានទេចំពោះក្បាលដីដែលអ្នកស្នើសុំបានចូលកាន់កាប់ដីក្រោយច្បាប់ភូមិបាលចូលជាធរមាន។

៦- មិនអាចចេញប័ណ្ណជូនជាឯកជនបានទេ ចំពោះក្បាលដីណាដែលត្រូវបានកំណត់ទាំងស្រុងជា ទ្រព្យសម្បត្តិសាធារណៈ ឬទុកបម្រើសេវាសាធារណៈ។ ចំពោះក្បាលដីស្នើសុំចុះបញ្ជី ដែលមានចំណែកណាមួយត្រួតគ្នាលើដីដែលជាសម្បត្តិសាធារណៈ ឬទុកបម្រើសេវាសាធារណៈអាចចេញប័ណ្ណជូនបុគ្គលឯកជនបានលុះត្រាតែចំណែកត្រួតគ្នានោះត្រូវបានដកចេញពីទំហំសរុបនៃក្បាលដី។

៧- នៅពេលទទួលប័ណ្ណថ្មី ម្ចាស់ដីត្រូវប្រគល់ឯកសារទាំងអស់ទាក់ទងនឹងសិទ្ធិលើក្បាលដីនោះដែលខ្លួនមានពីមុនមក ជូនមន្ត្រីសុរិយោដី។ រាល់ឯកសារទាក់ទងនឹងសិទ្ធិលើក្បាលដីដែលសាមីម្ចាស់ដីមិនបានប្រគល់ ឬមិនបានរាយការណ៍ពីការប្រើប្រាស់ជូនមន្ត្រីជំនាញមានសមត្ថកិច្ចត្រូវបានចាត់ទុកជាមោឃៈ និងមិនមានអានុភាពតាមផ្លូវច្បាប់។

៨- ការប្រគល់ប័ណ្ណដីត្រូវបានធ្វើឡើងដោយមានសៀវភៅសម្រាប់កត់ឈ្មោះ និងចុះហត្ថលេខាមន្ត្រីប្រគល់ និងកត់ឈ្មោះ រួចផ្តិតមេដៃអ្នកទទួលទុកជាភស្តុតាងផង។ ការប្រគល់ប័ណ្ណដីត្រូវប្រព្រឹត្តនៅអង្គភាពសុរិយោដីដែលមានសមត្ថកិច្ច។ មន្ត្រីសុរិយោដីមិនត្រូវបានអនុញ្ញាតឱ្យប្រគល់ប័ណ្ណដី ជូនបុគ្គលក្រៅពីម្ចាស់សិទ្ធិពិតប្រាកដឡើយ លើកលែង៖

- ករណីម្ចាស់សិទ្ធិទទួលមរណភាព ឬអវត្តមាន ឬត្រូវបាត់ខ្លួន ឬបាត់បង់សមត្ថភាព ហើយត្រូវបានច្បាប់ទទួលស្គាល់អ្នកតំណាងស្របច្បាប់

- ករណីពិសេស និងចាំបាច់ ម្ចាស់សិទ្ធិអាចប្រគល់សិទ្ធិឱ្យអ្នកតំណាងស្របច្បាប់របស់ខ្លួនមកទទួលយក ប័ណ្ណជំនួស តែត្រូវបញ្ជាក់ច្បាស់ជាលាយលក្ខណ៍អក្សរអំពីហេតុដែលមិនអាចមកទទួលយកនៅរដ្ឋបាលសុរិយោដី។

៩- ចំពោះនីតិបុគ្គល ប័ណ្ណត្រូវចុះឈ្មោះអង្គភាព ឬនាមករណ៍ ( នីតិបុគ្គលសាធារណៈ មានជាអាទិ៍ សាលារៀន សាលាឃុំ . . . នីតិបុគ្គលឯកជនមានជាអាទិ៍ សមាគម ក្រុមហ៊ុន . . . ) គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គល ជាដាច់ខាត ចំពោះដី ឬអចលនវត្ថុរបស់សមូហភាព ដូចជាវត្ត ឬសហគមន៍ជនជាតិដើមភាគតិច ... នៅក្នុងប័ណ្ណ ក៏ត្រូវ ចុះឈ្មោះវត្ត ឬសហគមន៍ ... ដែរ គឺមិនត្រូវចុះឈ្មោះរូបវន្តបុគ្គលជាតំណាងឡើយ។

ទាក់ទងដល់ការប្រើសិទ្ធិ និងការបំពេញកាតព្វកិច្ចផ្សេងៗ ក្នុងការអនុវត្តនីតិវិធីនៃការវិនិច្ឆ័យនីតិបុគ្គលនានា ក៏ដូចជាសមូហភាពទាំងអស់នោះ ត្រូវជ្រើសរើសតំណាងស្របច្បាប់រៀងខ្លួនតាមវិធីផ្សេងៗគ្នា ដូចជានីតិបុគ្គលសាធារណៈ មានលិខិតតែងតាំងនីតិបុគ្គលឯកជន មានការជ្រើសតាំងបណ្ណាធិការក្រុមហ៊ុន ឬប្រធានសមាគម បើវត្តមានប្រធាន គណៈកម្មការវត្ត បើសហគមន៍ជនជាតិដើមភាគតិច មានមេសហគមន៍ ...។ល។

## ផ្នែកទី៣៖ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

នៅក្នុងប្រទេសកម្ពុជាមានជនជាតិដើមភាគតិច២៣ក្រុម[175] ផ្សេងៗគ្នាដែលមានដូចជា **ព្នង កួយ ទំពួន ចារាយ គ្រឹង ព្រៅ កាវ៉ែត ស្មៀង ក្រោល មិល កាចក់ ព័រ ខោញ ជង សួយ លុន ស្អូច រដែ ខិ រអោង ស្ទុង ល្មឺន សំរ៉ៃ** និងជនជាតិដើមភាគតិចជាច្រើនទៀត។[176] ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជាត្រូវបានរដ្ឋាភិបាលយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងពេលបច្ចុប្បន្ន ដោយនៅក្នុងបទដ្ឋានគតិយុត្ត និងគោលនយោបាយជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជាបានចែងអំពីសញ្ញាណនៃជនជាតិដើមភាគតិចថាជាជនជាតិដើមនៅក្នុងប្រទេស។[177] ពាក្យថាជនជាតិដើមនៅទីនេះ មិនមែនសំដៅដល់ជនបរទេសដែលកំពុងរស់នៅលើទឹកដីខ្មែរមានដូចជា ជនជាតិវៀតណាម ឬ ជនជាតិចាមនោះឡើយ មានន័យថាជនជាតិដើមភាគតិចគឺពួកគាត់ជាជនជាតិខ្មែរដែលមានសញ្ជាតិខ្មែរពីកំណើតដូចប្រជាពលរដ្ឋទូទៅដែរ ប៉ុន្តែគ្រាន់តែបងប្អូនសហគមន៍ជនជាតិដើមភាគតិចមាន ភាសា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ដោយឡែកផ្ទាល់ខ្លួន ហើយការរស់នៅរបស់ពួកគាត់គឺតាមបែបប្រពៃណី និងអាស្រ័យទាំងស្រុងទៅលើធនធានធម្មជាតិ និងដីធ្លី ចំណែកឯការទ្រទ្រង់ជីវភាពរស់នៅរបស់ពួកគេវិញគឺពឹង

---

[175] វិទ្យាស្ថានសភាកម្ពុជា, ឯកសារស្រាវជ្រាវសង្ខេបដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨៖ *ការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច នៅក្នុងខេត្តរតនៈគិរី,* មេសា ២០១៦, ទំព័រ១។

[176] រាជរដ្ឋាភិបាល, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច, ២៤ មេសា ២០០៩, ទំព័រទី១។

[177] ធនាគារពិភពលោក, ក្របខណ្ឌគោលនយោបាយសម្រាប់ជនជាតិដើមភាគតិច, ទំព័រ១។

ផ្អែកលើដំណាំដូរវេន និងការប្រមូលផល អនុផលព្រៃឈើ ការបរបាញ់សត្វ ការនេសាទ និងការចញ្ចឹមសត្វ។[178] ណាមួយដោយសារតែជនជាតិដើមភាគតិចរស់នៅពឹងផ្អែកលើធនធានធម្មជាតិដូច្នេះហើយបានជាការធានាសិទ្ធិដីធ្លីគឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះពួកគាត់ ហេតុនេះទើប តាមរយៈច្បាប់ភូមិបាល២០០១ បានកំណត់ថា សហគមន៍ជនជាតិដើមភាគតិចគឺជាមុខសញ្ញាដែលត្រូវទទួលបាននូវកម្មសិទ្ធិ សមូហភាពលើដីរដ្ឋ[179] និងបានចែងបញ្ជាក់ពីសិទ្ធិលើអចលនវត្ថុរបស់ជនជាតិដើមភាគតិច ដែលមានចាប់ពីមាត្រា២៣ ដល់មាត្រា២៨ នៃច្បាប់នេះ។ ហើយកាន់តែពិសេស គឺកម្មសិទ្ធិសមូហភាពក៏អាចដាក់ពាក្យសុំចុះបញ្ជីជាកម្មសិទ្ធិបានដូចជាកម្មសិទ្ធិឯកជនផងដែរ ហេតុនេះហើយទើបរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយមួយចំនួនស្ដីពីការចុះបញ្ជីដី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅប្រទេសកម្ពុជាឡើងមក ហើយតាមរយៈគោលនយោបាយនេះគឺមានបំណងរៀបចំក្របខណ្ឌគតិយុត្តសមស្របមួយសម្រាប់ការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចដែលជាប្រការសំខាន់ដើម្បីពង្រឹងការគ្រប់គ្រងដីធ្លី ព្រៃឈើ និងធនធានធម្មជាតិដទៃទៀតឱ្យមាននិរន្តភាព និងមានតុល្យភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការធានាឱ្យជនជាតិដើមភាគតិចរក្សាបាននូវវប្បធម៌ ទំនៀមទម្លាប់និងប្រពៃណីល្អរបស់ខ្លួនទៅអនាគត។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយតាមរយៈគោលនយោបាយនេះបានចង្អុលបង្ហាញថា ដើម្បីអាចធ្វើការអនុវត្តនូវនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចបានគឺតម្រូវឱ្យមាននូវអនុក្រឹត្យដែលកំណត់ពីនីតិវិធីដាច់ដោយឡែកមួយផ្សេងទៀត។ ជាក់ស្តែងរាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ៨៣ អនក្រ.បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដែលអនុក្រឹត្យនេះមានគោលបំណងកំណត់គោលការណ៍ នីតិវិធី និងយន្តការសម្រាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព ក្នុងគោលបំណងផ្តល់សិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច ធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងដើម្បីការពារកម្មសិទ្ធិសមូហភាព ដោយរក្សានូវអត្តសញ្ញាណ វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីល្អរបស់សហគមន៍ជនជាតិដើមភាគតិច។ ដូចនេះដើម្បីអាចដឹងច្បាស់ពីដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនោះយើងនឹងធ្វើការពិភាក្សាទៅលើ ការកំណត់លក្ខណៈនៃដីសហគមន៍ជនជាតិដើមភាគតិច( **កថាខណ្ឌទី១** ) បន្ទាប់ពីបានដឹងពីដីដែលជាកម្មវត្ថុនៃការចុះបញ្ជីរួចមកយើងនឹងធ្វើការឈ្វេងយល់លម្អិតបន្ថែមទៀតទៅលើលក្ខខណ្ឌនៃការចុះបញ្ជីដីសមូហភាព( **កថាខណ្ឌទី២** ) ហើយនៅពេលដែលសហគមន៍ជនជាតិដើមភាគតិច

[178] សៀវភៅណែនាំស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៧។

[179] ក្រុមប្រឹក្សាគោលនយោបាយដីធ្លី, *គោលនយោបាយស្តីពី៖ ការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា*, ២៤ មេសា ២០០៩, ទំព័រ២។

បានបំពេញនូវលក្ខខណ្ឌត្រឹមត្រូវហើយនោះបន្តមកទៀតយើងនឹងសិក្សាអំពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច(**កថាខណ្ឌទី៣**)។

### កថាខណ្ឌទី១៖ ការកំណត់លក្ខណៈនៃដីសហគមន៍ជនជាតិដើមភាគតិច

មុននឹងអាចឈានទៅដល់នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច[180] ជាដំបូងត្រូវធ្វើការកំណត់ប្រភេទដីជាមុនសិន ព្រោះដើម្បីអាចដឹងថាដីប្រភេទណាខ្លះដែលអាចក្លាយជាកម្មវត្ថុនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច។ ការកំណត់បែបនេះក៏ព្រោះតែដីរបស់សហគមន៍ជនជាតិដើមភាគតិចគឺមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីដីឯកជន ព្រោះថាសហគមន៍ជនជាតិដើមភាគតិចគឺជាក្រុមមនុស្សដែលតាំងទីលំនៅរស់នៅលើផ្នែកខ្លះនៃដីឯកជនរបស់រដ្ឋ និងផ្នែកខ្លះទៀតជាដីសាធារណៈរបស់រដ្ឋ។ ទោះបីជាពួកគាត់បានតាំងទីលំនៅរស់នៅលើដីរដ្ឋក៏ពិតមែន ប៉ុន្តែការរស់នៅរបស់ពួកគាត់គឺត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់។ ជាក់ស្តែងតាមរយៈច្បាប់ភូមិបាលបានទទួលស្គាល់សិទ្ធិសហគមន៍ជនជាតិដើមភាគតិចក្នុងការកាន់កាប់ដីធ្លីលើដីរបស់រដ្ឋដើម្បីធ្វើជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍តាមរយៈការចុះបញ្ជីកម្មសិទ្ធិផងដែរ ប៉ុន្តែចំពោះសិទ្ធិរបស់បងប្អូនជនជាតិដើមភាគតិចត្រូវបានច្បាប់ទទួលស្គាល់ត្រឹមតែសិទ្ធិប្រើប្រាស់ និងអាស្រ័យផលតែប៉ុណ្ណោះ ដោយឡែកចំពោះសិទ្ធិចាត់ចែងមិនត្រូវបានច្បាប់ទទួលស្គាល់ឡើយ។ អនុលោមតាមមាត្រា ២៥ នៃច្បាប់ភូមិបាលបានចែងថា *"ដីសហគមន៍ជនជាតិដើមភាគតិចគឺជាដីទាំងអស់ដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្មប្រពៃណី។ សហគមន៍ជនជាតិដើមភាគតិច មិនមែនមានតែដីដែលបានដាំដុះជាក់ស្តែងនោះទេ ប៉ុន្តែមានដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំថែមទៀត ដែលតម្រូវទៅតាមរបៀបទាញយកផលដែលធ្លាប់ធ្វើកន្លងមក ហើយត្រូវបានទទួលស្គាល់ដោយអាជ្ញាធររដ្ឋបាល។ ការវាស់វែង និងការកំណត់ព្រំប្រទល់នៃអចលនវត្ថុរបស់សហគមន៍ទាំងនោះ ត្រូវកំណត់ទៅតាមស្ថានភាពជាក់ស្តែងដូចដែលបានអះអាងដោយសហគមន៍ ដោយមានការព្រមព្រៀងពីអ្នកជិតខាង"*។[181] បន្ថែមពីលើខ្លឹមសារដែលមាននៅក្នុងច្បាប់ភូមិបាល រដ្ឋាភិបាលបានបង្កើតនូវអនុក្រឹត្យលេខ៨៣ អនក្រ.បក មួយថែមទៀតដើម្បីធ្វើការកំណត់ឱ្យកាន់តែច្បាស់ពីប្រភេទនៃដីដែលជាកម្មវត្ថុនៅក្នុងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចឡើងមកហើយតាមរយៈអនុក្រឹត្យនេះបានកំណត់ដីដែលជាកម្មវត្ថុនៅក្នុងការចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិចមានពីរធំៗរួមមានដីឯកជនរបស់រដ្ឋ និងដីសាធារណៈរបស់រដ្ឋ។

---

[180] អនុក្រឹត្យ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣ អនក្រ.បក, ១៩ មិថុនា ២០០៩, មាត្រា៥ (តទៅហៅថាអនុក្រឹត្យលេខ៨៣ឆ្នាំ២០០៩)។ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច សំដៅដល់ការចុះបញ្ជីដីទាំងអស់របស់សហគមន៍មួយជាកម្មសិទ្ធិសមូហភាពនៅក្នុងប្លង់តែមួយ។

[181] ច្បាប់ភូមិបាល២០០១, មាត្រា២៥។

- ដីឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចមានដូចជា៖
  - **ដីលំនៅឋាន**[182] ឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន
  - ដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី មានដីដាំដុះជាក់ស្តែង ដីស្រែចម្ការ។
- ដីសាធារណៈរបស់រដ្ឋដែលមានកំណត់ទីតាំង ទំហំ ព្រំប្រទល់ជាក់លាក់ និងសិទ្ធិប្រើប្រាស់ដូចដែលសហគមន៍ធ្លាប់បានអនុវត្តកន្លងមក និងដែលបានចុះបញ្ជីរួចហើយជាមួយរដ្ឋដែលមានដូចជា៖[183]
  - **ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ**[184] ដែលបានទទួលស្គាល់ដោយអាជ្ញាធរ និងមានការព្រមព្រៀងពីអ្នកជិតខាង
  - **ដីព្រៃអារក្ស**[185] ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី០៧ (ប្រាំពីរ) ហិកតា។
  - **ដីកប់ខ្មោច**[186] ដែលអាចមានមួយកន្លែង ឬច្រើនកន្លែងសម្រាប់សហគមន៍នីមួយៗ ដោយមានទំហំសរុបមិនលើសពី០៧ (ប្រាំពីរ)ហិកតា។

ជារួម ដីដូចដែលមានរៀបរាប់ទាំងអស់នៅខាងលើសុទ្ធសឹងតែជាដីដែលជាកម្មវត្ថុនៃការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ដោយឡែកសម្រាប់ដីព្រៃអារក្ស និងដីកប់ខ្មោចរបស់សហគមន៍ជនជាតិដើមភាគតិចគឺត្រូវបានកំណត់ដោយកម្រិតចំពោះទំហំមិនឱ្យលើសពី ៧ហិកតា ដូចនេះមានន័យថាប្រសិនបើមុនពេលមានដំណើរការចុះបញ្ជីដី សហគមន៍ធ្លាប់បានប្រើប្រាស់ដីព្រៃអារក្ស ឬដីកប់ខ្មោចដែលមានទំហំធំជាង ៧ហិកតា នោះចំនួនដែលលើសគឺត្រូវកាត់បន្ថយជាកំហិតមកត្រឹមចំនួន ៧ហិកតាវិញទើបអាចធ្វើការចុះបញ្ជីបាន។ ហើយចំពោះចំណែកផ្សេងទៀតដែលសហគមន៍ជនជាតិដើមធ្លាប់ប្រើប្រាស់តាមបែបប្រពៃណីកន្លងមក ដែលមានដូចជាដីព្រៃឈើសម្រាប់ការប្រមូលផលនៃអនុផលព្រៃឈើ កន្លែងប្រើ

---

[182] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៤។ **ដីលំនៅឋាន** សំដៅទៅដល់ដីដែលសមាជិកសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់ដើម្បីសាងសង់លំនៅឋានសម្រាប់ស្នាក់នៅ ឬរស់នៅជាអចិន្ត្រៃយ៍(និវេសដ្ឋាន)។

[183] ក្រុមប្រឹក្សាគោលនយោបាយដីធ្លី, *គោលនយោបាយស្តីពី៖ ការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា*, ២៤ មេសា ២០០៩, ទំព័រ៤។

[184] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៤។ **ដីបម្រុងចាំបាច់ក្នុងការដូរវេនដំណាំ** ឬ**ដីរៀបចំបម្រុងសម្រាប់ចម្ការពនេចរ** ឬ**ដីចម្ការវិលជុំ** សំដៅដល់ដីដែលសហគមន៍ជនជាតិដើមភាគតិចធ្លាប់បានប្រើប្រាស់កន្លងមកជាស្រែ ឬចម្ការ ក្នុងការដូរវេនដំណាំតាមប្រពៃណី។

[185] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៤។ **ដីព្រៃអារក្ស** សំដៅដល់ទីកន្លែងដែលសហគមន៍ទុកសម្រាប់គោរពបូជា ឬសែនព្រេនតាមទំនៀមទម្លាប់ប្រពៃណី។

[186] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៤។ **ដីកប់ខ្មោច** សំដៅដល់ទីកន្លែងដែលសហគមន៍ប្រើប្រាស់សម្រាប់បញ្ចុះសពទៅតាមប្រពៃណីរបស់ខ្លួន។

ប្រាស់ទឹក សហគមន៍អាចបន្តប្រើប្រាស់ និងអាស្រ័យផលតាមប្រពៃណីរបស់ខ្លួនបន្តទៀតបាន ប៉ុន្តែត្រូវចុះកិច្ចព្រមព្រៀងជាមួយស្ថាប័នសាមីដែលមានអាណត្តិកាន់កាប់ដីរដ្ឋនោះ។[187]

**កថាខណ្ឌទី២៖ លក្ខខណ្ឌនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច**

តាមរយៈអនុក្រឹត្យលេខ៨៣ បានចែងពីលក្ខខណ្ឌធំៗចំនួន៣ ដែលតម្រូវឱ្យសហគមន៍ត្រូវបំពេញរួមមាន ការកំណត់អត្តសញ្ញាណពីក្រសួងអភិវឌ្ឍន៍ជនបទ(**វាក្យខណ្ឌទី១**) បន្ទាប់ពីសហគមន៍ត្រូវបានទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទរួច យើងនឹងពិភាក្សាអំពី ការចុះបញ្ជីទទួលស្គាល់ជាផ្លូវការដើម្បីទទួលបាននូវសិទ្ធិជានីតិបុគ្គល(**វាក្យខណ្ឌទី២**) និងចុងក្រោយ សហគមន៍ជនជាតិដើមភាគតិចដាក់ពាក្យសុំចុះបញ្ជីដីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(**វាក្យខណ្ឌទី៣**)។

**វាក្យខណ្ឌទី១៖ ការកំណត់អត្តសញ្ញាណពីក្រសួងអភិវឌ្ឍន៍ជនបទ**

នៅក្នុងដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទមានភារកិច្ចនៅក្នុងការផ្សព្វផ្សាយការយល់ដឹងអំពីខ្លឹមសារនៃគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច និងសារាចរណែនាំពាក់ព័ន្ធទៅនឹងការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាការពន្យល់បង្ហាញអំពីនីតិវិធីនៃការចុះបញ្ជីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច និងអំពីសិទ្ធិរបស់សហគមន៍ និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធនានាក៏ដូចជាសកម្មភាពដែលនឹងត្រូវអនុវត្តនៅក្នុងតំបន់របស់ពួកគាត់។[188] បន្ទាប់មកសហគមន៍ជនជាតិដើមភាគតិចណា ដែលចាប់អារម្មណ៍ទៅលើការកំណត់អត្តសញ្ញាណជាសហគមន៍ជនជាតិដើមភាគតិច តាមរយៈកិច្ចប្រជុំផ្ទៃក្នុងរបស់សហគមន៍ជនជាតិដើមភាគតិច អាចដាក់ពាក្យសុំធ្វើការកំណត់អត្តសញ្ញាណបាន។[189] ជាដំបូងសហគមន៍ជនជាតិដើមភាគតិចត្រូវធ្វើស្វ័យកំណត់អត្តសញ្ញាណ ខ្លួនថាជាជនជាតិដើមពិតប្រាកដមែន ដើម្បីជួយសម្រួលដល់ការងារនេះ ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទនឹងរៀបចំនូវកិច្ចប្រជុំមួយជាមួយនឹងសហគមន៍ ដើម្បីជូនដំណឹងពួកគាត់អំពីដំណើរការ និងដើម្បីផ្តល់នូវពេលវេលាដល់សមាជិកសហគមន៍ម្នាក់ៗក្នុងការសម្រេចថាពួកគាត់ចង់ក្លាយជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិចឬអត់ និងមានបំណងចង់ដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិសមូហភាពដែរឬទេ។ នៅពេលដែលដំណើរការនៃការកំណត់ ថាតើបុគ្គលមួយណានឹងក្លាយជាសមាជិកសហគមន៍ជនជាតិដើមភាគតិចត្រូវបានបញ្ចប់រួចរាល់ នោះមន្ទីរអភិវឌ្ឍន៍ជនបទដោយសហការយ៉ាង

---

[187] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៧។

[188] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ១៣។

[189] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ១៤។

ជិតស្និតជាមួយនិងអាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍ ត្រូវរៀបចំកិច្ចប្រជុំមួយ ដែលសហគមន៍នឹងធ្វើស្វ័យកំណត់អត្តសញ្ញាណជា ជនជាតិដើមភាគតិច និងត្រូវបានទទួលស្គាល់ថាជាសហគមន៍ជនជាតិដើមភាគតិចដោយសហគមន៍ជិតខាង និងអាជ្ញាធរមូលដ្ឋាន។ បន្ទាប់មកសហគមន៍ត្រូវរៀបចំបោះឆ្នោតដើម្បីជ្រើសរើសតំណាងគណៈកម្មាធិការសហគមន៍របស់ខ្លួនផងដែរ នៅក្នុងកិច្ចប្រជុំដដែលនោះ នឹងត្រូវតំណាងឱ្យសហគមន៍នៅក្នុងដំណើរការនៃការស្នើសុំប័ណ្ណកម្មសិទ្ធិដីសមូហភាព។[190] បន្ទាប់ពីសមាជិកសហគមន៍បានធ្វើស្វ័យកំណត់អត្តសញ្ញាណខ្លួនថាជា ជនជាតិដើមភាគតិច និងបានបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហគមន៍ពួកគេរួចហើយ នោះគណៈកម្មាធិការគួរដាក់ពាក្យស្នើសុំការទទួលស្គាល់សហគមន៍ជា ជនជាតិដើមភាគតិចនៅក្រសួងអភិវឌ្ឍន៍ជនបទ។ មន្ទីរអភិវឌ្ឍន៍ជនបទជាអ្នកគាំទ្រដល់គណៈកម្មាធិការសហគមន៍នៅក្នុងការបំពេញឱ្យបានត្រឹមត្រូវនូវទម្រង់លិខិតចាំបាច់នានាសម្រាប់ការដាក់ពាក្យស្នើសុំនេះ។[191] ក្រោយពីទទួលបានពាក្យស្នើសុំរួចហើយ នោះអ្នកតំណាងថ្នាក់កណ្តាលមកពីក្រសួងអភិវឌ្ឍន៍ជនបទនឹងដឹកនាំបេសកកម្មចុះទៅសហគមន៍ ដើម្បីធ្វើការសម្ភាសន៍សមាជិកសហគមន៍ និងសហគមន៍ជិតខាងដើម្បីធ្វើការវាយតម្លៃ និងផ្តល់នូវសុពលភាពទៅលើអត្តសញ្ញាណជា ជនជាតិដើមភាគតិច របស់សហគមន៍។ បន្ទាប់មកក្រសួងអភិវឌ្ឍន៍ជនបទធ្វើការវាយតម្លៃទៅលើរបៀបរបបសង្គមកិច្ច វប្បធម៌ និងសេដ្ឋកិច្ច ដែលរួមបញ្ចូលទាំងការគ្រប់គ្រងដីសមូហភាព ហើយធ្វើការផ្ទៀងផ្ទាត់នូវសុឆន្ទៈរបស់សមាជិកសហគមន៍ដែលត្រូវធ្វើការពិចារណាថាជាសហគមន៍ជនជាតិដើមភាគតិច។ ប្រសិនបើក្រសួងអភិវឌ្ឍន៍ជនបទសន្និដ្ឋានថាសហគមន៍មានលក្ខណៈសម្បត្តិជាសហគមន៍ជនជាតិដើមភាគតិច នោះក្រសួងនឹងចេញវិញ្ញាបនបត្រទទួលស្គាល់ដែលមានចុះហត្ថលេខាដោយក្រសួងអភិវឌ្ឍន៍ជនបទ ហើយពិធីប្រគល់វិញ្ញាបនបត្រឱ្យសហគមន៍ត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ។[192]

### ខ-កថាខណ្ឌទី២៖ ការចុះបញ្ជីទទួលស្គាល់ជាផ្លូវការ ដើម្បីទទួលបាននូវសិទ្ធិជានីតិបុគ្គល

ក្រោយសហគមន៍ជនជាតិដើមភាគតិចបានធ្វើស្វ័យអត្តសញ្ញាណទទួលស្គាល់ថាខ្លួនគឺជាសហគមន៍ជនជាតិដើមភាគតិច និងទទួលបានលិខិតបញ្ជាក់អំពីការទទួលស្គាល់ពីក្រសួងអភិវឌ្ឍន៍ជនបទរួចមកហើយនោះ សហគមន៍ជនជាតិដើមភាគតិចនឹងឈានចូលដំណាក់កាលថ្មីមួយទៀតនោះគឺការចុះបញ្ជីជានីតិបុគ្គលនៅក្រសួងមហាផ្ទៃ។ នៅក្នុងដំណើរការចុះបញ្ជីជានីតិបុគ្គលនេះសហគមន៍ជនជាតិដើមភាគតិចត្រូវតែរៀបចំ

[190] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ១៦។

[191] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ១៧។

[192] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ១៨។

បង្កើតឱ្យមាននូវសេចក្តីព្រាងលក្ខន្តិកៈសហគមន៍មួយឡើងមក។ បន្ទាប់មកសហគមន៍ជនជាតិដើមភាគតិចត្រូវសម្របសម្រួលរៀបចំឱ្យមានកិច្ចប្រជុំមួយ ក្នុងគោលបំណងពិនិត្យ និងពិភាក្សាដើម្បីសម្រេចអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈនេះ ព្រមទាំងជ្រើសតាំងគណៈកម្មាធិការសហគមន៍សម្រាប់បំពេញទម្រង់បែបបទចុះបញ្ជីនៅក្រសួងមហាផ្ទៃ។[193]

បន្តមកទៀតក្រោយពីសហគមន៍បានអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងជ្រើសតាំងគណៈកម្មាធិការសហគមន៍រួចប្រធានសហគមន៍ត្រូវរៀបចំចងក្រងប្រមូល និងបំពេញសំណុំឯកសារ ចំនួន៦ ទៀតរួមមាន៖[194]

- បញ្ជីសមាជិករួម ចំនួន ២ច្បាប់(មានការបញ្ជាក់ពីមេឃុំ ឬចៅសង្កាត់)
- លិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ដោយក្រសួងអភិវឌ្ឍន៍ជនបទ
- លក្ខន្តិកៈសហគមន៍ ចំនួន ២ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់គណៈកម្មាធិការសហគមន៍ក្នុងម្នាក់ៗ ចំនួន ២ច្បាប់ ដោយមានភ្ជាប់ជាមួយអត្តសញ្ញាណប័ណ្ណ ឬឯកសារពាក់ព័ន្ធនានា(ច្បាប់ថតចម្លង)
- សេចក្តីសម្រេចរបស់ឃុំស្តីពីការទទួលស្គាល់លក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍ ចំនួន២ច្បាប់
- សំណើសុំចុះឈ្មោះសហគមន៍ទៅក្រសួងមហាផ្ទៃ ចំនួន ២ច្បាប់។

នៅពេលដែលសហគមន៍បានរៀបចំនូវសំណុំឯកសារទាំង ៦ ខាងលើបានគ្រប់គ្រាន់ រួចរាល់ និងត្រឹមត្រូវហើយសហគមន៍សាមី ត្រូវបញ្ជូនសំណុំឯកសារទាំងអស់ជូនទៅមេឃុំ/ចៅសង្កាត់ អភិបាលក្រុង/ស្រុក និងអភិបាលខេត្តដើម្បីស្នើសុំចុះហត្ថលេខាបញ្ជាក់។ បន្ទាប់ពីពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជន និងឯកសារពាក់ព័ន្ធនានាត្រូវបានរៀបចំបញ្ចប់ជាស្ថាពររួចហើយនោះរដ្ឋបាលខេត្តដោយមានទីចាត់ការអន្តរវិស័យ ដែលជាសេនាធិការឱ្យអភិបាលនៃគណៈអភិបាលខេត្តមានតួនាទីក្នុងការសម្របសម្រួលទំនាក់ទំនងបញ្ជូនពាក្យស្នើសុំចុះបញ្ជីរបស់សហគមន៍ជនជាតិដើមភាគតិច និងសំណុំឯកសារពាក់ព័ន្ធនានាជូនមកក្រសួងមហាផ្ទៃ(**អគ្គនាយកដ្ឋានរដ្ឋបាល**) ដើម្បីធ្វើការពិនិត្យសំណុំឯកសារ និងសម្រេចចុះឈ្មោះសហគមន៍ជនជាតិដើមភាគតិចនោះទៅក្នុងបញ្ជីសហគមន៍ជនជាតិដើមភាគតិចផ្លូវការនៅក្រសួងមហាផ្ទៃ។[195] ក្រោយពេលដែលក្រសួងមហាផ្ទៃបានសម្រេចចុះឈ្មោះសហគមន៍ជនជាតិដើមភាគតិចទៅក្នុងបញ្ជីសហគមន៍នៅក្រសួងមហាផ្ទៃរួច

---

[193] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ២៣។

[194] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ២៤។

[195] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ២៤។

ហើយនោះគឺមានន័យថា សហគមន៍ជនជាតិដើមភាគតិចនោះទទួលបាននូវសិទ្ធិគ្រប់គ្រាន់ស្របច្បាប់នៅក្នុងការដាក់ពាក្យសុំចុះបញ្ជីដីធ្លីជាសមូហភាពដោយទទួលបានឋានៈជានីតិបុគ្គល។[196]

**ខាក្យខណ្ឌទី៣៖ ការដាក់ពាក្យសុំចុះបញ្ជីដីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ក្រោយពីសហគមន៍ជនជាតិដើមភាគតិចបានកំណត់អត្តសញ្ញាណទទួលស្គាល់ថាខ្លួនជាជនជាតិដើមភាគតិច ហើយបានទទួលស្គាល់ជានីតិបុគ្គលដោយក្រសួងមហាផ្ទៃរួចមក សហគមន៍នឹងឈានចូលដល់ដំណាក់កាលចុងក្រោយនោះគឺការស្នើសុំប័ណ្ណកម្មសិទ្ធិទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ នៅក្នុងនីតិវិធីនេះគឺតម្រូវឱ្យសហគមន៍ជនជាតិដើមភាគតិចរៀបចំតាក់តែងឱ្យមាននូវបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយត្រូវរៀបចំតាក់តែងនូវបទបញ្ជាផ្ទៃក្នុងដោយខ្លួនឯង។ បទបញ្ជាផ្ទៃក្នុង ជាការកំណត់អំពីបញ្ហាផ្ទៃក្នុងរបស់សហគមន៍ និងមានតួនាទីធានានូវការប្រើប្រាស់ ប្រកបដោយសមធម៌ទៅលើដីសមូហភាព និងការគ្រប់គ្រងដីទាំងនោះ និងដោះស្រាយជម្លោះផ្ទៃក្នុងណាមួយ ជាងនេះទៅទៀតបទបញ្ជាផ្ទៃក្នុងក៏ជួយថែរក្សានូវអត្តសញ្ញាណវប្បធម៌ ទំនៀមទម្លាប់ និងប្រពៃណីល្អរបស់សហគមន៍ផងដែរ តាមរយៈការប្រើប្រាស់ដីប្រកបដោយចីរភាព ការគ្រប់គ្រងដី ក៏ដូចជាធនធានធម្មជាតិ ហើយបទបញ្ជាផ្ទៃក្នុងមានសារៈសំខាន់ណាស់ពីព្រោះវាជាអ្នកគ្រប់គ្រងទំនាក់ទំនងរបស់សហគមន៍ជាមួយនឹងអ្នកខាងក្រៅ ដែលមានដូចជា អ្នកភូមិជាជនជាតិដើមភាគតិចដែលបានសម្រេចចិត្តថាមិនចូលរួមជាសមាជិកសហគមន៍ជនជាតិដើមភាគតិច ឬជាមួយនឹងប្រជាជនខ្មែរដែលរស់នៅក្នុងភូមិដែលមិនអាចចូលរួមបាន។[197] បន្ទាប់ពីបានរៀបចំតាក់តែងទៅលើបទបញ្ជាផ្ទៃក្នុងរួចរាល់ និងមានការឯកភាពនៅក្នុងសហគមន៍រួចមកនោះសហគមន៍អាចធ្វើការដាក់ពាក្យសុំចុះបញ្ជីដីរបស់ខ្លួនទៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានហើយ ប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីជនជាតិដើមភាគតិចនីមួយៗត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាពទៅកាន់មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ តាមរយៈការិយាល័យភូមិបាលក្រុង ស្រុក ខណ្ឌ ដែលដីតាំងនៅ ហើយនៅលើពាក្យសុំចុះបញ្ជីដីត្រូវមានបញ្ជាក់ពី មេឃុំ ចៅសង្កាត់ ថាសហគមន៍ដែលស្នើសុំចុះបញ្ជីពិតជាសហគមន៍ដែលស្ថិតនៅក្នុង ឃុំ សង្កាត់ របស់ខ្លួនពិតប្រាកដមែន។[198] បន្ទាប់មកមន្ទីរត្រូវពិនិត្យមើលនៅលើ

---

[196] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ២៥។

[197] សៀវភៅណែនាំ ស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ២៨។

[198] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៨។

ពាក្យសុំនោះ មុននឹងធ្វើរបាយការណ៍ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីធ្វើការចុះបញ្ជីដីជូនសហគមន៍ជនជាតិដើមភាគតិច។ ចំពោះសំណុំឯកសារដែលត្រូវភ្ជាប់អមជាមួយពាក្យស្នើមានដូចជា៖[199]

- ពាក្យស្នើសុំចុះបញ្ជីដីសហគមន៍ត្រូវមានស្នាមមេដៃប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី
- លិខិតប្រគល់សិទ្ធិជូនសមាជិកគណៈកម្មាធិការសហគមន៍ណាម្នាក់ជាតំណាងសហគមន៍ ក្នុងដំណើរការផ្តល់ព័ត៌មាន ការបំពេញទម្រង់បែបបទក្នុងការចុះបញ្ជីដីសហគមន៍តាមនីតិវិធីជាធរមាន ប្រសិនបើប្រធានគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណីមិនអាចចូលរួមបាន។
- លក្ខន្តិកៈរបស់សហគមន៍ និងបញ្ជីរាយនាមសមាជិកសហគមន៍មានសេចក្តីបញ្ជាក់ពីចៅសង្កាត់មេឃុំ
- បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ទាក់ទងនឹងរបៀបគ្រប់គ្រង និងការប្រើប្រាស់ដីជាសមូហភាព
- លិខិតជូនដំណឹងស្តីពីការយល់ព្រមឱ្យចុះបញ្ជីសហគមន៍ដោយក្រសួងមហាផ្ទៃ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា សង្កាត់ ឃុំស្តីពីការតែងតាំងគណៈកម្មាធិការសហគមន៍ និង
- រាល់ឯកសាពាក់ព័ន្ធនឹងដីដែលស្នើសុំចុះបញ្ជីប្រសិនបើមាន។

បន្តមកនៅពេលដែលទទួលបានការឯកភាពពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ថ្នាក់ខេត្តត្រូវជូនដំណឹងទៅអភិបាលខេត្តឱ្យប្រកាសថាជាតំបន់វិនិច្ឆ័យសម្រាប់សហគមន៍។[200] ក្នុងករណីប្រសិនបើទីតាំង ទំហំ និងព្រំប្រទល់ដីរបស់សហគមន៍ជនជាតិដើមភាគតិចនោះមានការឯកភាពពីអ្នកជិតខាង ពីអាជ្ញាធររដ្ឋបាល និងមិនមានទំនាស់ ឬមានទំនាស់តែត្រូវបានដោះស្រាយរួចហើយ ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីចេញសេចក្តីជូនដំណឹងជាសាធារណៈក្នុងរយៈពេល២០ថ្ងៃ យ៉ាងតិចមុនកាលបរិច្ឆេទនៃការចុះកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ហើយសេចក្តីជូនដំណឹងនេះត្រូវបិទនូវកន្លែងដែលងាយមើលឃើញដូចជា នៅទីស្នាក់ការភូមិ នៅសាលាសង្កាត់ ឃុំ ទីប្រជុំជន និងទីតាំងដីរបស់សហគមន៍សាមី[201] ក្រោយរយៈពេលបិទផ្សាយ និងក្រោយការតវ៉ាផ្សេងៗប្រសិនបើត្រូវបានដោះស្រាយរួចហើយរដ្ឋបាល

[199] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៨។

[200] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៣។

[201] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៩។

សុរិយោដីត្រូវចាប់ផ្តើមដំណើរការចុះបញ្ជីដី និងចេញវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពជូនសហគមន៍តាមនីតិវិធីនៃការចុះបញ្ជីដីដែលមានជាធរមាន។[202]

### កថាខណ្ឌទី៣៖ នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

បន្ទាប់ពីសហគមន៍បានបំពេញត្រឹមត្រូវស្របតាមលក្ខខណ្ឌដែលច្បាប់បានកំណត់រួចមក សហគមន៍នឹងឈានចូលដល់ដំណាក់កាលនៃនីតិវិធីនៅក្នុងការផ្តល់កម្មសិទ្ធិលើដីធ្លីជូនសហគមន៍ជនជាតិដើមភាគតិចតែម្តង។ ប៉ុន្តែ ក្នុងដំណើរការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចដើម្បីទទួលបានជាកម្មសិទ្ធិសមូហភាពមានលក្ខណៈខុសប្លែកបន្តិចពីដំណើរការនៃការចុះបញ្ជីដីកម្មសិទ្ធិឯកជន ព្រោះនេះគឺជាការចុះបញ្ជីក្បាលដីទាំងឡាយរបស់សហគមន៍ជនជាតិដើមភាគតិចដែលមានចំណែកខ្លះគឺជាដីឯកជនរបស់រដ្ឋ និងចំណែកខ្លះជាដីសាធារណៈរបស់រដ្ឋ ហើយការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចមានលក្ខណៈពិសេសជាងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ និងការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ទើបរាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី០៩ មិថុនា ២០០៩ ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចដែលបានកំណត់លម្អិតពីបែបបទនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។[203] នៅក្នុងដំណើរការនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺជាអ្នកទទួលបន្ទុកក្នុងការវាស់វែង បិទផ្សាយ អនុប្បយោគដើម្បីចេញប័ណ្ណកម្មសិទ្ធិដីសមូហភាពជូនដល់សហគមន៍ជនជាតិដើមភាគតិច ហើយក្រុមការងារចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចត្រូវបានបង្កើតឡើងដែលមានសមាសភាពពីដប់ ទៅ ដប់ប្រាំរូប និងតែងតាំងតាមការស្នើសុំរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងសុរិយោដីខេត្ត មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[204]

ដោយឡែកនៅក្នុងដំណើរការនីតិវិធីនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិចការងារដែលត្រូវអនុវត្តរួមមាន ៥ជំហ៊ានធំៗ ដែលមានដូចជា ការងារវាស់វែង(**ជំហ៊ានទី១**) ការបិទជាផ្សាយសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ(**ជំហ៊ានទី២**) ការប្រជុំ និងសម្រេចលើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត(**ជំហ៊ានទី៣**) ការធ្វើលិខិតទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(**ជំហ៊ានទី៤**) និងការចេញប័ណ្ណកម្មសិទ្ធិ(**ជំហ៊ានទី៥**)។

- **ជំហ៊ានទី១ ការងារវាស់វែង**

---

[202] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា៩។

[203] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៥។

[204] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៥។

ក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចធ្វើការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ កំណត់ព្រំ និងវាស់វែងដីសហគមន៍ជនជាតិដើមភាគតិចដែលមានប្រាំប្រភេទដែលមានដូចតទៅ៖[205]

- ការងារទីវាល៖ ការធ្វើអត្តសញ្ញាណកម្មដីរដ្ឋ ការកំណត់ព្រំ និងការវាស់វែង នឹងអនុវត្តចំពោះដី
  - ដីលំនៅដ្ឋាន ឬដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន
  - ដីដែលសហគមន៍ប្រកបរបរកសិកម្មតាមបែបប្រពៃណី
  - ដីបម្រុងចាំបាច់ក្នុងការដូវេនដំណាំ ដែលទទួលស្គាល់ដោយអាជ្ញាធរ ឬពីអ្នកជិតខាង
  - ដីព្រៃអារក្ស (មានទំហំមិនលើសពី ៧ ហិកតា)
  - ដីកប់ខ្មោច (មានទំហំមិនលើសពី ៧ ហិកតា)

នៅក្នុងដំណាក់កាលនេះសហគមន៍ត្រូវចូលរួមបង្ហាញនូវទីតាំង ព្រំប្រទល់ និងទំហំនៃចំណែកដីផ្សេងៗ ដែលសហគមន៍បានកាន់កាប់ និងកំពុងប្រើប្រាស់ ដល់ក្រុមការងារចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

- **ការងារការិយាល័យ**

មន្ត្រីជំនាញបញ្ចូលទិន្នន័យដែលប្រមូលបានទៅក្នុងកុំព្យូទ័រដើម្បីកសាងបញ្ជីឈ្មោះម្ចាស់ដីនិងប្លង់ផែនទីក្បាលដីព្រមទាំងរៀបចំឯកសារដើម្បីពិនិត្យអោយបានត្រឹមត្រូវ និងត្រៀមយកទៅបិទផ្សាយ។

❖ **ជំហ៊ានទី២ ការបិទផ្សាយជាសារធារណៈនូវឯកសារនៃការវិនិច្ឆ័យ**

ទិន្នន័យដែលប្រមូលបាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីនឹងធ្វើសំណើទៅអភិបាលស្រុក ដើម្បីចេញសេចក្ដីជូនដំណឹង ស្ដីពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដីរបស់សហគមន៍ជនជាតិដើមភាគតិចហើយរយៈពេលនៃការជូនដំណឹងស្ដីពីការបិទផ្សាយមានរយៈពេល ៣០ថ្ងៃ ដោយគិតបញ្ចូលទាំងថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សម្រាក។ ការបិទផ្សាយបែបនេះដើម្បីឱ្យម្ចាស់ដីសហគមន៍ ស្ថាប័នពាក់ព័ន្ធ និងសមាជិកគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តទាំងអស់ចូលរួមពិនិត្យ និងធ្វើការតវ៉ាករណីមានការខុសឆ្គង។[206]

- **ករណីមិនមានការឯកភាពពីអ្នកជិតខាង ឬអាជ្ញាធររដ្ឋបាល**

នៅក្នុងការអនុវត្តនីតិវិធី ជាពិសេសក្នុងដំណាក់កាលបិទផ្សាយជូនដំណឹងសាធារណៈរយៈពេល២០ថ្ងៃ មុនចុះការងារវាល កំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ប្រសិនបើទីតាំង ទំហំ និងព្រំប្រទល់ដីសហគមន៍ជនជាតិ

---

[205] សៀវភៅណែនាំស្ដីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៧។

[206] សៀវភៅណែនាំស្ដីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្ដល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៨។

ដើមភាគតិច ដែលស្នើសុំចុះបញ្ជីមិនទាន់មានការឯកភាពពីអ្នកជិតខាង ឬពីអាជ្ញាធររដ្ឋបាលគឺត្រូវរៀបចំកិច្ចដំណើរការតាមរយៈយន្តការ និងនីតិវិធីដូចខាងក្រោម៖[207]

ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលត្រូវលើកសំណើទៅអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើអត្តសញ្ញាណ និងធ្វើផែនទីដីរដ្ឋ នៅដែលតំបន់ដែលសហគមន៍ស្នើសុំចុះបញ្ជី។ បន្ទាប់ពីទទួលសំណើ អភិបាលស្រុកពិនិត្យ លើកយោបល់ជូនអភិបាលខេត្តដែលជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ សុំឱ្យក្រុមការងារដីរដ្ឋចុះធ្វើអត្តសញ្ញាណកម្ម និងធ្វើផែនទីដីរដ្ឋ។ អភិបាលខេត្តត្រូវចាត់តាំងក្រុមការងារដីរដ្ឋ ប្រសិនបើមិនទាន់បានចាត់តាំងដើម្បីដំណើរការធ្វើអត្តសញ្ញាណកម្ម និងធ្វើផៃទីដីរដ្ឋ និងដីសហគមន៍ដែលស្នើសុំចុះបញ្ជីតាមអនុក្រឹត្យលេខ៣២១ មាត្រា១១ មាត្រា១២ និងមាត្រា១៣ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ។[208]

ក្នុងករណីដែលមានសហគមន៍ សមាជិកសហគមន៍ជនជាតិដើមភាគតិចណាមួយរកឃើញកំហុសឆ្គង ឬជំទាស់ទៅនឹងឯកសារវិនិច្ឆ័យដែលកំពុងបិទផ្សាយជាសាធារណៈនោះសហគមន៍ ឬសមាជិកសហគមន៍អាចដាក់ពាក្យប្តឹង ឬស្នើសុំជាលាយលក្ខណ៍អក្សរដើម្បីឱ្យមន្ត្រីបច្ចេកទេសធ្វើការកែសម្រួល ឬផ្អាកការបិទផ្សាយជាបណ្តោះអាសន្ន។

- **ជំហ៊ានទី៣ ការប្រជុំសម្រេចលើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត**

បន្ទាប់ពីបញ្ចប់ការបិទផ្សាយជាសាធារណៈនូវការវិនិច្ឆ័យ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការបិទផ្សាយដាក់ជូនអភិបាលនៃគណៈអភិបាលខេត្តពិនិត្យ និងសម្រេចលើរបាយការណ៍ និងឯកសារវិនិច្ឆ័យ ដើម្បីផ្តល់វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីជូនសហគមន៍ជនជាតិដើមភាគតិច។ ដើម្បីធ្វើការសម្រេចនេះបានអភិបាលខេត្តត្រូវធ្វើសំណើទៅនាយករដ្ឋមន្ត្រីតាមរយៈក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដើម្បីស្នើសុំអនុប្បយោគសម្រាប់ប្រទានកម្ម ចំពោះដីលំនៅឋាន និងដីកសិកម្ម ដែលមានទីតាំងស្ថិតនៅក្នុងចំណែកដីសាធារណៈរបស់រដ្ឋ។[209]

- **ជំហ៊ានទី៤ ការធ្វើលិខិតទៅក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ក្រោយពីទទួលលិខិតស្នើសុំធ្វើអនុប្បយោគ ពីសំណាក់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងធ្វើលិខិតពីរដាច់ដោយឡែកពីគ្នាផ្ញើទៅក្រសួងបរិស្ថាន និងក្រសួង

[207] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា១០។

[208] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា១០។

[209] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៩។

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការស្នើសុំការពិនិត្យ និងយល់ស្របលើសំណើអនុប្បយោគដី ដែលសហគមន៍ជនជាតិដើមភាគតិចបានស្នើសុំចុះបញ្ជីជាដីសហគមន៍ជនជាតិដើមភាគតិច។ ប្រភេទដីដែលស្នើសុំការពិនិត្យ និងយល់ស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមានដីព្រៃសហគមន៍ និងដីកសិកម្ម និងដីគម្របព្រៃឈើឆ្នាំ។ល។ បន្ទាប់ពីក្រសួងបរិស្ថាន និងក្រសួងរុក្ខាប្រមាញ់ និងនេសាទ បានឆ្លើយតបទៅនឹងលិខិតស្នើសុំការពិនិត្យ និងការយល់ស្របហើយនោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ធ្វើលិខិតមួយទៀតទៅរាជរដ្ឋាភិបាលដើម្បីស្នើសុំអនុប្បយោគ និងប្រទានកម្ម ដីរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចតាមការស្នើសុំរបស់សហគមន៍។[210]

❖ **ជំហ៊ានទី៥ ការចេញប័ណ្ណកម្មសិទ្ធិ**

បន្ទាប់ពីទទួលបានការឯកភាព និងអនុញ្ញាតពីរដ្ឋាភិបាលមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ត្រូវរៀបចំបោះពុម្ពវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិដីសមូហភាព ដោយមានចុះហត្ថលេខា និងចែកជូនសហគមន៍ជនជាតិដើមភាគតិចដោយបញ្ជាក់ឈ្មោះសហគមន៍ ទីតាំងសហគមន៍ លេខយោងទៅរកប្លង់រួមដែលចង្អុលនូវទីតាំងទំហំ ព្រំប្រទល់ និយាមកានៃចំណែកដីដែលជាកម្មសិទ្ធិសមូហភាព ហើយមានបញ្ជាក់ប្រភេទនៃការប្រើប្រាស់ និងកំណត់សម្គាល់ផ្សេងៗ។[211]

**<u>កំណត់សម្គាល់</u>៖** ទោះបីជាសហគមន៍ជនជាតិដើមភាគតិចទទួលបានកម្មសិទ្ធិលើដី និងក្លាយជាម្ចាស់លើវិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាពក៏ពិតមែន ប៉ុន្តែសហគមន៍គ្មានសិទ្ធិចាត់ចែងនូវផ្នែកមួយណានៃកម្មសិទ្ធិសមូហភាពឱ្យទៅបុគ្គល ឬក្រុមណាមួយបានឡើយព្រោះថាដីដែលសហគមន៍កំពុងកាន់កាប់នោះមានផ្នែកខ្លះជាដីឯកជនរបស់រដ្ឋនិងផ្នែកខ្លះទៀតជាដីសាធារណៈរបស់រដ្ឋ ដូច្នេះហើយច្បាប់មិនបានអនុញ្ញាតឱ្យមានសិទ្ធិចាត់ចែងលើទ្រព្យរបស់រដ្ឋឡើយ។ ប៉ុន្តែនៅពេលមានសមាជិកណាម្នាក់សម្រេចចិត្តចាកចេញពីសហគមន៍ សាមីជននោះអាចនឹងត្រូវទទួលបាននូវចំណែកដីសមស្របដែល នឹងត្រូវកាត់ចេញពីដីកម្មសិទ្ធិសមូហភាពរបស់ជនជាតិដើមភាគតិច(អាចជាដីដែលសហគមន៍បានរៀបចំនិវេសនដ្ឋាន ឬដីដែលសហគមន៍ប្រកបរបរកសិកម្មប្រពៃណី ដូចជាដីដាំដុះជាក់ស្តែង និងដីស្រែចម្ការ) ឬអាចទទួលបានជាសំណងទូទាត់សមស្របទៅតាមការសម្រេចរបស់សមូហភាពសហគមន៍ក្នុងករណីដែលអ្នកចាកចេញយល់ព្រម។[212] ដោយឡែកប្រសិនបើ

---

[210] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៩។

[211] សៀវភៅណែនាំស្តីពីដំណើរការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា, ទំព័រ៣៩។

[212] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា១៩។

សហគមន៍នោះត្រូវរំសាយ ការចាត់ចែងទ្រព្យរបស់សហគមន៍ត្រូវអនុលោមតាមខ្លឹមសារនៃលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍។[213]

[213] អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩, មាត្រា១៥។

# ជំពូកទី៣
# អត្ថប្រយោជន៍នៃការចុះបញ្ជីដី

# ជំពូកទី៣
# អត្ថប្រយោជន៍នៃការចុះបញ្ជីដី

តាមរយៈការអនុវត្តនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាដែលបានដាក់ឱ្យដំណើរការចុះបញ្ជីដីធ្លីនៅទូទាំងប្រទេសកម្ពុជា ហើយការចុះបញ្ជីដីធ្លីពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់ ព្រោះធានាបាននូវសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី ការប្រើប្រាស់ដីធ្លីទៅតាមសក្តានុពលដីប្រកបដោយប្រសិទ្ធិភាព គួបផ្សំនឹងការផ្តល់ដីធ្លីដល់អ្នកផលិតពិតប្រាកដ ជាកត្តាគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាជនកាន់តែប្រសើរឡើង ដែលទាំងអស់នេះគឺជាសំណាញ់សុវត្ថិភាពនៃប្រជាជាតិមួយ។ នៅក្នុងការអនុវត្តនូវនីតិវិធីនៃការចុះបញ្ជីដីធ្លី លទ្ធផលដែលសម្រេចបានធំបំផុតនោះគឺការទទួលបានប័ណ្ណកម្មសិទ្ធិលើដីធ្លីរបស់ម្ចាស់ដី ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងធ្វើការចែកប័ណ្ណកម្មសិទ្ធិជូនដល់កម្មសិទ្ធិករពិតប្រាកដ។ ហើយតាមរយៈប័ណ្ណនេះក៏បានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនចំពោះស្ថាប័នដែលគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងប្រជាពលរដ្ឋ នៅក្នុងការប្រើប្រាស់ គ្រប់គ្រង និងការការពារនូវសុវត្ថិភាពដីធ្លីទាំងពេលបច្ចុប្បន្ន និងពេលអនាគត។ ជាពិសេសនោះការចុះបញ្ជីដីនេះបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការទប់ស្កាត់វិវាទដីធ្លីដែលជាបញ្ហាដ៏សំខាន់មួយនៅក្នុងសង្គមជាតិ ហើយអាចធ្វើឱ្យសង្គមទាំងមូលឈានទៅរកភាពសុខដុមនីយកម្ម និងបង្កើតបាននូវបរិយាកាសគ្មានវិវាទថែមទៀតផង។ ទាំងនេះក៏ព្រោះតែនៅក្នុងប័ណ្ណកម្មសិទ្ធិបានធ្វើការកំណត់យ៉ាងច្បាស់លាស់ពីប្រភេទទ្រព្យសម្បត្តិរបស់រដ្ឋ និងទ្រព្យសម្បត្តិរបស់ឯកជន ដូច្នេះវាមានភាពងាយស្រួលយ៉ាងខ្លាំងក្នុងការប្រើប្រាស់របស់កម្មសិទ្ធិករ។ បន្ថែមពីលើនេះការចុះបញ្ជីដីក៏បានជួយធ្វើឱ្យទីផ្សារដីមានស្ថិរភាព និងអាចទុកចិត្តបាន ដែលនេះគឺជាការសំខាន់នៅក្នុងវិស័យនៃការជួញដូរអចលនវត្ថុនឹងចូលរួមចំណែកនៅក្នុងការអភិវឌ្ឍប្រទេសជាតិ ដោយបានទាក់ទាញដល់វិនិយោគិនឱ្យចង់មកធ្វើការ វិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសារតែរចនាសម្ព័ន្ធនៃការគ្រប់គ្រងដីធ្លីរបស់ប្រទេសមានភាពរឹងមាំល្អ ដែលធ្វើឱ្យវិនិយោគិនអាចទុកចិត្តបាន។ ដូច្នេះដើម្បីឈ្វេងយល់ឱ្យកាន់តែលម្អិត យើងនឹងធ្វើការបកស្រាយបន្ថែមទៀតទៅលើ អត្ថប្រយោជន៍ចំពោះអាជ្ញាធរមានសមត្ថកិច្ច(**ផ្នែកទី១**) និងអត្ថប្រយោជន៍ចំពោះប្រជាពលរដ្ឋ(**ផ្នែកទី២**)។

## ផ្នែកទី១៖ អត្ថប្រយោជន៍ចំពោះអាជ្ញាធរមានសមត្ថកិច្ច

នៅក្នុងដំណើរការនៃការចុះបញ្ជីដីធ្លីក៏បានផ្តល់នូវគុណប្រយោជន៍ជាច្រើនដល់ស្ថាប័នរដ្ឋផងដែរ។ នៅពេលដែលដីរដ្ឋត្រូវបានចុះបញ្ជីរួចរាល់នោះវានឹងបង្កភាពងាយស្រួលដល់រដ្ឋនៅក្នុងការចាត់តាំងក្រសួង ស្ថាប័ន និងអង្គភាពដែលទទួលបាននូវអាណត្តិកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីគ្រប់គ្រង និងថែរក្សាទ្រព្យទាំងនោះឱ្យបានគង់វង្សនឹងជួយសម្រួលដល់ដំណើរការអភិវឌ្ឍរបស់រាជរដ្ឋាភិបាល និងការពារនូវការទន្ទ្រានចូលកាន់កាប់ដីរដ្ឋដោយខុសច្បាប់ពីសំណាក់ជនខិលខូច ឱកាសនិយម ឬក្រុមអ្នកមានលុយមានអំណាចមួយចំនួនផង

ដែលនេះនិងធ្វើឱ្យការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋប្រកបដោយចីរភាព។ ជាងនេះទៅទៀត ការចុះបញ្ជីដីធ្លីបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនផងដែរដល់អាជ្ញាធរដែលមានអាណាត្តិកាន់កាប់ និងគ្រប់គ្រងដីរដ្ឋ គ្រប់លំដាប់ថ្នាក់រួមមានដូចជាអាជ្ញាធរថ្នាក់ជាតិ(**កថាខណ្ឌទី១**)និងអាជ្ញាធរថ្នាក់ក្រោមជាតិ(**កថាខណ្ឌទី២**)។

### កថាខណ្ឌទី១៖ អាជ្ញាធរថ្នាក់ជាតិ

រដ្ឋ ទទួលបាននូវអត្ថប្រយោជន៍យ៉ាងច្រើនដែលបានមកពីដំណើរការនៃការចុះបញ្ជីដីធ្លី។ ជាពិសេសនោះគឺបានផ្តល់ភាពងាយស្រួលដល់អាជ្ញាធរដែលគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋនៅថ្នាក់ជាតិ នៅក្នុងការប្រើប្រាស់ និងចាត់ចែងដីធ្លីដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន មានដូចជាក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់(**វាក្យខណ្ឌទី១**) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(**វាក្យខណ្ឌទី២**) និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ(**វាក្យខណ្ឌទី៣**)។

#### វាក្យខណ្ឌទី១៖ ចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ច និងតួនាទីនៅក្នុងការគ្រប់គ្រង និងរៀបចំដីធ្លីទាំងឡាយនៅក្នុងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។ ហើយនៅពេលដែលដំណើរការចុះបញ្ជីដីធ្លីត្រូវបានបញ្ចប់ជាស្ថាពរនោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានភាពងាយស្រួលនៅក្នុងការគ្រប់គ្រង និងរៀបចំនូវប្រព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ(**NSDI**)[214] ដែលការរៀបចំនេះគឺផ្តោតទៅលើហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិនឹងធ្វើឱ្យព័ត៌មានអំពីដីធ្លីងាយស្រួលក្នុងការស្វែងរក មានតម្លៃទាប និងជាឧបករណ៍សម្រាប់ការគ្រប់គ្រង និងការប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធិភាពបន្ថែមទៀត។[215]ជាងនេះទៅទៀត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដី(**Parcel Bassed-LIS**) ដែលប្រព័ន្ធនេះត្រូវចាប់ផ្តើមធ្វើសមាហរណកម្មព័ត៌មានទាំងឡាយទាក់ទងនឹងដីធ្លីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយប្រើទិន្នន័យសុរិយោដីដែលមានស្រាប់ និងធ្វើសមាហរណកម្មព័ត៌មានផ្សេងៗទៀតអំពីដីធ្លីរបស់ក្រសួង។[216] ហើយមិនតែប៉ុណ្ណោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏មានភាពងាយស្រួលផងដែរនៅក្នុងការរៀបចំនូវទិន្នន័យសុរិយោដី ដែលជាការធ្វើសមាហរណកម្មទិន្នន័យសុរិយោដីជាមួយនឹងព័ត៌មានផ្សេងៗទៀតអំពីដីធ្លី មានដូចជាទិន្នន័យនៃផែនការរៀបចំដែនដី ផែនការប្រើប្រាស់ដី ការវាយតម្លៃថ្លៃដី ផែនទីឋានលេខា ទិន្នន័យភូមិសាស្ត្រ ទិន្នន័យប្រជាសាស្ត្រ បណ្តាញគមនាគមន៍

---

[214] (**NSDI**) National Spatial Data Infrastructure, គឺជាប្រព័ន្ធព័ត៌មានដីធ្លីជាមូលដ្ឋានសម្រាប់ហេដ្ឋារចនាសម្ព័ន្ធទិន្នន័យភូមិសាស្ត្រជាតិ។

[215] សៀវភៅ ស ដីធ្លី, ទំព័រ៣៣។

[216] សៀវភៅ ស ដីធ្លី, (**LIS**) Land Information System ជាប្រព័ន្ធព័ត៌មានដីធ្លី។

ទីតាំងតំបន់ទេសចរណ៍ ព្រំប្រទល់រដ្ឋបាល បណ្តាញប្រចពី នោះប្រព័ន្ធព័ត៌មានដីធ្លីផ្អែកលើក្បាលដីនឹងក្លាយជាមូលដ្ឋានទិន្នន័យសុរិយោដីបម្រើពហុគោលបំណង។[217] ក្រៅពីនេះ ក្រសួងអាចមានលទ្ធភាពដើរតាមគោលនយោបាយរៀបចំដែនដី ដែលគោលនយោបាយនេះ ជាផែនការអភិវឌ្ឍដីក្នុងការផ្គត់ផ្គង់សេចក្តីត្រូវការ ការកំណត់តំបន់ប្រើប្រាស់ដីសម្រាប់អភិវឌ្ឍន៍ទៅតាមអំណោយផលធម្មជាតិនៃដី ការធ្វើឱ្យប្រសើរឡើងនូវលក្ខណៈភូមិសាស្ត្រដោយឡែកៗ ការលើកកម្ពស់កម្រិតជីវភាពប្រជាជន ការកាត់បន្ថយនូវគម្លាតរវាងតំបន់ផ្សេងៗ និងបន្ស៊ីផែនការប្រើប្រាស់ដីក្នុងតំបន់ឱ្យស្របទៅនឹងការរៀបចំដែនដីទូទាំងប្រទេស ដោយពិចារណាអំពីលក្ខខណ្ឌ និងកត្តាតម្រូវនៃតំបន់ជាក់លាក់នីមួយៗ។ ជាងនេះទៅទៀតក្រសួងអាចអនុវត្តអនុវិស័យបែងចែកដីធ្លី ពោលគឺការផ្តល់ទិសដៅច្បាស់លាស់ដើម្បីធ្វើការបែងចែក និងផែនការប្រើប្រាស់ដីរដ្ឋ សម្រាប់គោលបំណងឯកជន និងសាធារណៈ ប្រកបដោយតម្លាភាព សមធម៌ និងជាការឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាពលរដ្ឋទូទៅ ជាពិសេសប្រជាពលរដ្ឋក្រីក្រ យុទ្ធជនពិការ និងគ្រួសារយុទ្ធជនពលី ដែលគ្មានដី និងខ្វះដីតាមរយៈកម្មវិធីសម្បទានសង្គមកិច្ច។ ហើយការបែកចែកដីធ្លីរបស់ក្រសួងនឹងធានាបាននូវសមធម៌ ស្ថេរភាពសង្គម សន្តិសុខស្បៀង សម្រួលដល់ការវិនិយោគ ដោយផ្អែកលើប្រភេទ និងគុណភាពអំណោយផលពីធម្មជាតិនៃដី ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចសង្គម ប្រកបដោយចីរភាព ទប់ស្កាត់ការប្រមូលដីទុក និងជម្រុញការប្រើប្រាស់ដីប្រកបដោយប្រសិទ្ធិភាពនិងផលិតភាព។ ជារួម តាមរយៈការចុះបញ្ជីដីធ្លីបានបង្កលក្ខណៈងាយស្រួលយ៉ាងខ្លាំងដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការៀបចំនូវប្រព័ន្ធទិន្នន័យដីបែបទំនើបមួយសម្រាប់ប្រទេសកម្ពុជា ដែលវានឹងជួយសម្រួលដល់ការគ្រប់គ្រងក្បាលដីទាំងអស់របស់ក្រសួង និងការងារអភិវឌ្ឍដីផងដែរ។

**ខ-វាក្យខណ្ឌទី២៖ ចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ក្រសួងកសិកកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងទៅលើវិស័យកសិកម្មនៃព្រះរាជាណាចក្រកម្ពុជា។[218] តាមរយៈនេះមានន័យថាក្រសួងកសិកម្មគ្រប់គ្រងទៅលើក្បាលដីកសិកម្មទាំងអស់ក្នុងប្រទេសកម្ពុជា ដែលផ្ទៃដីកសិកម្មនៅប្រទេសកម្ពុជាមានច្រើនប្រភេទ មានដូចជាដីស្រែ ដីចម្ការ ដីកសិដ្ឋានដីស្ថានីយ៍ពិសោធន៍ស្រាវជ្រាវ ដីមណ្ឌលអភិវឌ្ឍកសិកម្ម ដីដែននេសាទ ដីសមុទ្រ ដីព្រៃលិចទឹក ដីព្រៃកោងកាងជាពិសេសនោះគឺដីព្រៃ និងដីព្រៃបម្រុងទុកអចិន្ត្រៃយ៍ជាអាទិ៍ដែលដីទាំងអស់នេះត្រូវបានច្បាប់ភូមិបាល ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលបានផ្តល់សមត្ថកិច្ចដល់ក្រសួងកសិកម្មនៅក្នុងការគ្រប់គ្រង។ ហើយដីទាំងអស់នេះក៏ត្រូវបានច្បាប់ភូមិបាល២០០១ តម្រូវឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវធ្វើការចុះបញ្ជីនៅក្នុងសៀវភៅបញ្ជីគោលដីធ្លីជាមួយរដ្ឋបាលសុរិយោដីផងដែរ ដែលដំណើរការនៃការចុះបញ្ជីដីគឺប្រព្រឹត្តទៅតាម

---

217 សៀវភៅ ស ដីធ្លី, ទំព័រ៣៤។

218 ច្បាប់ស្តីពីការបង្កើតក្រសួងកិសកម្ម រុក្ខាប្រមាញ់ និងនេសាទ, ព្រះរាជក្រម នស/រកម/០១៩៦/១៣, ២៤ មករា ១៩៩៦។

នីតិវិធីដែលច្បាប់បានកំណត់។ ជាលទ្ធផលនៅពេលដែលដីទាំងអស់ដែលបានរៀបរាប់នៅខាងលើបានធ្វើការចុះបញ្ជីរួចរាល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញវិញ្ញាបនបត្រជូនក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ដើម្បីគ្រប់គ្រងលើដីទាំងនោះ។ ហើយនឹងមានភាពងាយស្រួល ក្នុងការគ្រប់គ្រងក្បាលដីដែលស្ថិតនៅក្រោមអាណត្តិកាន់កាប់របស់ខ្លួន ដើម្បីទប់ស្កាត់មិនឱ្យមានការទន្ទ្រានចូលកាន់កាប់ដោយខុសច្បាប់ណាមួយកើតឡើងលើដីរដ្ឋដែលបានរៀបរាប់ខាងលើ។ លើសពីនេះនឹងអាចរៀបចំនូវគោលនយោបាយកែទម្រង់ ការប្រើប្រាស់ដីធ្លីឱ្យមានប្រសិទ្ធិភាព ការចាត់ចែងដល់អង្គភាពនៅក្រោមឱវាទដើម្បីកាន់កាប់ និងរក្សាដីទាំងអស់នោះឱ្យបានគង់វង្ស។ ជាងនេះទៅទៀតក្រសួងកសិកម្មនឹងមានភាពងាយស្រួលក្នុងការចាត់ចែងដីធ្លីស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន មានដូចជាការធ្វើសម្បទានសេដ្ឋកិច្ចជាមួយក្រុមហ៊ុនឯកជនជាដើម ហើយចំពោះនីតិវិធីនៃការធ្វើសម្បទាននេះនឹងមានភាពងាយស្រួលដល់ការកំណត់ទំហំក្បាលដី ដែលជាកម្មវត្ថុនៃសម្បទានសេដ្ឋកិច្ចដោយមិនធ្វើឱ្យប៉ះពាល់ដល់កម្មសិទ្ធិឯកជន។

**វាក្យខណ្ឌទី៣៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងគ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅអភិវឌ្ឍសេដ្ឋកិច្ចនិងលើកតម្កើងជីវភាពប្រជាជន ដោយឈរលើគោលការណ៍សេដ្ឋកិច្ចនិងសមធម៌សង្គម។[219] ហើយក្រសួងនេះ ក៏មានមុខងារនិងភារកិច្ចក្នុងការប្រមូលពន្ធលើដីធ្លីទាំងពេលចុះបញ្ជី និងក្រោយពេលចុះបញ្ជីដី ជាក់ស្តែងការប្រមូលពន្ធជាតួនាទីរបស់អគ្គនាយកដ្ឋានពន្ធដារដែលជាអង្គភាពចំណុះឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ដូច្នេះហើយការចុះបញ្ជីដីធ្លី គឺពិតជាមានសារៈសំខាន់ណាស់ ព្រោះនៅពេលដែលក្បាលដីទាំងឡាយត្រូវបានចុះបញ្ជីរួចរាល់នោះក្រសួងអាចប្រមូលថវិការចូលជាតិតាមរយៈការបង់ពន្ធរបស់កម្មសិទ្ធិករលើដីធ្លី ដែលពន្ធលើដីធ្លីនេះមានពីរប្រភេទ គឺពន្ធលើដីដែលបានប្រើប្រាស់ និងពន្ធលើដីដែលមិនបានប្រើប្រាស់។ ជាងនេះទៅទៀត ក្រសួងសេដ្ឋ-កិច្ច និងហិរញ្ញវត្ថុ ក៏ជាអាជ្ញាធរ និងជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋផងដែរ។[220] ដែលតាមរយៈការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ នៅពេលដែលក្បាលដីរដ្ឋទាំងអស់ត្រូវបានចុះបញ្ជីរួចរាល់ ក្រសួងនឹងមានភាពងាយស្រួលក្នុងការពិនិត្យនិងដឹងពីបច្ចុប្បន្នភាពលើចំនួនក្បាលដីប្រភេទដី និងស្ថានភាពដីរបស់រដ្ឋមានក្នុងបញ្ជីសារពើភណ្ឌ ដែលអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋដាក់ជូនមក។ លើសពីនេះ នៅពេលដែលក្រសួងក្តោបបានព័ត៌មានអំពីដីរដ្ឋទាំងអស់បានហើយ នោះក្រសួងនឹងមានភាពងាយស្រួលក្នុងការចាត់ចែងដីរដ្ឋដូចជា

[219] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លេខ៤៣ អនក្រ.បក, ២៨ កុម្ភៈ ២០២២, មាត្រា២។
[220] អនុក្រឹត្យ ស្តីពីវិធាននីតិវិធី នៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, លេខ៦៦ អនក្រ.បក, ២៧ មេសា ២០១៧, មាត្រា៤។

ការលក់ ការដូរ ការជួល សម្បទាន ប្រទានកម្ម ដើម្បីបម្រើដល់ការអភិវឌ្ឍប្រទេសស្របតាមតម្រូវការជាក់ស្តែង។

ជារួម នៅពេលដីរបស់រដ្ឋទាំងអស់ត្រូវបានចុះបញ្ជី នោះវានឹងមានភាពងាយស្រួលដល់ក្រសួងក្នុងការពិនិត្យ តាមដាន គ្រប់គ្រង ប្រើប្រាស់ និងចាត់ចែងលើដីទាំងអស់នោះបានច្បាស់លាស់ ព្រោះតាមរយៈប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុបានផ្តល់នូវព័ត៌មានគ្រប់ជ្រុងជ្រោយ ដើម្បីឱ្យក្រសួងធ្វើការពិចារណាបានល្អិតល្អន់ក្នុងការចាត់ចែងលើដីរបស់រដ្ឋប្រកបដោយចីរភាព។

### កថាខណ្ឌទី២៖ អាជ្ញាធរថ្នាក់ក្រោមជាតិ

ចំពោះអត្ថប្រយោជន៍សម្រាប់អាជ្ញាធរថ្នាក់ក្រោមជាតិ ត្រូវបានបែងចែកជាពីរទៀតគឺរដ្ឋបាលដែនដីថ្នាក់រាជធានី ខេត្ត(**វាក្យខណ្ឌទី១**) និងរដ្ឋបាលដែនដីថ្នាក់ក្រុង ស្រុក ខណ្ឌ(**វាក្យខណ្ឌទី២**)។

### វាក្យខណ្ឌទី១៖ រដ្ឋបាលដែនដីថ្នាក់រាជធានី ខេត្ត

ក្រោយពីបានចុះបញ្ជីក្បាលដីទាំងអស់នៅក្នុងរាជធានី ខេត្ត រួចរាល់ហើយ ច្បាស់ណាស់ថ្នាក់រាជធានី ខេត្ត និងអាចសរុបទិន្នន័យនៃក្បាលដីទាំងអស់ ពោលគឺដឹងពីចំនួនក្បាលដីដែលនៅទំនេរ ក្បាលដីដែលម្ចាស់ទុកចោល ក្បាលដីដែលម្ចាស់ដីស្លាប់គ្មានទាយាទ ក្បាលដីសាធារណៈរបស់រដ្ឋ ឬនីតិបុគ្គលសាធារណៈ ក្បាលដីឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលឯកជន នៅពេលនោះរាជធានី ខេត្ត នឹងងាយស្រួលក្នុងការគ្រប់គ្រងនិងចាត់ចែងដីសាធារណៈរបស់រដ្ឋសម្រាប់បម្រើប្រយោជន៍សាធារណៈ ឯដីឯកជនរបស់រដ្ឋអាចធ្វើការលក់ ជួល ឬធ្វើអាជីវកម្មផ្សេងៗដើម្បីទទួលបានចំណូលយកមកផ្គត់ផ្គង់ដល់ការអភិវឌ្ឍក្នុងរាជធានី ខេត្ត របស់ខ្លួន។ ម៉្យាងវិញទៀត ងាយស្រួលក្នុងការរៀបប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ដែលជាការកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្រតម្រង់ទិសនៃការប្រើប្រាស់ដី ការអភិវឌ្ឍផ្នែករូបវន្ត បណ្តាញហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍សំខាន់ៗ ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗក្នុងក្របខណ្ឌថ្នាក់រាជធានី ខេត្ត។ បានន័យថានៅពេលដែលការចុះបញ្ជីដីធ្លីរួចរាល់ រាជធានី ខេត្ត និងអាចដឹងច្បាស់អំពីភូមិសាស្ត្រដី ក៏ដូចជាទីតាំងក្បាលដីទាំងអស់ ពោលគឺថ្នាក់ខេត្តអាចក្តោបបានច្បាស់លាស់នៅប្រភពព័ត៌មានបានគ្រប់ជ្រុងជ្រោយ ហើយអាចកំណត់អំពីតំបន់ដែលមានសក្តានុពលខ្ពស់ ដែលអាចជាប្រយោជន៍ក្នុងការអភិវឌ្ឍឱ្យស្របតាមតម្រូវការរបស់រាជធានី ខេត្ត។ ដោយឡែក នៅពេលដែលក្បាលដីនៅក្នុងរាជធានី ខេត្ត ទាំងមូលត្រូវបានចុះបញ្ជីរួចរាល់ និងមានភាពងាយស្រួលក្នុងការកំណត់ព្រំប្រទល់រាជធានី ខេត្ត ជាមួយនិងខេត្តដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីអាចបែងចែកដែនសមត្ថកិច្ចនៅក្នុងការគ្រប់គ្រងរាជធានី ខេត្ត ឱ្យមានសុវត្ថិភាពនិងស្ថេរភាព ព្រោះនៅពេលដែលរាជធានី ខេត្ត បានដឹងច្បាស់ពីព្រំប្រទល់និងដែនសមត្ថកិច្ចក្នុងការគ្រប់គ្រង នោះអាជ្ញាធររាជធានី ខេត្ត នឹងអាចទប់ស្កាត់និងហាមឃាត់បានចំពោះការចូលកាន់កាប់ និងទន្ទ្រានចាប់ដីរដ្ឋដោយខុសច្បាប់ពីសំណាក់ប្រជាពលរដ្ឋ។

**វាក្យខណ្ឌទី២៖ រដ្ឋបាលដែនដីថ្នាក់ក្រុង ស្រុក ខណ្ឌ**

តាមរយៈការងារចុះបញ្ជីដីបានផ្តល់អត្ថប្រយោជន៍ជាច្រើនដល់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលបានផ្តល់នូវលទ្ធភាពដល់អាជ្ញាធរនៅក្នុងការគ្រប់គ្រង និងប្រើប្រាស់ដី ប្រកបដោយប្រសិទ្ធិភាព និងចីរភាព។ ហើយនៅពេលដីទាំងអស់នៅក្នុងក្រុង ស្រុក ខណ្ឌ បានចុះបញ្ជីរួចរាល់ អាចធ្វើការរៀបចំទីប្រជុំជនឬតំបន់ជនបទដែលអាចគិតគូរទុកជាមុននិងរក្សានូវដីបម្រុងទុក សម្រាប់តម្រូវការនៃការអភិវឌ្ឍផ្នែកសាធារណៈ ឬការប្រើប្រាស់ផ្សេងទៀតនៃក្រុង ស្រុក ខណ្ឌ នៅពេលខាងមុខ ជាពិសេស សម្រាប់បណ្តាញគមនាគមន៍ និងតម្រូវការហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម ឬដំណោះស្រាយបញ្ហាលំនៅឋាន។ ជាងនេះទៅទៀតនឹងមានភាពងាយស្រួលនៅក្នុងការរៀបចំប្លង់គោលប្រើប្រាស់ដីសម្រាប់ថ្នាក់ស្រុក ខណ្ឌ និងប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ដើម្បីអភិវឌ្ឍក្នុងដែនដីរបស់ខ្លួន ព្រោះនៅពេលដែលក្បាលដីទាំងអស់នៅក្នុងក្រុង ស្រុក ខណ្ឌ ត្រូវបានចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី នោះវានឹងងាយស្រួលក្នុងការកំណត់នូវតំបន់អាទិភាព ដើម្បីអាចរៀបចំចក្ខុវិស័យក្រុង ស្រុក ខណ្ឌ នាពេលអនាគត។

## ផ្នែកទី២៖ អត្ថប្រយោជន៍ចំពោះប្រជាពលរដ្ឋ

នៅក្នុងការចេញប័ណ្ណសម្គាល់កម្មសិទ្ធិដីធ្លីគឺមានអត្ថន័យខ្លាំងណាស់ចំពោះប្រជាពលរដ្ឋ ព្រោះពួកគាត់នឹងក្លាយទៅជាម្ចាស់កម្មសិទ្ធិយ៉ាងពេញលេញ ដោយពួកគាត់អាចយកប័ណ្ណនេះទៅប្រើប្រាស់ទៅតាមតម្រូវការជាក់ស្តែង។ ក្រៅពីនេះ វាក៏បានជួយសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ការប្រកបរបរចញ្ចឹមជីវិត និងធ្វើឱ្យសេដ្ឋកិច្ចគ្រួសាររបស់ពួកគាត់មានភាពរីកចម្រើនជាលំដាប់ថែមទៀត។ ដូច្នេះដើម្បីដឹងថាការទទួលបានប័ណ្ណកម្មសិទ្ធិមានអត្ថប្រយោជន៍អ្វីខ្លះ យើងនឹងពិភាក្សាអំពី ការកាត់បន្ថយទំនាស់ក្នុងការរស់នៅ (**កថាខណ្ឌទី១**) និងការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី (**កថាខណ្ឌទី២**) ផងដែរ។

**កថាខណ្ឌទី១៖ ការកាត់បន្ថយទំនាស់នៅក្នុងការរស់នៅ**

ការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការកាត់បន្ថយវិវាទដីធ្លី និងបង្កើតឱ្យមាននូវបរិយាកាសមួយដែលគ្មានវិវាទនៅក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ។ បញ្ហាវិវាទដីធ្លី គឺជារឿង ដ៏ពុះកញ្ជ្រោលមួយនៅក្នុងសង្គមជាតិ មិនតែប៉ុណ្ណោះវាបានធ្វើឱ្យមានអស្ថិរភាពយ៉ាងធ្ងន់ធ្ងរនៅក្នុងសង្គម ហើយចំពោះការដោះស្រាយវិវាទវិញ គឺកាន់តែមានភាពស្មុគស្មាញ ថែមទាំងតម្រូវឱ្យភាគីត្រូវចំណាយថវិការជាច្រើនផងដែរ។ ដូច្នេះហើយការដែលគ្មានវិវាទដីធ្លី គឺជាសញ្ញាណដ៏ល្អមួយ ដែលបង្ហាញពីភាពរុងរឿងនៅក្នុងសង្គមជាតិ និងជួយឱ្យប្រទេសជាតិមានសន្ទស្សន៍នៃភាពរីកចម្រើនយ៉ាងឆាប់រហ័ស ព្រោះប្រជាពលរដ្ឋលែងខ្វល់ខ្វាយនិងបញ្ហាវិវាទនានាដែលអាចកើតឡើងលើដីធ្លីរបស់ពួកគាត់ ពោលគឺពួកគាត់និងមានពេលងាកមកគិតគូរនឹងពិចារណាទៅលើការប្រើប្រាស់ដីឱ្យអស់ពីលទ្ធភាព ដើម្បីទាញរកចំណូលមកផ្គត់ផ្គង់ដល់គ្រួសារឱ្យមានជីវភាព

ល្អប្រសើរ ដែលនេះជាកត្តាមួយអាចជម្រុញឱ្យសេដ្ឋកិច្ចជាតិមានភាពរីកចម្រើន។ លើសពីនេះប័ណ្ណកម្មសិទ្ធិដីធ្លីអាចឱ្យប្រជាពលរដ្ឋយកទៅប្រើប្រាស់ដើម្បីអះអាងចំពោះតតិយជនថាខ្លួនពិតជាម្ចាស់កម្មសិទ្ធិនៅលើដីយ៉ាងពិតប្រាកដ។ ហើយនៅពេលនោះបញ្ហានៃការប្រើហិង្សា ឬមធ្យោបាយទុច្ចរិតណាមួយដើម្បីទន្ទ្រានយកដីរបស់គាត់នឹងលែងកើតមាន ព្រោះបើមានការប្រព្រឹត្តសកម្មភាពទន្ទ្រានដូចបានរៀបរាប់នេះ ច្បាប់នឹងដាក់ទណ្ឌកម្មចំពោះជនទាំងទុច្ចរិតទាំងនេះ។ ជារួម ការចុះបញ្ជីនឹងធ្វើឱ្យប្រជាពលរដ្ឋមានភាពយល់ដឹងកាន់តែច្រើនពីកម្មសិទ្ធិរបស់ខ្លួន ជាពិសេសគឺព្រំដី ដូច្នេះការរស់នៅរបស់ពួកគាត់នឹងលែងមានការបំពានគ្នាទៅវិញទៅមក ដែលនេះគឺជាកត្តាដ៏ល្អមួយក្នុងការកាត់បន្ថយទំនាស់នៅក្នុងសង្គម។

### កថាខណ្ឌទី២៖ ការទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី

តាមរយៈការចុះបញ្ជីដី ប្រជាពលរដ្ឋនឹងទទួលបាននូវប័ណ្ណកម្មសិទ្ធិពីរដ្ឋ។ ហើយនៅក្រោយពេលដែលទទួលបានប័ណ្ណកម្មសិទ្ធិប្រជាពលរដ្ឋដែលជាម្ចាស់ដី និងត្រូវបានទទួលស្គាល់ជាម្ចាស់កម្មសិទ្ធិករយ៉ាងពេញលេញ ហើយអាចធ្វើការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យនោះបានដោយសេរី ដោយគាត់អាចយកប័ណ្ណនោះទៅប្រើប្រាស់នៅក្នុងប្រតិបត្តិការជំនួញផ្សេងៗ។ ហើយមិនតែប៉ុណ្ណោះប័ណ្ណកម្មសិទ្ធិដីធ្លី និងអាចជួយសម្រួលទៅដល់កម្មសិទ្ធិករដូចជាទទួលបាន ការការពារតាមផ្លូវច្បាប់(**ក**) សុវត្ថិភាពនៃការកាន់កាប់(**ខ**) ការលក់-ទិញ(**គ**) ការផ្ទេរកម្មសិទ្ធិ(**ឃ**) និងឥណទាន(**ង**) ។

#### ក. ការការពារតាមផ្លូវច្បាប់

ប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិដែលបានចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជូនដល់ប្រជាពលរដ្ឋ ហើយប័ណ្ណនេះត្រូវបានទទួលស្គាល់ និងការពារដោយច្បាប់ដែលនៅជាធរមាន ជាពិសេសនោះគឺរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈនេះ ប្រជាពលរដ្ឋគ្រប់រូបដែលជាម្ចាស់កម្មសិទ្ធិនៅលើដី ហើយច្បាប់បានទទួលស្គាល់ថាជាកម្មសិទ្ធិករស្របច្បាប់ មានសិទ្ធិក្នុងការការពារដីធ្លីរបស់ខ្លួន ដោយនៅពេលមានការទន្ទ្រានចូលកាន់កាប់ណាមួយដែលមិនត្រឹមត្រូវពីសំណាក់បុគ្គលឯកជនក្តី ឬការដកហូតពីសំណាក់នីតិបុគ្គលសាធារណៈក្តី ប្រសិនបើការដកហូតនោះមិនមែនធ្វើឡើងដើម្បីផលប្រយោជន៍សាធារណៈនោះទេ កម្មសិទ្ធិករអាចសុំការអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចឱ្យជួយការពារដល់ខ្លួន ហើយអ្វីដែលកាន់តែពិសេសនោះគឺអាចដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នតុលាការអំពីការបំពានដើម្បីសុំឱ្យតុលាការធ្វើការដោះស្រាយស្របតាមនីតិវិធីរបស់ច្បាប់ដែលមានជាធរមាន។ ផ្ទុយទៅវិញ ប្រសិនបើការដកហូតនោះក្នុងគោលបំណងបម្រើផលប្រយោជន៍របស់សាធារណៈ វាជាករណីលើកលែងមួយដែលត្រូវបានអនុញ្ញាតដោយច្បាប់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយការដកហូតនេះមិនអាចចេះតែធ្វើបាននោះទេ គឺត្រូវធ្វើឡើងស្របតាមនីតិវិធីច្បាប់នៃការដកហូត ពោលគឺច្បាប់ស្តីពីអស្សាមិករណ៍ដោយត្រូវផ្តល់សំណងយ៉ាងសមរម្យ

មួយដល់ប្រជាពលរដ្ឋដែលជាម្ចាស់ដី។[221] មួយវិញទៀត ប័ណ្ណកម្មសិទ្ធិក៏ជាភស្តុតាងមួយដ៏សំខាន់ផងដែរ ដែលអាចយកទៅបង្ហាញនិងអះអាងដល់ជនទាំងឡាយបាន នៅពេលដែលមានបញ្ហាវិវាទណាមួយកើតឡើង ដើម្បីបញ្ជាក់ថាខ្លួនគឺជាម្ចាស់កម្មសិទ្ធិយ៉ាងពិតប្រាកដលើដីនោះដែលមិនអាចប្រកែកបានឡើយ។ ជារួមមក នៅពេលដែលទទួលបានប័ណ្ណកម្មសិទ្ធិ នោះកម្មសិទ្ធិករនឹងត្រូវបានការពារដោយច្បាប់យ៉ាងពិតប្រាកដ ដោយម្ចាស់កម្មសិទ្ធិករអាចធ្វើការគ្រប់គ្រង និងប្រើប្រាស់យ៉ាងពេញលេញនៅលើដីរបស់ខ្លួន ហើយមិនតែប៉ុណ្ណោះ ច្បាប់ក៏បានអនុញ្ញាតដល់កម្មសិទ្ធិករអាចយកប័ណ្ណនេះទៅប្រើប្រាស់នៅក្នុងប្រតិបត្តិការជំនួញផ្សេងៗផងដែរ។

### ខ. សុវត្ថិភាពនៃការកាន់កាប់

តាមរយៈការទទួលបានប័ណ្ណកម្មសិទ្ធិ គឺបានផ្តល់នូវគ្រឹះនៃទំនុកចិត្តយ៉ាងខ្លាំងដល់កម្មសិទ្ធិករគ្រប់រូប ក្នុងការកាន់កាប់ និងការប្រើប្រាស់ដីរបស់ខ្លួនប្រកបដោយសុខសុវត្ថិភាព ដោយពួកគាត់និងមិនមានភាពបារម្ភ សោះឡើយពីការបាត់បង់នូវភាពជាម្ចាស់លើដីរបស់ខ្លួន។ ដោយប័ណ្ណនេះបានធានាសិទ្ធិយ៉ាងពេញលេញក្នុង ការធ្វើជាម្ចាស់របស់ប្រជាពលរដ្ឋ ព្រោះថានៅក្នុងការចុះបញ្ជីដីធ្លីបានធ្វើការកំណត់អត្តសញ្ញាណម្ចាស់សិទ្ធិលើ ក្បាលដី ហើយប្រសិនបើក្បាលដីនោះបានចុះបញ្ជី និងបានផ្តល់ប័ណ្ណកម្មសិទ្ធិរួចរាល់ហើយ ក្បាលដីនោះនឹង ត្រូវបានធានាទាំងផ្នែកបច្ចេកទេស និងទិដ្ឋភាពច្បាប់។ លើសពីនេះ នៅពេលដែលការកាន់កាប់មានសុវត្ថិភាព ហើយ នោះការប្រើប្រាស់ដីរបស់ពួកគាត់នឹងកាន់តែមានភាពល្អប្រសើរឡើងជាលំដាប់ជាក់ជាមិនខាន ដោយ ពួកគាត់នឹងមិនមានការបារម្ភ ឬភ័យខ្លាចច្រើនទៀតឡើយ។

### គ. ការលក់-ទិញ

ក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់បានទទួលស្គាល់ និងអនុញ្ញាតឱ្យមានការទិញ លក់ នូវអចលនវត្ថុ របស់បុគ្គលឯកជន និងបុគ្គលឯកជន ដែលនៅក្នុងប្រតិបត្តិការនេះ គឺផ្តោតសំខាន់យ៉ាងខ្លាំងទៅលើកម្មវត្ថុនៃ កិច្ចសន្យា ប្រសិនបើកម្មវត្ថុនេះមិនស្របច្បាប់ ឬច្បាប់មិនទទួលស្គាល់នោះនឹងនាំឱ្យមានបញ្ហាកើតមានឡើង ជាក់ជាមិនខាន។ ជាក់ស្តែងក្នុងវិស័យទិញ លក់អចលនវត្ថុ ប័ណ្ណសម្គាល់ម្ចាស់អចលនវត្ថុ គឺជាកម្មវត្ថុជាចម្បង នៃការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ ដែលអ្នកលក់មានកាតព្វកិច្ចផ្ទេរនូវសិទ្ធិកម្មសិទ្ធិនៅលើអចលនវត្ថុទៅឱ្យភាគីម្ខាង ទៀតដែលជាភាគីនៃកិច្ចសន្យាទិញ លក់។ ត្រង់ចំណុចនេះ គេអាចសង្កេតឃើញថាប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការទិញលក់អចលនវត្ថុ ព្រោះកាលណាមានប័ណ្ណកម្មសិទ្ធិវានឹងបង្កភាព ងាយស្រួលដល់អ្នកលក់ និងអ្នកទិញ ហើយជួយពន្លឿនដល់នីតិវិធីនៃការទិញ លក់ មិនឱ្យមានភាពស្មុគស្មាញ

[221] ច្បាប់ស្តីពី អស្សាមិករណ៍, លេខនស/រកម/០២១០/00៣, ២៦ កុម្ភៈ ២០១០, មាត្រា១ បានចែងថាច្បាប់នេះមានគោលដៅកំណត់ពី អស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសំណងឱ្យបានសមរម្យ និងយុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និងគម្រោងពង្រីក ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍ជាតិ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា។

ចំណេញទាំងពេលវេលា និងថវិការ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការទិញ លក់ដីធ្លីអាចធ្វើទៅបាន ចំពោះតែប្រជាពលរដ្ឋខ្មែរតែប៉ុណ្ណោះ ដោយច្បាប់មិនបានអនុញ្ញាតឱ្យមានការទិញលក់ដីជាមួយនឹងជនបរទេសនោះឡើយ។[222] ប៉ុន្តែកម្មសិទ្ធិករក៏មានសេរីភាពយ៉ាងពេញលេញផងដែរចំពោះការដាក់លក់នូវដីធ្លីរបស់ខ្លួន នៅពេលដែលមានតម្រូវការចាំបាច់ដើម្បីដោះស្រាយជីវភាព ដែលនេះគឺជាសិទ្ធិនៅក្នុងការចាត់ចែងទៅលើកម្មសិទ្ធិ ហើយសិទ្ធិនេះក៏ត្រូវបានការពារដោយច្បាប់ផងដែរ។

### ឃ. ការផ្ទេរកម្មសិទ្ធិលើដីធ្លី

នៅក្នុងសង្គមខ្មែរ ប្រជាពលរដ្ឋតែងតែផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនដែលមានដូចជា គោក្របី ផ្ទះសម្បែង ជាពិសេសនោះគឺដីធ្លីដល់កូនចៅរបស់ខ្លួន ដែលវាជារឿងដ៏សំខាន់មួយនៅចំពោះការរស់នៅក្នុងសង្គម។ ការផ្ទេរបែបនេះមានតាំងពីមុនសម័យអាណានិគមបារាំងមកម្ល៉េះ ទោះបីជាពេលនោះច្បាប់មិនទាន់ចែងឡើងក៏ដោយ ក៏ប្រជាពលរដ្ឋបានអនុវត្តបន្តគ្នាពីជំនាន់មួយទៅជំនាន់មួយ រហូតក្លាយទៅជាទំនៀមទម្លាប់មួយនៅក្នុងប្រទេស។ ប៉ុន្តែចាប់តាំងពីមានក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា របបសន្តតិកម្មថ្មីមួយត្រូវបានបង្កើតឡើង ដោយរបបនេះគ្រប់គ្រងទៅលើការផ្ទេរមត៌កនៅក្នុងប្រទេស។ ជាក់ស្តែងចំពោះដីធ្លី នៅពេលដែលម្ចាស់ដីបានស្លាប់ទៅមិនមានបណ្តាំ ដីនោះក៏ត្រូវបានផ្ទេរតាមវិធាននៃសន្តតិកម្មតាមច្បាប់ ទៅឱ្យសន្តតិជនដែលជាអ្នកទទួលបន្តនូវចំណែកមត៌កផងដែរ ប៉ុន្តែបញ្ហាត្រង់ថា ប្រសិនបើដីនោះពុំទាន់បានចុះបញ្ជីទេ វាអាចនឹងកើតមានជម្លោះរឿងម្ចាស់កម្មសិទ្ធិនៅលើដី ដោយឡែកប្រសិនបើដីនោះបានចុះបញ្ជីរួចរាល់និងមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះឈ្មោះម្ចាស់កម្មសិទ្ធិពិតប្រាកដនិងឃើញមាននៅលើសន្លឹកប័ណ្ណនោះតែម្តង ដូច្នេះបើមានជម្លោះកើតមានឡើងនោះតុលាការនិងងាយស្រួលក្នុងការពិចារណាថាអ្នកណានិងជាអ្នកទទួលបន្តនិងមានសិទ្ធិនៅលើក្បាលដីនោះ។ ម៉្យាងវិញទៀត នៅពេលដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ម្ចាស់ដីនឹងមានភាពងាយស្រួលនៅក្នុងការផ្ទេរដីនោះទៅឱ្យនរណាម្នាក់តាមរយៈការសរសេរបណ្តាំចុងក្រោយមុននិងខ្លួនស្លាប់ទៅបានផងដែរ ដោយការផ្ទេរបែបនេះ គឺជាការផ្ទេរតាមរយៈមតកសាសន៍។ ផ្ទុយទៅវិញ ចំពោះករណីម្ចាស់ដីនៅរស់រានមានជីវិតវិញ នោះគាត់ក៏អាចផ្ទេរដីនោះតាមរយៈប្រទានកម្ម ឬធ្វើអំណោយទៅឱ្យនរណាម្នាក់បានយ៉ាងងាយស្រួលផងដែរ ព្រោះថាលើប័ណ្ណដីនោះមានឈ្មោះគាត់ជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ដូច្នេះគាត់អាចបង្ហាញឆន្ទៈក្នុងការផ្ទេរទៅឱ្យនរណាម្នាក់បានគ្រប់ពេល ដោយគ្រាន់តែទៅធ្វើការកាត់ឈ្មោះផ្ទេរម្ចាស់កម្មសិទ្ធិលើក្បាលដីនោះនៅរដ្ឋបាលសុរិយោដីដែលនៅជិតគាត់។ ជារួមគេអាចសង្កេតឃើញថាការផ្ទេរកម្មសិទ្ធិលើដីនៅពេលដែលមានប័ណ្ណកម្មសិទ្ធិ គឺមានភាពផ្លាស់ប្តូរយ៉ាងខ្លាំងជាងពេលដែលមិនទាន់មានប័ណ្ណកម្មសិទ្ធិ ព្រោះក្បាលដីទាំងអស់ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបានកំណត់ឈ្មោះរបស់ម្ចាស់កម្មករលើដី

[222] រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣, មាត្រា៤៤។

នោះបានច្បាស់លាស់ ហើយធ្វើឱ្យការផ្ទេរនោះមានភាពឆាប់រហ័ស សុវត្ថិភាព ប្រសិទ្ធិភាព ថែមទាំងជួយទប់ស្កាត់និងការពារមិនឱ្យមានបញ្ហាជម្លោះរឿងម្ចាស់កម្មសិទ្ធិកើតមានឡើងផងដែរ។

**ខ. ឥណទាន**

ឥណទាន គឺជាសេវារបស់ធនាគារមួយប្រភេទ ដែលបើកឱ្យម្ចាស់ទ្រព្យអាចយកទ្រព្យរបស់ខ្លួនដែលមានទៅដាក់បញ្ចាំនៅធនាគារ ដើម្បីទទួលបានប្រាក់ពីធានាគារយកមកប្រើប្រាស់តាមតម្រូវការជាក់ស្តែងរបស់ខ្លួន។ តាមរយៈនេះ នៅក្រោយពេលការចុះបញ្ជីដីបានបញ្ចប់ ប្រជាពលរដ្ឋនឹងទទួលបាននូវប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិ ហើយប័ណ្ណនេះក៏បានផ្តល់នូវសិទ្ធិយ៉ាងពេញលេញដល់ប្រជាពលរដ្ឋផងដែរ ក្នុងការយកប័ណ្ណនោះទៅដាក់បញ្ចាំ ឬដាក់ហ៊ីប៉ូតែកជាដើម ដើម្បីបានប្រាក់មកផ្គត់ផ្គង់ជីវភាពគ្រួសារ ពង្រីកមុខរបរ និងធ្វើអាជីវកម្មជាដើមស្របទៅតាមតម្រូវការជាក់ស្តែងរបស់ពួកគាត់។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវ និងបកស្រាយនូវខ្លឹមសាររបស់ប្រធានបទខាងលើរួចមក ឃើញថាការចុះបញ្ជីដីធ្លីគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់សង្គមជាតិទាំងមូល ព្រោះវាគឺមាគ៌ាមួយដ៏ល្អប្រសើរសម្រាប់ផ្តល់ឱ្យប្រជាពលរដ្ឋទទួលបានសិទ្ធិជាម្ចាស់កម្មសិទ្ធិយ៉ាងពិតប្រាកដចំពោះទ្រព្យរបស់ខ្លួនដែលមានបញ្ជាក់ច្បាស់នៅក្នុងវិញ្ញាបនបត្រដែលជាតឹកតាងដ៏សំខាន់មួយដែលប្រៀបបានដូចជាទ្រព្យដ៏មានតម្លៃដែលអាចបន្តគ្រប់ជំនាន់។ ជាងនេះទៅទៀត ការចុះបញ្ជីក៏បានជួយបញ្ជាក់ពីភាពច្បាស់លាស់ចំពោះប្រភេទកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សផ្សេងទៀតដែលមាននៅលើក្បាលដី ពោលគឺអាចកំណត់អត្តសញ្ញាណម្ចាស់កម្មសិទ្ធិ និងម្ចាស់សិទ្ធិប្រត្យក្សនៅលើក្បាលដី ប្រែប្រួលទៅតាមទីតាំងភូមិសាស្ត្រ និងសក្តានុពលនៃដីនៅទូទាំងប្រទេសផងដែរ ដែលទាំងនេះក៏បានជួយទប់ស្កាត់ជម្លោះណាមួយដែលអាចកើតមានឡើងនៅក្នុងសង្គម និងបានផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់កម្មសិទ្ធិករ និងម្ចាស់កម្មសិទ្ធិកាន់កាប់ដទៃផ្សេងទៀត និងថែមទាំងបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរុងរឿងថែមទៀតផង។

ជាការពិតណាស់នៅក្នុងការអនុវត្តដំណើរការចុះបញ្ជីដីធ្លីវិញ មាននូវលិខិតបទដ្ឋានគតិយុត្តជាច្រើនដែលត្រូវបានបង្កើតឡើងមកដើម្បីកំណត់អំពីគោលការណ៍ក្នុងការអនុវត្ត និងគាំទ្រដល់នីតិវិធីនៃការចុះបញ្ជីដីដែលបានយកមកប្រើប្រាស់នៅក្នុងការផ្តល់កម្មសិទ្ធិលើដីធ្លី។ ជាក់ស្តែងគេអាចមើលឃើញថាមាននីតិវិធីធំៗចំនួនពីរ ដែលកំពុងអនុវត្តក្នុងប្រទេសកម្ពុជា ហើយនីតិវិធីនេះអាចត្រូវធ្វើឡើងតាមគំនិតផ្តួចផ្តើមពីសំណាក់រាជរដ្ឋាភិបាល និងអាចតាមការស្នើសុំរបស់កម្មសិទ្ធិករ។ លើសពីនេះដើម្បីអាចអនុវត្តនូវដំណើរការទាំងនេះបានតម្រូវឱ្យជនដែលពាក់ព័ន្ធគ្រប់មជ្ឈដ្ឋានទាំងអស់ត្រូវតែចូលរួមស្របទៅតាមដំណាក់កាលនីមួយៗដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត ឬអនុក្រឹត្យជាដើម ដើម្បីសម្រេចបាននូវលទ្ធផលចុងក្រោយនោះគឺការទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលបញ្ជាក់ពីភាពច្បាស់លាស់ចំពោះកម្មសិទ្ធិលើក្បាលដី។

ជារួមមក ដំណើរការចុះបញ្ជីដីគឺមានភាពស្មុគស្មាញយ៉ាងខ្លាំង និងមានច្រើនដំណាក់កាលដែលត្រូវអនុវត្ត និងត្រូវតែអនុវត្តពីមួយដំណាក់កាលទៅមួយដំណាក់កាល ទើបអាចទទួលបានជោគជ័យ និងទទួលបាននូវកម្មសិទ្ធិទៅលើដីធ្លី។ ដូច្នេះដើម្បីធ្វើឱ្យការចុះបញ្ជីដីធ្លី អាចប្រព្រឹត្តទៅបានដោយរលូននោះគឺវាទាមទារឱ្យអ្នកដែលពាក់ព័ន្ធ ត្រូវតែគោរពប្រតិបត្តិទៅតាមអ្វីដែលមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តិ ដែលមានជាធរមានឱ្យបានខ្ជាប់ខ្ជួន ហើយត្រូវអនុវត្តប្រកបដោយតម្លាភាព ដើម្បីពន្លឿននីតិវិធី និងអាចសម្រេចបានទាំងគុណភាព និងមានប្រសិទ្ធិភាពខ្ពស់។ យ៉ាងណាក៏ដោយក្នុងករណីម្ចាស់ដីអវត្តមានក្នុងការចុះបញ្ជីជាប្រព័ន្ធ ឬក្នុងករណីកម្មសិទ្ធិករត្រូវការផ្ទេរសិទ្ធិនៅក្រោយពេលចុះបញ្ជីវិញ ក៏នៅតែជារឿងមួយដ៏ស្មុគស្មាញផងដែរនៅក្នុងសង្គម ដែលទាំងអស់នេះគឺតម្រូវឱ្យគោរពនូវនីតិវិធីដាច់ដោយឡែកផ្សេងទៀត។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅទៅលើប្រធានបទ “**អំពីការចុះបញ្ជីដីធ្លីនៅកម្ពុជា**” ឃើញថា នៅក្នុងដំណើរការចុះបញ្ជីដីធ្លី ពិតជាបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍប្រទេសជាតិ និងជួយលុបបំបាត់នូវជម្លោះបានមួយផ្នែកធំដែលកើតមាននៅក្នុងសង្គមផងដែរ។ ហើយដំណើរការនេះក៏មានការយកចិត្តទុកដាក់ និងគាំទ្រយ៉ាងខ្លាំង ពីសំណាក់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសគឺក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។ ប៉ុន្តែក្នុងនាមយើងខ្ញុំជានិស្សិតដែលជាអ្នកសិក្សាស្រាវជ្រាវ សូមធ្វើការចូលរួមផ្តល់ជាគំនិត មតិយោបល់ និងការយល់ឃើញជាសំណូមពរដល់ភាគីដែលពាក់ព័ន្ធសម្រាប់ជាការពិចារណា ដើម្បីធ្វើឱ្យការចុះបញ្ជីដីកាន់តែមានភាពល្អប្រសើរ និងងាយស្រួលបន្ថែមទៀត។

**ចំពោះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**ការផ្សព្វផ្សាយអំពីការចុះបញ្ជីបច្ចុប្បន្នមានភាពល្អប្រសើរ ប៉ុន្តែពុំទាន់មានភាពទូលំទូលាយនៅឡើយ ដូច្នេះក្រសួងគប្បីបោះពុម្ព ចែកផ្សាយខិត្តប័ណ្ណ និងបង្កើនការផ្សព្វផ្សាយនេះឱ្យបានភ្លៀវភ្លាអំពីឯកសារនានាពាក់ព័ន្ធនឹងការចុះបញ្ជីដែលមានដូចជា ច្បាប់ លិខិតបទដ្ឋានគតិយុត្ត សៀវភៅណែនាំ វីឌីអូអប់រំ សិក្ខាសាលាជាអាទិ៍ តាមរយៈទូរផ្សាយ ប្រព័ន្ធអ៊ីនធឺណេត ឱ្យបានដល់ភាគីពាក់ព័ន្ធ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ដាច់ស្រយ៉ាល។ លើសពីនេះគប្បីបង្កើនការពង្រឹងសមត្ថភាពរបស់មន្ត្រីសុរិយោដី ព្រមទាំងរឹតបន្តឹងវិន័យចំពោះមន្ត្រីខិលខូចដែលបានយកកម្រៃសេវាលើសអ្វីដែលច្បាប់បានកំណត់ តាមរយៈការដាក់ចេញនូវគោលការណ៍នានា ដើម្បីឱ្យការអនុវត្តការងារកាន់តែមានភាពច្បាស់លាស់ថែមទៀត។ ជាពិសេសគប្បីពន្លឿននីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចឱ្យមានមានភាពងាយស្រួល និងឆាប់រហ័ស ចាត់តាំងមន្ត្រីសុរិយោដីឱ្យចុះទៅណែនាំលម្អិតអំពីនីតិវិធីនៃការចុះបញ្ជីដីដល់សហគមន៍ជនជាតិដើមភាគតិច តាមរយៈមធ្យោបាយផ្សេងៗ ដើម្បីអាចឱ្យពួកគាត់យល់ច្បាស់នឹងអាចចូលរួមក្នុងការអនុវត្តបាន។

**ចំពោះប្រជាពលរដ្ឋ** គប្បីសិក្សាស្វែងយល់ជាមុននូវរាល់ព័ត៌មានទាំងឡាយណា ដែលទាក់ទងនិងការចុះបញ្ជី ដើម្បីអាចត្រៀមខ្លួនក្នុងការរៀបចំឯកសារឱ្យបានច្បាស់លាស់សម្រាប់ដំណើរការចុះបញ្ជី។ ហើយគួរតែស្វែងរកការឯកភាពគ្នារវាងម្ចាស់ដែលមានក្បាលដីជាប់គ្នា ក្នុងការកំណត់ព្រំឱ្យបានមុន ចៀសវាងមានជម្លោះនៅពេលអនុវត្តនីតិវិធី ដែលវានឹងរំខានដល់ដំណើរការនៃវាស់វែង ប៉ុន្តែប្រសិនបើក្នុងករណីមានវិវាទណាមួយកើតឡើងគប្បីព្យាយាមសម្រុះសម្រួល និងដោះស្រាយដោយសន្តិវិធី មុននឹងសំណុំរឿងត្រូវបញ្ជូនទៅដល់គណៈកម្មការសុរិយោដី ឬតុលាការដែលត្រូវការពេលយូរ និងចំណាយថវិកាច្រើន។ ចំណែកឯក្នុងករណីម្ចាស់ដីឱ្យគេចាំដីដើម្បីថែរក្សាដីនោះ គប្បីធ្វើកិច្ចសន្យាឱ្យបានច្បាស់លាស់ជាមួយអ្នកចាំដី ចៀសវាងគាត់លួចធ្វើប័ណ្ណកម្មសិទ្ធិ ដែលជាហេតុនាំឱ្យមានជម្លោះក្រោយពេលចេញប័ណ្ណដី។

# ឯកសារយោង

# ឯកសារយោង

## រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ឆ្នាំ១៩៩៣។

រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា, ៣០ មេសា ១៩៨៩។

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា, ឆ្នាំ១៩៨១។

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, ឆ្នាំ១៩៧៥។

## ច្បាប់

ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ, លេខនស/រកម/១១២០/០៣០, ១៤ វិច្ឆកា ២០២០។

ច្បាប់ស្តីពីសញ្ជាតិ, លេខ នស/រកម/០៦១៨/០០៨, ២១ មិថុនា ២០១៨។

ច្បាប់ស្តីពីអស្សាមិករណ៍, លេខ នស/រកម/០២១០/០០៣, ២៦ កុម្ភៈ ២០១០។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧។

ច្បាប់ភូមិបាល, លេខ នស/រកម/ ០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ស្តីពីព្រៃឈើ, លេខ នស/រកម/០៨០២/០១៦, ៣០ សីហា ២០០២។

ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ នស/រកម/០៦៩៩/០៩, ២៣ មិថុនា ១៩៩៩។

ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, លេខ នស/រកម/០១៩៦/១៣, ២៤ មករា ១៩៩៦។

ច្បាប់ភូមិបាល, លេខ ១០០ក្រ,១៣ តុលា ១៩៩២។

## អនុក្រឹត្យ

អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ, លេខ៣២១អនក្រ.បក, ២ វិច្ឆកា ២០២៣។

អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, លេខ៤៣ អនក្រ.បក, ២៨ កុម្ភៈ ២០២២។

អនុក្រឹត្យ ស្តីពីវិធាននីតិវិធី នៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ, លេខ៦៦ អនក្រ.បក, ២៧ មេសា ២០១៧។

អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១នៃអនុក្រឹត្យលេខ៤៦អនក្រ.បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ១២២អនក្រ.បក, ០៩ មិថុនា ២០១៦។

អនុក្រឹត្យ ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ៣១ ឧសភា ២០០២,

ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ,លេខ១២១ អនក្រ.បក, ០៩ មិថុនា ២០១៦។
អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣ អនក្រ.បក,១៩មិថុនា ២០០៩។
អនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច, លេខ១៩អនក្រ, ១៩ មីនា ២០០៣។
អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦អនក្រ.បក, ៣១ ឧសភា ២០០២។
អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨អនក្រ, ៣១ ឧសភា ២០០២។
អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, លេខ៦២ អនក្រ/បក, ២០ កក្កដា ១៩៩៩។
អនុក្រឹត្យ ស្តីការផ្ទេរនាយកដ្ឋានសុរិយោដីនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី, លេខ៥៨ អនក្រ, ៣០ តុលា ១៩៩៤
អនុក្រឹត្យស្តីពីការផ្តល់កម្មសិទ្ធិលើផ្ទះសម្បែងជូនប្រជាពលរដ្ឋកម្ពុជា, លេខ២៥អនក្រ, ២២ មេសា ១៩៨៩។

**សារាចរណែនាំ**

សារាចរណែនាំ ស្តីពីការអនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ, លេខ១៤ ដនស/សរណន, ៣០ កញ្ញា ២០០៩។
សារាចរណែនាំ ស្តីពីការអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ០០១ ដនស/សដ, ១៩ សីហា ២០០២។

**សេចក្តីសម្រេច**

សេចក្តីសម្រេចស្តីពី នីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី,លេខ០៤០ សសរ, ២២ កក្កដា ២០១៤។
សេចក្តីសម្រេចស្តីពី នីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ, លេខ០៤១សសរ, ២២ កក្កដា ២០១៤។

**គោលនយោបាយ**

រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយដីធ្លី, “សៀវភៅសដីធ្លី”, (រៀបចំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់), ២៨ សីហា ២០១៥។
រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា, ០៨ មេសា ២០១១។
រាជរដ្ឋាភិបាលកម្ពុជា, ក្របខណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី, ០៦ កញ្ញា ២០០២។
ក្រុមប្រឹក្សាគោលនយោបាយដីធ្លី, គោលនយោបាយស្តីពី៖ ការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅព្រះរាជាណាចក្រកម្ពុជា, ២៤ មេសា ២០០៩។

ធនាគារពិភពលោក, ក្របខណ្ឌគោលនយោបាយសម្រាប់ជនជាតិដើមភាគតិច។
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤ ដល់២០១៨, ខែមិថុនា ២០១៥។
**សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល**
សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយដីធ្លី, កក្កដា ២០០៩។
**ប្រកាស**
ប្រកាសស្តីពីការតែងតាំង និងនាយកដ្ឋានសុរិយោដី, លេខ១១១ ប្រក/កសក, ៣១ តុលា ១៩៨៩។
**សៀវភៅ**
East-west management Institute. Inc, សៀវភៅច្បាប់ភូមិបាលកម្ពុជា សៀវភៅសិក្សាស្រាវជ្រាវ, (កែសម្រួលនៅឆ្នាំ២០០៥)។
ក្រសួងអប់រំ យុវជន និងកីឡា, ប្រវត្តិវិទ្យាថ្នាក់ទី១២, (ភ្នំពេញ៖ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ, ឆ្នាំ២០១១)។
ត្រឹង ងា, ប្រវត្តិសាស្ត្រខ្មែរភាគ១~២ (សម្រាប់មធ្យមសិក្សានិង ឧត្តមសិក្សា), ភ្នំពេញគ.ស១៩៧៣។
បណ្ឌិត អ៊ុន សកក្កដា, នីតិទ្រព្យសម្បត្តិសាធារណៈ៖ សំរាប់បរិញ្ញាបត្រជាន់ខ្ពស់ រដ្ឋបាលសាធារណៈ, ឆ្នាំសិក្សា ២០១៥-២០១៦
ពៅ សារឿន, ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា, ឆ្នាំ២០១០។
សៀវភៅណែនាំស្តីពីដំណើរការនៃការកំណត់អត្តសញ្ញាណការចុះបញ្ជីជានីតិបុគ្គល និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា។
ហាប់ ផល្លី, វាយទ្បើងវិញក្រមរងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងដីធ្លី និងនគរូបនីយកម្មឆ្នាំ ១៩៨៥-២០១៥, បោះពុម្ពលើកទី៤ (ភ្នំពេញជោគជ័យ, ឆ្នាំ២០១៨)។
ហាប់ ផល្លី, នីតិទ្រព្យសម្បត្តិឯកជន៖ ករណីសិក្សានៅកម្ពុជា, (ភ្នំពេញ៖ Premium Advertising, ២០២១)។
ឥន្ទ ឱមសាម៉េង, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា, ឆ្នាំ២០០៩។
**ឯកសារដែលបានបោះពុម្ពផ្សាយ**
វិទ្យាស្ថានសភាកម្ពុជា, ឯកសារស្រាវជ្រាវសង្ខេបដោយក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨៖ ការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច នៅក្នុងខេត្តរតនៈគីរី។
ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសាធារណៈការ និងដឹកជញ្ជូន, សម្រាប់ក្រុមធានាគារពិភពលោក, ក្របខណ្ឌកសាងផែនការសម្រាប់ជនជាតិដើមភាគតិចសម្រាប់គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យក្នុងប្រទេសកម្ពុជា, ខែធ្នូ ឆ្នាំ២០០៨។
មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ និងសមាគមន៍អាដហុក, គំរោងសាកល្បងស្តីពី ការអប់រំច្បាប់ភូមិបាល៖ ឯកសារសម្រាប់ការអប់រំប្រជាពលរដ្ឋ, ឆ្នាំ២០០២។

វេទិកាមិនមែនរដ្ឋាភិបាល( The NGO Forum on Cambodia ), ព្រឹត្តប័ត្រប្រចាំត្រីមាសៈ ដី និងជីវិត, ឆ្នាំទី៣ លេខ០៩, ខែមករា-ខែមីនា ឆ្នាំ២០០៨។

វេទិកាមិនមែនរដ្ឋាភិបាល( The NGO Forum on Cambodia ), កាទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា, ភ្នំពេញ ខែវិច្ឆកា ២០១២។

## លិខិត

លិខិតរបស់គណៈរដ្ឋមន្ត្រីស្តីពីករណីបញ្ហាទំនាស់កម្មសិទ្ធិដីធ្លីរវាងអាជ្ញាធរ និងប្រជារាស្ត្រ, លេខ១០៥២ សជណ/សរ, ៥ កក្កដា ១៩៩៥

លិខិតរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តបន្ទាយមានជ័យ, ស្តីពីការគ្រប់គ្រងដីរដ្ឋក្នុងអាណត្តិដែលបានចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវចុះបញ្ជីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ( កម្មសិទ្ធិលើដីរដ្ឋ ) ក្នុងខេត្តបន្ទាយមានជ័យ,លេខ ៤៨៩៩/២២ដនសស-បជ/សដភ, ១៥ កក្កដា ២០២២។

## ឯកសារដែលមិនបានបោះពុម្ពផ្សាយ

លឹម វ៉ាន់, “ការគ្រប់គ្រងដីធ្លីនៅកម្ពុជា” ( ២៤ ឧសភា ២០០៧ )។

លឹម វ៉ាន់, “របបដីធ្លីនៅកម្ពុជា”, ( កក្កដា ឆ្នាំ២០០៦ )។

## គេហទំព័រ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, ដំណើរការទទួលបានកម្មសិទ្ធិនៅកម្ពុជា, https://www.sithi.org/km/land-rights។

រដ្ឋបាលខេត្តកណ្តាល, ពិធីផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់វិនិច្ឆ័យ សម្រាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ចំនួន៣ឃុំ ក្នុងស្រុកលើកដែក, https://www.kandal.gov.kh/detail/24736។

រដ្ឋបាលខេត្តមណ្ឌលគិរី, ពិធីប្រកាសផ្សព្វផ្សាយតំបន់វិនិច្ឆ័យនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនៅភូមិជ្រៃសែន សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី, https://www.mondulkiri.gov.kh/detail/4318។

វិទ្យុបារាំងអន្តរជាតិ RFI, នាទីយល់ដឹងច្បាប់ និងជំនួញ, នីតិវិធីចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ, *https://www.rfi.fr/km/procedure-collective-registration-land-property*

អង្គការទិន្នន័យអំពីការអភិវឌ្ឍ, ដីធ្លី, ដីធ្លី | Open Development Cambodia ( ODC )។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ**

## បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ,លេខ៣២១អនក្រ.បក,២វិច្ឆកា ២០២៣។

ឧបសម្ព័ន្ធទី២៖ អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី, លេខ៤៦ អនក្រ. បក, ០៩ មិថុនា ២០១៦។

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១នៃអនុក្រឹត្យលេខ៤៦អនក្រ.បក ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីលេខ១២២អនក្រ.បក, ៩មិថុនា ២០១៦។

ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ, លេខ៤៨ អនក្រ.បក, ៩ មិថុនា ២០១៦។

ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ, ៩ មិថុនា ២០១៦។

ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច, លេខ៨៣ អនក្រ.បក, ១៩ មិថុនា ២០០៩។

ឧបសម្ព័ន្ធទី៧៖ គម្រូពាក្យស្នើសុំចុះបញ្ជីដី។

ឧបសម្ព័ន្ធទី៨៖ គម្រូទម្រង់វិញ្ញាបនបត្រចាស់ និងគម្រូទម្រង់វិញ្ញាបនបត្រថ្មី។

ឧបសម្ព័ន្ធទី៩៖ គម្រូទម្រង់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដីរដ្ឋ(ប្លង់ដីរបស់រដ្ឋ)។

ឧបសម្ព័ន្ធទី១០៖ គម្រូទម្រង់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ឯកជន (ប្លង់ដីរបស់ឯកជន)។

ឧបសម្ព័ន្ធទី១១៖ គម្រូទម្រង់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់សមូហភាព (ប្លង់ដីរបស់សហគមន៍ជនជាតិដើមភាគតិច)។

# ឧបសម្ព័ន្ធទី១

អនុក្រឹត្យស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ, លេខ៣២១អនក្រ.បក,២ វិច្ឆកា ២០២៣។

ចូល
លេខ 6391
ថ្ងៃទី 6.11.23

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## លក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៤៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤ ន.ស.៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៤/០០៨ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីផ្លូវថ្នល់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ២៤៨ អនក្រ.បក ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២១ មាត្រា២២ និងមាត្រា២៣ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងដីចំណីតាមបណ្តោយផ្លូវជាតិនិងផ្លូវរថភ្លើងនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញអនុក្រឹត្យលេខ៩៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ ស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីលក្ខខណ្ឌនិងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ តាមរយៈការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ក្នុងគោលបំណងដើម្បីធានាការពារកម្មសិទ្ធិនិងសិទ្ធិផ្សេងទៀតលើដីរដ្ឋ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីរដ្ឋគ្រប់ប្រភេទ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ** សំដៅដល់ក្រុមការងារធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋនៅតាមក្រុង ស្រុក ខណ្ឌ។

២- **ដីរដ្ឋ** សំដៅដល់ដីសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត ព្រមទាំងដីឯកជនរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត។

៣- **រដ្ឋបាលថ្នាក់ក្រោមជាតិ** សំដៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

៤- **អាជ្ញាធរកាន់កាប់ដីរដ្ឋ** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងនីតិបុគ្គលសាធារណៈផ្សេងទៀត ដែលកាន់កាប់និងប្រើប្រាស់ដីរដ្ឋ។

៥- **ការធ្វើអត្តសញ្ញាណកម្មដីរដ្ឋ** សំដៅដល់ការអង្កេត ការស្រាវជ្រាវ និងការប្រមូលព័ត៌មានដីរដ្ឋ ដើម្បីធ្វើការចុះបញ្ជីដីរដ្ឋ មានជាអាទិ៍ ព័ត៌មានអំពីអាជ្ញាធរកាន់កាប់ដីរដ្ឋ ទីតាំង ព្រំប្រទល់ ប្រភេទដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី។

៦- **ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ** សំដៅដល់ការកំណត់ប្រភេទដីរដ្ឋ ជាដីសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ឬដីឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ដើម្បីចុះបញ្ជីដីរដ្ឋ។

៧- **ដីសាធារណៈរបស់រដ្ឋ** សំដៅដល់ដីដែលដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើត ឬក្រោយពីបានរៀបចំរួច ឬដីដែលមានជាប់ផលប្រយោជន៍សាធារណៈ ឬជាដីដែលមានការរៀបចំពិសេសសម្រាប់ប្រយោជន៍សាធារណៈទូទៅ។

៨- **ដីឯកជនរបស់រដ្ឋ** សំដៅដល់ដីទាំងអស់ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋនិងមិនមែនជាដីដែលកាន់កាប់ជាភោគៈស្របច្បាប់ ឬមិនមែនជាកម្មសិទ្ធិដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១។

## ជំពូកទី២
## សមត្ថកិច្ច

**មាត្រា៤ ._**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចក្នុងការគ្រប់គ្រងការចុះបញ្ជីជីរដ្ឋ។

**មាត្រា៥ ._**

ការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋស្ថិតក្រោមសមត្ថកិច្ចដូចខាងក្រោម៖

១- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានទីតាំងក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងមានសិទ្ធិប្រើត្រារបស់រដ្ឋបាលរាជធានី ខេត្ត។

២- ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មានទីតាំងក្នុងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមានសិទ្ធិប្រើត្រារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា៦ ._**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ប្រធាន |
| - ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| - មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | សមាជិក |
| - ស្នងការនគរបាលរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត | សមាជិក |
| - ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត | សមាជិក |
| - នាយខណ្ឌរដ្ឋបាលព្រៃឈើដែលពាក់ព័ន្ធ | សមាជិក |
| - នាយករដ្ឋបាលរាជធានី ខេត្ត | សមាជិក។ |

សមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អាចអញ្ជើញតំណាងមន្ទីរនិងអង្គភាពពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំតាមការចាំបាច់។

**មាត្រា៧ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌក្នុងការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីអាណាព្យាបាលកាន់កាប់និងប្រភេទដីរដ្ឋ
- ប្រមូលនិងចងក្រងឯកសារព័ត៌មានអំពីទីតាំង ប្រភេទដី ប្រភេទប្រើប្រាស់ដី និងតំបន់ប្រើប្រាស់ដី
- ផ្តល់មតិយោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីអាណាព្យាបាលកាន់កាប់និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ
- ថែរក្សានិងធ្វើបរច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋប្រចាំរាជធានី ខេត្ត
- សម្រេចនិងត្រួតពិនិត្យលើការរៀបចំផែនការសកម្មភាពប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់
- ផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លីនិងសហការតាមដានការអនុវត្តគម្រោងទាំងនោះ
- សហការក្នុងការរៀបចំពិគ្រោះយោបល់ជាសាធារណៈលើគម្រោងសម្បទានដីធ្លី
- លើកគម្រោងថវិកាប្រចាំឆ្នាំ។

**មាត្រា៨ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីជួយក្នុងកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសមានជាអាទិ៍ ការបញ្ចូលទិន្នន័យ និងព័ត៌មានពីក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ការថែរក្សា និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ។

លេខាធិការដ្ឋានគ្រប់គ្រងដីរដ្ឋនេះ ដឹកនាំដោយប្រធាន១(មួយ)រូបដែលជាអនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ទទួលបន្ទុកការងារសុរិយោដី និងមានសមាជិកមួយចំនួនតាមការចាំបាច់ ដែលត្រូវតែងតាំងដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

លេខាធិការដ្ឋាននេះមានទីតាំងនៅក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត។

**មាត្រា៩ .-**

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ | ប្រធាន |
| - ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ | សមាជិកអចិន្ត្រៃយ៍ |
| - ប្រធានការិយាល័យជំនាញពាក់ព័ន្ធចំណុះរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនាយផ្នែករដ្ឋបាលព្រៃឈើដែលពាក់ព័ន្ធ | សមាជិក |
| - មេឃុំ ចៅសង្កាត់ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

**មាត្រា១០ ._**

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតក្រោមការណែនាំផ្នែករដ្ឋបាលពីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និងក្រោមការណែនាំផ្នែកបច្ចេកទេសពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ចំពោះដីរដ្ឋនៅតាមបណ្តោយព្រំដែន ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវស្ថិតក្រោមការណែនាំផ្នែកបច្ចេកទេសបន្ថែមពីរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន។

ភារកិច្ចរបស់ក្រុមការងាររដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មានដូចខាងក្រោមៈ

- ប្រមូលនិងចងក្រងឯកសារ ព័ត៌មានដើម្បីធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋ
- សម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬអ្នកកាន់កាប់ដីរដ្ឋ អំពីអាណាព្យាបាលកាន់កាប់ដីរដ្ឋ
- ស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ប្រភេទដី ប្រភេទប្រើប្រាស់ដី និងតំបន់ប្រើប្រាស់ដី
- ធ្វើការបិទផ្សាយជាសាធារណៈនូវសំណៅព័ត៌មាននិងផែនទីដីរដ្ឋនៅតាមទីប្រជុំជន និងតាមឃុំ សង្កាត់ពាក់ព័ន្ធ និងទទួលមតិយោបល់ពីសាធារណជនតាមកាលបរិច្ឆេទនិងទីកន្លែងដែលបានកំណត់
- សង្ខេបមតិយោបល់សាធារណៈដែលបានទទួល និងរៀបចំទិន្នន័យនិងឯកសារចាំបាច់ រួមទាំងផែនទីដីរដ្ឋ ដែលមានបញ្ជាក់ព័ត៌មានទាំងអស់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត
- ចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនិងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ
- រៀបចំការពិគ្រោះយោបល់និងចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី ព្រមទាំងសហការតាមដានការអនុវត្តគម្រោងសម្បទានដីធ្លី
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

## ជំពូកទី៣

## ការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ

**មាត្រា១១ ._**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានភារកិច្ចដឹកនាំក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ ដោយត្រូវប្រមូលនិងចងក្រងឯកសារដូចខាងក្រោមៈ

១- ទីតាំងនិងព្រំប្រទល់ប្រហាក់ប្រហែលនៃដីរដ្ឋ។

២- ព័ត៌មានដែលបញ្ជាក់អំពីប្រភេទដីរដ្ឋ។

៣- ព័ត៌មានអំពីប្រភេទប្រើប្រាស់ដីនិងតំបន់ប្រើប្រាស់ដី ប្រសិនបើមាន។

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋ ដោយត្រូវប្រមូលរាល់ការអះអាងទាំងអស់ទាក់ទងនឹងប្រភេទដីនិងអាណាព្យាបាលកាន់កាប់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនោះ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចផ្តល់ព័ត៌មាននិងឯកសារទាក់ទងនឹងដីរដ្ឋទាំងអស់ដែលស្ថិតនៅក្រោមអាណាព្យាបាលកាន់កាប់របស់ខ្លួន។ រដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចផ្តល់ព័ត៌មានទាក់ទងនឹងដីរដ្ឋទាំងអស់ដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួន ទោះបីដីនោះស្ថិតឬមិនស្ថិតនៅក្រោមអាណាព្យាបាលកាន់កាប់របស់ខ្លួនក៏ដោយ។

ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលអះអាងអំពីអាណាព្យាបាលកាន់កាប់លើក្បាលដីរដ្ឋណាមួយ ឬអះអាងអំពីប្រភេទដីរដ្ឋណាមួយ ត្រូវផ្តល់ព័ត៌មាននិងឯកសារគាំទ្រ។

រាល់ព័ត៌មានដែលប្រមូលបានពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ ត្រូវចាត់ទុកជាព័ត៌មានបឋម និងមិនទាន់មានការបញ្ជាក់ច្បាស់លាស់ជាផ្លូវការ រហូតដល់ដីនោះត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

**មាត្រា១២ .-**

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋតាមនីតិវិធីដូចខាងក្រោម៖

១- ប្រមូលព័ត៌មានទាក់ទងនឹងដីរដ្ឋនៅក្នុងឃុំ សង្កាត់ ពីសមាជិកក្រុមការងាររបស់ខ្លួន និងពីតំណាងក្រសួង ស្ថាប័ន មេភូមិ និងមេឃុំ ចៅសង្កាត់ដែលពាក់ព័ន្ធនៅក្នុងក្រុង ស្រុក ខណ្ឌ។

២- ស្វែងរកការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ដែលមានការពាក់ព័ន្ធ។ ក្នុងករណីមិនអាចសម្រេចបាននូវការឯកភាពមតិគ្នា ត្រូវបញ្ជាក់អំពីការអះអាងដែលមិនស្របគ្នាទាំងឡាយនៅក្នុងរបាយការណ៍ការងារដែលត្រូវដាក់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

៣- ធ្វើការបិទផ្សាយជាសាធារណៈរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នូវសេចក្តីសង្ខេបអំពីការអះអាងអំពីផែនទីបង្ហាញពីការអះអាង និងសេចក្តីពន្យល់ច្បាស់លាស់អំពីគោលបំណងនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋសម្រាប់ឱ្យសាធារណជនចូលរួមផ្តល់មតិយោបល់ និងធ្វើការសង្ខេប និងបញ្ចូលមតិយោបល់សាធារណៈដែលទទួលបានទៅក្នុងរបាយការណ៍ការងាររបស់ខ្លួន ដើម្បីដាក់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

៤- រៀបចំរបាយការណ៍ការងារជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដោយមានបញ្ចូលព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា១១នៃអនុក្រឹត្យនេះ និងផែនទីបង្ហាញពីការអះអាងរបស់តំណាងក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ព្រមទាំងសេចក្តីសង្ខេបអំពីមតិសាធារណៈ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ ក្នុងករណីចាំបាច់។

**មាត្រា១៣ .-**

ក្នុងករណីមានការអះអាងមិនស្របគ្នារវាងក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវធ្វើការស៊ើបអង្កេតលើការអះអាងទាំងនោះ និងត្រូវពិចារណារាល់មតិយោបល់សាធារណៈដែលបានសង្ខេបបញ្ចូលនៅក្នុងរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងត្រូវស្វែងរកការឯកភាពគ្នាក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ដែលមានការពាក់ព័ន្ធ។

ក្នុងករណីមានការឯកភាពមតិគ្នាលើលទ្ធផលនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ រវាងក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវបញ្ចូលព័ត៌មានអំពីការឯកភាពនេះទៅក្នុងប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋដែលត្រូវបង្កើតឡើងស្របតាមអនុក្រឹត្យនេះ។

ក្នុងករណីគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មិនអាចស្វែងរកឯកភាពមតិគ្នាលើការអះអាងដែលមិនស្រប លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ រួមទាំងព័ត៌មានអំពីការអះអាងដែលមិនស្របគ្នានោះ ត្រូវបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋ។

បែបបទនិងបរិបថនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៤
## ការចុះបញ្ជីដីរដ្ឋ

**មាត្រា១៤ .-**

ការចុះបញ្ជីដីរដ្ឋ ត្រូវធ្វើឡើងតាមរយៈការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធឬលក្ខណៈដាច់ដោយដុំដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៥ .-**

ដំណើរការចុះបញ្ជីដីរដ្ឋ រួមមានៈ

១- ការបញ្ជាក់កម្មសិទ្ធិរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀតលើដី។

២- ការកំណត់ព្រំប្រទល់ច្បាស់លាស់លើដី។

៣- ការស្វែងរកការឯកភាពគ្នាពីគ្រប់ភាគីដែលពាក់ព័ន្ធ។

៤- ការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។

រាល់លទ្ធផលនៃការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋដោយមិនអនុលោមតាមនីតិវិធីដូចមានចែងក្នុងជំពូកទី៣នៃអនុក្រឹត្យនេះមិនមែនជាព័ត៌មានសម្រេចឡើយ តែជាព័ត៌មានបឋមសម្រាប់ប្រើប្រាស់ក្នុងដំណើរការចុះបញ្ជីដីរដ្ឋ។

ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអះអាងថាក្បាលដីរដ្ឋណាមួយជាដីសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ត្រូវផ្តល់ឯកសារនិងភស្តុតាងផ្សេងៗទៀតដែលបង្ហាញថា ដីនោះត្រូវចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃ។ ដីរដ្ឋដែលមិនបានបង្ហាញឱ្យឃើញថាមានចរិតបម្រើប្រយោជន៍សាធារណៈ ត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត។

**មាត្រា១៦ .-**

នៅក្នុងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធលើកដំបូង ដីរដ្ឋនៅក្នុងតំបន់វិនិច្ឆ័យត្រូវបានកំណត់ព្រំប្រទល់ហើយដីនោះត្រូវបានចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីថាជាដីរដ្ឋ។

ប្រភេទជាដីសាធារណៈឬជាដីឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត ត្រូវបានចុះបញ្ជីប្រសិនបើៈ

- ការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋត្រូវបានធ្វើចប់មុនការចុះបញ្ជីដោយគ្មានការអះអាងណាមួយរបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមិនស្របគ្នា ឬ
- ទោះបីមិនទាន់មានការធ្វើអត្តសញ្ញាណកម្មនិងការធ្វើផែនទីដីរដ្ឋ ប៉ុន្តែមានព័ត៌មានដែលអាចឱ្យធ្វើការសន្និដ្ឋានបានអំពីប្រភេទដី និងប្រភេទប្រើប្រាស់ដីបច្ចុប្បន្ននៃដីនោះ ហើយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងឡាយក៏មានការឯកភាពមតិគ្នាលើប្រភេទដីនោះជាដីសាធារណៈ ឬជាដីឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត។

**មាត្រា១៧ .-**

ក្នុងការចុះបញ្ជីដីធ្លីដែលមានលក្ខណៈដាច់ដោយដុំលើកដំបូង ដីរដ្ឋដែលមានព្រំប្រទល់ជាក់លាក់ត្រូវបានចុះបញ្ជីដោយមានប្រភេទដីច្បាស់លាស់ ជាដីសាធារណៈឬជាដីឯកជនរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈដទៃទៀត។

## ជំពូកទី៥
## ការធ្វើចំណាត់ថ្នាក់ដីរដ្ឋ

**មាត្រា១៨ .-**

នីតិវិធីនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋដូចមានចែងក្នុងជំពូកនេះ ត្រូវយកមកអនុវត្តមុននឹងធ្វើការចុះបញ្ជីដីបាន ចំពោះស្ថានភាពដូចខាងក្រោម៖

- ក្នុងការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ដីនោះត្រូវបានចុះបញ្ជីថាជាដីរដ្ឋ ប៉ុន្តែដីនោះ មិនទាន់ត្រូវបានធ្វើចំណាត់ថ្នាក់ជាដីសាធារណៈ ឬជាដីឯកជនរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈ ដទៃទៀតនៅឡើយ
- ក្នុងការអនុវត្តការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំលើកដំបូង ការធ្វើអត្តសញ្ញាណកម្មនិងការធ្វើ ផែនទីដីរដ្ឋត្រូវបានធ្វើរួច ប៉ុន្តែមានការអះអាងមិនស្របគ្នារវាងក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ ក្រោមជាតិអំពីប្រភេទដីនេះ ឬដីនោះគ្មានព័ត៌មានច្បាស់លាស់អំពីប្រភេទដី និងអំពីប្រភេទប្រើប្រាស់ ដីបច្ចុប្បន្ន។

**មាត្រា១៩ .-**

ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ត្រូវអនុវត្តនីតិវិធី ដូចខាងក្រោម៖

១- ពិនិត្យរបាយការណ៍របស់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានរួមបញ្ចូលទាំងមតិ យោបល់សាធារណៈ ក្នុងករណីបានធ្វើអត្តសញ្ញាណកម្មនិងបានធ្វើផែនទីដីរដ្ឋរួចហើយ ឬធ្វើការ ស៊ើបអង្កេតរាល់ការអះអាងដែលមិនស្របគ្នារបស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ និង ផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិលើការធ្វើចំណាត់ថ្នាក់នោះ ក្នុងករណីមិនទាន់បានធ្វើ អត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋ។

២- លើកយោបល់សុំការសម្រេចពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីប្រភេទដីនោះ ដោយបង្ហាញអំពីមូលដ្ឋានគតិយុត្តនៃការធ្វើចំណាត់ថ្នាក់ដីនោះ។

ក្នុងករណីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មិនអាចសម្រេចអំពីប្រភេទនៃដីរដ្ឋណាមួយ ក្រសួងត្រូវស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។

បែបបទនិងបរិបទនៃការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២០ .-**

រាល់អនុក្រឹត្យស្តីពីការធ្វើអនុប្បយោគដីរដ្ឋនិងអនុក្រឹត្យស្តីពីការធ្វើអធិប្បយោគដីរដ្ឋ ត្រូវបញ្ជូនទៅក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីអំពីប្រភេទដីរដ្ឋឬការចុះបញ្ជីអំពីការធ្វើចំណាត់ ថ្នាក់ឡើងវិញ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ចូលព័ត៌មាននៃការធ្វើចំណាត់ថ្នាក់ឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យស្តីពីការធ្វើអនុប្បយោគដីរដ្ឋ ឬអនុក្រឹត្យស្តីពីការធ្វើអធិប្បយោគដីរដ្ឋនោះទៅក្នុង ប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋ និងត្រូវចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី។

## ជំពូកទី៦
## ប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋ

**មាត្រា២១ .-**

ប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋជាទិន្នន័យដែលមានផ្ទុកព័ត៌មានអំពីដីរដ្ឋដូចខាងក្រោម៖

១- ព័ត៌មានបឋមមិនទាន់បានបញ្ជាក់ច្បាស់លាស់ដែលបានមកពីការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ។

២- ព័ត៌មានដែលបង្ហាញថា ដីនោះបានចុះបញ្ជីរួចហើយឬមិនទាន់បានចុះបញ្ជី។

៣- អត្តសញ្ញាណនៃក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានអាណាត្តិកាន់កាប់ដីនោះ។

៤- ឯកសារផ្តល់ដោយក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានអាណាត្តិកាន់កាប់ដីនោះដែលបង្ហាញអំពីការអះអាងពីប្រភេទដីនោះ។

៥- ព័ត៌មានអំពីប្រភពដី មានជាអាទិ៍ ការលក់ទិញ ការដូរ ប្រទានកម្ម អច្ច័យទាន ទ្រព្យនិទាយាទ ទ្រព្យគ្មានម្ចាស់គ្រប់គ្រង ការអនុវត្តសិទ្ធិពិសេសរបស់រដ្ឋ ការរឹបអូសតាមសេចក្តីសម្រេចស្ថាពររបស់តុលាការ ឬប្រភពផ្សេងទៀតតាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន និងអំពីបន្ទុកលើដី មានជាអាទិ៍ សម្បទាន ការជួល ឬបន្ទុកផ្សេងៗទៀត។

**មាត្រា២២ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានភារកិច្ចថែរក្សានិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋប្រចាំរាជធានី ខេត្ត។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់លក្ខណៈបច្ចេកទេសនៃប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋ និងត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការថែរក្សានិងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងផែនទីដីរដ្ឋ។

ប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋនេះបំពេញទិន្នន័យឱ្យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដែលគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងបំពេញឱ្យសៀវភៅគោលបញ្ជីដីធ្លីដែលគ្រប់គ្រងដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

សាធារណជនមានសិទ្ធិមើលប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋក្នុងថ្ងៃធ្វើការ និងទទួលបានឯកសារថតចម្លងដោយត្រូវបង់ថ្លៃថតចម្លង។

**មាត្រា២៣ .-**

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលសាធារណៈដទៃទៀតដែលជាអាជ្ញាធរកាន់កាប់ដីរដ្ឋណាមួយ ឬអះអាងថាក្បាលដីណាមួយស្ថិតនៅក្រោមអាណាត្តិកាន់កាប់របស់ខ្លួន មានកាតព្វកិច្ចប្រគល់មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវរាល់ព័ត៌មាននិងឯកសារចាំបាច់ដើម្បីគាំទ្រនូវអំណះអំណាងរបស់ខ្លួន។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់រាល់ព័ត៌មាននិងឯកសារទាក់ទងនឹងដីរដ្ឋទាំងអស់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បើទោះបីជាដីទាំងនោះមិនស្ថិតនៅក្រោមអាណាត្តិកាន់កាប់របស់ខ្លួនក៏ដោយ។

## ជំពូកទី៧
## នីតិវិធីពិសេសនៃការចុះបញ្ជីដីរដ្ឋ

**មាត្រា២៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចចាត់ចែងធ្វើការចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេសនៃការចុះបញ្ជីដីរដ្ឋដូចមានចែងក្នុងជំពូកនេះ ក្នុងលក្ខខណ្ឌដូចខាងក្រោម៖

១- ដីរដ្ឋត្រូវបានកំណត់ទំហំ ប្រភេទ ប្រភេទប្រើប្រាស់ និងមានព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការចុះបញ្ជីត្រឹមត្រូវរួចហើយ។

២- អាជ្ញាធរកាន់កាប់ដីរដ្ឋបានស្នើសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស។

**មាត្រា២៥ .-**

អាជ្ញាធរកាន់កាប់ដីរដ្ឋដែលស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស ត្រូវផ្តល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវឯកសារដូចខាងក្រោម៖

១- លិខិតបទដ្ឋានគតិយុត្តដែលបានកំណត់អាណត្តិកាន់កាប់ដីរដ្ឋ ទំហំដី ប្រភេទដី ប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងព័ត៌មានចាំបាច់ដទៃទៀតសម្រាប់ការចុះបញ្ជីដីរដ្ឋ។

២- ផែនទីដីរដ្ឋដែលមានភ្ជាប់តារាងនិយាមកា ទាំងទម្រង់រឹង ទាំងទម្រង់ឌីជីថល។

៣- របាយការណ៍ស្តីពីការវាស់វែងដោយមន្ត្រីជំនាញនៃអាជ្ញាធរកាន់កាប់ដីរដ្ឋសាមី។

៤- របាយការណ៍ស្តីពីការបោះបង្គោលព្រំដីរដ្ឋ។

៥- ឯកសារនិងព័ត៌មានចាំបាច់ផ្សេងទៀតដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៦ .-**

បន្ទាប់ពីបានទទួលសំណើពីអាជ្ញាធរកាន់កាប់ដីរដ្ឋឱ្យចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចអនុវត្តជម្រើសណាមួយដូចខាងក្រោម៖

១- ក្នុងករណីព័ត៌មាននិងឯកសារពាក់ព័ន្ធផ្តល់ដោយអាជ្ញាធរកាន់កាប់ដីរដ្ឋមានលក្ខណៈគ្រប់គ្រាន់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចាត់រដ្ឋបាលសុរិយោដីឱ្យធ្វើការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសម្រាប់ដីរដ្ឋនោះ ដោយពុំចាំបាច់អនុវត្តនីតិវិធីដូចមានកំណត់ក្នុងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំឡើយ។

២- ក្នុងករណីមានភាពចាំបាច់ដើម្បីធានាពីតម្លាភាពនៃការចុះបញ្ជីដីរដ្ឋនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសម្រាប់ដីរដ្ឋ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចសម្រេចឱ្យធ្វើការបិទផ្សាយជាសាធារណៈរយៈពេលមិនលើសពី១៥(ដប់ប្រាំ)ថ្ងៃ នូវព័ត៌មាននិងឯកសារទាំងឡាយដែលទទួលបានពីអាជ្ញាធរកាន់កាប់ដីរដ្ឋនៅតាមទីតាំងពាក់ព័ន្ធ មុននឹងការចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសម្រាប់ដីរដ្ឋនោះតាមនីតិវិធីដូចមានកំណត់ក្នុងចំណុចទី១ខាងលើ។

៣- ក្នុងករណីព័ត៌មាននិងឯកសារដែលផ្តល់ដោយអាជ្ញាធរកាន់កាប់ដីរដ្ឋមានលក្ខណៈមិនគ្រប់គ្រាន់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចតម្រូវឱ្យអាជ្ញាធរកាន់កាប់ដីរដ្ឋដែលជាម្ចាស់សំណើកំណត់អត្តសញ្ញាណក្បាលដីរដ្ឋ កសាងផែនទី និងកំណត់និយាមកាដីរដ្ឋនោះឱ្យបានចប់សព្វគ្រប់ រួចផ្តល់លទ្ធផលត្រលប់មកវិញមុននឹងចុះបញ្ជីនិងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសម្រាប់ដីរដ្ឋនោះតាមនីតិវិធីដូចមានកំណត់ក្នុងចំណុចទី១ខាងលើ។

**មាត្រា២៧ .–**

អាជ្ញាធរកាន់កាប់ដីរដ្ឋដែលបានស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេសមានភារកិច្ចចូលរួមឱ្យបានពេញលេញក្នុងដំណើរការចុះបញ្ជីដីរដ្ឋ ដោយត្រូវផ្តល់ព័ត៌មាននិងឯកសារជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

នៅក្នុងកំលុងពេលនៃការអនុវត្តការកំណត់អត្តសញ្ញាណ ការកសាងផែនទី ការកសាងប្លង់សុរិយោដីនិង/ឬការកំណត់និយាមកាដីរដ្ឋ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលបានស្នើសុំចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេសមានភារកិច្ចសម្របសម្រួលស្វែងរកការឯកភាពគ្នាពីគ្រប់ភាគីពាក់ព័ន្ធយ៉ាងច្រើន២(ពីរ)លើក ក្នុងរយៈពេលពេលសរុបមិនលើសពី១៤(ដប់បួន)ថ្ងៃ។ ផុតរយៈពេលកំណត់នេះ ប្រសិនបើនៅតែមិនអាចរកការឯកភាពគ្នាជាស្ថាពរ អាជ្ញាធរកាន់កាប់ដីរដ្ឋដែលជាម្ចាស់សំណើ ត្រូវបញ្ជូនសំណុំឯកសារមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដើម្បីពិនិត្យនិងសម្រេច។

**មាត្រា២៨ .–**

បែបបទនិងបរិបថនៃការចុះបញ្ជីដីរដ្ឋតាមនីតិវិធីពិសេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៨

## ប្រភពធនធាន

**មាត្រា២៩ .–**

ថវិកាសម្រាប់ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីដីរដ្ឋ ការធ្វើចំណាត់ថ្នាក់ ការចុះបញ្ជីដីរដ្ឋ ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋ ស្ថិតនៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាននិងថវិកាសម្រាប់ការធ្វើអត្តសញ្ញាណកម្ម ការធ្វើផែនទីដីរដ្ឋ ការធ្វើចំណាត់ថ្នាក់ ការចុះបញ្ជីដីរដ្ឋ ការថែរក្សា និងការធ្វើចរន្តការប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋ បានមកពីថវិកាជាតិ ហិរញ្ញប្បទានឥតសំណង ជំនួយបច្ចេកទេស និងប្រភពស្របច្បាប់ផ្សេងទៀត។

## ជំពូកទី៩

## អន្តរប្បញ្ញត្តិ

**មាត្រា៣០ .–**

រាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនឹងការចុះបញ្ជីដីរដ្ឋ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣១ .-**

អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

អនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី,

លេខ៤៦អនក្រ.បក, ៣១ ឧសភា ២០០២។

# ឧបសម្ព័ន្ធទី៥

អនុក្រឹត្យស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក
ស្តីពីការចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ, ០៩ មិថុនា ២០១៦។

# ឧបសម្ព័ន្ធទី៦

អនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច,

លេខ៨៣ អនក្រ.បក, ១៩ មិថុនា ២០០៩។

# ឧបសម្ព័ន្ធទី៧

គម្រូពាក្យស្នើសុំចុះបញ្ជីដីនៅកម្ពុជា

# ឧបសម្ព័ន្ធទី៨

គម្រូទម្រង់សន្លឹកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលវត្ថុ**ចាស់** និងគម្រូទម្រង់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ**ថ្មី**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លេខ : 12010604-0005

| | | | |
|---|---|---|---|
| រាជធានី/ខេត្ត | : ភ្នំពេញ | សន្លឹកផែនទីលេខ : | 5932-II 94 b 4 |
| ក្រុង/ស្រុក/ខណ្ឌ | : ចំការមន | លេខក្បាលដី : | 5 |
| ឃុំ សង្កាត់ | : ទួលស្វាយព្រៃទី ១ | ទំហំ : | 107 ម៉ែត្រ² |
| ភូមិ | : ៤ | ប្រភេទដី : | |
| | | រូបភាពប្រើប្រាស់ដី : | ល័ខៅហ៊ាន |
| | | លក្ខណៈនៃការប្រើប្រាស់ដី : | ឯកជន |




មាត្រដ្ឋាន 1/600

ធ្វើនៅភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០...

តប.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

# គំរូសន្លឹកប័ណ្ណចាស់

សម្គាល់ៈ [illegible]

No. 3176097

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លេខ : 12010604-0005

| | | | |
|---|---|---|---|
| រាជធានី/ខេត្ត : ភ្នំពេញ | | សន្លឹកផែនទីលេខ : | 5932-II 94 b 4 |
| ក្រុង/ស្រុក/ខណ្ឌ : ចំការមន | | លេខក្បាលដី : | 5 |
| ឃុំ សង្កាត់ : ទួលស្វាយព្រៃទី ១ | | ទំហំ : | 107 ម៉ែ២ |
| ភូមិ : ៤ | | ប្រភេទដី : | |
| | | រូបភាពប្រើប្រាស់ដី : | លំនៅឋាន |
| | | លក្ខណៈនៃការប្រើប្រាស់ដី : | ឯកជន |




មាត្រដ្ឋាន 1/600

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥...
ធ្វើនៅភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ ២០...
តប.ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

គំរូសន្លឹកបណ្ណថ្មី

No. 04699002

# ឧបសម្ព័ន្ធទី៩

គម្រូទម្រង់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដីរដ្ឋ( ប្លង់ដីរបស់រដ្ឋ )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

លេខ : 02-00002

រាជធានី/ខេត្ត : បាត់ដំបង
ក្រុង/ស្រុក/ខណ្ឌ :
ឃុំ/សង្កាត់ :
ភូមិ :

សន្លឹកផែនទីលេខ : 5534-I 77
លេខក្បាលដី : 2
ទំហំ : 984.31 ហ.ត
ប្រភេទដី :

រូបភាពប្រើប្រាស់ដី : តំបន់បេតិកភណ្ឌធម្មជាតិ គីរីយង់
លក្ខណៈនៃការប្រើប្រាស់ដី : រដ្ឋ




មាត្រដ្ឋាន 1/150000

ថ្ងៃពុធ ៥រោច ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២៥
រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សាយ សំអាល់

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ដែលកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ មានកាតព្វកិច្ចថែរក្សា និងការពារទ្រព្យសម្បត្តិរដ្ឋដោយចាត់វិធានការគ្រប់រូបភាព ដើម្បីទប់ស្កាត់បង្ក្រាបសកម្មភាពកេងប្រវ័ញ្ច ក្លែងបន្លំ រំលោភកាន់កាប់ទ្រព្យសម្បត្តិរដ្ឋដោយខុសច្បាប់ ឬអំពើដែលបង្កអន្តរាយដល់ទ្រព្យសម្បត្តិរដ្ឋ (ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ)។

No. 00000030

ឈ្មោះកម្មសិទ្ធិករ/អាជ្ញាធរកាន់កាប់ដីរដ្ឋ : ក្រសួងបរិស្ថាន

អាសយដ្ឋាន(ទីស្នាក់ការ)  ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

| **អត្តានុកូលដ្ឋានម្ចាស់អចលនវត្ថុ** | | | **ការផ្លាស់ប្តូរ** | | 02-00002 |
|---|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួន / ប្រភេទទ្រព្យ | ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត | សាវតារ | លេខាចារឹកដោយសង្ខេបនៃ លិខិតសញ្ញា ឬ សាលក្រមតុលាការ | បន្ទុកលើអចលនវត្ថុ | សេចក្តីផ្សេងៗ |
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| (រដ្ឋ) | មើលព័ត៌មាននៅខាងលើ | | អំណោយពីរដ្ឋ | | ដីរដ្ឋនេះត្រូវបានចុះបញ្ជីតាមនីតិវិធីពិសេសកំណត់ដោយអនុក្រឹត្យលេខ ៣២១ អនុក្រ.បក ចុះថ្ងៃ ០២.១១.២០២៣ ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីដីរដ្ឋ។ |

# ឧបសម្ព័ន្ធទី១០

គម្រូទម្រង់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់ឯកជន (ប្លង់ដីរបស់ឯកជន)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ

**លេខ : [redacted]**

| | | | |
|---|---|---|---|
| រាជធានី/ខេត្ត | : [redacted] | សន្លឹកផែនទីលេខ | : [redacted] |
| ក្រុង/ស្រុក/ខណ្ឌ | : [redacted] | លេខក្បាលដី | : [redacted] |
| ឃុំ/សង្កាត់ | : [redacted] | ទំហំ | : [redacted] ម៉² |
| ភូមិ | : [redacted] | ប្រភេទដី | : |

រូបភាពប្រើប្រាស់ដី : លំនៅឋាន

លក្ខណៈនៃការប្រើប្រាស់ដី : ឯកជន




មាត្រដ្ឋាន 1/800

ថ្ងៃ សុក្រ ១១ កើត ខែ ជេស្ឋ ឆ្នាំ កុរ ឯកស័ក ព.ស.២៥៦៣

[redacted], ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៩

**តប.រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

សារិន_ខណ្ណា

ប្រការ: [illegible]

No. 0[redacted]

# ឧបសម្ព័ន្ធទី១១

គម្រូទម្រង់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុរបស់សហគមន៍ជនជាតិដើមភាគតិច

( ប្លង់ដីរបស់សហគមន៍ជនជាតិដើមភាគតិច )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# វិញ្ញាបនបត្រសម្គាល់កម្មសិទ្ធិសមូហភាព

**លេខ : រ.គ ០០០០៤៩**

ខេត្ត : រតនគិរី
ស្រុក : អូរជុំ
ឃុំ : អូរជុំ
ភូមិ : ល្អើនជង
សហគមន៍ជនជាតិដើមភាគតិច គ្រឹង

លេខរៀងប្លង់ភូមិសាស្ត្រ : ១៦០៦០៧០២
ក្បាលដីលេខ : ០០១៨
ទំហំ : ០.៦០៩០ ហ.ត
ប្រភេទនៃការប្រើប្រាស់ដី : ដីលំនៅឋាន
លក្ខណៈនៃការប្រើប្រាស់ដី : សមូហភាព

ជើង

មាត្រដ្ឋាន
១/២៥០០




ធ្វើនៅរតនគិរី ថ្ងៃទី ... ខែ... ឆ្នាំ២០១១
តប.នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឌឹម ស៊ុំភាព

[illegible]

No. 2846507